# ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១

## វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលករខ្មែរចំនួន២នាក់ ត្រឡប់មកពីប្រទេសថៃនៅចំណុចឃុំជ្រៃសីមា

http://cambodiapolice.com/policekh/ 12:29 pm 30 ឧសភា 2021

ខេត្តបាត់ដំបង ៖ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ នៅថ្ងៃអាទិត្យ ៤រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាការ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ៩ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ គុន ហ៊ាង នាយប៉ុស្តិ៍ស្តីទី សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកសំពៅលូន ដឹកនាំដោយលោកព្រិន្ទបាលឯក ស៊ិត ដាលី (មន្ត្រី) និងកម្លាំងយោធាវរសេនាតូច ៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ ចំរើន មេបញ្ជាការរង-គ ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន ២នាក់ ,ស្រី ១នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ សហការទទួលពលករខ្មែរមកពីប្រទេសថៃ២នាក់ និងល្បាតការពារសន្តិសុខ សុវត្ថិភាព នៅតាមបន្ទាត់ព្រំដែន

http://cambodiapolice.com/policekh/ 1:13 pm 30 ឧសភា 2021

ខេត្តបាត់ដំបង ៖ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ នៅថ្ងៃអាទិត្យ ៤រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាការ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែន គីឡូ ១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ម៉ឹង ម៉េត នាយប៉ុស្តិ៍ស្តីទី សហការជាមួយកម្លាំងកងខេមរភូមិន្ទឈរជើងនៅជួរមុខចេញល្បាតតាមព្រំដែនកម្ពុជា-ថៃ ក្នុងភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ដល់ភូមិឈើទាល ឃុំសិរីមានជ័យ ស្រុកសំពៅលូន និងបានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញពីយោធាថៃកងអនុសេនាធំ១៣០៥ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ចំនួន ២នាក់ ,ស្រី១នាក់ ក្នុងនោះក្មេងប្រុស ១នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៣នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអាទិត្យ ទី៣០ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៣នាក់ ស្រី ២២នាក់ ក្នុងនោះកុមារ ១នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៥នាក់ ស្រី ១នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤នាក់ ស្រី នាក់ កុមារ ១នាក់ កុមារី ០០នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០៩នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣៩នាក់ ស្រី ២០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៣នាក់ ស្រី ២២នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## កងទ័ពកម្ពុជា ស្នើភាគីថៃកុំឲ្យមានការបាញ់ពលរដ្ឋខ្មែរ ខណៈពួកគេលួចឆ្លងដែនខុសច្បាប់

https://news.btv.com.kh/ 05/31/2021 10:05 AM

ភ្នំពេញ ៖ មន្ត្រីយោធារបស់កម្ពុជា បានស្នើទៅភាគីថៃជាថ្មីម្តងទៀត ដោយសូមឲ្យឆ្មាំការពារព្រំដែនរបស់ថៃមានការយោគយល់ និងកុំធ្វើការបាញ់សម្លាប់ពលរដ្ឋខ្មែរ ពេលដែលពួកគាត់លួចឆ្លងដែនខុសច្បាប់ និងលួចទៅកាប់ឈើនៅលើទឹកដីថៃ ជាដើមនោះ។ ការស្នើសុំរបស់យោធាកម្ពុជានេះ គឺបានធ្វើឡើងនៅក្នុងកិច្ចប្រជុំមួយ កាលពីចុងសប្តាហ៍កន្លងទៅនេះ នៅក្នុងភូមិសាស្ត្រជួរមុខតំបន់ភ្នំតាថាវ ខេត្តព្រះវិហារ ដើម្បីបន្តកិច្ចសហប្រតិបត្តិការរួមគ្នា ក្នុងទប់ស្កាត់បង្ក្រាបរាល់បទល្មើស ផ្សេងៗនៅតាមព្រំដែននៃប្រទេសទាំងពីរ(កម្ពុជា-ថៃ)។ នៅក្នុងកិច្ចប្រជុំនោះភាគីទាំងពីរ បានប្តេជ្ញារួមគ្នាបន្តក្នុងការបង្ក្រាប និងទប់ស្កាត់រាល់បទល្មើសដែលលួចឆ្លងដែនដោយខុសច្បាប់ ពិសេសបទល្មើសឆ្លងដែនដោយខុសច្បាប់ របស់បងប្អូនពលរដ្ឋខ្មែរលួចឆ្លងដែនចូលទៅរកកាប់ឈើប្រណិតក្នុងទឹកដីថៃជាដើមនោះ។

យ៉ាងណាក៏ដោយនៅក្នុងកិច្ចប្រជុំនោះភាគីកម្ពុជា បានធ្វើការស្នើសុំការយោគយល់ពីសំណាក់ថ្នាក់ដឹកនាំ ក៏ដូចជាអាជ្ញាធរថៃ កុំមានការបាញ់សម្លាប់ពលរដ្ឋខ្មែរពេលដែលពួកគាត់លួចឆ្លងដែនទៅកាន់ប្រទេសថៃ។ រួមគ្នាទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ តាមព្រំដែន មិនត្រូវធ្វើអ្វីថ្មីនៅចំណុចដែលមិនទាន់បានកំណត់ រួមគ្នាទប់ស្កាត់ការលួចឆ្លងដែន និងកាប់ព្រៃឈើខុសច្បាប់ និងការណាត់ជួបគ្នាឡើងវិញក្នុងរយៈពេល១ខែម្តងនោះ។ នៅក្នុងកិច្ចប្រជុំនោះដែរ លោកឧត្តមសេនីយ៍ត្រី ច័ន្ទ សុខុន មេបញ្ជាការកងពលតូចអន្តរាគមន៍លេខ៨ បានបញ្ជាក់ផងដែរថា គោលបំណងសំខាន់ក្នុងកិច្ចប្រជុំនេះ គឺបង្កើនកិច្ចសហប្រតិបត្តិការល្អបន្ថែមទៀត រវាងកងកម្លាំងឈរជើងជួរមុខ

ដើម្បីរក្សាបានសុខសន្តិភាព និងការអភិវឌ្ឍន៍ ព្រមទាំងការរស់នៅប្រកបដោយភាពសុខសាន្តរបស់ប្រជាជន នៃប្រទេសទាំងពីរ ឈរលើគោលការណ៍ដោះស្រាយគ្នាដោយសន្តិវិធី ជៀសវាងការប្រឈមមុខដាក់គ្នាដោយកម្លាំងប្រដាប់អាវុធ។

បន្ថែមពីនោះទៀត លោកឧត្តមសេនីយ៍ត្រី ច័ន្ទ សុខុន បានធ្វើការក្រើនរំលឹកទៅដល់គ្រប់បណ្តាអង្គភាពទាំងអស់ ដែលកំពុងបំពេញភារកិច្ច ក្នុងកិច្ចការពារ នៅតាមគោលដៅខ្សែត្រៀមជួរមុខព្រំដែនកម្ពុជា-ថៃត្រូវប្តេជ្ញាចិត្តខ្ពស់ខិតខំប្រឹងប្រែងបន្តក្នុងការការពារ គ្រប់គ្រងបានយ៉ាងរឹងមាំ ដោយឈរលើស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់។ ពិសេសបង្កើនការចេញដើរល្បាតបានជាប់ជាប្រចាំ ទោះបីជាសភាពការណ៍ព្រំដែន មានសភាពស្ងប់ស្ងាត់ជាធម្មតាក្តី ក៏ត្រូវតែមានការប្រុងប្រយ័ត្នជាប់ជានិច្ច៕ អត្ថបទបាន ចក់

## ថៅកែហាងម៉ាស្សាម្នាក់បញ្ជូនទៅតុលាការ , ស្ត្រីរកស៊ីផ្លូវភេទចំនួន ៥នាក់ ប្រគល់ជូនមន្ទីរសង្គមកិច្ច ដើម្បីធ្វើការស្តារនីតិសម្បទា

https://cen-news.com/ Posted ByPen Srey Neat May 31, 2021

ខេត្តសៀមរាប៖ លោក ជា ហេង នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារនីតិជននៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានឲ្យដឹងថា កាលរសៀលថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១នេះ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារនីតិជន បានប្រគល់ស្ត្រីចំនួន ០៥នាក់ ក្នុងនោះមានអនីតិជន ០១នាក់ ដែលប្រមូលបានពីការចុះបង្ក្រាបករណីសញ្ជរកម្ម និងផលិតរូបភាព សម្ភារអាសអាភាស នៅក្នុងហាងម៉ាស្សាឈ្មោះសាលីណោរស៊ើជិន៍ ដែលស្ថិតនៅភូមិស្វាយដង្គំ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ ទៅមន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាខេត្តសៀមរាប ក្រោយពីបញ្ចប់ការធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ ដើម្បីឲ្យមន្ទីរសង្គមកិច្ចធ្វើការកំណត់អត្តសញ្ញាណបន្ត ព្រមទាំងធ្វើការស្តារនីតិសម្បទា និងធ្វើសមាហរណកម្មទៅសហគមន៍វិញ ជនសង្ស័យសមត្ថកិច្ចបានយកទៅធ្វើតេស្តរហ័សរកជំងឺកូវីដ-១៩ និងបានបញ្ជូនខ្លួនទៅតុលាការ។ នេះបើតាមការផ្សាយរបស់មន្ទីរព័ត៌មានខេត្តសៀមរាប។

លោកស្រី ធេង វណ្ណា អនុប្រធានមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានឱ្យដឹងថា បន្ទាប់ពីទទួលបានស្ត្រីទាំង០៥នាក់ ពីស្នងការដ្ឋាននគរបាលខេត្ត និងក្រោយពីការបញ្ចប់ការធ្វើចត្តាឡីស័ក១៤ថ្ងៃមក មន្ទីរបានធ្វើការសម្ភាសន៍កំណត់អត្តសញ្ញាណ ដោយក្នុងនោះបានធ្វើការសមាហរណកម្មត្រឡប់ទៅសហគមន៍វិញនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ចំនួន ០៤នាក់ ដែលក្នុងម្នាក់ៗ ទទួលបានការឧបត្ថម្ភថវិកាពីអង្គការកុមារមេត្រីអន្តរជាតិ ចំនួន ២០ដុល្លារ ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក រីឯអនីតិជន អាយុ១៧ឆ្នាំ ចំនួន០១នាក់នោះ ត្រូវបានមន្ទីរបញ្ជូនទៅស្នាក់នៅមណ្ឌលអង្គការកុមារមេត្រីអន្តរជាតិនៅរាជធានីភ្នំពេញ ដើម្បីធ្វើការស្តារនីតិសម្បទា តាមរយៈការរៀនជំនាញវិជ្ជាជីវៈ ។

## ពលរដ្ឋខ្មែរ១០នាក់ទៀត ដែលជាប់គាំងនៅម៉ាឡេស៊ី នឹងមកដល់កម្ពុជានៅល្ងាចនេះ

http://freshnewsasia.com/ 2021-05-31 11:25am

**(ភ្នំពេញ)៖** ពលរដ្ឋខ្មែរ១០នាក់ទៀត ដែលក្នុងនោះមានពលករ៩នាក់ និងកុមារ១នាក់ នឹង ធ្វើដំណើរមកដល់មាតុប្រទេសវិញ នៅល្ងាចថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១នេះ។ នេះបើតាម លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា។ ពលរដ្ឋខ្មែរទាំង១០នាក់នេះ នឹងមកដល់កម្ពុជាតាមជើងយន្តហោះលេខ SQ158 ដោយមានកិច្ចអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី។ លោក កុយ គួង បានបញ្ជាក់បន្ថែមថា ស្ថានទូតបានចេញលិខិតធ្វើដំណើរបណ្តោះអាសន្នចំពោះអ្នកដែលគ្មានលិខិតឆ្លងដែន និងរៀបចំឯកសារទៅអគ្គនាយកដ្ឋាន

អន្តោប្រវេសន៍ម៉ាឡេស៊ី ជូនទៅធ្វើតេស្តកូវីដ១៩ ព្រមទាំងបានចាត់ មន្ត្រីជូនពួកគាត់ខាងលើ ទៅអាកាសយានដ្ឋានអន្តរជាតិ KLIA ផងដែរ៕

## កម្លាំងសមត្ថកិច្ចការពារព្រំដែនថៃឃាត់ពលករខ្មែរចំណាកស្រុកខុសច្បាប់ចំនួន07នាក់

https://www.facebook.com/aranpostOfficial/ 30/05/2021

30.05.2021 កម្លាំងសមត្ថកិច្ចការពារព្រំដែនថៃ ឃាត់ពលករខ្មែរចំណាកស្រុកខុសច្បាប់ ចំនួន 07នាក់ ខណៈឆ្លងដែនខុសច្បាប់ចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ។

## កំលាំងអាជ្ញាធរវរៈការពារព្រំដែនលេខ ១២៤-១២៥ សហការជាមួយអាជ្ញាធរទាហាននិងប៉ូលីសនៅក្នុងមូលដ្ឋាន បានចាប់ឃាត់ខ្លួនជនជាតិថៃ ១នាក់ និងជនជាតិខ្មែរ ៦នាក់

https://www.facebook.com/Khmer.Channel.kh/ 30/05/2021

កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ កំលាំងអាជ្ញាធរវរៈការពារព្រំដែនលេខ ១២៤-១២៥ សហការជាមួយអាជ្ញាធរទាហាននិងប៉ូលីសនៅក្នុងមូលដ្ឋាន បានចាប់ឃាត់ខ្លួនជនជាតិថៃ ១នាក់ និងជនជាតិខ្មែរ ៦នាក់ នៅបរិវេណភូមិថាប់ស្យ៉ាម ស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ។ ជនជាតិថៃត្រូវបានចោទប្រកាន់ពីបទជួយលួចលាក់ផ្តល់កន្លែងស្នាក់នៅដល់ជនអន្តោប្រវេសន៍ខុសច្បាប់ និងជនជាតិខ្មែរត្រូវបានចោទប្រកាន់ពីបទលួចឆ្លងដែនដោយខុសច្បាប់ និងបំពានច្បាប់ស្តីពីជំងឺឆ្លងរបស់ប្រទេសថៃ។

## អាជ្ញាធរថៃចុះត្រួតពិនិត្យករណីឆ្លងជំងឺកូវីដ១៩ នៅរោងចក្រសាច់មាន់ CPF ខេត្តសារ៉ាក់បុរី ឃើញពលករខ្មែរ ចំនួន ២៤០នាក់ ឆ្លងកូវីដ១៩

https://www.facebook.com/Khmer.Channel.kh/ 30/05/2021

ករណីឆ្លងជំងឺកូវីដ១៩ នៅរោងចក្រសាច់មាន់ CPF ខេត្តសារ៉ាក់បុរី៖

-កម្មករសរុបចំនួន ៥,៨០០នាក់

-ត្រួតពិនិត្យកម្មករចំនួន ៣,៤០០នាក់

-លទ្ធផលចេញចំនួន ២,២៩៩នាក់

-លទ្ធផលវិជ្ជមានចំនួន ៣៩១នាក់

-មានពលករខ្មែរឆ្លងចំនួន ២៤០នាក់

# ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១

## រាជរដ្ឋាភិបាល៖ កុមារមួយចំនួនកំពុងរងគ្រោះ និងរងគ្រោះដោយឪពុក-ម្តាយ ធ្វើទេសន្តរប្រវេសន៍ និងបោះបង់ចោល

https://dap-news.com/national/ ByKD102Posted on May 31, 2021

ភ្នំពេញ៖ ក្នុងឱកាសខួបលើកទី៧២ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២០ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២១ សម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានផ្ញើសារក្រើនរំលឹកថា ទោះបីជាជោគជ័យក្នុងការមើល ការខុសត្រូវលើកុមារពីសំណាក់ ភាគីពាក់ព័ន្ធយ៉ាងណាក៏ដោយ ប៉ុន្តែកុមារកម្ពុជាមួយចំនួន កំពុងស្ថិតក្នុងភាពរងគ្រោះ និងរងគ្រោះដោយសារតែឪពុក-ម្តាយ បានធ្វើទេសន្តប្រវេសន៍ និងបោះបង់ចោលរយៈពេលយូរ ។

នៅថ្ងៃស្អែកទី១ មិថុនា គឺជាខួបលើកទី៧២ នៃទិវាកុមារអន្តរជាតិ១មិថុនា ប៉ុន្តែដោយកម្ពុជាបានជួបប្រទះវិបត្តិជំងឺកូវីដ-១៩ ជាហេតុមិនអាចប្រារព្ធពិធីអង្គមីទ្ធីង ដូចសព្វមួយដងបាន ទើបសម្តេចតេជោក្នុងនាមជា ប្រមុខរាជរដ្ឋាភិបាលកម្ពុជាផង និងប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារផង បានផ្ញើសារលិខិតអបអរសាទរដល់កុមារនៅទូទាំងប្រទេស ។ ក្នុងសារលិខិតចំនួន៤ទំព័រចុះថ្ងៃ១៩ ឧសភា ហើយចេញផ្សាយជាសាធារណៈនាថ្ងៃ៣១ ឧសភា នេះ សម្តេចតេជោបានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តប្តេជ្ញាចិត្ត លើកកម្ពស់ការគោរពសិទ្ធិកុមារនិងផ្តល់ កិច្ចការពារយ៉ាងពេញទំហឹង នៅគ្រប់ស្ថានភាពដោយបានបង្កើត នូវយន្តការជាច្រើនក្នុងការគ្រប់គ្រង និងផ្តល់សេវាដល់មុខសញ្ញាកុមារទូទៅ កុមារងាយរងគ្រោះ និងកុមាររងគ្រោះ។ សម្តេចបន្តថា "តែទោះបីជាមានការខិតខំប្រឹងប្រែង យ៉ាងនេះហើយក៏ដោយ ក៏នៅមានកុមារមួយចំនួនកំពុងរស់នៅ ក្នុងស្ថានភាពងាយរងគ្រោះ និងរងគ្រោះ ព្រោះតែឪពុក-ម្តាយ ឬអាណាព្យាបាលធ្វើទេសន្តរប្រវេសន៍ និងបោះបង់ចោលរយៈពេលយូរ"។

សម្តេចបានក្រើនរំលឹកបន្តថា ជាពិសេសក្នុងការរស់នៅក្នុងស្ថានភាព នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នេះ គឺត្រូវការការគាំទ្រ និងអន្តរាគមន៍ជាចាំបាច់ដោយ ជំរុញការអនុវត្តនូវគោលនយោបាយ និងបទដ្ឋាននានាផ្តោតលើកិច្ចការពារ និងការគោរពសិទ្ធិមូលដ្ឋានរបស់កុមារ ក្នុងគោលដៅការពារឧត្តមប្រយោជន៍របស់កុមារ។ ក្នុងនាមជាប្រធានកិត្តិយស ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សម្តេចតេជោ បានថ្លែងឿតថា ទន្ទឹមនឹងនោះយន្តការអនុវត្តប្រព័ន្ធកិច្ចការពារ កុមារត្រូវការជាចាំបាច់នូវធនធានមនុស្ស និងហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ ដែលអាចពង្រឹងនិងពង្រីក សមត្ថភាពក្នុងការគ្រប់គ្រង និងអនុវត្តផែនការយុទ្ធសាស្រ្ត ផែនការសកម្មភាពឲ្យទទួលបាន លទ្ធផលតាមការរំពឹងទុក។ ឆ្លៀតក្នុងឱកាសនេះដែរ សម្តេចនាយករដ្ឋមន្ត្រី ក៏ស្នើដល់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ទាំងអស់បន្តពង្រឹងយន្តការសម្របសម្រួល ក្នុងការបង្ការទប់ស្កាត់ អន្តរាគមន៍ និងការឆ្លើយតបលើករណីកុមារ ដើម្បីលើកកម្ពស់ និងផ្តល់សេវាយុត្តិធម៌សង្គម ដោយធានាឲ្យមានសមភាពរវាងកុមារា និងកុមារី ព្រមទាំងបង្កើនឱកាសស្មើភាពគ្នាក្នុងកម្លាំង ចលករសង្គមសម្រាប់ជីវភាពសាធារណៈ ជីវភាពនយោបាយ សកម្មភាព សង្គម វប្បធម៌ សិល្បៈ សាសនា និងសកម្មភាពផ្សេងៗទៀត៕

## កម្លាំងរបស់តំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ បន្តអនុវត្តបទបញ្ជាចូលរួមការពារទប់ស្កាត់ជំងឺកូវីដ-១៩

https://www.kampucheathmey.com/ ថ្ងៃចន្ទ ៣១ ឧសភា ២០២១ ដោយ Kang Tola

ឧត្តរមានជ័យ ៖ នៅល្ងាចថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ លោកឧត្តមសេនីយ៍ទោ តន់ ញាន មេបញ្ជាការតំបន់ប្រតិបត្តិការ សឹករងឧត្តរមានជ័យ បានបន្តចាត់តាំងកម្លាំង ប្រមាណ៣៥នាក់ សហការជាមួយក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជា ប្រចាំច្រកចំនួន៣ គឺច្រកអូរស្មាច់ ថ្មដូន និងច្រកជប់គគី និងកងពលតូចជឹកជញ្ជូនលេខ៩៩ ត្រៀមដឹកជញ្ជូនប្រជាពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់ និងប្រចាំការ ការពារតាមទីតាំងមណ្ឌលចត្តាឡីស័កទាំង០៤ក្នុងខេត្ត។ គិតត្រឹមម៉ោង១៩និង០០នាទីថ្ងៃនេះ មានបងប្អូនប្រជាពលរដ្ឋឆ្លងដែនពីប្រទេសថៃមកដល់ទឹកដីកម្ពុជាតាមច្រកអន្តរជាតិ អូរស្មាច់សរុបចំនួន១២៥នាក់ ស្រី៥៩នាក់ ដោយក្នុងនោះ ប្រជាពលរដ្ឋដែលត្រូវធ្វើចត្តាឡីស័កនៅតាមមណ្ឌល ក្នុងខេត្តឧត្តរមានជ័យមានចំនួន០៦នាក់ ស្រី០៤នាក់ ដោយឡែកប្រជាពលរដ្ឋចំនួន១១៩នាក់ ក្នុងនោះស្រី៥៥នាក់ផ្សេងទៀត បានដឹកជញ្ជូនទៅធ្វើចត្តាឡីស័កនៅតាមបណ្តាខេត្តរៀងៗខ្លួន៕ *ដោយ ៖ ចាន់ ធី*

## ឃាត់ខ្លួនពលរដ្ឋខ្មែរ ២នាក់ ដែលលួចឆ្លងដែនពីទឹកដីថៃ ចូលមកកម្ពុជាវិញ ដោយខុសច្បាប់ ក្នុងភូមិសាស្រ្តចាក់ច្រែង ព្រំដែនកម្ពុជា-ថៃ

https://kohsantepheapdaily.com.kh/ Preah Vihear ៣១ ខែ ឧសភា ឆ្នាំ ២០២១ ម៉ោង ១៩:៥២

ខេត្តព្រះវិហារ៖ ប្រជាពលរដ្ឋខ្មែរ ២នាក់ ត្រូវបានកងកម្លាំង នៃអង្គភាពកងពលតូចអន្តរាគមន៍លេខ៨ ធ្វើការឃាត់ខ្លួន ខណៈពេលដែលពួកគាត់ លួចឆ្លងដែនចេញពីទឹកដីថៃ ចូលមកកម្ពុជាវិញដោយខុសច្បាប់។ ការឃាត់ខ្លួននេះ បានធ្វើឡើង កាលពីវេលាម៉ោងប្រមាណជាង ៩ ព្រឹកថ្ងៃអាទិត្យ ទី៣០ ខែឧសភា ឆ្នាំ២០២១ ក្នុងភូមិសាស្រ្តចាក់ច្រែង នៃទិសទី១ ប្រាសាទព្រះវិហារ។

កំណត់ហេតុរបស់នាយការិយាល័យនៃកងពលតូចអន្តរាគមន៍លេខ៨ លោកវរសេនីយ៍ទោ ផង អឿន បានឲ្យដឹងថា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ពលរដ្ឋខ្មែរទាំងពីរនាក់នេះ បានលួចឆ្លងដែនដោយខុសច្បាប់ ចូលទៅទឹកដីថៃ បំណងរកការងារធ្វើតាមច្រកព្រំដែនជាំស្រងាំ រហូតមកដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១នេះ ក៏សម្រេចចិត្តលួចឆ្លងដែនត្រឡប់ចូលមកកម្ពុជាវិញ។ ប៉ុន្តែត្រូវបានកម្លាំងឃាត់ខ្លួន ខណៈពេលកំពុងដើរល្បាតតាមភូមិសាស្រ្តចាក់ច្រែង នៃទិសទី១ ប្រាសាទព្រះវិហារ តាមបន្ទាត់ព្រំដែន កម្ពុជា-ថៃ។ លោកវរសេនីយ៍ទោ ផង អឿន នាយការិយាល័យទី២ កងពលតូចអន្តរាគមន៍លេខ៨ ក៏បានឲ្យដឹងដែរថា ចំពោះពលករខ្មែរ ដែលលួចឆ្លងដែនពីទឹកដីថៃ ចូលមកកម្ពុជាវិញនោះ ទី១ឈ្មោះ ចយ អាន ភេទប្រុស អាយុ ២៥ឆ្នាំ រស់នៅភូមិមន្ទិល ឃុំ យាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ២ឈ្មោះ ឡុង ប៉ាន់ ភេទប្រុស អាយុ ៣០ឆ្នាំ រស់នៅភូមិរវៀង ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប។ ពលករខ្មែរទាំងពីរនាក់ ត្រូវបានមន្រ្តីសុខាភិបាល ដឹកបញ្ជូនយកទៅធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កកម្រិត១ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ក្រោយពីសាកសួរព័ត៌មានចប់៕ សុខ សារ៉ាយ

## ពលករខ្មែរ៧នាក់នឹងអ្នកមើលផ្លូវជនជាតិថៃម្នាក់ ត្រូវសមត្ថកិច្ចថៃចាប់ខ្លួន

http://nokorwatnews.com/ 01/06/2021

ក្រុងប៉ោយប៉ែត៖ ទោះបីមានការទប់ស្កាត់ក្នុងការលួចឆ្លងដែនរបស់កម្លាំងសមត្ថកិច្ចជំនាញក៏ដោយប៉ុន្តែការលួចឆ្លងដែននៅតែមានបន្ត ក្នុងនោះសមត្ថកិច្ចថៃចាប់ពលករខ្មែរ ឆ្លងដែនខុសច្បាប់ចំនួន៧នាក់ នឹងអ្នកមើលផ្លូវជនជាតិថៃម្នាក់ នៅក្នុងទឹកដីស្រុកតាព្រះយ៉ា ខេត្តស្រះកែវ។ យោងតាមការសាកសួរពលករទាំង៧នាក់បានចំណាយប្រាក់ឲ្យមេខ្យល់ជនជាតិខ្មែរ ក្នុងម្នាក់៦,០០០បាត ក្រោយទៅដល់គោលដៅហើយ។

សេចក្តីរាយការណ៍ពីប្រទេសថៃថា កាលពីយប់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១នេះ សមត្ថកិច្ចថៃវិធានការរឹតបន្តឹង ទប់ស្កាត់ពលករបរទេសលួចចូលប្រទេសដោយខុសច្បាប់ និងវិធានការការពារការរាតត្បាតរបស់កូវីដ-១៩ រហូតអាចចាប់ឃុំខ្លួនពលករខ្មែរបានចំនួន៧នាក់ ក្នុងនោះប្រុស៣ ស្រី៣នាក់ នឹងក្មេងស្រីម្នាក់ ព្រមទាំងអ្នកមើលផ្លូវជនជាតិថៃម្នាក់ ។ អ្នករាយការណ៍បញ្ជាក់ថា សមត្ថកិច្ចថៃប្រទះឃើញពលករខាងលើ នៅបរិវេណបង្គោលឡាក់ចម្ងាយពីចំណុចត្រួតពិនិត្យទី២៦ ជ្រៅចូលទៅប្រមាណ២គីឡូម៉ែត្រ ក្នុងទឹកដីភូមិ ទ័ពសៀម ឃុំតាព្រះយ៉ា នឹងក្រោយពីសួរនាំពលករខ្មែរបានប្រាប់ថា ចង់ធ្វើដំណើរចូលទៅធ្វើការខាងសំណង់ នៅខេត្តឆាកធឹង សៅ ដោយទាក់ទងតាមរយៈមេខ្យល់ជនជាតិខ្មែរ និងចំណាយលុយក្នុងម្នាក់៦,០០០បាត បន្ទាប់ពីដល់គោលដៅហើយនោះ។ ពលករទាំងអស់ត្រូវនាំខ្លួនទៅសួរនាំ នឹងធ្វើកំណត់ហេតុចាប់ខ្លួននិងអនុវត្តតាមវិធានការសុខាភិបាល លទ្ធផលមានសុខភាពធម្មតា ដោយឡែកអ្នកមើលផ្លូវជនជាតិថៃ សមត្ថកិច្ចបាននាំខ្លួនមកសួរនាំ ដើម្បីស្វែងរកចាប់ខ្លួនអ្នកពាក់ព័ន្ធបន្ថែម ចំពោះពលករខ្មែរទាំង៧នាក់ខាងលើ សមត្ថកិច្ចបានបញ្ជូនខ្លួនទៅឲ្យជំនាញស្រុកតា ព្រះយ៉ា ដើម្បីចាត់ការតាមច្បាប់បន្ត នឹងបណ្តេញឲ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ តាមច្រកអូរបីជាន់ក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៧នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាបៈ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃចន្ទ ទី៣១ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៧នាក់ ស្រី ២៧នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២៤នាក់ ស្រី ១២នាក់ កុមារា ១នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៦នាក់ ស្រី ៥នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៦នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១០នាក់ ស្រីចំនួន ៧នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥៧នាក់ ស្រី ២៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករ/ពលការិនីខ្មែរចំនួន១៦នាក់ និងកុមារ២នាក់ ដែលបានមករស់នៅ និងធ្វើការខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី នឹងធ្វើដំណើរទៅស្រុកកំណើតវិញ នាល្ងាចនេះ

https://cen-news.com/ Posted ByPen Srey Neat June 1, 2021

ភ្នំពេញ ៖ ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានជូនដំណឹងថា ពលករ/ពលការិនីខ្មែរចំនួន១៦នាក់ និងកុមារ២នាក់ ដែលបានមករស់នៅ និងធ្វើការខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី នឹងធ្វើដំណើរតាមជើងយន្តហោះអាកាសចរណ៍សិង្ហបូរីលេខ SQ158 នាថ្ងៃទី០១ ខែមិថុនា វេលាម៉ោង ០៥និង៣៥នាទីល្ងាច។ ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានបញ្ជាក់យ៉ាងដូច្នេះថា "សូមមបញ្ឈប់ការធ្វើចំណាកស្រុកដោយខុសច្បាប់ !!!

ដោយមានការជួយសម្របសម្រួល របស់ស្ថានទូត ពលករ/ពលការិនីខ្មែរចំនួន១៦នាក់ និងកុមារ២នាក់ ដែលបានមករស់នៅ និងធ្វើការខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី នឹងទៅដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងយន្តហោះអាកាសចរណ៍សិង្ហបូរីលេខ SQ158 នាថ្ងៃទី១ ខែមិថុនា វេលាម៉ោង ០៥និង៣៥នាទីល្ងាច។សូមបងប្អូនអនុវត្តឱ្យបានត្រឹមត្រូវ នូវវិធានការសុខាភិបាល ជាពិសេស វិធានការ "៣ការពារ ៣កុំ" ដើម្បីសុខភាព និងសុវត្ថិភាពសង្គមជាតិយើង ៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

# តុលាការសម្រេចឃុំខ្លួនមនុស្សប្រុសស្រី ២ នាក់ ករណីនាំក្មេងអនីតិជនប៉ុនប៉ងឱ្យបម្រើក្នុងហាងស្រាបៀរ

https://www.postkhmer.com/ គឹម សារុំ | Publication date 01 June 2021 | 17:04 ICT

**ព្រះវិហារៈ** តុលាការខេត្តព្រះវិហារសម្រេចឃុំខ្លួនមនុស្សប្រុសស្រី ២ នាក់ ក្នុងពន្ធនាគារខេត្តកាលពីថ្ងៃទី ៣១ ឧសភា ពាក់ព័ន្ធករណីនាំក្មេងស្រីជាអនីតិជន ២ នាក់ ចេញពីភូមិពោធិ៍ទាប ឃុំម្លូព្រៃ ១ ស្រុកឆែប ខេត្តព្រះវិហារ ប៉ុនប៉ងយកទៅឱ្យបម្រើក្នុងហាងលក់ស្រាបៀរ ១ កន្លែង ក្នុងក្រុងព្រះវិហារ កាលពីថ្ងៃទី ២៧ ឧសភា។

លោកស្រីឧត្តមសេនីយ៍ត្រី ប្រាំង ធីតា ស្នងការរងទទួលផែនការងារនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ បានប្រាប់នៅរសៀលថ្ងៃទី ១ មិថុនាថា ជនសង្ស័យឈ្មោះ សុខ សាយ ភេទ ប្រុស អាយុ ២២ ឆ្នាំ មានរបរជាជាងឈើ រស់នៅក្នុងភូមិពោធិ៍ទាប ឃុំម្លូព្រៃ១ ស្រុកឆែប។ ចំណែកស្ត្រីម្នាក់ទៀតឈ្មោះ សុខ ស្រីពៅ អាយុ ២៨ ឆ្នាំ ប្រកបរបរជានារីបម្រើសេវាស្រាបៀរ ស្នាក់នៅបន្ទប់ជួលក្នុងភូមិកណ្ដាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។ លោកស្រីថ្លែងថា៖ «បុរសឈ្មោះ សុខ សាយ ត្រូវតុលាការចោទពីបទការនាំចេញយកអនីតិជនជាអាទិ៍ចេញ ដោយមិនស្របច្បាប់តាមមាត្រា ៩។ ស្ត្រីម្នាក់ទៀតចោទពីបទការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើសតាមមាត្រា ២០។ ទាំង ២ នាក់ចោទតាមច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ»។

យោងតាមមាត្រា ៩ នៃច្បាប់នេះ បើតុលាការរកឃើញថា ពិតជាបានប្រព្រឹត្តមែននោះនឹងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំដល់ ៥ ឆ្នាំ។ រីឯមាត្រា ២០ នឹងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំដល់ ៥ ឆ្នាំ និងពិន័យជាប្រាក់ចូលថវិការដ្ឋពី ៤ លានដល់ ១០ លានរៀល។ តែបើជនរងគ្រោះជាអនីតិជនវិញនឹងត្រូវផ្ដន្ទាទោសពី ៥ ឆ្នាំដល់ ១០ ឆ្នាំ។

បើតាម លោកស្រី ធីតា ការចាប់ខ្លួននេះធ្វើតាមបណ្ដឹងអាណាព្យាបាលរបស់ក្មេងស្រីទាំង ២ នាក់ ថ្ងៃទី ៣០ ឧសភា ដែលបានប្ដឹងទៅនគរបាលប៉ុស្តិ៍ឃុំម្លូព្រៃ ១ ដោយបានអះអាងថា កាលពីថ្ងៃទី ២៧ ឧសភា មានបុរសម្នាក់ឈ្មោះ សុខ សាយ បាននាំក្មេងស្រីឈ្មោះ ម.ថ អាយុ ១៥ ឆ្នាំ និងក្មេងស្រីឈ្មោះ ណ.រ អាយុ១៦ ឆ្នាំ រស់នៅក្នុងភូមិ-ឃុំជាមួយគ្នាដោយឌុបតាមម៉ូតូនាំទៅស្នាក់នៅក្នុងបន្ទប់ជួលរបស់ស្ត្រីឈ្មោះ សុខ ស្រីពៅ ក្នុងភូមិកណ្ដាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ។ លោកស្រីបន្តថា ក្រោយពីនគរបាលប៉ុស្តិ៍ទទួលបានពាក្យបណ្ដឹងរួចមកក៏បានរាយការណ៍ទៅលោកអធិការនគរបាលស្រុកឆែប និងបន្តមកការិយាល័យប្រឆាំងការជួញដូរមនុស្សខេត្តព្រះវិហារ ទើបមានការស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យបាននៅភូមិកណ្ដាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ នៅថ្ងៃទី ៣០ ឧសភា ក្រោយទទួលបណ្ដឹងតែប៉ុន្មានម៉ោងប៉ុណ្ណោះ។ លោកស្រី ធីតា បានបញ្ជាក់ថា៖ «ជនប្រុសស្រី២នាក់នោះមិនសារភាពថា នាំក្មេងរងគ្រោះក្នុងគោលដៅឱ្យទទួលភ្ញៀវក្នុងហាងទេ តែបើតាមការសន្និដ្ឋានរបស់យើងគឺជនត្រូវចោទមានបំណងយកក្មេងទៅបម្រើក្នុងហាងលក់ស្រាបៀរ ព្រោះស្ត្រីត្រូវចោទធ្វើការនៅក្នុងហាងនោះ»។

ពាក់ព័ន្ធករណីនេះដែរ នៅរសៀលថ្ងៃទី ១ មិថុនា លោក សូ ស្ម័គ្រ នាយនគរបាលប៉ុស្តិ៍ឃុំព្រៃម្លូ ១ បានប្រាប់ថា ក្មេងស្រីរងគ្រោះទាំង ២ នាក់នោះ រស់នៅក្នុងភូមិជាមួយគ្នា ហើយត្រូវបានសមត្ថកិច្ចរំដោះ និងអនុញ្ញាតឱ្យត្រឡប់មកលំនៅឋានវិញហើយ។ លោកថា៖ «បុរសម្នាក់ឈ្មោះ សុខ សាយ នោះគាត់ឌុបក្មេងស្រីពីភូមិមិនឱ្យឪពុកម្ដាយក្មេងដឹង ទើបគាត់មកប្ដឹងខ្ញុំ។ ឥឡូវក្មេងរងគ្រោះមកផ្ទះវិញអស់ហើយ»៕

# ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១

## ពលករ ៩នាក់ ដែលមានថៃម្នាក់ និងមេខ្យល់ម្នាក់ ត្រូវកងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែន ឃាត់ខ្លួន

https://kohsantepheapdaily.com.kh/ Banteay Meanchey ០១ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ២៣:៣៣

បន្ទាយមានជ័យ៖ កម្លាំងឈរជើងតាមបន្ទាត់ព្រំដែន បានឃាត់ខ្លួនពលករលួចឆ្លងដែន ៣ករណី ចំនួន ៩ នាក់ ក្នុងនោះ មានជនជាតិថៃម្នាក់ និងមេខ្យល់ម្នាក់។ ពលករ និងមេខ្យល់ទាំងនោះ ត្រូវបានឃាត់ខ្លួន នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ តាមបន្ទាត់ព្រំដែនកម្ពុជាថៃ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងនគរបាល ខេត្តបន្ទាយមានជ័យ បានប្រាប់ថា កងកម្លាំងចម្រុះ ដែលឈរជើងតាមបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ បានបង្ក្រាបបទល្មើសលួចឆ្លងដែន ៣ករណី ដោយឃាត់បាន៩នាក់ (ស្រី ២នាក់) និងមានម្នាក់ជាជនជាតិថៃ។ ក្នុងនោះ ក៏មាន ម្នាក់ទៀត ជាមេខ្យល់។ លោកស្រី បានបញ្ជាក់ថា ករណី១ នៅវេលាម៉ោង ៩ព្រឹកថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ នៅចំណុចមុខអាគារខេ ស្ថិតភូមិសាមគ្គីមានជ័យ សង្កាត់.ក្រុងប៉ោយប៉ែត ឃាត់ខ្លួនពលករខ្មែរចំនួន ៣នាក់ ដែលលួចឆ្លង ចូលពីប្រទេសថៃមកកម្ពុជាវិញ ដែលគេចវេះពីធ្វើចត្តាឡីស័ក។ ករណីទី២. នៅវេលាម៉ោង ៩ និង៥៥នាទីព្រឹកថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២១ នៅចំណុចគោលដៅ៣៨ ស្ថិតភូមិទំនប់ក៥ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត បានឃាត់ខ្លួនពលករខ្មែរចំនួន ៤នាក់ (ស្រីម្នាក់) ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់។ ករណីទី៣. នៅវេលាម៉ោង ០៥ និង ៣០នាទីទៀបភ្លឺ ចូលថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ នៅតាមដងផ្លូវជាតិលេខ៥៨ ស្ថិតភូមិសីលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ កម្លាំងបានឃាត់ខ្លួន ២នាក់ ដែលលួចឆ្លងដែនមកពីប្រទេសថៃ ចូលមកកម្ពុជា មានម្នាក់ប្រុស ជាជនជាតិថៃ និងម្នាក់ទៀត ស្ត្រី ជាមេខ្យល់ ចូលមកក្រុងប៉ោយប៉ែត។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ បានបញ្ជាក់ថា ចំពោះមេខ្យល់ម្នាក់ ត្រូវកសាងសំណុំរឿង បញ្ជូនទៅសាលាដំបូង ខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមច្បាប់ និងពលករ ៨នាក់ ត្រូវបានធ្វើកិច្ចសន្យាអប់រំ ហើយបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ៕ ប៊ុន ធឿន

## លោក ណុប ដារ៉ា នឹងនាំយកទុកលំបាក របស់កងកម្លាំងជួរមុខ នៅតាមព្រំដែន ជូនថ្នាក់ដឹកនាំខេត្តបាត់ដំបង ដើម្បីដោះស្រាយ

https://dap-news.com/ BySS107Posted on June 1, 2021

ភ្នំពេញ៖ ដោយមើលឃើញពី ទុកលំបាករបស់កងកម្លាំងជួរមុខ លោកណុប ដារ៉ា អភិបាលរងខេត្ត និងជាប្រធានក្រុមការងារស្រាវជ្រាវបង្ក្រាប បទល្មើសឆ្លងដែនគ្រប់ភេទ មានប្រសាសន៍ថា នឹងពាំនាំបញ្ហាប្រឈមទាំងនេះជូនថ្នាក់ដឹកនាំខេត្ត ដើម្បីដោះស្រាយ ជូនក្នុងពេលឆាប់ៗនេះ។ ការលើកឡើងនេះ ធ្វើឡើងក្នុងឱកាសអញ្ជើញប្រជុំការងារ ដើម្បីពិភាក្សាស្រាវជ្រាវ បង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទនៅក្នុងភូមិសាស្ត្រ ស្រុកសំឡូត ខេត្តបាត់ដំបង នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ ។ នៅក្នុងកិច្ចប្រជុំនេះ សំដៅពង្រឹងបន្ថែមទៀតក្នុងការស្រាវជ្រាវបង្ក្រាប បទល្មើសឆ្លងដែនខុសច្បាប់ គ្រប់ប្រភេទពិសេសស្រាវជ្រាវ រកមេខ្យល់ដែលនាំពលករ ចេញ-ចូល ប្រទេសថៃ ក៏ដូចជានាំពលករ គិចពីការធ្វើចត្តាឡីស័ក ។ ជាចុងក្រោយលោក សូមកោតសរសើរ ដល់កងកម្លាំងជួរមុខ គ្រប់ប្រភេទដែលបានលះបង់កម្លាំងកាយចិត្ត និងឃ្លាតឆ្ងាយពីគ្រួសារជាទីស្រលាញ់ ដើម្បីជាតិមាតុភូមិ ហើយដោយឃើញផ្ទាល់ នូវទុកលំបាករបស់កងកម្លាំងជួរមុខ លោកមានប្រសាសន៍ថា នឹងពាំនាំបញ្ហាប្រឈមទាំងនេះ ជូនថ្នាក់

ដឹកនាំខេត្ត ដើម្បីដោះស្រាយ ជូនក្នុងពេលឆាប់ៗនេះ។ ក្រោយពីបញ្ចប់អង្គប្រជុំលោក ណុប ដារ៉ា បានអញ្ជើញចុះត្រួតពិនិត្យច្រកទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ (ច្រក៤០០) ផងដែរ៕

## ប្រជាពលរដ្ឋខ្មែរ ត្រឡប់ពីថៃ តាមច្រក២ ក្នុងខេត្តបន្ទាយមានជ័យ ១ថ្ងៃជាង ១០០នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey ០១ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ២៣:៤៨

បន្ទាយមានជ័យ៖ ប្រជាពលរដ្ឋខ្មែរ ដែលត្រឡប់ពីប្រទេសថៃ បានចូលមកកម្ពុជាវិញ តាមច្រកព្រំដែនចំនួន ២ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ១ថ្ងៃ មានជាង ១០០នាក់ កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ បានប្រាប់ថា នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១នេះ ក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ ស្រុកអូរជ្រៅ ទទួលប្រជាពលរដ្ឋខ្មែរ ដែលត្រឡប់ពីប្រទេសថៃ មានចំនួន ៦៣នាក់ ស្រី ២៦នាក់ ក្នុងនោះ មានប្រជាពលរដ្ឋខេត្តបន្ទាយមានជ័យ ចំនួន ២២នាក់ ស្រី ២នាក់ ខេត្តបាត់ដំបងចំនួន ២នាក់ ខេត្តកំពង់ឆ្នាំងចំនួន ២នាក់ ខេត្តកំពង់ស្ពឺម្នាក់ ខេត្តកំពង់ធំ ចំនួន ៤នាក់ ខេត្តកណ្ដាល ចំនួន ៤នាក់ ខេត្តព្រះវិហារចំនួនម្នាក់ ខេត្តសៀមរាបចំនួន ២៤នាក់ (ស្រី ១២នាក់) ខេត្តឧត្តរមានជ័យ ចំនួន ៣នាក់។

ចំណែកលោក អ៊ែម សុខា អភិបាលស្រុកថ្មពួក បានបញ្ជាក់ថា នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ក្រុមការងារទទួលពលករខ្មែរ នៅច្រកបឹងត្រកួន ក្នុងស្រុកថ្មពួក បានចំនួន ៤៤នាក់ (ស្រី ១៧នាក់) និងកុមារ ៦នាក់ (ស្រី ៤នាក់)។ ក្នុងនោះ មានប្រជាពលរដ្ឋខេត្តបន្ទាយមានជ័យ ចំនួន ២១នាក់ ខេត្តបាត់ដំបង ចំនួន ៦នាក់ ខេត្តព្រៃវែងចំនួន ៤នាក់ ខេត្តសៀមរាបចំនួន ៧នាក់ ខេត្តពោធិ៍សាត់ចំនួន ៤នាក់ ខេត្តកំពង់ធំចំនួនម្នាក់ និងខេត្តត្បូងឃ្មុំចំនួនម្នាក់។

អភិបាលស្រុក ជាប់ជាយដែនទាំង២ បានបញ្ជាក់ថា ពលករខ្មែរត្រឡប់ពីប្រទេសថៃ ដែលចូលមកកម្ពុជាវិញតាមច្រកភូមិសាស្ត្រខេត្តបន្ទាយមានជ័យ មានច្រកអូរបីជាន់ ស្រុកអូរជ្រៅ និងច្រកបឹងត្រកួន ស្រុកថ្មពួក រយៈពេល ១ថ្ងៃ មានជាង ១០០នាក់ នៅពេលក្រុមការងារទទួលហើយ បានពិនិត្យសុខភាព ហើយនិងទទួលអាហារសម្រន់ រួចក្រុមការងារ បានណែនាំអប់រំ អោយបញ្ឈប់សកម្មភាពលួចឆ្លងដែន តាមរយៈមេខ្យល់ ដើម្បីការពារសុវត្ថិភាព។ ក្រោយណែនាំហើយ អ្នកឆ្លងដែនទាំងនោះ ត្រូវធ្វើកិច្ចសន្យា និងបញ្ជូនទៅដាក់នៅមណ្ឌល ដើម្បីធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ៕ ប៊ុន ធឿន

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣

http://cambodiapolice.com/policekh/ 11:10 am 1 មិថុនា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃចន្ទ ៥រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថារុង ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ម៉ឹង-ម៉េត (នាយប៉ុស្តិ៍ស្តីទី) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ដឹកនាំដោយលោកវរសេនីយ៍ត្រី វ៉ាន់-សុផល (មេបញ្ជាការរង ផ្នែកសឹករង) និងកម្លាំងយោធាវរសេនាតូច៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ស៊ីន សេងអាន

(មេបញ្ជាការរង គ) ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ចំនួន៤នាក់, ស្រី១នាក់ ក្នុងនោះក្មេងប្រុស១នាក់។

បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ចុះទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣

http://cambodiapolice.com/policekh/ 12:18 pm 1 មិថុនា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនកូនភ្នំ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ខៀវ-រ៉ាត់ (នាយប៉ុស្តិ៍ស្តីទី) និងកម្លាំងប៉ុស្តិ៍ព្រំដែនចក្រី ដឹកនាំដោយលោកអនុសេនីយ៍ឯក ស៊ឹម-កុសល(នាយរងប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី២,វរសេនាតូចលេខ១ ដឹកនាំដោយលោកអនុសេនីយ៍ឯក អ៊ួង-វណ្ណនី(មេបញ្ជាការរង គ) បានចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ស្ថិតក្នុងភូមិសាស្ត្រស្រុកសំពៅលូន និងមួយគោលដៅទៀតដឹកនាំដោយលោកអនុសេនីយ៍ទោឌឹម-ធុល (មន្ត្រីប៉ុស្តិ៍នគរបាលព្រំដែនកូនភ្នំ ) រួមជាមួយកម្លាំងផ្នែកស៊ើបការណ៍នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧) ដឹកនាំដោយលោកអនុសេនីយ៍ទោ សេង-អ៊ុននាយផ្នែក សហការជាមួយកម្លាំងយោធាកងអនុសេនាធំគាំទ្រ,វរសេនាតូច ៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ភួង-វ៉ៃ (មេបញ្ជាការរងគ) និងកម្លាំងយោធាកងអនុសេនាធំទី១,វរសេនាតូចលេខ១ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឡៃ-លឿន(មេបញ្ជាការខ) ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូនចំនួន២នាក់ .ស្រី១នាក់ ។

បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## ក្រសួងការបរទេសត្រួតពិនិត្យពលករចំណាកស្រុកនៅប្រទេសថៃ

https://www.khmertimeskh.com/ June 1, 2021 Yin Soeum / ខ្មែរថាមស៍

យោងតាមក្រសួងការបរទេសបានឲ្យដឹងថា មន្ត្រីកម្ពុជានៅប្រទេសថៃកំពុងតាមដាន និងផ្ទៀងផ្ទាត់ចំនួនករណីកូវីដ-១៩ក្នុងចំណោមពលករចំណាកស្រុកកម្ពុជា។ លោក កុយ គួង អ្នកនាំពាក្យក្រសួងបាននិយាយកាលពីម្សិលមិញថា៖ «អាជ្ញាធរថៃនឹងផ្តល់ការព្យាបាលដល់ពលករចំណាកស្រុកបរទេសទាំងអស់ដោយឥតគិតថ្លៃ ដូចទៅនឹងពលរដ្ឋថៃដែរ»។ លោកបន្តថា៖ «ស្ថានទូតកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់បំផុតក្នុងការជួយដល់ពលករ

ចំណាកស្រុកកម្ពុជាទាំងអស់ដែលរស់នៅប្រទេសថៃ។ ស្ថានទូតបានត្រៀមរួចជាស្រេចក្នុងការជួយពលករកម្ពុជានៅទីនោះ»។

កាលពីម្សិលមិញលោក អ៊ូក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃបានទៅសួរសុខទុក្ខពលករកម្ពុជា បន្ទាប់ពីមានការសំណូមពរដែលត្រូវបានចុះផ្សាយដោយកាសែតខ្មែរថាមស៍កាលពីថ្ងៃសុក្រជុំវិញការព្រួយបារម្ភអំពីការផ្ទុះឡើងនៃជំងឺកូវីដ-១៩។ ទន្ទឹមនឹងនេះ ពលករចំណាកស្រុកកម្ពុជាដែលរស់នៅប្រទេសថៃមានការព្រួយបារម្ភកាន់តែខ្លាំងលើការផ្ទុះឡើងនេះ ដោយសារពលករមួយចំនួនបានស្លាប់ដោយសារជំងឺកូវីដ-១៩។

លោក រ៉េត ផាន់ណា បានធ្វើការនៅរោងចក្រវេចខ្ចប់អាហារនៅទីក្រុងបាងកកចាប់តាំងពីឆ្នាំ ២០១៩ បាននិយាយថា នៅពេលមានករណីឆ្លងថ្មី បន្តកើនឡើងនៅប្រទេសថៃ វាបានធ្វើឲ្យលោកមានភាពតានតឹងខ្លាំងដោយសារការមិនមានប្រាក់ចំណូល និងការងារធ្វើកាលពីខែមុន។

កញ្ញា ណៃ វណ្ណៈ ជាពលករចំណាកស្រុកដែលបានស្លាប់ដោយសារជំងឺកូវីដ-១៩ នៅទីក្រុងបាងកកកាលពីថ្ងៃអាទិត្យ។ ពលករកម្ពុជាផ្សេងទៀតកំពុងស្វែងរកការងារធ្វើនៅប្រទេសថៃ បើទោះបីស្ថានភាពនៃការផ្ទុះឡើងនាពេលបច្ចុប្បន្នមិនមានសុវត្ថិភាពសម្រាប់ពួកគេក៏ដោយ។

លោក ចាន់ ម៉ៅ ជាពលករចំណាកស្រុកម្នាក់បាននិយាយថា នៅពេលពលករខ្មែរព្យាយាមឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ពួកគេមានហានិភ័យខ្ពស់ក្នុងឆ្លងកូវីដ-១៩ ពីពលករផ្សេងទៀត។ លោកបន្តថា មុនពេលទទួលបានការងារធ្វើនៅទីនោះពលករភាគច្រើនត្រូវប្រឈមនឹងការធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃនៅពេលចូលទៅដល់ប្រទេសថៃ។

ក្រសួងសុខាភិបាលថៃមានក្រុមការងារចល័តដែលចុះទៅពិនិត្យមើលស្ថានភាពកូវីដ-១៩ លើពលករចំណាកស្រុកទាំងស្របច្បាប់ និងខុសច្បាប់។ លោកChawetsan Namwat ប្រធានស្ដីទីនៃការិយាល័យអាសន្នលើសុខភាពសាធារណៈបាននិយាយថា៖ «យើងមានការព្រួយបារម្ភខ្លាំងណាស់ចំពោះសុខភាពរបស់ពលករចំណាកស្រុក ព្រោះយើងមិនអាចបណ្ដោយឲ្យអ្នកដែលវិជ្ជមានកូវីដ-១៩ មិនទទួលបានការព្យាបាលនោះទេ»។ លោកបន្តថា៖ «យើងមិនអាចឲ្យពលករណាម្នាក់ស្លាប់ដោយមិនទទួលបានការគាំទ្រពីមន្ត្រីសុខាភិបាលទេ ហើយអ្វីដែលសំខាន់បំផុតនោះគឺយើងត្រូវតែជួយសង្គ្រោះជីវិតមនុស្ស»។

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ចុះទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ គ្រប់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣

http://cambodiapolice.com/policekh/ 12:18 pm 1 មិថុនា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនកូនភ្នំ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ខៀវ-ព៉ាត់ (នាយប៉ុស្តិ៍ស្តីទី) និងកម្លាំងប៉ុស្តិ៍ព្រំដែនចក្រី ដឹកនាំដោយលោកអនុសេនីយ៍ឯក ស៊ឹម-កុសល(នាយរងប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី២,វរសេនាតូចលេខ១ ដឹកនាំដោយលោកអនុសេនីយ៍ឯក អ៊ួង-វណ្ណនី(មេបញ្ជាការរង គ) បានចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ស្ថិតក្នុងភូមិសាស្ត្រស្រុកសំពៅលូន និងមួយគោលដៅទៀត

ដឹកនាំដោយលោកអនុសេនីយ៍ទោឌីម-ធុល (មន្ត្រីប៉ុស្តិ៍នគរបាលព្រំដែនកូនភ្នំ ) រួមជាមួយកម្លាំងផ្នែកស៊ើបការណ៍នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧) ដឹកនាំដោយលោកអនុសេនីយ៍ទោ សេង-អ៊ើន នាយផ្នែក សហការជាមួយកម្លាំងយោធាកងអនុសេនាធំគាំទ្រ,វរសេនាតូច ៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កួង-វ៉េ (មេបញ្ជាការរងគ) និងកម្លាំងយោធាកងអនុសេនាធំទី១,វរសេនាតូចលេខ១ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឡៃ-លឿន(មេបញ្ជាការខ) ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូនចំនួន២នាក់ .ស្រី១នាក់ ។

បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## ពលករខ្មែរអះអាងថាមេខ្យល់នាំឆ្លងដែនក្នុងម្នាក់៥.000បាតត្រូវទាហានថៃ ចាប់ខ្លួន

http://nokorwatnews.com/ 02/06/2021

ក្រុងប៉ោយប៉ែត៖ ទាហានថៃបានល្បាតតាមព្រំដែន ចាប់ពលករខ្មែរចំនួន៥នាក់ លួចឆ្លងចូលប្រទេសថៃ តែអះអាងថា ចំណាយលុយក្នុងម្នាក់៥,០០០បាតឲ្យមេខ្យល់។ សេចក្តីរាយការណ៍ពីប្រទេសថៃថាៈ កាលពីវេលាម៉ោង១២នឹង២០នាទី ថ្ងៃទី២ មិថុនា ២០២១ នេះសមត្ថកិច្ចទាហានស្រុកតាព្រះយ៉ា កងកម្លាំងបូរផា បានទទួលសរចក្តីរាយការណ៍ពីក្រុមល្បាតនគបាលល្បាតព្រំដែនទី១២ ថាខណៈកំពុងល្បាតនៅក្នុងភូមិសាស្ត្រទទួលខុសត្រូវនោះបានពិនិត្យឃើញក្រុមសង្ស័យ ដែលគិតថា ហ្នឹងលួចចូលមកប្រទេសថៃដោយខុសច្បាប់ នៅបរិវេណចម្ការដំឡូងក្រោយភូមិទ័ពសៀម ឃុំតា ព្រះយ៉ា ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ រវាងចំណុចត្រួតពិនិត្យគីឡូម៉ែត្រ២៦-២៧ ទើបសមត្ថកិច្ចស្រុកតាព្រះយ៉ា ចូលទៅត្រួតពិនិត្យ និងឃុំខ្លួនពលរដ្ឋខ្មែរចំនួន៥នាក់។

ក្រោយពីសួរនាំ បានឲ្យដឹងថា ពលរដ្ឋខ្មែរខាងលើបានលួចឆ្លងដែនចូលមកប្រទេសថៃចំនួន៥នាក់ ក្នុងនោះប្រុស២ និងស្រី៣នាក់ រួមមានឈ្មោះ៖ មាន ដុង ប្រុស អាយុ៤៥ឆ្នាំ,តេ សន្តិ ប្រុស អាយុ២៣ឆ្នាំ,ភូ ផាហ្វយ ស្រី អាយុ៤១ឆ្នាំ,ចះរស់ សាន់ដេ ស្រី អាយុ២៤ឆ្នាំ,ចះរ៉េះ សាន់ឌី ស្រី អាយុ១៨ឆ្នាំ ដោយពលរដ្ឋខ្មែរទាំង៥នាក់ទទួលសារភាពថា ធ្វើដំណើរមកពីស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ត្រូវការចូលទៅធ្វើការសំណង់នៅខេត្តនុនថៈ បុរី ដោយមានញាតិរបស់ខ្លួនធ្វើការនៅទីនោះ មានជនជាតិខ្មែរដឹងឈ្មោះមេខ្យល់នាំផ្លូវ តាមច្រករបៀងក្នុងការធ្វើដំណើរលួចចូលមក ដោយបានបោះបង់ចោលពួកខ្លួន និងប្រាប់ថា ហ្នឹងមានអ្នកមកទទួលនាំទៅបន្ត ក្នុងពេលរង់ចាំនោះ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនមុន។

ពលករខ្មែរខាងលើ បានឆ្លើយថា ការធ្វើដំណើរចូលមកព្រំដែនខាងលើ ចំណាយលុយអស់ក្នុងម្នាក់៥,០០០បាត និងបានចំណាយរួចទៅហើយចំនួន២,៥០០បាត ទើបសមត្ថកិច្ចអនុវត្តតាមវិធានការរបស់សុខាភិបាលដោយពិនិត្យកម្តៅ ឃើញថា ទាំង៥នាក់មានកម្តៅធម្មតា បន្ទាប់មកសមត្ថកិច្ចបានចោទប្រកាន់ជនត្រូវចោទទាំង៥នាក់ ឱ្យដឹងថា ពីទង្វើខុសច្បាប់ជាបុគ្គលបរទេសលួចចូលមក។ និងស្នាក់នៅក្នុងរាជាណាចក្រថៃដោយមិនបានទទួលការអនុញ្ញាត ទើបបានធ្វើកំណត់ហេតុចាប់ឃុំខ្លួនទុកជាភស្តុតាង ក្រោយមកបាននាំជនត្រូវចោទទាំងអស់ បញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញតាមច្រកMOU ចំណុចត្រួតពិនិត្យអូរបីជាន់ស្រុកអូរជ្រៅខេត្តបន្ទាយមានជ័យ ៕

## ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១
## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៧នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអង្គារ ទី០១ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៧នាក់ ស្រី ២១នាក់ ក្នុងនោះកុមារ ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៩នាក់ ស្រី ១៥នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ២នាក់ ស្រីចំនួន ១នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ១៦នាក់ ស្រីចំនួន ៤នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥៧នាក់ ស្រី ២១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## អ្នកនាំពាក្យក្រសួងការបរទេស ៖ គិតត្រឹមឆ្នាំ២០២០ អាមេរិកបញ្ជូនពលរដ្ឋខ្មែរ មកកម្ពុជាវិញ សរុប ៧៧៤នាក់

https://cen-news.com/ Posted ByPen Srey Neat June 3, 2021

ភ្នំពេញ ៖ អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លោក កុយ គួង បានមានប្រសាសន៍បញ្ជាក់កាលពីរសៀលថ្ងៃទី៣ ខែមិថុនា នេះថា ប្រជាពលរដ្ឋខ្មែរដែលសហរដ្ឋអាមេរិក បញ្ជូនខ្លួនមកកម្ពុជាវិញ នាពេលកន្លងមកនេះមានចំនួនសរុប ៧៧៤នាក់ ដោយឡែកនៅក្នុងឆ្នាំ ២០២០ កន្លងមកនេះ មានចំនួន២៥នាក់។ អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់ទៀតថា ប្រជាពលរដ្ឋខ្មែរដែលសហរដ្ឋអាមេរិកបញ្ជូនមកស្រុកកំណើតវិញ ពួកគេបានរស់នៅក្នុងសមាហរណកម្មមានជីវភាពល្អសមរម្យមានមុខរបរធ្វើនៅក្នុងសង្គមជាតិ ។ "កម្ពុជាយើងទទួលប្រជាពលរដ្ឋដែលសហរដ្ឋអាមេរិកបញ្ជូនមកវិញ គឺតែងតែធ្វើឲ្យពួកគាត់មានការរស់នៅប្រកបដោយសមរម្យអាចរស់នៅបាននៅក្នុងសង្គមជាតិយើង មិនមែនយកមកប្រលែងចោល គឺយើងបានខិតខំយកចិត្តទុកដាក់ ជាពិសេសគឺតាមរយៈក្រសួងដែលស្រាយផ្ទាល់ គឺក្រសួងមហាផ្ទៃដែលបានទទួលយកមក ហើយបានចាត់ចែងជាមួយក្រសួងពាក់ព័ន្ធបន្តទៀត"។

សូមជម្រាបថា នៅក្នុងជំនួបពិភាក្សារវាងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាជាមួយលោកស្រី វិនឌី រូត្ស ស៊ើមែន (Wendy Ruth Sher man) អនុរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ជាមួយ នៅ វិមាន សន្តិភាព កាលពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ ភាគីទាំងពីរក៏បាន

ពិភាក្សាពីការប្ដេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះកម្មវិធីមាតុភូមិនិវត្តន៍ ពលរដ្ឋលើការបញ្ជូនពលរដ្ឋកម្ពុជាពីសហរដ្ឋអាមេរិកមកកម្ពុជាវិញ ដោយផ្អែកលើគោលការណ៍ គោរពសិទ្ធិមនុស្ស លើទិដ្ឋភាពមនុស្សធម៌ និងមេត្តាករុណាធម៌ ។ គួរបញ្ជាក់ថា កម្ពុជា – អាមេរិក បានចុះអនុស្សរណៈជាមួយគ្នា ( MoU) កាលពីឆ្នាំ២០១៦ ។ ចំពោះពលរដ្ឋកម្ពុជាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌបំពានច្បាប់សហរដ្ឋអាមេរិក ត្រូវចាប់ បញ្ជូនមកប្រទេសកំណើតវិញ៕ រក្សាសិទ្ធិដោយៈ ចេស្តារ

## កម្លាំងចម្រុះសហការចុះការពារសន្តិសុខ និងត្រួតពិនិត្យពលរដ្ឋ ឆ្លងដែន ខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 03/06/2021

ខេត្តបាត់ដំបង ៖ តាមបទបញ្ជា របស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្ដីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូច នគរបាលការពារ ព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាល ការពារព្រំដែនគោកលេខ៨ ១៧ កាលពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១នេះ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែន១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ម៉ឹង-ម៉េត (នាយប៉ុស្តិ៍ស្ដីទី) រួមជាមួយលោកអនុសេនីយ៍ទោ ហ៊ឹង-កុម្ភៈ (នាយរងផ្នែកសេនាធិការ) សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកសំពៅលូន ដឹកនាំដោយលោកវរសេនីយ៍ត្រី វ៉ាន់-សុផល (មេបញ្ជាការរងផ្នែកសឹករង) និងកម្លាំងយោធាវរសេនាតូច៥៣៣ ដឹកនាំដោយលោក អនុសេនីយ៍ឯក ស៊ីន-សេងអាន(មេបញ្ជាការរងគ) បានចេញល្បាតតាមខ្សែបន្ទាត់កម្ពុជា_ថៃ ក្នុងមុខសញ្ញាប៉ុស្តិ៍គ្រប់គ្រងចាប់ពីចំណុចភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ដល់ចំណុចភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ៕

## មេខ្យល់ថៃម្នាក់ត្រូវបានចាប់ខ្លួនពីបទនាំពលករខ្មែរឆ្លងកាត់ព្រំដែនខុសច្បាប់

https://www.khmertimeskh.com/ យិន សឿម / ខ្មែរថាមស៍ June 2, 2021

អាជ្ញាធរខេត្តបន្ទាយមានជ័យបានចាប់ខ្លួនពលករចំណាកស្រុកកម្ពុជាចំនួន ៩ នាក់ និងមេខ្យល់ជនជាតិថៃម្នាក់ ខណៈពួកគេកំពុងព្យាយាមលួចឆ្លងដែនទៅប្រទេសថៃ។ លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងនគរបាលខេត្តបាននិយាយថា ជនសង្ស័យបានព្យាយាមឆ្លងដែនចូលប្រទេស ថៃដោយខុសច្បាប់ពី ភូមិសាមគ្គីមានជ័យ ក្រុងប៉ោយប៉ែត។ លោកស្រីបានបន្ថែមថាមេខ្យល់ថៃម្នាក់នឹងត្រូវបញ្ជូនទៅតុលាការ ខណៈដែលកម្មករទាំង ៨ នាក់ត្រូវឆ្លងកាត់ការធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ៕

## សមត្ថកិច្ចថៃចាប់បញ្ជូនពលករជិត២០នាក់ ប្រគល់ឲ្យសមត្ថកិច្ចកម្ពុជា ខណៈពួកគេឆ្លងដែនមកពីប្រទេសថៃចូលកម្ពុជាវិញ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៤ មិថុនា ២០២១ ដោយ Sorn Phanith

ពលករដែលបានវិលពីប្រទេសថៃជិត២០នាក់ ត្រូវបានសមត្ថកិច្ចការពារតំបន់ព្រំដែន នាំខ្លួនរួចរៀបចំបញ្ជូនឲ្យធ្វើចត្តាឡីស័ក១៤ថ្ងៃ តាមវិធានការក្រសួងសុខាភិបាល។ នគរបាលវរសេនាតូចការពារព្រំដែនគោកលេខ

៨១៧ បានប្រាប់ឲ្យដឹងថា ក្រោមកិច្ចសហការជាមួយកម្លាំងប៉ុស្តិ៍ផ្នែកសឹករង ក៏ដូចជាកម្លាំងយោធាវរសេនាតូច ៥៣៣ បានទទួលប្រជាពលរដ្ឋចំនួន១៦នាក់ ពីភាគីយោធាថៃកងអនុសេនាធំកាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០២១ កន្លងមកនេះ។

ប្រភពខាងលើបន្តថា ប្រជាពលរដ្ឋជាពលករទាំងអស់ខាងលើនៅថ្ងៃកើតហេតុ ពួកគេបាននាំគ្នាឆ្លងដែនដោយថ្មើរជើងចេញពីប្រទេសថៃ ក្នុងគោលដៅចូលមកប្រទេសកម្ពុជាវិញកាត់តាមចំណុចភូមិសាស្រ្តភូមិពោធិ៍ជ្រៃឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ក៏ត្រូវយោធាថៃឃាត់ខ្លួនហើយប្រគល់ឲ្យភាគីសមត្ថកិច្ចកម្ពុជាតែម្តង។ ពលករខ្មែរ ដែលធ្វើចំណាកស្រុកខុសច្បាប់ហើយវិលមកកម្ពុជាវិញ ត្រូវយោធាថៃឃាត់ខ្លួនសរុបចំនួន១៦នាក់ ក្នុងនោះបុរសចំនួន៨នាក់ ស្រ្តីនិងក្មេងតូចចំនួន៨នាក់ផងដែរ។ ក្រោយការសាកសួរអប់រំណែនាំនិងតម្រូវឲ្យធ្វើកិច្ចសន្យាបញ្ឈប់កម្លាំងពាក់ព័ន្ធ បានប្រគល់ពលករខាងលើទៅឲ្យក្រុមគ្រូពេទ្យ ដើម្បីបញ្ជូនបន្តទៅកាន់មណ្ឌលធ្វើចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល៕ **អត្ថបទ៖ សៅ សារិទ្ធ**

## ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១

### ពលករខ្មែរ ១៦នាក់ បានឆ្លងដែនពីប្រទេសថៃចូលមកកម្ពុជាវិញ ត្រូវសមត្ថកិច្ចថៃចាប់ប្រគល់ឲ្យសមត្ថកិច្ចកម្ពុជា

http://gntimes.com/ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២១

ខេត្តបាត់ដំបង៖ សមត្ថកិច្ចប្រទេថៃនៅតាមតំបន់ព្រំដែនបានស្ទាក់ចាប់ឃាត់ខ្លួនពលករខ្មែរដែលបានវិលពីប្រទេសថៃចូលមកកម្ពុជាវិញ ប្រមាណ ១៦នាក់ប្រគល់ឲ្យសមត្ថកិច្ចកម្ពុជាការពារតំបន់ព្រំដែន ដើម្បីរៀបចំបញ្ជូនឲ្យធ្វើចត្តាឡីស័ក ១៤ថ្ងៃ តាមវិធានការក្រសួងសុខាភិបាល ។

នគរបាលវរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៧ បានប្រាប់ឲ្យដឹងថា ក្រោមកិច្ចសហការជាមួយកម្លាំងប៉ុស្តិ៍ផ្នែកសឹករង ក៏ដូចជាកម្លាំងយោធាវរៈសេនាតូច ៥៣៣ បានទទួលប្រជាពលរដ្ឋ ១៦នាក់ ពីភាគីយោធាថៃកងអនុសេនាធំ កាលពីថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០២១នេះ ។ ពលករខ្មែរដែលធ្វើចំណាកស្រុកខុសច្បាប់ហើយវិលមកកម្ពុជាវិញ ត្រូវយោធាថៃឃាត់ខ្លួនសរុប ១៦នាក់ ក្នុងនោះបុរស ៨នាក់ ស្ត្រី ០៨នាក់ និងក្មេងតូចផងដែរ ។ នគរបាលដដែលបន្តថា ប្រជាពលរដ្ឋជាពលករទាំងអស់ខាងលើនៅថ្ងៃកើតហេតុពួកគេបាននាំគ្នាឆ្លងដែនដោយថ្មើរជើងចេញពីប្រទេសថៃក្នុងគោលដៅចូលមកប្រទេសកម្ពុជាវិញកាត់តាមចំណុចភូមិសាស្រ្តភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ក៏ត្រូវយោធាថៃឃាត់ខ្លួន ហើយប្រគល់ឲ្យភាគីសមត្ថកិច្ចកម្ពុជាតែម្តង ។ ក្រោយពីសាកសួរអប់រំណែនាំ និងតម្រូវឲ្យធ្វើកិច្ចសន្យាបញ្ឈប់ កម្លាំងសមត្ថកិច្ចក៏បានប្រគល់ពលករខាងលើទៅឲ្យក្រុមគ្រូពេទ្យដើម្បីបញ្ជូនបន្តទៅកាន់មណ្ឌលធ្វើចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

### ពលករខ្មែរ ៣រូប ត្រឡប់ពីថៃ ឆ្លងកូវីដបំប្លែងថ្មី B.1.617 ជាប្រភេទឆ្លងខ្លាំង និងមេរោគគួរឲ្យព្រួយបារម្ភ

https://kohsantepheapdaily.com.kh/ ០៤ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ២១:៥៤

រាជធានីភ្នំពេញ ៖ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី០៤ មិថុនា ២០២១នេះ បានប្រកាសរកឃើញមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ប្រភេទ B.1.617 ឬ delta Variant នៅក្នុងខ្លួនពលករខ្មែរចំនួន ៣ រូប ដែលត្រឡប់មកពីប្រទេសថៃ ដែលជាប្រភេទមេរោគឆ្លងខ្លាំងបំផុត និងមេរោគគួរឲ្យព្រួយបារម្ភបំផុត ។

ពលករទាំង៣នាក់ ត្រឡប់មកពីប្រទេសថៃ តាមច្រកអូស្មាច់ រួមមាន ៖

ទី១. ភេទស្រី អាយុ ២៧ឆ្នាំ កំពុងសំរាកព្យាបាលនៅមន្ទីរពេទ្យខេត្តឧត្តរមានជ័យ

ទី២. ភេទប្រុស អាយុ ៤៦ឆ្នាំ កំពុងសំរាកព្យាបាលនៅមន្ទីរពេទ្យឯកភ្នំ ខេត្តបាត់ដំបង

និងទី៣. ភេទស្រី អាយុ ៤៣ឆ្នាំ កំពុងសំរាកព្យាបាលនៅមន្ទីរពេទ្យមោងឫស្សី ខេត្តបាត់ដំបង ។ ជាការកត់សម្គាល់ឃើញថា រហូតមកដល់ពេលនេះ វីរុសបំប្លែងថ្មី ប្រភេទ B.1.617 ដែលពិភពលោកមានការព្រួយបារម្ភខ្លាំង ត្រូវបានគេរកឃើញនៅបណ្តាប្រទេសចំនួន ៧ហើយ នៅក្នុងតំបន់អាស៊ាន (ប្រទេសឥណ្ឌូណេស៊ី ប្រទេសម៉ាឡេស៊ី ប្រទេសហ្វីលីពីន ប្រទេសសិង្ហបុរី ប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសកម្ពុជា) និងបណ្តាប្រទេសមួយចំនួនទៀត លើពិភពលោក ។

## តំណាងអយ្យការកំពុងសាកសួរស្ត្រីម្ចាស់ផេកហ្វេសប៊ុក Madam Chords លក់ផលិត ផលនាំចូល ពីប្រទេសថៃ ទៅតុលាការករណីនិយាយពាក្យអាសអាភាស

https://cen-news.com/ Posted ByPen Srey Neat June 5, 2021

ភ្នំពេញ ៖ ការចាប់ខ្លួនស្ត្រីជនសង្ស័យ បានធ្វើឡើងដោយកម្លាំងជំនាញនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ នៅព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២១នេះ បានធ្វើការចាប់បញ្ជូនខ្លួនស្ត្រីម្ចាស់គណនីផេកហ្វេសប៊ុក មាដាមឆដា (Madam Chords) ផលិតផលនាំចូលពីប្រទេសថៃ ទំនុកចិត្តនិងគុណភាព ទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការសាកសួរពាក់ព័ន្ធនឹងករណី ឡាយវីដេអូលក់អីវ៉ាន់ ហើយនិយាយពាក្យអាស អាភាស។

សមត្ថកិច្ចជំនាញនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ កម្លាំងប៉ុស្តិ៍រដ្ឋបាលចោមចៅ១ កាលពីថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២១ បានចុះអនុវត្ត ដីកាបញ្ជាឲ្យចូលខ្លួនលេង១១៣អ.យ.ក របស់ឯកឧត្តម ច្រឹង ខ្មៅ ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បាននាំខ្លួនជនសង្ស័យខាងលើមាន ឈ្មោះ សៀន សូលក្ខិណា ហៅប៉ុប ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មកប្រគល់ជូនអយ្យការអមសាលាដំបូង ដើម្បីចាត់ការតាមផ្លូវច្បាប់។ សមត្ថកិច្ចបានបញ្ជាក់ថា ជនសង្ស័យមានឈ្មោះ សៀន សូលក្ខិណា ហៅ ប៉ុប ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មានស្រុកកំណើតនៅឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ស្នាក់នៅផ្ទះជួលលេខ៧៥សេ ផ្លូវលេខ២ ក្នុងបុរីហុងឡាយ ភូមិត្រពាំងថ្លឹង៣ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ ចំពោះមុខសមត្ថកិច្ចស្ត្រីជនសង្ស័យបញ្ជាក់ថា គាត់ពិតជាការឡាយ (Live) វីដេអូ លក់ផលិតផល បាននិយាយ លេងសើចជាមួយភ្ញៀវដោយប្រើពាក្យ អាសអាភាស ពិតប្រាកដមែន ។

សមត្ថកិច្ចបានបញ្ជាក់ថា ស្ត្រីជាជនសង្ស័យ បាននិយាយសារភាពថា ខ្លួនជាម្ចាស់គណនីផេកហ្វេសប៊ុក មាដាមឆដា (Madam Chords) បានឡាយលក់ផលិតផលថែរក្សាសម្រស់ របស់ក្រុមហ៊ុន ម៉ាដាមដា (Madam Da) តាំងពីអំឡុងឆ្នាំ២០១៨ ជាកម្មសិទ្ធិរបស់បងស្រីខ្លួន ដោយមានប្តីជាជនជាតិថៃ មានផលិតផល ឡេលាបមុខ ឡេលាបខ្លួន សាប៊ូដុះខ្លួន ទឹកអនាម័យស្ត្រី ហ្វាយបឺ (Fiber) និងខូឡេជេន (collagen) តាំងពីឆ្នាំ២០១៨ របស់ក្រុមហ៊ុន ម៉ាដាមដា (Madam Da) ដោយមានច្បាប់អនុញ្ញាតត្រឹមត្រូវ ជាមធ្យមខ្លួនលក់ផលិតផលឲ្យភ្ញៀវ ក្នុងមួយថ្ងៃបានពី៤០ទៅ៥០នាក់ ៕ រក្សាសិទ្ធិដោយ៖ CEN

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ចុះទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិស្ពានយោល

http://cambodiapolice.com/policekh/ 10:59 pm 4 មិថុនា 2021

បាត់ដំបង: កាលពីថ្ងៃព្រហស្បតិ៍ ៨រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងកានគរបាលខេត្តបាត់ដំបង ស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្ដិ៍នគរបាលព្រំដែន ៩ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ គុន-ហ៊ាង (នាយប៉ុស្ដិ៍ស្ដីទី) រួមជាមួយកម្លាំងផ្នែកសេនាធិការ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក សំ-វុទ្ធី (នាយផ្នែក សេនាធិការ ) សហការជាមួយកម្លាំងយោធាផ្នែកសឹករង ស្រុកសំពៅលូន ដឹកនាំដោយលោកអនុសេនីយ៍ត្រីណៃចិន-ទីត (មេបញ្ជាការរង គ) និងកម្លាំងយោធាវរសេនាតូច៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ឯកពៅ-ចំរើន (មេបញ្ជាការរងគ) បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិស្ពានយោល ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន ៨ នាក់, ស្រី៥នាក់។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ចុះទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុចនៃភូមិសាស្រ្តភូមិពោធិ៍ជ្រៃ

http://cambodiapolice.com/policekh/ 8:52 am 4 មិថុនា 2021

ខេត្តបាត់ដំបង ៖ ថ្ងៃព្រហស្បតិ៍ ៨រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្ដិ៍នគរបាលព្រំដែន១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ម៉ឹង ម៉េត (នាយប៉ុស្ដិ៍ស្ដីទី) សហការជាមួយកម្លាំងយោធាផ្នែកសឹករង ដឹកនាំដោយលោកវរសេនីយ៍ត្រី វ៉ាន់ សុផល (មេបញ្ជាការរងផ្នែកសឹករង) និងកម្លាំងយោធាវរសេនាតូច៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក អាំផន(មេបញ្ជាការ គ) បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ចំនួន ០៤នាក់ ស្រី ០៣នាក់ ក្នុងនោះក្មេងប្រុស ០១នាក់ និងក្មេងស្រី ០២នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ។

## បញ្ជូនពលករខ្មែរ៤នាក់ពីប្រទេសឡាវឲ្យវិលត្រឡប់មកកម្ពុជា

https://www.rasmeinews.com/ 5 June, 2021

**ដោយ: សុខុម / ស្ទឹងត្រែង:** *ស្ថានអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតឡាវ បានបញ្ជូនពលករដែលបម្រើការងារនៅទីនោះ ឲ្យវិលត្រឡប់មកស្រុកកំណើតវិញចំនួន៤នាក់ នៅព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២១។*

យោងតាមទំព័រហ្វេសប៊ុកផ្លូវការរបស់ស្ថានអគ្គរាជទូតកម្ពុជាប្រចាំ ស.ប.ប.ឡាវ បានបង្ហោះនៅព្រឹកថ្ងៃទី៥ មិថុនាថា ស្ថានទូតសហការជាមួយស្ថានអគ្គកុងស៊ុលកម្ពុជានៅទីក្រុងប៉ាក់សេ បានបញ្ជូនពលករខ្មែរចំនួន៤នាក់ ដោយជួយសម្រួលដំណើរ និងបំពេញបែបបទនៅច្រកទ្វារព្រំដែនអន្តរជាតិណងណុកខៀន- ត្រពាំងក្រៀលមកប្រទេសកម្ពុជា។ ពលរដ្ឋខ្មែរឈ្មោះ សន ខាំគន់ ភេទប្រុស អាយុ ២៧ឆ្នាំ មានស្រុកកំណើតនៅខេត្តក្រចេះ ត្រូវបានសមត្ថកិច្ចឡាវឃាត់ខ្លួនកាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ ពីបទឆ្លងដែនចូលឡាវខុសច្បាប់ និងពិន័យជាប្រាក់ ១០០ដុល្លារអាមេរិក។ ជាមួយនោះស្ថានទូតបានជួយអន្តរាគមន៍ដោះលែង និងជួយបង់ប្រាក់ពិន័យខាងលើ។

ស្ថានទូតបានផ្តល់ការស្នាក់នៅ និងអាហារហូបចុករយៈពេល ១០ថ្ងៃ ទិញសម្លៀកបំពាក់ បង់ថ្លៃធ្វើតេស្តជំងឺកូវីដ-១៩ និងថវិកាចំនួន ១៥០ដុល្លារសម្រាប់ដាក់តាមខ្លួនដល់ពលករខាងលើ។ បន្ថែមពីនេះដោយរដ្ឋាភិបាលឡាវ បន្តបិទប្រទេសរហូតដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ មិនអនុញ្ញាតឱ្យរថយន្តដឹកអ្នកដំណើរចេញ-ចូលឆ្លងខេត្តបាន ស្ថានទូតបានជួយសម្រួលដំណើរដល់ពលរដ្ឋខ្មែរចំនួន ៣នាក់ទៀត ដែលបម្រើការនៅកាស៊ីណូនាទីក្រុងវៀងច័ន្ទ ត្រូវចប់អាណត្តិការងារអាចវិលត្រឡប់ទៅកម្ពុជានៅថ្ងៃនេះ ផងដែរ៕

## ពលករខ្មែរ១៧នាក់ លួចឆ្លងដែនខុសច្បាប់ត្រូវទាហានថៃ ឃាត់ខ្លួន

http://nokorwatnews.com/ 06/06/2021

ក្រុងប៉ោយប៉ែត៖ សមត្ថកិច្ចថៃនៅបន្តចាប់ពលករខ្មែរលួចឆ្លងខុសច្បាប់ចូលប្រទេសថៃ១៧នាក់ ក្នុងទឹកដីស្រុកតាព្រះយ៉ា ខេត្តស្រះកែវ ពួកគាត់អះអាងថា ធ្វើដំណើរទៅធ្វើការនៅខេត្តឈុនបុរី និងខេត្តសមុទ្រប្រាកាន ។

សេចក្តីរាយការណ៍ពីរ ប្រទេសថៃនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២១ ថា ខាងខេត្តស្រះកែវ បានបទបញ្ជាឲ្យបង្កើតប៉ុស្តិ៍ត្រួតពិនិត្យ ការពារសុវត្ថិភាពនៅតាមបណ្តាភូមិជាប់ព្រំដែន សមត្ថកិច្ចការពារព្រំដែនមើលការខុសត្រូវយ៉ាងតឹងតែង រហូតដល់វេលាម៉ោង០៣នឹង១៤នាទីទៀបភ្លឺ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២១ សមត្ថកិច្ចឈុតចំពោះកិច្ចតាព្រះយ៉ា កងកម្លាំងបូរផា បានទទួលសេចក្តីរាយការណ៍ថា ប្រទះឃើញក្រុមបុគ្គលលួចធ្វើដំណើរឆ្លងចូលមកក្នុងប្រទេសថៃ ទើបចាត់កម្លាំង ដោយសហការជាមួយកងរយទី៣ កងកម្លាំងនគនបាលល្បាតព្រំដែនទី១២ ចូលទៅឃ្លាំមើលក្នុងភូមិសាស្រ្តដែលគិតថា នឹងមានការលួចឆ្លងដែនចូលប្រទេសដោយខុសច្បាប់។ សមត្ថកិច្ចបានឲ្យដឹងថា នៅម៉ោងប្រមាណ៣នឹង២៦នាទីទៀបភ្លឺ សមត្ថកិច្ចបានប្រទះឃើញក្រុមពលករបរទេស ទើបបង្ហាញខ្លួនចូលទៅចាប់ឃុំខ្លួនពលករខ្មែរបានចំនួន១៧នាក់ ក្នុងនោះប្រុស៩នាក់ និងស្រី៨នាក់ ខណៈកំពុងលួចឆ្លងដែនចូលនៅបរិវេណ បង្គោលឡាក់48 PTA 6037442955 ភូមិខៅ លូកធាង ឃុំតាព្រះយ៉ា ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ ។

ក្រោយពីការសួរនាំពីសមត្ថកិច្ច ពលករខ្មែរទាំង១៧នាក់ខាងលើ បានប្រាប់ថា ធ្វើដំណើរពីប្រទេសកម្ពុជាតាមច្រករបៀង ដោយមានមេខ្យល់នាំផ្លូវជនជាតិខ្មែរ នាំមកប្រគល់ឲ្យជនជាតិថៃ ឆ្លងចូលមកតាមច្រករបៀងចំណុចត្រួតពិនិត្យ 21-22 ដោយពលករខាងលើ ត្រូវការធ្វើដំណើរទៅធ្វើការនៅខេត្តឈុន បុរី និងខេត្ត សមុទ្រ ប្រាកាន ទើបសមត្ថកិច្ចអនុវត្តតាមវិធានការសុខាភិបាល បន្ទាប់មកបានធ្វើកំណត់ហេតុចាប់ឃុំ និងបញ្ជូនបណ្តេញឲ្យត្រឡប់ទៅប្រទេសវិញ តាមច្រកMOU ចំណុចត្រួតពិនិត្យ 38 ភូមិ ណូន ម៉ាកមុន ស្រុកគោកឃ្សូង ឆ្លងតាមច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅខេត្តបន្ទាយមានជ័យ៕

## កម្លាំងសមត្ថកិច្ចថៃឃាត់ខ្លួនជនជាតិថៃ ប្រុស-ស្រី ២៥នាក់ជាបន្តបន្ទាប់ លួចឆ្លងដែនចូលមកកម្ពុជា ដើម្បីទៅធ្វើការនៅកាស៊ីណូ

http://gntimes.com/ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២១

បន្ទាយមានជ័យ ៖ កម្លាំងទាហានកងកម្លាំងបូផា ខេត្តស្រះកែវ ប្រទេសថៃ បានឃាត់ខ្លួនជនជាតិថៃមកពីតំបន់ភាគខាងជើង និងមកពីតាមបណ្តាខេត្តមួយចំនួនទៀតជាបន្តបន្ទាប់សរុបប្រមាណ ២៥នាក់ រួមទាំងមេខ្យល់ និងអ្នកមើលផ្លូវចំនួន៥នាក់ ខណៈពេលកំពុងលួចឆ្លងដែនពីប្រទេសថៃ ចូលមកប្រទេសកម្ពុជានៅពេលយប់ ក្នុងភូមិសាស្ត្រស្រុក គោកឃ្យូង ដើម្បីទៅធ្វើការនៅកាស៊ីណូអនឡាញ ក្នុងក្រុងប៉ោយប៉ែត ខេត្ត បន្ទាយមានជ័យ នៃប្រទេសកម្ពុជា ។

បើតាមសេចក្តីរាយការណ៍ ពីសមត្ថកិច្ចនៅបន្ទាត់ព្រំដែនកាលថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០២១ បានបញ្ជាក់ថា៖ អនុវត្តតាមវិធានការរឹតបន្តឹងការលួចឆ្លងដែនចូលប្រទេសដោយខុសច្បាប់ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ អាជ្ញាធរខេត្តស្រះកែវ បានដាក់ចេញនូវបទបញ្ជាឲ្យបង្កើតប៉ុស្តិ៍ទប់ស្កាត់ ក្នុងភូមិសាស្ត្រតាមបន្ទាត់ព្រំដែន ។ លុះនាពេលយប់កន្លងមក សមត្ថកិច្ចទាហានឈុត តាប់ប្រាយ៉ា កងកម្លាំងបូផា បានទទួលសេចក្តីរាយការណ៍ពីក្រុមចល័តរហ័សកងកម្លាំងបូផា ដែលដាក់ប៉ុស្តិ៍ត្រួតពិនិត្យប្រចាំ ក្នុងទឹកដីស្រុក គោកឃ្យូង ខេត្តស្រះកែវ បានប្រទះឃើញរថយន្តគួរឲ្យសង្ស័យ នាំក្រុមមនុស្សលួចចេញក្រៅប្រទេសដោយខុសច្បាប់ ទើបចាត់កម្លាំងចល័តរហ័សរបស់ស្រុកតាប់ប្រាយ៉ា រួមជាមួយកងការពារព្រំដែនទី១២ ចូលទៅត្រួតពិនិត្យ និងបានឃាត់ខ្លួនក្រុមជនជាតិថៃ ដែលកំពង់លួចឆ្លងដែលចូលមកប្រទេសកម្ពុជា ដោយជិះតាមរថយន្ត ប៊ិកអាប់ចំនួន៧នាក់ ព្រមទាំងមេខ្យល់និងអ្នកមើលផ្លូវផងដែរ ។

បើតាមសមត្ថកិច្ចថៃបានឲ្យដឹងទៀតថា ជនជាតិថៃ ដែលលួចឆ្លងដែនទៅប្រទេសកម្ពុជាចំនួន៧នាក់ មានប្រុស២នាក់ និងស្រី៥នាក់ មកពីតាមបណ្តាខេត្តក្នុងប្រទេសថៃ ដែលមេខ្យល់គឺជាអ្នកបើករថយន្តជនជាតិថៃម្នាក់ និងអ្នកមើលផ្លូវជនជាតិថៃ២នាក់ ដោយសមត្ថកិច្ចឃាត់ខ្លួនបាននៅបរិវេណភូមិ ណងស្មេត ឃុំគោកឃ្យូង ស្រុកតាប់ប្រាយ៉ា ខេត្ត ស្រះកែវ ហើយនាំខ្លួនអ្នកទាំងអស់មកសួរនាំ ។ ជំហានដំបូង ជនជាតិថៃទាំង៧នាក់ បានសារភាពថា៖ ពួកខ្លួនបានធ្វើដំណើរមកពីខេត្តឈៀងរ៉ាយ ដើម្បីចូលទៅធ្វើការនៅឯកាស៊ីណូអនឡាញ ក្រុងប៉ោយប៉ែត ប្រទេសកម្ពុជា ដោយទាក់ទងតាមរយៈ អេតមីនវេបសាយរបស់កាស៊ីណូខាងកម្ពុជា ទើបសមត្ថកិច្ចអនុវត្តតាមវិធានការសុខាភិបាល និងនាំខ្លួនជនត្រូវចោទទាំង ១០នាក់ មកសួរចម្លើយដើម្បីបំបែកសំណុំរឿងនៅស្រុក តាប់ប្រាយ៉ា ដើម្បីរកអ្នកពាក់ពន្ធ័បន្ថែមទៀត ។

គួរបញ្ជាក់ផងដែរថា កន្លងមកធ្លាប់តែឃើញមានជនជាតិខ្មែរ ដែលក្រីក្រខ្វះខាត លួចរត់ឆ្លងដែនទៅរកការងារធ្វើនៅក្នុងប្រទេសថៃ ប៉ុន្តែស្រាប់តែពេលនេះអ្វីៗបានប្រែប្រួលដោយមានជនជាតិថៃ លួចឆ្លងដែនខុសច្បាប់ចូលមករកការងារធ្វើនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាវិញម្តង ៕ អត្ថបទ រឿង ចន្ទ្រា

# ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១

## ស្នងការនគរបាលខេត្តត្បូងឃ្មុំ ក្រើនរំលឹកនគរបាលការពារព្រំដែនទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់

https://cen-news.com/ Posted ByPen Srey NeatJune 6, 2021

ខេត្តត្បូងឃ្មុំ ៖ លោកឧត្តមសេនីយ៍ត្រីស្នងការ ម៉ុន មាគ៌ា បានក្រើនរំលឹកដល់នគរបាលការពារព្រំដែន ឲ្យយកចិត្តទុកដាក់ល្បាតការពារ ខ្សែបន្ទាត់ព្រំដែន ទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ហើយការកសាងអភិវឌ្ឍ និងការយកចិត្តទុកដាក់ជីវភាព សុខភាព បងប្អូននគរបាលព្រំដែន ។

នៅព្រឹកថ្ងៃ០៥ មិថុនា ២០២១ លោកឧត្តមសេនីយ៍ត្រី ម៉ុន មាត់ា ស្នងការនគរបាលខេត្តត្បូងឃ្មុំ និងសហការី បានចុះត្រួតពិនិត្យស្ថានភាពទីតាំងភូមិសាស្ត្រ ប៉ុស្តិ៍នគរបាលព្រំដែន ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៦១៥ ដែលនឹងត្រូវសាងសង់ថ្មី ក្នុងនោះរួមមាន ១- ប៉ុស្តិ៍នគរបាល អន្លង់ជ្រៃ តាមបទដ្ឋាន និងថវិកាក្រសួងមហាផ្ទៃ លើទំហំដី ៨០ គុណ ៩០ ម៉ែត្រ ២- ស្នាក់ការត្រួតពិនិត្យ ប៉ុស្តិ៍អន្លង់ជ្រៃ ទំហំ ១២គុណ៨ ម៉ែត្រ (ថវិកាសប្បុរសជន) ៣- ប៉ុស្តិ៍នគរបាល ត្រាចខោល តាមបទដ្ឋាន និងថវិកាក្រសួងមហាផ្ទៃ លើទំហំដី ៦៧ គុណ ៨៨ ម៉ែត្រ។ លោកឧត្តមសេនីយ៍ត្រីស្នងការ បានក្រើនរំលឹក បងប្អូននគរបាលការពារព្រំដែន ឲ្យយកចិត្តទុកដាក់ល្បាតការពារ ខ្សែបន្ទាត់ព្រំដែន ទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ និងរក្សាបានអនាម័យ ពិសេសអនុវត្តវិធានការសុខាភិបាល និង ៣កុំ ៣ការពារ របស់សម្ដេចតេជោ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ៕ រក្សាសិទ្ធិះបញ្ញាស័ក្តិ

## ទាហានថៃបញ្ជូនពលករខ្មែរ១៧នាក់ មកទឹកដីខ្មែរវិញ បន្ទាប់ពីលួចឆ្លងខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ៦ មិថុនា ២០២១ដោយ Sokhom Khon

ទាហានថៃឃាត់ពលករខ្មែរ១៧នាក់ ដែលបានលួចឆ្លងខុសច្បាប់ទៅរកការងារធ្វើនៅស្រុកថៃ ហើយបានបញ្ជូនមកឲ្យសមត្ថកិច្ចខ្មែរវិញ កាលពីវេលាម៉ោង៣ទៀបភ្លឺ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២១ ក្នុងទឹកដីស្រុកតាព្រះយ៉ា ខេត្តស្រះកែវ។ សមត្ថកិច្ចថៃបានឲ្យសមត្ថកិច្ចខ្មែរដឹងថា ពលករខ្មែរទាំង១៧នាក់ ក្នុងនោះមានប្រុស៩នាក់ និងស្រី៨នាក់បានលួចឆ្លងដែនចូលទៅថៃដើម្បីស្វែងរកការងារធ្វើនៅប្រទេសថៃ នៅម្តុំបរិវេណ បង្គោលឡាក់ 48 PTA 6037442955 ភូមិខៅលូកឆាង ឃុំតាព្រះយ៉ា ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ។

ពលករខ្មែរទាំង១៧នាក់ ក្រោយពីកម្លាំងយោធាថៃធ្វើការសាកសួររួចមក ត្រូវបានធ្វើកំណត់ហេតុហើយបានបញ្ជូនឲ្យត្រឡប់មកមាតុប្រទេសវិញ តាមច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ឲ្យសមត្ថកិច្ចខ្មែរចាត់ការបន្ត។ ពលករខ្មែរ១៧នាក់នោះ ត្រូវបានកម្លាំងជំនាញបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅស្រុកថ្មពួក ឲ្យបានគ្រប់ចំនួន១៤ថ្ងៃ ទើបអាចឲ្យវិលត្រឡប់ទៅផ្ទះវិញ។ ក្នុងនោះកម្លាំងជំនាញបានជំរុញពលករខ្មែរទាំង១៧នាក់ ក្រោយពីបានវិលទៅដល់គេហដ្ឋានវិញហើយ ត្រូវចូលរួមយកចិត្តទុកដាក់ពីវិធាន៣កុំ ៣ការពារ ២អនុវត្តរបស់រាជរដ្ឋាភិបាលនិងការណែនាំរបស់ក្រសួងសុខាភិបាល៕ អត្ថបទ ៖ វ៉ាន់ ណាង

## ខេត្តឧត្តរមានជ័យ រកឃើញមនុស្ស១៥នាក់ ឆ្លងជំងឺកូវីដ១៩ ជាពលករមកពីប្រទេសថៃ

http://freshnewsasia.com/ 2021-06-06 08:28pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២១នេះ បានចេញសេចក្តីប្រកាសព័ត៌មាន បង្ហាញអត្តសញ្ញាណមនុស្សចំនួន១៥នាក់បន្ថែមទៀត ដែលទើបរកឃើញឆ្លងជំងឺកូវីដ១៩ ជាពលករវិលត្រឡប់មកពីប្រទេសថៃ។ នេះបើតាមសេចក្តីប្រកាសព័ត៌មានដែលបណ្តាញព័ត៌មាន Fresh Newsទទួលបាន។ បច្ចុប្បន្នអ្នកជំងឺចំនួន៣នាក់ ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្ត និងអ្នកជំងឺផ្សេងទៀត ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមណ្ឌលព្យាបាលផ្ទះសំណាក់ ឧត្តមរដ្ឋា។ ដោយឡែក អ្នកពាក់ព័ន្ធមានហានិភ័យខ្ពស់ត្រូវបានបញ្ជូនទៅតាមដានសុខភាព និងធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័កវិទ្យាល័យតេជោសែនសំរោង។ សូមជម្រាបថា មកទល់ពេលនេះ ខេត្តឧត្តរមានជ័យ មានអ្នកជំងឺកូវីដ១៩ ចំនួន៧៧នាក់ ក្នុងនោះករណីនាំចូលពីបរទេសចំនួន៧៥នាក់ និងករណីពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ចំនួន២នាក់។ ព្យាបាលជាសះស្បើយចំនួន២២នាក់ និងកំពុងសម្រាកព្យាបាលចំនួន៥៥នាក់៕

## អាជ្ញាធរខេត្តឧត្តរមានជ័យ និងខេត្តសុរិន្ទ ប្តេជ្ញាពង្រឹងចំណងមិត្តភាព សាមគ្គីភាព និងរិះរកវិធីដោះស្រាយបញ្ហាប្រឈមមួយចំនួន អំឡុងពេលវិបត្តិកូវីដ-១៩

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០២១

AKP ឧត្តរមានជ័យ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២១–ឯកឧត្តម ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានដឹកនាំក្រុមការងារជួបពិភាក្សាការងារ និងពង្រឹងចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការល្អ ជាមួយ ឯកឧត្តម ស៊ុរ៉ះផុង គិទិផាត់ភិប៊ូន អភិបាលខេត្តសុរិន្ទ នៅច្រកព្រំដែនអន្តរជាតិអូរស្មាច់ ឆងចម នាព្រឹកថ្ងៃសុក្រ ៩រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹង ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ ។

លទ្ធផលក្នុងជំនួបគ្នានេះ អាជ្ញាធរនៃខេត្តទាំងពីរ ប្តេជ្ញាបន្តរួមគ្នាទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ឆ្លងដែន បន្តជួយគ្នារក្សាសុខសុវត្ថិភាព និងសុខុមាលភាពជូនពលរដ្ឋខ្មែរដែលកំពុងស្នាក់នៅក្នុងប្រទេសថៃ ពិសេសអ្នកដែលអាចស្នាក់នៅហួសទិដ្ឋាការកំណត់ក្នុងអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩ ដ៏អាក្រក់នេះ។ ភាគីទាំងពីរបន្តអនុញ្ញាតឱ្យឆ្លងកាត់ចេញ-ចូលរាល់ទំនិញដែលមានលក្ខណៈពាណិជ្ជកម្ម ដូចដែលបានឯកភាពគ្នាកន្លងមក និងបន្តទាក់ទងគ្នាជាប់ជាប្រចាំ និងសហប្រតិបត្តិការល្អ ពិសេសជូនព័ត៌មានគ្នាទៅវិញទៅមកពេលមានការវិវត្តប្រែប្រួលនានាឱ្យបានទាន់ពេលវេលា។

ឯកឧត្តម ប៉ែន កុសល្យ ក៏បានស្នើសុំឱ្យឯកឧត្តមអភិបាលខេត្តសុរិន្ទជួយថែរក្សា និងការពាររាល់ទ្រព្យសម្បត្តិ និងកម្មសិទ្ធិឯកជនស្របច្បាប់របស់ប្រជាពលរដ្ឋ អាជីវករ ពាណិជ្ជករ និងពលករខ្មែរដែលកំពុងស្ថិតនៅក្នុងប្រទេសថៃនាពេលបច្ចុប្បន្ន ។ ឯកឧត្តម អភិបាលខេត្តឧត្តរមានជ័យ ក៏បានលើកឡើងបន្តទៀតថា ក្នុងអំឡុងពេលស្ថានភាពដ៏លំបាកនៃការប្រយុទ្ធប្រឆាំងវីរុសកូវីដ១៩នេះ ក៏មានមេខ្យល់នាំពលករឆ្លងដែនសូមឱ្យអាជ្ញាធរថៃបន្តពង្រឹង និងសហការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងស្វែងរកចាប់មេខ្យល់ទាំងខាងខ្មែរនិងខាងថៃមកដាក់ទោសតាមច្បាប់ ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១នេះ ស្របពេលវិបត្តិជំងឺកូវីដ១៩ បានរីករាលដាលជាសកល ពលករខ្មែរបានឆ្លងដែនមកពីប្រទេសថៃ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួន ៧៥.៨៤៦ នាក់ ស្រីចំនួន៣៤.០១៨ នាក់ ពលករក្នុងខេត្តឧត្តរមានជ័យចំនួន១១.០៧០ នាក់ ពលករដែលកំពុងធ្វើចត្តាឡីស័កចំនួន ៣៨២ នាក់ ករណីឆ្លងជំងឺកូវីដ-១៩ ចំនួន៥៩ នាក់ ព្យាបាលជាសះស្បើយចំនួន១៦ នាក់។

ឯកឧត្តម អភិបាលខេត្តឧត្តរមានជ័យ ក៏បានស្នើឱ្យក្រុមការងារឈរជើងនៅតាមច្រកព្រំដែន បន្តពិនិត្យសុខភាពរបស់ប្រជាពលរដ្ឋ និងបានណែនាំឱ្យពួកគេដាក់ខ្លួននៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ ការពារកុំឱ្យមានការចម្លងមេរោគទៅក្រុមគ្រួសារ និងអ្នកដទៃ ៕ ដោយ ៖ ទិត ស្រី

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៥នាក់

https://www.facebook.com/tvkchannel7/ 07/06/2021

ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអាទិត្យ ទី០៦ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកជួង ស្រុក

កំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៥នាក់ ស្រី ៣២នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១១នាក់ ស្រី ៦នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១០នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៤៤នាក់ ស្រី ២២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារា ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៦៥នាក់ ស្រី ៣២នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ៕ ប្រភព: ក្រុមការងារប្រចាំការតាមព្រំដែនរបស់រដ្ឋបាលខេត្តសៀមរាប

## ទាហានថៃស្ទាក់ចាប់ពលករខ្មែរ២១នាក់ ដែលឆ្លងដែនខុសច្បាប់

https://www.rasmeinews.com/ 6 June, 2021

**ដោយ: ប.ជ័យ/ព្រំដែនកម្ពុជា-ថៃ:** *ពលករខ្មែរចំនួន២១នាក់ (ស្រី១៤នាក់) ត្រូវទាហានថៃនៅខេត្តស្រះកែវ និងនៅស្រុកតាប្រាយ៉ា ឃាត់ខ្លួនកាលពីរសៀលថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២១ ខណៈឆ្លងដែននៅតំបន់បាខៅលុច ឆាងវភូមិលេខ១៤ ឃុំតាប្រាយ៉ា ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ*។

តាមការសាកសួរ ពលករបានប្រាប់ថា ពួកគេបានឆ្លងដែន ដើរកាត់ផ្លូវព្រៃដោយបង់ថ្លៃ តាមការជូនរបស់មេខ្យល់ខ្មែរ និងថៃក្នុងបំណងប្រថុយប្រថាន ទៅធ្វើការស៊ីឈ្នួលនៅខេត្តឈុនបូរី និងខេត្តសាមុត្រប្រាកាន ភាគនិរតីប្រទេសថៃ។ កងកម្លាំង និងក្រុមគ្រូពេទ្យជួរមុខបាននាំពលករទៅបំពេញបែបបទ យកសំណាករកកូវីដ-១៩ ធ្វើចត្តាឡីស័កមុននឹងបញ្ជូនមកប្រទេសកម្ពុជាវិញ ៕

## ពលករខ្មែរ៤នាក់នឹងមេខ្យល់ជនជាតិខ្មែរម្នាក់ ត្រឡប់ចូលប្រទេសកម្ពុជាវិញត្រូវទាហានឈុតខ្មៅថៃឃាត់ខ្លួន

http://nokorwatnews.com/ 06/06/2021

ក្រុងប៉ោយប៉ែត៖ កម្លាំងទាហានឈុតខ្មៅអង្គភាពទី១២ ចាប់ឃុំខ្លួនពលករខ្មែរចំនួន៤នាក់ ព្រមទាំងមេខ្យល់ជនជាតិខ្មែរម្នាក់កាលពីវេលាម៉ោង១០នឹង២៤នាទី ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២១ អ្នកសារព័ត៌មានថៃរាយការណ៍ថា កម្លាំងទាហានកងវរយទី១២០៥ ចំណុះអង្គភាពទាហានឈុតខ្មៅទី១២ ស្រុកអារញ្ញ កងកម្លាំងបូរផា បានចាត់កម្លាំងដាក់ប៉ុស្តិ៍ត្រួតពិនិត្យភូណាំក្លៀង ភូមិ ភូ ណាំក្លៀង ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ បានប្រទះឃើញរថយន្តប៊ិកអាប់គួរឲ្យសង្ស័យមួយគ្រឿង ផ្ទុកសម្ភារផ្នែកខាងក្រោយរថយន្ត បើកមកតាមថ្នល់ជាតិលេខ3381 ផ្លូវភូមិ ប៉ារ៉ៃ-ភូណាំ ក្លៀង សំដៅទៅភូមិ ណូន ម៉ាកមុន ឃុំណូន ម៉ាកមុន ស្រុកគោកឃ្សូង ខេត្តស្រះកែវ ទើបសមត្ថកិច្ចហៅឲ្យឈប់ត្រួតពិនិត្យ ប្រទះឃើញអ្នកបើកតថយន្តជាជនជាតិខ្មែរម្នាក់ ព្រមទាំងពលករខ្មែរអង្គុយក្នុងរថយន្តចំនួន៤នាក់ ក្នុងនោះប្រុស២នាក់ និងស្រី២នាក់ សរុប៥នាក់ ទើបនាំខ្លួនមកសួរនាំនៅទីបញ្ជាការកងវរយទី១២០៥។ ក្រោយពីសួរនាំជំហានដំបូង មេខ្យល់ជាអ្នកបើកឡានជនជាតិខ្មែរ បានដឹកពលករខ្មែរទាំង៤នាក់មកពីផ្ទះជួល បរិវេណមជ្ឈមណ្ឌលពាណិជ្ជកម្ម ផារ៉ា ដាយផាក ក្រុងបាងកក ដើម្បីដឹកត្រឡប់ទៅប្រទេសកម្ពុជា ទើបសមត្ថកិច្ចឃុំខ្លួនពលករខ្មែរទាំងអស់ព្រមទាំងអ្នកបើកឡានជនជាតិខ្មែរនាំយកទៅសាកសួរនៅទីបញ្ជាការកងកម្លាំងបូរផា។

ពលករខ្មែរទាំងអស់ខាងលើ រួមមានឈ្មោះ នីក និវឌ្ឍ ប្រុស អាយុ៤២ឆ្នាំ ដែលជាមេខ្យល់ និងជាអ្នកបើកឡាន ,ព្រហ្ម សូរី ប្រុស អាយុ៣១ឆ្នាំ,កែវ ឆៃយ៉ា ប្រុស អាយុ២៥ឆ្នាំ, ព្រហ្ម ស៊ិលី ស្រី អាយុ២៨ឆ្នាំ,ព្រហ្ម ចិន្តា ស្រី អាយុ២០ឆ្នាំ អ្នកទាំងអស់មានទីលំនៅភូមិ បន្ទាយនាង ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដោយឈ្មោះ នីក និវឌ្ឍ អាយុ៤២ឆ្នាំ ដែលជាមេខ្យល់ និងជាអ្នកបើកឡាន មានលិខិតអនុញ្ញាតបើករថយន្ត ស៊ីឈ្នួលបើករថយន្តដឹកផ្លែឈើ នៅបរិវេណមជ្ឈមណ្ឌលពាណិជ្ជកម្មមួយកន្លែង នៅបាងកក ធ្វើការនៅប្រទេសថៃ បានប្រមាណជា២ឆ្នាំ ដោយមិនបានត្រឡប់ទៅផ្ទះ ស្នាក់នៅផ្ទះជួលជាមួយញាតិ៤នាក់ទៀត បើករថយន្តថៅកែមក កាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២១ពេលព្រឹក បានទទួលការទាក់ទងពីក្រុមរបស់ឈ្មោះ ព្រហ្ម សូរី ដែលជាប្អូនប្រុស ស្នាក់នៅផ្ទះជួលជាមួយគ្នា ថា ចង់ត្រឡប់ទៅផ្ទះនៅកម្ពុជា ដោយសារតែហាងលក់អាហារត្រូវបិទ ហើយថៅកែមិនជួលបន្ទប់ឲ្យទើបសម្រេចចិត្តមកស្រុកកំណើតវិញ ៕

## សម្តេចក្រឡាហោម និងឯកអគ្គរដ្ឋទូតអាមេរិក វាយតម្លៃចំពោះកិច្ចសហប្រតិបត្តិការល្អលើការងារប្រយុទ្ធប្រឆាំងបទល្មើស ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://cen-news.com/ Posted ByPen Srey Neat June 8, 2021

ភ្នំពេញ ៖ នៅរសៀលថ្ងៃចន្ទ ទី៧ ខែមិថុនា ឆ្នាំ២០២១នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតជូនឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជាចូលជួបពិភាក្សាការងារនៅទីស្តីការក្រសួងមហាផ្ទៃ។ ជាកិច្ចចាប់ផ្តើមនៃជំនួបនោះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក បានកត់សំគាល់ និងវាយតម្លៃខ្ពស់ចំពោះដំណើរទស្សនកិច្ចរបស់លោកជំទាវអនុរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកមកកាន់កម្ពុជាកាលពីពេលថ្មីៗនេះ។ ក្នុងនោះដែរ សម្តេចក្រឡាហោមបានមានប្រសាសន៍ថា តាមរយៈទស្សនកិច្ចនេះដ៏មានសារៈសំខាន់នេះ នឹងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងមិត្តភាពរវាងប្រទេសទាំងពីរកាន់តែខ្លាំងក្លាយថែមទៀត។ ជាមួយគ្នានេះ សម្តេចក្រឡាហោម ក៏បានថ្លែងអំណរគុណតាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូត ជូនចំពោះរដ្ឋាភិបាលអាមេរិកដែលបានផ្តល់ការគាំទ្រដល់ការងារជួយប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នៅកម្ពុជា។

នៅលើវិស័យអនុវត្តច្បាប់វិញ សម្តេចក្រឡាហោម និងឯកឧត្តមឯកអគ្គរដ្ឋទូតអាមេរិក សុទ្ធតែបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការល្អលើការងារប្រយុទ្ធប្រឆាំងបទល្មើស ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេស កិច្ចគាំពារកុមារ និងការអនុវត្តតាមសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ។ ចំពោះការអនុវត្តតាមសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិនេះ សម្តេចបានមានប្រសាសន៍ថាប្រទេសកម្ពុជាតែងតែអនុវត្តយ៉ាងខ្ជាប់ខ្ជួនបន្ទុកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួន ក្នុងការអនុវត្តនូវសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិទៅលើកិច្ចការនានា ជាពិសេសពាក់ព័ន្ធនឹងក្រុមប្រឹក្សាសន្តិសុខ។ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការលើការងារពាក់ព័ន្ធវិស័យបរិស្ថាន ឯកឧត្តមឯកអគ្គរដ្ឋទូតអាមេរិក បានជម្រាបជូនសម្តេចក្រឡាហោមដថា បច្ចុប្បន្ននេះ មានគម្រោងមួយចំនួនពាក់ព័ន្ធនឹងការងារបរិស្ថានកំពុងដំណើរការនៅកម្ពុជា ក្រោមការជួយគាំទ្ររបស់សហរដ្ឋអាមេរិក ហើយឯកឧត្តមចង់ឃើញវឌ្ឍនភាពបន្តរីកចំរើនលើការងារទាំងនោះពាក់ព័ន្ធនឹងវិស័យបរិស្ថាននេះ។

សម្តេចក្រឡាហោមបានមានប្រសាសន៍ថា ក្រៅពីការងារពង្រឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ភាគីទាំងពីរក៏អាចកំណត់នូវវិស័យផ្សេងៗទៀត សម្រាប់ពង្រីកកិច្ចសហប្រតិបត្តិការជាមួយគ្នា ហើយនៅក្នុងវិស័យបរិស្ថាននេះ សម្តេចបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាតែងតែគិតគូ និងផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការថ្លឹងថ្លែងអំពីការអភិវឌ្ឍ និងផលប៉ះពាល់ទៅលើបញ្ហាបរិស្ថាន។ សម្តេចក្រឡាហោមក៏បានមានប្រសាសន៍ថា សម្តេចផ្ទាល់តែងតែផ្តល់ការលើកទឹកចិត្តដល់អាជ្ញាធរពាក់ព័ន្ធ ជាពិសេសអាជ្ញាធរនៅមូលដ្ឋានឱ្យបន្តកិច្ចសហប្រតិបត្តិការ

ក្នុងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាប្រឈមនានា និងរួមគ្នាបំរើផលប្រយោជន៍រួម។ សម្ដេចបានបន្ថែមថា រាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានតែងតែចាត់ទុកអ្នកធ្វើការងារផ្នែកបរិស្ថានជាដៃគូ និងតែងតែលើកទឹកចិត្តអ្នកធ្វើការងារពាក់ព័ន្ធនឹងបញ្ហានេះ ចាត់ទុកគ្នាជាដៃគូទៅវិញទៅមក ដើម្បីដោះស្រាយបញ្ហារួមជាមួយគ្នា។ នាឱកាសនោះដែរ សម្តេចក្រឡាហោម ក៏បានសង្កត់ធ្ងន់ដែរថា កន្លងមកក៏មានសកម្មភាពមួយចំនួនដែលបានធ្វើឡើងក្រោមហេតុផលនៃសកម្មភាពការពារបរិស្ថាន ប៉ុន្តែមានចេតនាបង្កបញ្ហាអសន្តិសុខ ប៉ះពាល់សណ្តាប់សាធារណៈ ដែលសកម្មភាពទាំងនោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែមានវិធានការសមស្របទៅតាមច្បាប់៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ឯកអគ្គរដ្ឋទូតអាមេរិក បង្ហាញការប្តេជ្ញាចិត្តចំពោះមុខសម្តេចក្រឡាហោម ស ខេង ក្នុងការពង្រឹងការធ្វើការជាមួយភាគីពាក់ព័ន្ធកម្ពុជាឡើងវិញ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១

(ភ្នំពេញ)៖ ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា នៅថ្ងៃទី៧ ខែមិថុនាបានឲ្យដឹងថា លោកឯកអគ្គរដ្ឋទូត W. Patrick Murphy បានជួបសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងពិភាក្សាពីកិច្ចខិតខំក្នុងកិច្ចសហប្រតិបត្តិការ ដែលរក្សាឱ្យកម្ពុជា និងសហរដ្ឋអាមេរិកមានសុវត្ថិភាព រួមបញ្ចូលទាំងការអនុវត្តនូវទណ្ឌកម្មនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ប្រឆាំងនឹងប្រទេសកូរ៉េខាងជើង និងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ។

បើតាមស្ថានទូតសហរដ្ឋអាមេរិក លោកឯកអគ្គរដ្ឋទូត បានបញ្ជាក់ពីការពង្រឹងឡើងវិញ នូវការប្តេជ្ញាចិត្តសហរដ្ឋអាមេរិកក្នុងការធ្វើការជាមួយភាគីពាក់ព័ន្ធកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ ការជួញដូរមនុស្ស ប៉ះពាល់ដល់ប្រជាជននៅគ្រប់ប្រទេសលើផែនដីនេះ ហើយសហរដ្ឋអាមេរិក ជំរុញនូវកិច្ចខិតខំយ៉ាងខ្លាំងថែមទៀត នៅប្រទេសកម្ពុជា ក្នុងការកាត់ទោសអ្នកជួញដូរ ការពារជនរងគ្រោះ និងបង្ការកុំឱ្យមានឧក្រិដ្ឋកម្មជួញដូរមនុស្ស។ ជាមួយគ្នានេះ លោកឯកអគ្គរដ្ឋទូត ក៏បង្ហាញនូវកង្វល់ជាខ្លាំង ជូនចំពោះលោករដ្ឋមន្ត្រី អំពីការកាត់ទោសដាក់ពន្ធនាគារ នូវសកម្មជនបរិស្ថានមួយចំនួន។ យើងអំពាវនាវឱ្យមានការដោះលែង។ សេរីភាពបញ្ចេញមតិ គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។ លោកឯកអគ្គរដ្ឋទូតបានបន្តថា ការហ៊ាននិយាយដើម្បីការពារបរិស្ថាន ដែលប្រឈមនឹងការគំរាមកំហែង ដោយសារការកាប់ឈើខុសច្បាប់ និងកេងយកប្រយោជន៍ពាណិជ្ជកម្ម គឺជារឿងគួរឱ្យសរសើរទៅវិញទេ។ ការគោរពនូវសិទ្ធិសេរីភាពជាមូលដ្ឋាន អាចជួយធានានូវអនាគតមួយដែលប្រកបដោយសុខសន្តិភាព វិបុលភាព មានអធិបតេយ្យ និងប្រជាធិបតេយ្យ សម្រាប់ប្រទេសកម្ពុជា៕

# ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៩នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអង្គារ ទី០៨ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦និង០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ

និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៩នាក់ ស្រី ២៦នាក់ ក្នុងនោះកុមារ ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១០នាក់ ស្រី ៥នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៤៨នាក់ ស្រី ២១នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥៩នាក់ ស្រី ២៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអរសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ឧត្តរមានជ័យរកឃើញករណីឆ្លងថ្មីចំនួន ១៣ ករណីលើពលករចំណាកស្រុក

https://www.khmertimeskh.com/ June 8, 2021 ខ្មែរថាមស៍

រដ្ឋបាលខេត្តឧត្តរមានជ័យនៅថ្ងៃទី៧ ខែមិថុនានេះបានចេញសេចក្តីប្រកាសព័ត៌មានស្តីពីការធ្វើរោគវិនិច្ឆ័យករណីកូវីដ-១៩ថ្មីចំនួន ១៣ ករណីបន្ថែមទៀត។ ករណីទាំងនេះត្រូវបានរកឃើញលើពលករខ្មែរដែលត្រឡប់មកពីប្រទេសថៃ។ ពួកគេក៏បានប្រកាសពីការជាសះស្បើយនៃអ្នកជំងឺចំនួនពីរនាក់ផងដែរ។ នៅថ្ងៃទី ៧ ខែមិថុនាឆ្នាំ ២០២១ រដ្ឋបាលខេត្តឧត្តរមានជ័យបានរាយការណ៍ថាមានករណីថសរុបចំនួន ៩០ ករណីនៅទូទាំងខេត្ត និង អ្នកជាសះស្បើយចំនួន ២៤ នាក់ ខណៈអ្នកកំពុងសំរាកព្យាបាលចំនួន ៦៦ នាក់៕

## អូស្ត្រាលីធ្វើការជាមួយកម្ពុជា ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់អំពើហិង្សាលើស្ត្រី

https://cen-news.com/ Posted ByPen Srey Neat June 8, 2021

ភ្នំពេញ ៖ កាលពីសប្តាហ៍មុន ឯកអគ្គរាជទូតអូស្ត្រាលី Pablo Kang រួមជាមួយ លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានចូលរួមតាមអ៊ីនធឺណេតក្នុងពិធីអបអរដល់មន្ត្រីចំនួន ៤១នាក់ របស់ក្រសួងកិច្ចការនារីដែលបានបញ្ចប់កម្មវិធីបណ្តុះបណ្តាលស្តីពីវិធីអនុវត្តច្បាប់ដើម្បីទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។ វគ្គបណ្តុះបណ្តាលនេះ ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS ។ ការលើកកម្ពស់សមភាពយេនឌ័រ និងការលុបបំបាត់រាល់ទម្រង់ នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី គឺជាចំណុចសំខាន់នៃរបៀបវារៈរបស់រដ្ឋាភិបាលអូស្ត្រាលី ទាំងនៅក្នុងប្រទេសនិងអន្តរជាតិ។ សូមអបអរដល់សិក្ខាកាមទាំងអស់ នេះគឺជាសមិទ្ធផលអាជីពដ៏អស្ចារ្យមួយ សម្រាប់អ្នកទាំងអស់គ្នា។

លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានចូលរួមក្នុងពិធីបិទវគ្គបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងក្របខណ្ឌគតិយុត្តពាក់ព័ន្ធ តាមរយៈប្រព័ន្ធអនឡាញ ដោយមានការចូលរួមពីឯកឧត្តម Pablo Kang អគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា លោកមេធាវី សុក សំអឿន។ ឆ្លៀតក្នុងឱកាសនេះផងដែរ លោកជំទាវក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ឯកឧត្តម ឯកអគ្គរដ្ឋទូតអូស្ត្រាលី និងក្រុមការងារកម្មវិធី ACCESS ដែលបានផ្តល់ការគាំទ្រទាំងផ្នែកមធ្យោបាយបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការពិនិត្យឡើងវិញលើសេចក្តីពន្យល់ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

និងកិច្ចការពារជនរងគ្រោះ និងការរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់នេះ ។ ក្រុមការងារនាយកដ្ឋានការពារផ្លូវច្បាប់ក្រោមការដឹកនាំរបស់លោកជំទាវ ហ៊ូ សាមិត្ត ដែលបានផ្តួចផ្តើមគំនិតឱ្យមានកម្មវិធីនេះឡើង។

លោកមេធាវី សុក សំអឿនដែលមួយរយៈកន្លងទៅនេះ បានជួយដល់ក្រសួងកិច្ចការនារី លើការពិនិត្យឡើងវិញលើសេចក្តីពន្យល់ច្បាប់ស្តីអំពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ព្រមទាំងបានខិតខំចែករំលែកនូវចំណេះដឹង បទពិសោធន៍ ដោយផ្សាភ្ជាប់នឹងករណីជាក់ស្តែង ដើម្បីឱ្យសិក្ខាកាមទាំងអស់ងាយយល់ ងាយចាំ និងមានមូលដ្ឋានវិភាគត្រឹមត្រូវ ទាក់ទងនឹងខ្លឹមសារច្បាប់ពាក់ព័ន្ធដែលទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី រួមទាំងបច្ចេកទេស ក្នុងការផ្តល់កិច្ចការពារជូនជនរងគ្រោះ ហើយ ខ្ញុំជឿជាក់ថា សិក្ខាកាមទាំងអស់ នឹងយកចំណេះដឹងនិងបទពិសោធន៍ថ្មីៗដែលទទួលបានពីវគ្គបណ្តុះបណ្តាលនេះ ទៅអនុវត្តក្នុងការបំពេញការងារប្រចាំថ្ងៃរបស់ខ្លួនប្រកបដោយសមត្ថភាព និងការទទួលខុសត្រូវខ្ពស់។ ក្នុងគោលបំណងអភិវឌ្ឍន៍សមត្ថភាពផ្នែកច្បាប់ដល់មន្ត្រីរបស់ក្រសួងកិច្ចការនារី ជាពិសេសមន្ត្រីនៃនាយកដ្ឋានការពារផ្លូវច្បាប់ ដែលមានតួនាទីសម្របសម្រួល និងផ្តល់ការគាំទ្រដល់មន្ទីរកិច្ចការនារី ក្នុងការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាពិសេសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឱ្យកាន់តែមានប្រសិទ្ធភាព គុណភាព និងប្រកបដោយបរិយាបន្ន៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ថៃបន្តពេលវេលាធ្វើតេស្តកូវីដដល់ពលករមកពី៣ប្រទេសមានទាំងកម្ពុជាផង

https://www.kampucheathmey.com/ ថ្ងៃពុធ ៩ មិថុនា ២០២១ ដោយ chean virakbot

ទីស្តីការគណៈរដ្ឋមន្ត្រីថៃបានសម្រេចពន្រឹកពេលវេលានៃការធ្វើកូវីដ-១៩ដល់ពលករអន្តោប្រវេសន៍មកពី៣ប្រទេសរយៈពេល៣ខែបន្ថែមទៀតរហូតដល់ថ្ងៃទី១៣ ខែកញ្ញា ដោយសារបុគ្គលិកសុខាភិបាលរវល់ធ្វើតេស្តគ្មានពេលសម្រាក។

អ្នកនាំពាក្យរដ្ឋាភិបាលថៃ អ្នកនាង Ratchada Dhanadirek បាននិយាយល្ងាចថ្ងៃអង្គារ៍ថា គណៈរដ្ឋមន្ត្រីបានយល់ព្រមបន្តពេលវេលាចាប់ពីថ្ងៃទី១៦ ខែមិថុនានេះទៅមុខទៀត ដូច្នេះពលករចំណាកស្រុកអាចដាក់ពាក្យស្នើសុំធានារ៉ាប់រងសុខភាព និងច្បាប់អនុញ្ញាតធ្វើការងារ។ គណៈរដ្ឋមន្ត្រីថៃក៏បានអនុញ្ញាតឲ្យពលករចំណាកស្រុកចំនួន៥៣៨០០នាក់ ដែលបានចុះឈ្មោះសម្រាប់ភាពអត់ការងារធ្វើឲ្យបំពេញព័ត៌មានផ្ទាល់ខ្លួនក្នុងទម្រង់ Tor Ror 38/1 និងដាក់ពាក្យស្នើសុំប័ណ្ណពណ៌ផ្កាឈូក ឬច្បាប់ធ្វើការបណ្តោះអាសន្នត្រឹមថ្ងៃ៣១ ខែមីនា ឆ្នាំ២០២២ ដែលកាលបរិច្ឆេទកំណត់កន្លងមកគឺត្រឹមថ្ងៃទី១៦ ខែមិថុនានេះ។ នារីនាំពាក្យបាននិយាយថា ការពន្រឹកពេលវេលានឹងអនុញ្ញាតឲ្យពលករចំណាកស្រុកស្នាក់នៅ និងធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសថៃដោយមិនចាំបាច់បង្កើនបន្ទុកដល់បុគ្គលិកសុខាភិបាល។ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំមុន គណៈរដ្ឋមន្ត្រីបានអនុញ្ញាតពលករចំណាកស្រុកមកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ស្នាក់ និងធ្វើការស្របច្បាប់នៅក្នុងប្រទេសថៃដោយករណីពិសេសកំឡុងពេលការផ្ទុះកូវីដ-១៩។ ដើម្បីធ្វើបានដូច្នេះ ពួកគេតម្រូវឲ្យផ្តល់ដំណឹងទៅមន្ត្រីអន្តោប្រវេសន៍ដើម្បីប្រមូលទិន្នន័យជីវមាត្រ និងដាក់ពាក្យស្នើសុំធានារ៉ាប់រងសុខភាព និងច្បាប់អនុញ្ញាតធ្វើការត្រឹមថ្ងៃទី១៦ ខែមិថុនា។

នារីនាំពាក្យបានឲ្យដឹងថា ក្នុងរយៈពេលប៉ុន្មានខែកន្លងទៅនេះ ពលករអន្តោប្រវេសន៍ចំនួន ៦៥៤ ០០០ នាក់បានចុះឈ្មោះ និងចូលក្នុងដំណើរការនេះ។ ក្នុងចំណោមពួកគាត់ មាន ៦០១ ០០០នាក់បានចុះឈ្មោះស្វែងរកការងារធ្វើ។ បន្ទាប់ពីធ្វើការត្រួតពិនិត្យរួច មានប្រហែល ៤៩៦ ០០០នាក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការអនុញ្ញាតច្បាប់ធ្វើការ។ ត្រឹមថ្ងៃទី៣១ ខែឧសភា ៩៨%នៃពួកគេ ឬស្មើនឹង ៤៨៥ ០០០នាក់ ទិន្នន័យជីវមាត្ររបស់ពួកគេត្រូវបានប្រមូលដោយការិយាល័យអន្តោប្រវេសន៍ ប៉ុន្តែមានតែ៧០%ប៉ុណ្ណោះដែលបានទៅធ្វើតេស្តកូវីដ-១៩នៅក្រសួងសុខាភិបាលថៃ។ មានតែ៥០%នៃពួកគេ ឬស្មើ ២៣៩ ០០០នាក់ ដែលបានបំពេញគ្រប់លក្ខខណ្ឌ និងទទួលបានច្បាប់អនុញ្ញាតធ្វើការពីក្រសួងការងារ។ នៅពេលប្រទេសថៃកំពុងទទួលរងការ

វាយប្រហារពីកូវីដ-១៩ បុគ្គលិកសុខាភិបាលថៃ និងមន្ទីរពេទ្យមិនអាចបញ្ចប់ការធ្វើតេស្តកូវីដ-១៩ដល់ពលករអន្តោប្រវេសន៍តាមកាលបរិច្ឆេទកំណត់ត្រឹមថ្ងៃទី១៦ ខែមិថុនានេះបានទេ។ ដូច្នេះ ការធ្វើតេស្តកូវីដ-១៩ដល់ពលករអន្តោប្រវេសន៍ត្រូវពន្យារពេលដល់ថ្ងៃទី១៣ ខែកញ្ញា៕ ប្រែសម្រួល៖ វីរបុត្រ

## ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១

### ការសម្រេចចិត្តរបស់បងប្អូនជាពលករ គឺនៅតែមិនខ្លាចពីគ្រោះថ្នាក់ ជាក់ស្តែង លួចឆ្លងដែនទាំងយប់

https://kohsantepheapdaily.com.kh/ Banteay Meanchey ០៩ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ០៩:៥២

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងប៉ុស្តិ៍សង្កែនៃនគរបាលការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាវរៈ៥១១ប្រចាំនៅបន្ទាត់ព្រំដែនស្រុកម៉ាឡៃបានពួនស្ទាក់ឃាត់ខ្លួនពលករ១៥នាក់ ដែលប្រុងលួចឆ្លងដែនទៅប្រទេសថៃខុសច្បាប់ និងឃាត់បានទាំងជនសង្ស័យជាអ្នកជូនផ្លូវម្នាក់ផងដែរ។

ហេតុការណ៍ខាងលើ បានកើតឡើងកាលពីម៉ោង០៤ និង៣០នាទីព្រឹកថ្ងៃទី៩ មិថុនា នេះ ក្នុងភូមិសង្កែឃុំបឹងបេងស្រុកម៉ាឡៃ។ ពលករទាំង១៥នាក់ មានស្រី៨នាក់ កុមារ២នាក់ ដោយពួកគេមកពីខេត្តចំនួន៤ រួមមានបាត់ដំបង៨នាក់, កំពង់ធំ៤នាក់, ព្រៃវែង២នាក់ និងបន្ទាយមានជ័យ១នាក់។ ក្នុងនោះ សមត្ថកិច្ចក៏បានឃាត់ខ្លួនជនសង្ស័យជាអ្នកជូនផ្លូវម្នាក់ផងដែរ គឺឈ្មោះយឿន ណារ៉ុង ភេទប្រុស អាយុ២០ឆ្នាំ មានទីលំនៅក្នុងឃុំស្រុកកើតហេតុខាងលើ។

លោកវរសេនីយ៍ សួង សៅ មេបញ្ជាការនគរបាលការពារព្រំដែនគោកលេខ៨១៥ ប្រាប់តាមទូរស័ព្ទថា ការឃាត់ខ្លួនពលករ និងជនសង្ស័យខាងលើបាន គឺខណៈកម្លាំងប៉ុស្តិសង្កែរបស់លោកសហការជាមួយកម្លាំងយោធាវរៈ៥១១ ពិសេសអនុវត្តតាមបទបញ្ជាឲ្យទប់ស្កាត់រាល់បទល្មើសពីលោកឧត្តមសេនីយ៍ទោ សិទ្ធ ឡោះ ស្នងការដ្ឋាននគរបាលខេត្តតែម្តង។ ពលករទាំង១៥នាក់ រួមទាំងជនសង្ស័យជាអ្នកជូនផ្លូវត្រូវបានកម្លាំងជួរមុខធ្វើការប្រគល់ឲ្យខាងកម្លាំងជំនាញនៃអធិការដ្ឋាននគរបាលស្រុកម៉ាឡៃនៅព្រឹកថ្ងៃដដែល ដើម្បីចាត់ការបន្តតាមនិតិវិធីច្បាប់ ៕

### សមត្ថកិច្ចចម្រុះ ឃាត់ខ្លួនពលករខ្មែរ២០នាក់ និងមេខ្យល់១នាក់ បម្រុងឆ្លងដែនខុសច្បាប់ទៅថៃ

https://cen-news.com/ Posted ByPen Srey Neat June 9, 2021

បន្ទាយមានជ័យ ៖ អគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញផ្សាយព័ត៌មានថា កងកម្លាំងនគរបាល និងយោធាឈរជើងយាមប្រចាំការនៅតាមខ្សែបន្ទាត់ព្រំដែន បានឃាត់ខ្លួនពលរដ្ឋខ្មែរប្រុស ស្រី ចំនួន២០នាក់ និងមេខ្យល់១នាក់ នៅចំណុច២ទីតាំងផ្សេងគ្នា គឺនៅស្រុកម៉ាឡៃ និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ខណៈពួកគេបម្រុងឆ្លងដែនចូលទៅប្រទេសថៃ ។

យោងតាមរបាយការណ៍ របស់វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង៤ និង៣០នាទីព្រឹក កម្លាំងនគរបាលការពារព្រំដែនគោក និងកម្លាំងនគរបាលប៉ុស្តិ៍សង្កែ សហការជាមួយកម្លាំងកងពលតូចលេខ៥១ បានទប់ស្កាត់ប្រជាពលរដ្ឋបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃចំនួន ១៥នាក់ (ស្រី០៨នាក់ កុមារ០២នាក់) នៅក្នុងភូមិសាស្ត្រឃុំបឹងបេង ស្រុកម៉ាឡៃ ។ ក្នុងនោះឃាត់ខ្លួនអ្នកនាំផ្លូវ ១នាក់ ឈ្មោះ យឿន ណារ៉ុង ភេទប្រុស អាយុ ២០ឆ្នាំ មានទីលំនៅក្នុងភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោក

លេខ៨១៥ បានបញ្ជាក់ថា ក្រោយពីធ្វើការឃាត់ខ្លួន កម្លាំងបានប្រគល់ឲ្យកម្លាំងជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីសួរនាំ និងចាត់វិធានការបន្ត។

ដោយឡែក នៅស្រុកស្វាយចេក កម្លាំងនគរបាលអធិការដ្ឋាននគរបាលស្រុកស្វាយចេក និងកម្លាំងនគរបាលការពារព្រំដែនគោកប៉ុស្តិ៍ថ្នល់បំបែក នៃវរសេនាតូចការពារព្រំដែនគោកលេខ៩១១ បានសហការជាមួយកម្លាំងយោធា៥០៣ និងកម្លាំងកងពលតូចថ្មើរជើងលេខ៥១ នៅវេលាម៉ោង១១ព្រឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ បានដើរល្បាតក្នុងភូមិសាស្រ្តភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក បានឃាត់ខ្លួនពលរដ្ឋខ្មែរ ចំនួន៥នាក់ (ស្រី២នាក់ ក្នុងនោះកុមារតូចអាយុ៣ឆ្នាំ១នាក់) បម្រុងលួច ឆ្លងដែនទៅប្រទេសថៃ ។ បន្ទាប់ពីឃាត់ខ្លួន និងសួរនាំ កម្លាំងបានបញ្ជូនទៅទីសំចត នៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ដើម្បីចាត់ការបន្ត ៕រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៦នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃពុធ ទី០៩ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៦នាក់ ស្រី ១៩នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១២នាក់ ស្រី ៥នាក់ កុមារា ១នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៧នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ២នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៦នាក់ ស្រី ១១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៦នាក់ ស្រី ១៩នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## មន្ត្រីសង្គមស៊ីវិល ស្នើសមត្ថកិច្ចមូលដ្ឋានឱ្យចុះអប់រំប្រជាពលរដ្ឋ ដើម្បីទប់ស្កាត់កុំឱ្យឆ្លងដែនខុសច្បាប់ទៅប្រទេសជិតខាង

https://www.rfa.org/khmer/ ដោយ ហេង វស្នី 2021-06-09

អ្នកសម្របសម្រួលសមាគមអាដហុក ប្រចាំខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា ស្នើឱ្យអាជ្ញាធរមូលដ្ឋានបន្តចុះអប់រំដល់ប្រជាពលរដ្ឋ ជាពិសេស នៅតាមខេត្តជាប់ព្រំដែនប្រទេសថៃ ដើម្បីទប់ស្កាត់ការនាំពលករឆ្លងដែនដោយខុសច្បាប់ទៅក្រៅប្រទេស។ លោកបន្តថា ពលករខ្មែរ ដែលមានជីវភាពលំបាក នៅតែបន្តឆ្លងដែនទៅប្រទេស

ថៃ បើទោះបីជាពួកគាត់ដឹងថា មានគ្រោះថ្នាក់ និងប្រឈមនៃការឆ្លងជំងឺកូវីដ១៩ ក៏ដោយ។ លោកថា ប្រសិនបើអាជ្ញាធរមូលដ្ឋាន ចុះអប់រំដល់ប្រជាពលរដ្ឋពីបញ្ហាទាំងនេះ ប្រហែលជាអាចទប់ស្កាត់ការឆ្លងដែនបានខ្លះដែរ៖ «អ្វីដែលសំខាន់ពីមុនមកឃើញខាងអង្គការសង្គមស៊ីវិល ក្រសួងកិច្ចការនារី និងមន្ត្រីរដ្ឋាភិបាលចុះទៅណែនាំ។ ប៉ុន្តែកន្លងមកដល់សម័យកូវីដ នេះអត់មានការណែនាំអ្វីទេ ឱ្យតែឆ្លងដែនគឺចាប់តែម្តង។ ពីមុនមករកឃើញពាក់ព័ន្ធ អ្នកដែលមេខ្យល់នាំឆ្លងដែន គឺពិបាករកណាស់។ មូលហេតុអ្វី គឺដោយសារអ្នកដែននាំឆ្លងដែន នៅកន្លែងហ្នឹងមានខាងយោធា បោះតង់ជួយមើលផ្លូវទៀត»។ សមត្ថកិច្ចខេត្តបន្ទាយមានជ័យនៅថ្ងៃទី៩ មិថុនា បានឃាត់ខ្លួនមេខ្យល់ម្នាក់ទៀតក្រោយពីបាននាំពលករចំនួន១៥នាក់ ឆ្លងដែនដោយខុសច្បាប់ទៅធ្វើការនៅប្រទេសថៃតាមច្រកព្រំដែនស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទង មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក ៨១៥ លោក សួង សៅ បានទេ ដោយទូរស័ព្ទហៅចូលហើយ តែលោកនិយាយថា ស្តាប់មិនឮ។ ចំណែកស្នងការប៉ូលិសខេត្តបន្ទាយមានជ័យ លោក សិទ្ធិ ឡោះ ថា លោកកំពុងស្រាវជ្រាវករណីនេះសិន។

តុលាការខេត្តបន្ទាយមានជ័យ កាលពីខែឧសភា បានសម្រេចឃុំខ្លួនមេខ្យល់ ៣នាក់ នៅក្នុងពន្ធនាគារខេត្ត បន្ទាប់ពីសមត្ថកិច្ចចាប់ខ្លួនបានកាលពីយប់ថ្ងៃទី២២ ឧសភា នៅសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ក្នុងពេលដែលពួកគេកំពុង នាំពលករឆ្លងដែនដោយខុសច្បាប់ចំនួន ១០នាក់ទៅប្រទេសថៃ៕

## ពលករខ្មែរចំនួន ២១នាក់ ត្រូវទាហានថៃចាប់ខ្លួន ក្នុងពេលលបឆ្លងដែនចូលទឹកដីថៃខុសច្បាប់

https://l.facebook.com/Fneakmeasnews.com ចេញផ្សាយថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ដោយ ជីវ័ន្ត

ប្រទេសថៃ ៖ ពលករខ្មែរដែលត្រូវមេខ្យល់បោះបង់ចោលក្នុងព្រៃ ចំនួន ២១ នាក់ ត្រូវបានទាហានព្រំដែនថៃចាប់ខ្លួន ដោយមិនអនុញ្ញាតអោយចូលទៅក្នុងទឹកដីថៃឡើយ បន្ទាប់ពីពលករទាំងនេះបម្រុងឆ្លងចូលទៅរកការងារធ្វើនាវេជ្ជកូវីដ ១៩ កំពុងវាយលុកខ្លាំងនៅក្នុងប្រទេសថៃ ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីល្ងាចថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២០២១ ត្រង់ចំណុចកូនដំរី ក្នុងឃុំតាផាយ៉ា ស្រុកតាផាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ ដោយពលករខ្មែរសរុបមានចំនួន ២១ នាក់ ក្នុងនោះមាន ប្រុស៧ នាក់ ស្រី ១៤ នាក់ ។ ពួកគេបានសារភាពថា ការឆ្លងចូលទៅក្នុងទឹកដីថៃតាមច្រករបៀងនេះ គឺមានមេខ្យល់ជាអ្នកនាំមុខ ប៉ុន្តែក្រោយពីដឹងថាមានទាហានថៃនៅខាងមុខ មេខ្យល់ក៏បានគេខ្លួនបាត់ស្រមោល ដោយបោះបង់ពួកគេអោយនៅក្នុងព្រៃ មិនដឹងទៅខាងណា ទើបត្រូវថៃឃាត់ខ្លួនតែម្តង។ ទិសដៅដែលពួកគេទៅ គឺបម្រុងទៅរកការងារធ្វើនៅក្នុងខេត្ត ឈុនបុរី និងខេត្ត សមុទ្រប្រាកាន ។ ក្រោយពីបានត្រួតពិនិត្យកម្តៅរួចមក ភាគីថៃសម្រេចបញ្ជូនពលករទាំង២១ នាក់ មកកម្ពុជាវិញ តាមច្រកអូរបីជាន់ខេត្តបន្ទាយមានជ័យ ៕

# ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១

## សម្តេច ស ខេង បញ្ជាឲ្យអភិបាលខេត្តជាប់ព្រំដែនវៀតណាម ពង្រឹងការបង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់

https://thmeythmey.com/ 10, Jun 2021 , 9:29 pm

ភ្នំពេញ៖ សម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាឲ្យអភិបាលខេត្តជាប់ព្រំដែនវៀតណាម បង្កើនការត្រួតពិនិត្យការចេញ-ចូលនៅច្រកព្រំដែន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងការឆ្លងដែនខុសច្បាប់។ សម្តេច ស ខេង បានចេញលលិខិតជម្រាបទៅអភិបាលខេត្តជាប់ព្រំដែនវៀតណាម នៅថ្ងៃទី៩ មិថុនានេះ ឲ្យរៀបចំកិច្ចប្រជុំដោយផ្ទាល់ ឬតាមប្រព័ន្ធវីដេអូជាមួយអាជ្ញាធរប្រទេសទាំងពីរ ដើម្បីពិភាក្សាការអនុវត្តវិធានការទប់ស្កាត់កូវី

ដ-១៩។ ការធ្វើបែបនេះ គឺដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពតាមតំបន់ព្រំដែន។ លើសពីនេះ គឺទប់ស្កាត់និងបង្ក្រាបបទល្មើសនាំមនុស្សឆ្លងដែនខុសច្បាប់។ ជាមួយគ្នានេះ សម្តេច ស ខេង ជំរុញឲ្យរៀបចំកិច្ចពិភាក្សាគ្នារវាងអាជ្ញាធរកម្ពុជា និងវៀតណាម ដើម្បីសម្រួលដល់ការផ្លាស់ប្តូរទំនិញកសិផល គ្រឿងឧបភោគបរិភោគ នៅក្នុងជីវភាពរស់នៅប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះ សម្តេច ស ខេង បានប្រាប់អភិបាលខេត្តជាប់ព្រំដែនធ្ងន់ៗថា៖ «ត្រូវពង្រឹងអនុវត្តឲ្យបានតឹងរ៉ឹងនិងម៉ឺងម៉ាត់នូវវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនដោយខុសច្បាប់ឲ្យមានប្រសិទ្ធភាព»។ សម្តេច ស ខេង ក៏បានជំរុញឲ្យបន្តការអប់រំនិងផ្សព្វផ្សាយ ដល់សាធារណជនតាមមូលដ្ឋានរបស់ខ្លួន ឲ្យបង្កើនការប្រុងប្រយ័ត្ន តាមវិធានការក្រសួងសុខាភិបាលផងដែរ។

## ពលរដ្ឋនៅស្រុកស្រីស្នំ សំណូមពរដល់សមត្ថកិច្ចឲ្យបង្កើនការផ្សព្វផ្សាយអំពីរូបភាពនៃការជួញដូរមនុស្ស និងការរំលោភបំពានលើកុមារ ខណៈមន្ត្រីលើកទឹកចិត្តឲ្យពលរដ្ឋត្រូវតែហ៊ានរាយការណ៍ពីករណីជួញដូរមនុស្សនៅពេលដែលខ្លួនបានឃើញ និងបានដឹង

https://www.facebook.com/pdisiemreap/ 10/06/2021

មានមតិក្នុងកម្មវិធីយើងធ្វើបាន របស់វិទ្យុ និងទូរទស្សន៍ជាតិខេត្ត នៃមន្ទីរព័ត៌មានខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ ម្សិលមិញនេះ អ្នកស្រី វ៉ង់ ជាប្រជាពលរដ្ឋម្នាក់ រស់នៅក្នុងឃុំមោង ស្រុកស្រីស្នំ បានលើកឡើងថា រយៈកាលកន្លងមក អ្នកស្រីក៏ធ្លាប់បានឃើញការផ្សព្វផ្សាយអំពីអំពើជួញដូរមនុស្សដែរ តាមរយៈបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក ប៉ុន្តែចំពោះករណីនេះ អ្នកស្រីមិនដែលបានដឹងថា បានកើតមាននៅក្នុងមូលដ្ឋានរបស់អ្នកស្រីកំពុងរស់នៅដែរ តែទោះជាយ៉ាងនេះក៏ដោយ ក្នុងឱកាសនេះ សូមសំណូមពរឲ្យអាជ្ញាធរពាក់ព័ន្ធបង្កើនការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ជាពិសេសរូបភាពនៃការជួយដូរមនុស្ស និងរំលោភបំពានលើកុមារជាដើម ។

ពាក់ព័ន្ធនឹងបញ្ហានេះ លោកស្រី ឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរងនគរបាលខេត្ត និងជាប្រធានក្រុមការងារកិច្ចការអនុវត្តច្បាប់ នៃលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានបញ្ជាក់ថា រូបភាពនៃការជួញដូរមនុស្ស គឺជាការបោកបញ្ឆោតឲ្យនរណាម្នាក់ជឿតាមពាក្យលួងលោមរបស់គេ ដូចជាការនាំទៅធ្វើការនៅក្រៅប្រទេស ឬទីកន្លែងដទៃទៀត ប៉ុន្តែគ្មានទីតាំងជាក់លាក់ ដែលជាក់ស្តែងគ្រាន់តែជាការបោកប្រាស់តែប៉ុណ្ណោះ ឬ មានគោលបំណងផ្សេងពីការព្រមព្រៀងគ្នា និងម្យ៉ាងទៀត ការរំលោភបំពានលើកុមារ ដោយមានទាំងការរំលោភផ្លូវភេទ ដោយផ្ទាល់ និងតាមរយៈប្រព័ន្ធអនឡាញជាដើម ។ លោកស្រី ឧត្តមសេនីយ៍ត្រី ដួង ថាវរី មានប្រសាសន៍បន្ថែមថា ការងារជួញដូរមនុស្ស វាមិនត្រឹមតែជាកាតព្វកិច្ចរបស់គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប៉ុណ្ណោះទេ ប្រជាពលរដ្ឋទូទៅក៏អាចចូលរួម និង ត្រូវតែមានការចូលរួមសហការនិងត្រូវក្លាហានធ្វើការរាយការណ៍ចំពោះករណីសង្ស័យថាជាអំពើជួញដូរមនុស្ស ទោះក្នុងកាលៈទេសៈណាក៏ដោយ សំខាន់សូមឲ្យបងប្អូនប្រជាពលរដ្ឋ ត្រូវតែស្វែងយល់ពីរូបភាពនៃអំពើជួញដូរមនុស្ស ដើម្បីជួយដល់ជនរងគ្រោះបានទាន់ពេលវេលា ។

លោក ប៊ុក ទ្រី ប្រធានមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ នៃអង្គការមូលនិធិអេ២១ បានមានប្រសាសន៍ថា ជុំវិញការចូលរួមរាយការណ៍ ចំពោះករណីជាក់ស្តែង ឬ ករណីសង្ស័យ លើសកម្មភាពអំពើជួញដូរមនុស្ស និង ការរំលោភបំពានលើកុមារនោះ ប្រជាពលរដ្ឋអាចទាក់ទងទៅមន្ត្រីមានសមត្ថកិច្ច ឬ ទៅកាន់អង្គការមូលនិធី អេ២១ បាន ជាពិសេសគឺការស្វែងយល់ពីរូបភាពនៃការជួញដូរ មនុស្ស និង ការរំលោភបំពានលើកុមារផ្សេងៗ តាមរយៈបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក វេបសាយ ឬតាមលេខទូរស័ព្ទ ០១០ ២២០ ៧៧១ និង ០១២ ៦៧៨ ៧៩៩ ។ អត្ថបទ ៖ លោកស្រី ហែម បូរ៉ាន្នី រូបភាព ៖ សហការី កែសម្រួលអត្ថបទ ៖ លោក លីវ សាន្ត

## រកឃើញពលករខ្មែរមកពីថៃ១៩នាក់ មានវិជ្ជមានកូវីដ១៩ នៅខេត្តព្រៃវែង

http://freshnewsasia.com/ 2021-06-10 03:05pm

(ព្រៃវែង)៖ លោក ញ៉ែម សៅគ្រី ប្រធានមន្ទីរព័ត៌មានខេត្តព្រៃវែង និងជាសមាជិកអ្នកនាំពាក្យរដ្ឋបាលខេត្តព្រៃវែង បានប្រាប់អង្គភាពព័ត៌មាន Fresh News ថា ពលករខ្មែរដែលទើបមកពីប្រទេសថៃថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ចំនួន១៩នាក់ មានវិជ្ជមានកូវីដ។ លោកបានបន្តថា ក្នុងចំណោមពលករខ្មែរទាំង៣៦នាក់ (ស្រី១១នាក់) ដែលបានធ្វើដំណើរមកដល់ស្រុកកំណើតវិញ កាលពីយប់ត្រូវបានមន្ត្រីសុខាភិបាលធ្វើតេស្តរហ័ស ហើយក៏រកឃើញវិជ្ជមានចំនួន១៩នាក់។ ក្រោយទទួលបាន លទ្ធផលខាងលើនេះ អ្នកជំងឺទាំង១៩នាក់ ត្រូវបានបញ្ជូនទៅសម្រាកព្យាបាល និងអ្នកផ្សេងទៀត ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃផងដែរ ដើម្បីបន្តតាមដានសុខភាព៕

## ខេត្តបាត់ដំបងបញ្ជូនពលករ២០នាក់ ទៅបន្តធ្វើចត្តាឡីស័កតាមបណ្ដាខេត្តចំនួន០៤

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍១០ មិថុនា ២០២១ ដោយ Sorn Phanith

អភិបាលខេត្តបាត់ដំបង បានបញ្ជូនពលករ២០ទៀត បន្តទៅធ្វើចត្តាឡីស័កតាមបណ្ដាខេត្តចំនួន០៤ តាមរថយន្តនៅព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១។

លោក សឿម ប៊ុនរិទ្ធ អភិបាលរងខេត្តបាត់ដំបង បានឲ្យដឹងតាមរបាយការណ៍របស់ខ្លួនដែលមានខ្លឹមសារថា សូមគោរពរាយការណ៍ជូនថា នៅព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ មណ្ឌលចត្តាឡីស័កកម្រិត១ វិទ្យាល័យពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ បានបញ្ជូនបងប្អូនពលករចំនួន២០នាក់ ទៅបន្តធ្វើចត្តាឡីស័កតាមបណ្ដាខេត្តចំនួន០៤ ខេត្ត ប្រើប្រាស់រថយន្តចំនួន១គ្រឿង ដឹកជញ្ជូនពលករទាំង២០នាក់ ទៅកាន់គោលដៅខេត្តចំនួន០៤ផ្សេងៗពីគ្នា ដើម្បីបន្តធ្វើចត្តាឡីស័ក។

ប្រភពខាងលើបន្តថា បណ្ដាខេត្តទាំង០៤ដែលត្រូវបញ្ជូនពលករខាងលើទៅបន្តធ្វើចត្តាឡីស័ករួមមានខេត្តបន្ទាយមានជ័យ០៣នាក់ ខេត្តសៀមរាប១០ចំនួននាក់ ខេត្តត្បូងឃ្មុំចំនួន០១នាក់ និងខេត្តព្រៃវែង០៦នាក់ សរុប២០នាក់ តាមរយៈរថយន្តកងពលតូចដឹកជញ្ជូនលេខ៩៩នៃយោធភូមិភាគទី៥៕ **អត្ថបទ៖ សៅ សារិទ្ធ**

## អគ្គស្នងការនគរបាលជាតិបានរកឃើញពលរដ្ឋជាង ៧ ៦០០ នាក់ ឆ្លងដែនខុសច្បាប់ និងដាក់ធ្វើចត្តាឡីស័ក

https://postkhmer.com/ គឹម សារុំ | Publication date 10 June 2021 | 16:07 ICT

**ភ្នំពេញៈ** គិតពីខែកុម្ភៈ ដល់ខែមិថុនា ឆ្នាំ ២០២១ នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ បានរកឃើញប្រជាពលរដ្ឋខ្មែរ ប្រុស-ស្រី ឆ្លងដែនខុសច្បាប់ ហើយត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅតាមបណ្ដាខេត្ត-រាជធានីមួយចំនួនទូទាំងប្រទេសមានប្រមាណ ៧ ៦០០ នាក់។ នេះបើយោងតាមអ្នកនាំពាក្យរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ។

លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិបានប្រាប់ឱ្យភ្នំពេញប៉ុស្តិ៍ដឹងនៅថ្ងៃទី ៩ មិថុនា ថា ករណីពលករប្រុសស្រីខុសច្បាប់ដែលលួចឆ្លងដែនចេញចូលប្រទេសថៃ ហើយគេចចេញពីការធ្វើចត្តាឡីស័កត្រូវបានសមត្ថកិច្ចរកឃើញមានចំនួនប្រមាណជា ៧ ៦០០ នាក់នៅតាមខេត្ត-រាជធានីមួយចំនួនទូទាំងប្រទេស។ ចំនួននេះគឺគិតចាប់ពីថ្ងៃទី ១៣ ខែកុម្ភៈ ដល់ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០២១។ លោកមានប្រសាសន៍បញ្ជាក់ថា ពលករឆ្លងដែនដែលត្រូវសមត្ថកិច្ចយកទៅធ្វើចត្តាឡីស័ក គឺជាពលករមិនមែនចំពោះតែសមត្ថកិច្ចឃាត់នៅតាមព្រំដែនទាំងអស់ទេ។ ប៉ុន្តែពលករខ្លះ

អាចត្រូវគេរកឃើញនៅស្រះកែវប្រទេសថៃ ហើយថៃបានបញ្ជូនមកវិញ និងពួកគាត់ចូលមកដល់ខេត្តរបស់ពួកគាត់ បន្ទាប់ពីព្យាយាមគេចចេញពីមណ្ឌលចត្តាឡីស័កហើយសមត្ថកិច្ចបានរកឃើញ។ លោកបញ្ជាក់ថា៖ «ពលករប្រមាណ ៧ ៦០០ នាក់នេះ គឺពួកគាត់បានគេចចេញពីតំបន់ចត្តាឡីស័កនៅតាមព្រំដែនហើយទៅកាន់បណ្តាខេត្តដែលពួកគាត់រស់នៅ។ ចំពោះថាខេត្តមួយៗតាមព្រំដែនមានពលករឆ្លងដែនខុសច្បាប់ប៉ុន្មាននោះ ខ្ញុំមិនទាន់មានពេលធ្វើទេ»។

លោក គឹមខឿន មានប្រសាសន៍បន្តថា ចំពោះមូលហេតុនៃការគេចវេះពីមណ្ឌលចត្តាឡីស័ករបស់ពលករទាំងនោះលោកក៏មិនដឹងដែរ ប៉ុន្តែបើតាមលោកយល់ គឺមានចំណុចមួយចំនួនដោយសារពួកគាត់ធ្លាប់ចេញទៅប្រទេសថៃរកការងារធ្វើដោយខុសច្បាប់។ ដូច្នេះពេលពួកគាត់ចូលមកវិញតាមច្រកដដែលគឺពួកគាត់មិនហ៊ានចូលទេ ដូច្នេះពួកគាត់ធ្លាប់ចូលតាមច្រករបៀងណាបានគាត់ក៏រកគេនាំចូលតាមច្រកនោះដែលភាគច្រើនគឺបែបនេះ។ លោក គឹមខឿន បានថ្លែងឱ្យដឹងថា៖ «ជួនកាលគាត់គេចចេញពីមណ្ឌលចត្តាឡីស័កព្រោះគាត់មកពីប្រទេសថៃគាត់ចង់ទៅផ្ទះគាត់ភ្លាមៗអ៊ីចឹងបើឱ្យគាត់ធ្វើចត្តាឡីស័កវាអស់ ១៤ ថ្ងៃបាត់ហើយវាយូរ។ អ៊ីចឹងគាត់អត់ចង់ទេគាត់ចង់ទៅធ្វើចត្តាឡីស័កនៅតាមភូមិ-ឃុំព្រោះវាជិតផ្ទះគាត់»។

ពាក់ព័ន្ធបញ្ហាពលករឆ្លងដែនខុសច្បាប់នេះដែរ កាលពីវេលាម៉ោងជិត ៥ ភ្លឺថ្ងៃ ៩ មិថុនា សមត្ថកិច្ចចម្រុះដែលប្រចាំការនៅតាមព្រំដែនត្រង់ចំណុចភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃពលករ ១៣ នាក់ រួមកូនរបស់ពលករ ២ នាក់ត្រូវបានសមត្ថកិច្ចទប់ស្កាត់បាន និងឃាត់ខ្លួនបុរសមេខ្យល់ម្នាក់ផង។

លោកស្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យប្រាប់នៅថ្ងៃទី ៩ មិថុនាដែរថា ពលករទាំង ១៣ នាក់ និងក្មេងស្រីជាកូនពលករចំនួន ២ នាក់នោះត្រូវបានបុរសសង្ស័យជាមេខ្យល់ម្នាក់ឈ្មោះ យើន ណារ៉ុង អាយុ ២០ ឆ្នាំ រស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃត្រូវបានសមត្ថកិច្ចចម្រុះឃាត់ និងទប់ស្កាត់បាននៅថ្ងៃទី ៩ មិថុនា ហើយពលករទាំងនោះកំពុងសាកសួរនៅអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ។ ពួកគេមកពីខេត្តបាត់ដំបងចំនួន ៨ នាក់ (ស្រី) ខេត្តកំពង់ធំ ២ នាក់ ខេត្តព្រៃវែង ២ នាក់ និងខេត្តបន្ទាយមានជ័យម្នាក់។ លោកស្រីថា៖ «ពលករដែលសមត្ថកិច្ចទប់ស្កាត់បានត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅតាមខេត្តដែលពួកគាត់រស់នៅ។ ចំណែកបុរសម្នាក់សង្ស័យជាមេខ្យល់ប្រសិនបើគាត់ប្រព្រឹត្តមែននោះនឹងត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធីច្បាប់ ព្រោះគាត់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស»៕

## ស្ថានទូតវៀតណាមថា ជនជាតិវៀតណាមត្រូវបានជួញដូរមកធ្វើការតាមកាស៊ីណូក្នុងប្រទេសកម្ពុជា

https://www.rfa.org/khmer/ ដោយ ហេង រស្មី2021-06-10

ស្ថានទូតវៀតណាម បានទទួលព័ត៌មាន ថាមានជនជាតិវៀតណាម ត្រូវបានក្រុមជួញដូរមនុស្ស បោកប្រាស ឱ្យមកធ្វើការ នៅកន្លែងកាស៊ីណូ កន្លែងល្បែងកម្សាន្ត និងនៅតាមកន្លែងល្បែងអនឡាញ ផ្សេងៗ នៅក្នុងប្រទេសកម្ពុជា។ សកម្មភាពជួញដូរនេះធ្វើឡើងតាមរយៈមេខ្យល់ជនជាតិ ចិន និងកម្ពុជា ហើយជនជាតិវៀតណាមត្រូវបានក្រុមជួញដូរ បានផ្សព្វផ្សាយថា ពួកគេនឹងទទួលបានការងារសាមញ្ញ តែប្រាក់ខែខ្ពស់ ចាប់ពី ៨០០ ទៅ ១.០០០ដុល្លារ និងផ្តល់អាហារហូបចុក កន្លែងស្នាក់នៅ ក្នុងកន្លែងសណ្ឋាគារ និងកាស៊ីណូ ភាគច្រើន នៅក្រុងព្រះសីហនុ ជាទីកន្លែងដែលអាចទាក់ទាញ អ្នកមកលេងល្បែងតាមអនឡាញ នៅទីនោះ។ ស្ថានទូតវៀតណាម បានបន្ថែមថា និយោជិក ត្រូវបានពិនិត្យឃើញថា មានការកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយបង្ខំឱ្យធ្វើការមួយថ្ងៃពី ១៥ ទៅ ១៦ម៉ោង បើមិនដូច្នេះទេ ពួកគេនឹងត្រូវវាយធ្វើបាប។ និយោជិកភាគច្រើនបានរងនូវការធ្វើទារុណកម្ម វាយដំ

នៅពេលដែលពួកគេព្យាយាមរត់គេច និងបដិសេធមិនធ្វើការតាមការកំណត់។ ចំពោះអ្នកដែលមានបំណងចង់ត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញ នោះថៅកែក្រុមហ៊ុន បង្ខំឱ្យចុះហត្ថលេខាលើលិខិតជំពាក់បំណុលក្រុមហ៊ុនច្រើនរាប់ពាន់ដុល្លារ ឬមួយពួកគេត្រូវនាំយកទៅលក់កម្លាំងពលកម្ម នៅក្រុមហ៊ុនផ្សេងទៀត។

វិទ្យុអាស៊ីសេរីបានព្យាយាមទាក់ទង អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិ លោក ឆាយ គឹមឃឿន និងមន្ត្រីស្ថានទូតវៀតណាមផ្នែកជួញដូរមនុស្ស តែមិនអាចទាក់ទងបានកាលពីយប់ថ្ងៃទី១០ មិថុនា៕

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣

http://cambodiapolice.com/policekh/ 8:56 am 10 មិថុនា 2021 បោះពុម្ព អ៊ីម៉ែល

ខេត្តបាត់ដំបង ៖ ថ្ងៃពុធ ១៤រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនកូនភ្នំ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ រឿន វ៉ាន់នី មន្ត្រីប៉ុស្តិ៍ រួមជាមួយកម្លាំងផ្នែកស៊ើបការណ៍ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ សេង រ៉ើន នាយផ្នែក សហការជាមួយកម្លាំងយោធាបានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ចំនួន ០១នាក់ ប្រុស ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៧១នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃព្រហស្បតិ៍ ទី១០ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៧១នាក់ ស្រី ៣៣នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៣នាក់ ស្រី ៥នាក់ កុមារា ១នាក់ កុមារី ១នាក់។

២-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៨នាក់ ស្រី ២នាក់ កុមារា ១នាក់ កុមារី ២នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៤០នាក់ ស្រី ២១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១០នាក់ ស្រីចំនួន ៥នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៧១នាក់ ស្រី ៣៣នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១

## អាជ្ញាធរខេត្តបាត់ដំបង បង្ហាញអត្តសញ្ញាណអ្នកវិជ្ជមានកូវីដ១៩ ចំនួន២២នាក់ ក្នុងនោះពលករទើបមកពីថៃ៥នាក់

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១១ មិថុនា ២០២១ ដោយ Kang Tola

បាត់ដំបង ៖ ថ្ងៃនេះអាជ្ញាធរខេត្តបាត់ដំបង បង្ហាញអត្តសញ្ញាណអ្នកវិជ្ជមានកូវីដ-១៩ចំនួន២២នាក់ និងអ្នកជាសះស្បើយចំនួន៥នាក់ ក្នុងនោះជាពលករទើបវិលត្រឡប់មកពីប្រទេសថៃ ចំនួន ៥ នាក់ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍២០កុម្ភៈចំនួន ១៧ នាក់ និងមានករណីជាសះស្បើយចំនួន ៥នាក់។ នេះបើតាមសេចក្តីប្រកាសព័ត៌មានដែលបណ្តាញព័ត៌មាន កម្ពុជាថ្មី ទទួលបាននៅយប់ថ្ងៃទី១១ ខែមិថុនា នេះ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០២១នេះ ខេត្តបាត់ដំបង មានអ្នកឆ្លងជំងឺកូវីដ១៩ សរុបចំនួន ៥០៥ នាក់ និងបានជាសះស្បើយចំនួន ១៨៣ នាក់ ស្លាប់ចំនួន ២នាក់ និងកំពុងសម្រាកព្យាបាលក្នុងមន្ទីរពេទ្យចំនួន ៣២០ នាក់៕ *ដោយ ៖ សោ និយមវ័ត្ត*

## ពលករខ្មែរ៤៥នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃខុសច្បាប់ ត្រូវឃាត់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១១ មិថុនា ២០២១ ដោយ Sorn Phanith

ពលករចំនួន ៤៥នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងកងពលតូចថ្មើរជើងលេខ៥១ ឃាត់ខ្លួនបាននៅយប់ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ពេលដែលពួកគេបម្រុងលួចឆ្លងដែនទៅប្រទេសថៃ ក្នុងចំនួន ៤៥នាក់នោះមានស្រី ចំនួន ២៣នាក់មកពីខេត្តចម្រុះត្រង់ចំណុចភូមិសាស្ត្រ ភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

លោក វរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ៥១៤ បានឲ្យដឹងថា នៅម៉ោង១យប់ ឈានចូលថ្ងៃទី១១នោះ លោកបានដឹកនាំកម្លាំងចម្រុះ១ក្រុមចុះល្បាត នៅចំណុចខាងលើក៏បានជួប ពលករបម្រុងលួចឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំង វរសេនាតូចថ្មើរជើងលេខ៥១៤ កងពលតូចថ្មើរជើងលេខ៥១ឃាត់ខ្លួន។ ក្រោយពីឃាត់ខ្លួនបានពលករទាំង៤៥នាក់ហើយបានណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំឲ្យបន្តចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣កុំ ៣ការពារ ឲ្យបានទាំងអស់គ្នា។ លោកបានបញ្ជាក់ឲ្យដឹងទៀតថា ពលករទាំង៤៥នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័ក ខេត្តបន្ទាយមានជ័យ និងបន្តស្រាវជ្រាវរកមេខ្យល់ និងអ្នកពាក់ព័ន្ធដើម្បីចាត់វិធានការតាមផ្លូវច្បាប់៕

# អាជ្ញាធរខេត្តសៀមរាប ទទួលពលករមកពីប្រទេសថៃ តាមច្រកអន្តរជាតិនានាចំនួន ៥១ នាក់ កាលពីម្សិលមិញ

https://www.postkhmer.com/ នៅ ស៊ីវុត្ថា | Publication date 12 June 2021 | 10:44 ICT

**សៀមរាប៖** អាជ្ញាធរខេត្តសៀមរាប កាលពីម្សិលមិញនេះ បានទទួលពលករមកពីប្រទេសថៃ តាមច្រកអន្តរជាតិនានាមកកាន់ខេត្តមានចំនួន៥១នាក់ ខណៈពលករនៅតែបន្តវិលចូលជារៀងរាល់ថ្ងៃប៉ុន្តែមានចំនួនតិចជាមុន។

លោក ស៊ុន ចំណាន អ្នកនាំពាក្យរដ្ឋបាលខេត្តសៀមរាបប្រាប់ ភ្នំពេញប៉ុស្តិ៍ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០២១ នេះថា ប្រជាពលរដ្ឋខ្មែរទាំង ៥១ នាក់នោះ បានទៅបំពេញការងារនៅក្នុងប្រទេសថៃ។ លោក ស៊ុន ចំណាន បន្តថា ជាមួយគ្នានេះ រដ្ឋបាលខេត្តបានរៀបចំក្រុមការងារចំនួន ៣ ក្រុម សម្រាប់ធ្វើការសម្របសម្រួលនៅតាមព្រំដែន រួមមានប៉ោយប៉ែត អូស្មាច់ និងអូរបីជាន់ជាដើម បន្ទាប់ពីពលករទាំងនោះត្រឡប់មកវិញ តាមរយៈការដឹកជញ្ជូនតាមរថយន្តដែលត្រូវបានរៀបចំជូនពួកគាត់ ដើម្បីយកមកធ្វើចត្តាឡីស័កចំនួន ៣ ទីតាំង។ បើតាមលោក ស៊ុន ចំណាន មកដល់ពេលនេះ ចំនួនពលករដែលមកពីប្រទេសថៃ ចូលមកកាន់ខេត្តសៀមរាប ហាក់មានចំនួនថយចុះច្រើនជាងលើកមុន ដោយសារតែ អាជ្ញាធរថៃមានការរឹតបន្តឹង និងមួយទៀត គឺពលរដ្ឋបានមកកាលពីលើកមុនមានចំនួនច្រើនដងរួចមកហើយ។ លោក ស៊ុន ចំណាន ថ្លែងថា៖ «នៅពេលដែលគាត់មកដល់ យើងយកពួកគាត់ទៅដាក់នៅមណ្ឌលចត្តាឡីស័កដែលយើងរៀបរួចហើយ ដើម្បីតាមដានសុខភាពរបស់ពួកគាត់នៅពេលចប់ ១៤ ថ្ងៃហើយ អត់មានអីទេ យើងឱ្យគាត់ទៅផ្ទះវិញហើយ»។

បើតាមរបាយការណ៍របស់រដ្ឋបាលខេត្តសៀមរាបបង្ហាញថា ពលករទាំង ៥១ នាក់ មានស្រី ចំនួន ២៥ នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័កនៅសៀមរាបក្នុងថ្ងៃនេះទាំងអស់ហើយ។

ដោយឡែក របាយការណ៍របស់រដ្ឋបាលខេត្តបាត់ដំបងកាលពីថ្ងៃម្សិលមិញ បានទទួលពលករវិលត្រឡប់ពីប្រទេសថៃ ចំនួន ៥ នាក់ និងរកឃើញឆ្លងជំងឺកូវីដ ១៩។ របាយការណ៍ដដែលបញ្ជាក់ថា ចំពោះពលករដឹកចូលពីខេត្តប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ២៤ នាក់ ពលករចូលតាមច្រកក្នុងខេត្ត ១៤៨ នាក់ និងពាក់ព័ន្ធព្រឹត្តិការណ៍ ២០ កុម្ភៈ ៣២ នាក់ ដូច្នេះពលរដ្ឋចូលក្នុងមណ្ឌលចត្តាឡីស័កថ្ងៃនេះសរុប ២០៤ នាក់៕

# អូស្ត្រាលី ផ្តល់ថវិកា ១៣ម៉ឺនដុល្លារ សម្រាប់លុបបំបាត់ ការគំរាមកំហែង និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅកម្ពុជា

https://dap-news.com/international/ ByKD102 Posted on June 12, 2021

**ភ្នំពេញ៖** **រដ្ឋាភិបាលអូស្ត្រាលី បានផ្តល់ថវិកា១៣ម៉ឺនដុល្លារ ដើម្បីគាំទ្រដល់ការកសាងសមត្ថភាព និងកិច្ចសហការជាមួយនគរបាលជាតិកម្ពុជាសម្រាប់លុបបំបាត់ការគំរាមកំហែងនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា។**

តាមរយៈគេហទំព័រហ្វេសប៊ុករបស់ ស្ថានទូតអូស្ត្រាលី ប្រចាំកម្ពុជា នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ បានឲ្យដឹងថា ក្នុងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ អូស្ត្រាលី បញ្ជាក់ជាថ្មីពីការគាំទ្រ លើការលុបបំបាត់ការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារ នៅកម្ពុជា។ ស្ថានទូតបន្តថា កុមារគ្រប់រូបសមទទួលបាន ការធំធាត់ដោយសុវត្ថិភាព និងគ្មានការគំរាមកំហែងរំលោភបំពាន ឬបង្ខិតបង្ខំឲ្យធ្វើការ។ នៅកម្ពុជា ប៉ូលីសសហព័ន្ធអូស្ត្រាលី កំពុងធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនគរបាលជាតិកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងការគំរាមកំហែង កេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា។

ស្ថានទូត បញ្ជាក់ថា «អូស្ត្រាលី នឹងបន្តវិនិយោគពេលវេលា និងធនធានរបស់យើង ក្នុងបញ្ហាសំខាន់នេះ រួមទាំង ថវិកាចំនួន១៣ម៉ឺនដុល្លារអូស្ត្រាលី ដើម្បីគាំទ្រដល់ការកសាងសមត្ថភាព និងកិច្ចសហការជាមួយនគរបាលជាតិកម្ពុជា ដើម្បីលុបបំបាត់ការគំរាមកំហែងកេងប្រវ័ញ្ច ផ្លូវភេទលើកុមារនៅកម្ពុជា»។ ជាងនេះទៅទៀត ស្ថានទូត

អូស្ត្រាលី ប្រចាំកម្ពុជា ក៏បានលើកឡើងថា អូស្ត្រាលី កំពុងផ្តល់ការបណ្តុះបណ្តាលជំនាញ គាំទ្រផ្នែកកោសល្យវិច្ច័យឌីជីថល និងសម្ភារៈព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់នគរបាលជាតិកម្ពុជា ធ្វើការស៊ើបអង្កេតរបស់ខ្លួន។ ហើយក៏បានគាំទ្រ អង្គការ APLE Cambodia ធ្វើការបោះពុម្ពបញ្ជីជាតិរៀបរាប់ពីសេវាកម្មគាំទ្រជនរងគ្រោះ នៅក្នុងប្រទេសកម្ពុជា ផងដែរ ៕

## សមត្ថកិច្ចស្ទាក់ឃាត់ខ្លួនពលករខ្មែរ ១០នាក់ដែលត្រឡប់មកពីប្រទេសថៃតាមផ្លូវកាត់ យកទៅធ្វើចត្តាឡីស័កតាមវិធានការសុខាភិបាល

https://www.gntimes.com/ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១

ខេត្តបាត់ដំបង÷ សមត្ថកិច្ចការពារគោលដៅព្រំដែនកម្ពុជាថៃ បានស្ទាក់ឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរដែលជាពលករសំណាកស្រុក១០នាក់ ដែលបាននាំគ្នាត្រឡប់មកពីប្រទេសថៃតាមផ្លូវកាត់ច្រករបៀងយកទៅណែនាំ និងប្រគល់ឲ្យគ្រូពេទ្យយកទៅធ្វើចត្តាឡីស័កតាមវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺ កូវីដ-១៩ នៅក្នុងសហគមន៍ ។ នគរបាលការពារគោលដៅតំបន់ព្រំដែនបានឲ្យដឹងថា អនុវត្តតាមផែនការស្តីពីការត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃនៅថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០២១ កន្លងមកនេះកម្លាំងចម្រុះបានចុះល្បាតនាំខ្លួនពលករខ្មែរ ១០នាក់ ដើម្បីយកទៅអនុវត្តវិធានការសុខាភិបាលដើម្បីទប់ស្កាត់ជំងឺ កូវីដ-១៩ ពីខាងក្រៅចូលមកក្នុងប្រទេសកម្ពុជា ។

ពលករខាងលើសរុប ១០ នាក់ក្នុងនោះ ប្រុស០៤នាក់ ក្មេងស្រី ០៦នាក់ ដោយអ្នកទាំងអស់បាននាំគ្នាព្យាយាមគេចវេសមិនចូលធ្វើចត្តាឡីស័កក៏ត្រូវសមត្ថកិច្ចនាំខ្លួនតែម្តង ។ ប្រភពដដែលបន្តថា ពលករទាំង១០នាក់ នៅថ្ងៃខាងលើបាននាំគ្នាលួចឆ្លងដែនដោយចេញពីទឹកដីថៃហើយចូលមកប្រទេសកំណើតវិញកាត់តាមត្រង់ចំណុចភូមិសាស្ត្រភូមិគីឡូលេខ៩ ឃុំ ជ្រៃសីមា និង ភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំ សិរីមានជ័យស្រុកសំពៅលូនខេត្តបាត់ដំបង ។ ក្រោយពីសមត្ថកិច្ចការសាកសួរនិងណែនាំអប់រំកម្លាំងសមត្ថកិច្ចការពារគោលដៅតំបន់ព្រំដែនបានបញ្ជូនពលករទាំង ១០នាក់ទៅឲ្យក្រុមគ្រូពេទ្យដើម្បីនាំយកទៅធ្វើចត្តាឡីស័ក នៅអនុវិទ្យាល័យ កូនភ្នំ៣២ តាមវិធានការរបស់ក្រសួងសុខាភិបាលក៏ដូចជារាជរដ្ឋាភិបាលផងដែរ ៕

## សមត្ថកិច្ចចម្រុះការពារព្រំដែនកម្ពុជា-ថៃ ទទួលពលករខ្មែរ៦នាក់ពីយោធាថៃ

http://khmeread.com/ June 12, 2021 11:58AM

បាត់ដំបង ៖ សមត្ថកិច្ចចម្រុះ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ នាថ្ងៃសុក្រ ទី១១ ខែមិថុនា ឆ្នាំ២០២១ បានទទួលពលករខ្មែរ៦នាក់ ពីយោធាថៃកងអនុសេនាធំ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។ សមត្ថកិច្ចនិយាយថា លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុលិសប៉ុស្តិ៍ព្រំដែនគីឡូ៩ ចំណុះវរសេនាតូចប៉ូលិសការពារព្រំដែនលេខ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ កុន ហ៊ាង (នាយប៉ុស្តិ៍ស្តីទី) សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកសំពៅលូន៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ភី ទូច (មេបញ្ជាការ ខ), កម្លាំងយោធាវរសេនាតូចលេខ១ ចំនួន៣នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី នូ បូរ៉ា (មេបញ្ជាការរងវរៈ) បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ពីយោធាថៃកងអនុសេនាធំ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ៦នាក់ (ស្រី០២នាក់, ក្មេងម្នាក់)។ បន្ទាប់ពី

សាកសួរ កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងសមត្ថកិច្ចបានប្រគល់បងប្អូនឱ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ចុះសហការទទួលពលរដ្ឋខ្មែរត្រឡប់មកពីប្រទេសថៃចំនួន៦នាក់ ចំណុចឃុំជ្រៃសីមា ស្រុកសំពៅលូន

http://cambodiapolice.com/policekh/ 8:29 am   12 មិថុនា 2021

ខេត្តបាត់ដំបង ៖ នាថ្ងៃសុក្រ ២កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ៩ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនលេខ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ កុន ហ៊ាង (នាយប៉ុស្តិ៍ស្តីទី) សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកសំពៅលូន ចំនួន៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ភី ទូច ( មេបញ្ជាការ ខ), កម្លាំងយោធាវរសេនាតូចលេខ១ ចំនួន០៣នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី នូ ប៉ូរ៉ា (មេបញ្ជាការរងវរៈ) បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ពីយោធាថៃកងអនុសេនាធំ ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន០៦នាក, ស្រី០២នាក់ ,ក្មេង០១នាក់។ បន្ទាប់ពីសាកសួរ កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងបានប្រគល់បងប្អូនឱ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ៕

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលករខ្មែរមកពីប្រទេសថៃចំនួន៤នាក់ នៅចំណុចឃុំសិរីមានជ័យ ស្រុកសំពៅលូន

http://cambodiapolice.com/policekh/ 10:12 am   12 មិថុនា 2021

ខេត្តបាត់ដំបង ៖ ថ្ងៃសុក្រ ២កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាបានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែន១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ម៉ឹង ម៉េត នាយប៉ុស្តិ៍ស្តីទី សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកសំពៅលូន ដឹកនាំដោយលោកវរសេនីយ៍ត្រី វ៉ាន់ សុផល មេបញ្ជាការរងផ្នែកសឹករង និងកម្លាំងយោធាវរសេនាតូច៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក អាំផន មេបញ្ជាការ-គ បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ពីភាគីយោធាថៃកងអនុសេនាធំ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូ ចំនួន៤នាក់, ស្រី២នាក់ ក្នុងនោះក្មេងស្រី១នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏

ធ្វើការអប់រំណែនាំ ហើយកម្លាំង បានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ ចុះសហការទទួលពលករខ្មែរត្រឡប់មកពីប្រទេសថៃចំនួន៣៨នាក់

http://cambodiapolice.com/policekh/ 11:47 am 12 មិថុនា 2021

ខេត្តបាត់ដំបង ៖ នាថ្ងៃសុក្រ ០២កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ស៊ិន ប៊ុនរស្មី ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី ជាមេបញ្ជាបានដាក់បទបញ្ជាអោយលោកនាយប៉ុស្តិ៍តាមច្រកតំបន់ដែលគ្រប់គ្រងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រូវធ្វើការល្បាតត្រួតពិនិត្យប្រជាពលរដ្ឋលួចឆ្លងដែនខុសច្បាប់ ដោយសហការជាមួយកម្លាំងយោធា និងទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃវិញ សរុបមានចំនួន៣៨នាក់, ស្រី១៩នាក់ និងក្មេង១០នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំរួច រថយន្តកងយោធាដឹកជញ្ជូនយកទៅកាន់មណ្ឌលចត្តាឡីស័ក នៅអនុវិទ្យាល័យកំរៀង និងអនុវិទ្យាល័យពេជ្រចិន្តា ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥១នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសុក្រ ទី១១ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥១នាក់ ស្រី ២៥នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៨នាក់ ស្រី ៩នាក់ កុមារា ២នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២២នាក់ ស្រី ១២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ១០នាក់ ស្រីចំនួន ៤នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥១នាក់ ស្រី ២៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអរសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ខេត្តបាត់ដំបង បង្ហាញអត្តសញ្ញាណអ្នកកើតជំងឺកូវីដ ចំនួន៩នាក់ មកពីប្រទេសថៃ ខណៈជាសះស្បើយ៣នាក់

http://freshnewsasia.com/ 2021-06-13 07:12pm

(បាត់ដំបង)៖ រដ្ឋបាលខេត្តបាត់ដំបង នៅល្ងាចថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១នេះ បានបង្ហាញអត្តសញ្ញាណអ្នកកើតជំងឺកូវីដ១៩ ចំនួន ០៩នាក់បន្ថែមទៀត ដែលទើបរកឃើញថ្មី ជាពលករមកពីប្រទេសថៃ។ ក្នុងសេចក្តីប្រកាសព័ត៌មាន ដែលបណ្តាញព័ត៌មាន Fresh News ទទួលបានរដ្ឋបាលខេត្តបាត់ដំបង ក៏បានបញ្ជាក់អំពីចំនួនអ្នកជាសះស្បើយ ៣នាក់ផងដែរ។ សូមជម្រាបថា ចាប់ផ្តើមពីមានការឆ្លងរាលដាលជំងឺកូវីដ១៩ ខេត្តបាត់ដំបង មានអ្នកឆ្លងចំនួន ៥៣១នាក់ និងបានព្យាបាលជាសះស្បើយ ចំនួន ១៩៥នាក់, ស្លាប់ចំនួន២នាក់ និងកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យបង្អែកនានាក្នុងខេត្ត ចំនួន៣៣៤នាក់៕

## សមត្ថកិច្ចចម្រុះឃាត់ខ្លួនពលរដ្ឋខ្មែរ ប្រមាណ ១០នាក់បម្រុងឆ្លងដែនទៅប្រទេសថៃ និងឃាត់ខ្លួនអ្នកបើកបររថយន្តម្នាក់ទៀត

https://gntimes.com/news/ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងសមត្ថកិច្ចចម្រុះឈរជើងតាមបន្ទាត់ព្រំដែន បានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរ ១០នាក់ បម្រុងឆ្លងដែនទៅធ្វើការនៅប្រទេសថៃ និងអ្នកបើករថយន្តម្នាក់ ខណៈកម្លាំងកំពុងដើរល្បាតខាងជើងភូមិតេជោភ្នំធំត្រ ចម្ងាយប្រហែល៥០ម៉ែត្រ ក្នុងភូមិសាស្រ្តភូមិតេជោភ្នំធំត្រ ឃុំស្វាយចេក ស្រុកស្វាយចេក កាលវេលាម៉ោង ៤ និង៣០នាទីល្ងាច ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២១ ។ នេះបើតាមលោកវរសេនីយ៍ឯក ជា ស្លួញ អធិការនគរបាលស្រុកស្វាយចេក បានឲ្យដឹងនៅល្ងាចថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ នេះ ។

លោក ជា ស្លួញ បានឲ្យដឹងទៀតថា កម្លាំងដែលបានចុះល្បាតរួមមាន កម្លាំងអធិការដ្ឋាននគរបាលស្រុកស្វាយចេក ប្រចាំការនៅមុខខ្លោងទ្វារផ្លូវចូលភូមិតេជោភ្នំធំត្រ និងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៩១១ ប៉ុស្តិ៍ថ្នល់បំបែក សហការជាមួយម្លាំងយោធា ការពារព្រំដែកគោកលេខ៥០៣ ។ លោកបានបញ្ជាក់ថាប្រជាពលរដ្ឋដែលបម្រុងឆ្លងដែននោះគឺសុទ្ធតែបុរសទាំងអស់ មកពីខេត្តព្រៃវែង ។ ជាមួយគ្នានោះសមត្ថកិច្ចបានឃាត់ខ្លួនអ្នកដឹកជញ្ជូនម្នាក់ឈ្មោះ សេង ហ៊ុយ ភេទប្រុស អាយុ៣១ឆ្នាំ រស់នៅភូមិភ្នំជញ្ជាំង ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ បើកបររថយន្តម៉ាក HIGHLANDER ពណ៌ស ពាក់ស្លាក់លេខភ្នំពេញ2AH-3897 ។ ក្រោយពីឃាត់ខ្លួនប្រជាពលរដ្ឋទាំង ១០នាក់នោះ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក នៅវិទ្យាល័យស្វាយចេក ចំណែកអ្នកបើកបររថយន្តកំពុងធ្វើការសួរនាំនៅអធិការដ្ឋាននគរបាលស្រុកស្វាយចេក និងបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តចាត់ការបន្ត ៕ អត្ថបទ រឿង ចន្ទ្រា

## ខេត្តឧត្តរមានជ័យ បន្តរកឃើញអ្នកឆ្លងកូវីដចំនួន៥នាក់, ៣នាក់មកពីប្រទេសថៃ

http://m.freshnewsasia.com/ 2021-06-13 09:03pm

(ឧត្តរមានជ័យ)៖ រដ្ឋបាលខេត្តឧត្តរមានជ័យ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១នេះ បានចេញសេចក្តីប្រកាសព័ត៌មាន បញ្ជាក់ពីការរកឃើញមនុស្ស ៥នាក់បន្ថែមទៀត ឆ្លងជំងឺកូវីដ១៩ ក្នុងនោះ៣នាក់ ជាពលករមកពីប្រទេសថៃ និង២នាក់ទៀតឆ្លងក្នុងសហគមន៍។ នេះបើតាមសេចក្តីប្រកាសព័ត៌មានដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅយប់នេះ។ សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី១៣ ខែមិថុនាឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យ បានរកឃើញវិជ្ជមានជំងឺកូវីដ១៩ ចំនួន១២១ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន១០៨ករណី និងឆ្លងក្នុង

សហគមន៍ចំនួន ១៣ករណី បានព្យាបាលជាសះស្បើយចំនួន ៤៣នាក់ កំពុងសម្រាកព្យាបាលចំនួន៧៧នាក់ និងស្លាប់ម្នាក់ផងដែរ៕

## អនិច្ចា! ពលករខ្មែរធ្លាក់ពីលើផ្ទះកម្ពស់៣ជាន់នៅថៃ ហើយស្លា.ប់ក្នុងពេទ្យស្រុកសំពៅលូន

https://kohsantepheapdaily.com.kh/ Banteay Meanchey១៣ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ១៦:២៦

ខេត្តបន្ទាយមានជ័យ ៖ បើតាមសេចក្ដីរាយការណ៍បានឱ្យដឹងថា មានពលករខ្មែរម្នាក់បានរងគ្រោះដោយសារធ្លាក់ពីលើផ្ទះថ្មកម្ពស់៣ជាន់ កាលពីវេលាម៉ោង២និង៣០នាទីរសៀលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ នៅឃុំមិនបូរី ខេត្តណងចក ប្រទេសថៃ ក្រោយមកក៏បានស្លា.ប់នៅមន្ទីរពេទ្យស្រុកសំពៅលូន ។

បើតាមលោកវរសេនីយ៍ឯកយ៉ត សុផល អធិការនគរបាលស្រុកភ្នំស្រុក បានឲ្យដឹងថា ជនរងគ្រោះខាងលើមានឈ្មោះ ញិប យាន ភេទប្រុស អាយុ៣៧ឆ្នាំ រស់នៅភូមិគោកចាស់ ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ បានធ្វើចំណាកស្រុកទាំងគ្រួសារដើម្បីទៅធ្វើកម្មករសំណង់នៅប្រទេសថៃ ស្ថិតនៅឃុំមិនបូរី ខេត្តណងចក ប្រទេសថៃ។ តាមការឲ្យដឹងពីក្រុមគ្រួសារបានឲ្យដឹងថា មុនពេលកើតហេតុកាលពីវេលាម៉ោង២ និង៣០នាទីរសៀលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ខណៈជនរងគ្រោះកំពុងតែធ្វើការ ក៏ស្រាប់តែបានធ្លាក់ពីលើផ្ទះថ្មដែលកំពុងធ្វើនោះមានកម្ពស់៣ជាន់ បណ្ដាលឲ្យរងរបួសធ្ងន់ធ្ងរ ហើយត្រូវក៏បានដឹកជញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យប្រទេសថៃ តែដោយសាររបួសធ្ងន់ធ្ងរពេក មិនអាចព្យាបាលបាន ទើបក្រុមគ្រួសារនាំយកមកព្យាបាលនៅមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន លុះវេលាម៉ោង៥និង១៥នាទីព្រឹក ថ្ងៃទី១៣ ខែមិថុនា ជនរងគ្រោះក៏បានបាត់បង់ជីវិតតែម្ដង។ ប្រភពដដែលបន្តថា ស.ពជនរងគ្រោះត្រូវបានក្រុមគ្រូពេទ្យស្រុកសំពៅលូន ដឹកមកធ្វើបុណ្យតាមប្រពៃណីនៅគេហដ្ឋាននៃភូមិគោកចាស់ ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ចំពោះប្រពន្ធ និងកូនស្រីរបស់ស.ពជនរងគ្រោះវិញ ត្រូវបានអនុញ្ញាតឲ្យធ្វើចត្តាឡីស័កនៅនឹងផ្ទះផងដែរ៕

## សមត្ថកិច្ចថៃ ចាប់ជនជាតិថៃប្រុសស្រី១៨នាក់ កំពុងលួចឆ្លងដែនទៅធ្វើការកាស៊ីណូនៅក្រុងប៉ោយប៉ែត

http://nokorwatnews.com/ 12/06/2021

ក្រុងប៉ោយប៉ែត៖ សមត្ថកិច្ចការពារព្រំដែនថៃបាន ចាប់ឃុំជនជាតិថៃប្រុស-ស្រី ចំនួន១៨នាក់ ខណៈកំពុងលួចឆ្លងចេញពីប្រទេសថៃ ចូលកម្ពុជា នៅបរិវេណព្រំដែនស្រុកគោកឃ្សូង ខេត្តស្រះកែវ។ សមត្ថកិច្ចថៃឈរជើងតាមបន្ទាត់ព្រំដែនរាយការណ៍ថា នៅវេលាម៉ោង៣និង២៥នាទី ទៀបភ្លឺ ឈានចូលថ្ងៃទី១២ មិថុនា ២០២១ មេបញ្ជាការកងកម្លាំងបូរផា បានបញ្ជាឲ្យកងកម្លាំងការពារព្រំដែនថៃ ត្រូវធ្វើការរឹតបន្តឹងឲ្យបានតឹងរឹងបំផុត។ រហូតដល់យប់កណ្ដាលអធ្រាត្រកន្លងមក សមត្ថកិច្ចទាហានស្រុកតាព្រះយ៉ា កងកម្លាំងបូរផា បានទទួលសេចក្ដីរាយការណ៍ថាមានជនជាតិខ្លួន(ថៃ)លួចចេញពីប្រទេសដោយខុសច្បាប់ ទើបសមត្ថកិច្ចដាក់កម្លាំង ដោយសហការជាមួយកងវរេទី៤ នគរបាលល្បាតព្រំដែនទី១២ បញ្ជូនកម្លាំងតាមឃ្លាំមើលនៅក្នុងភូមិសាស្ត្រភូមិណង យ៉ាកែវ ឃុំគោកឃ្សូង ស្រុកគោកឃ្សូង ខេត្តស្រះកែវ រហូតជួបប្រទះក្រុមមនុស្សគួរឲ្យសង្ស័យចំនួន១៨នាក់ ក្នុងនោះប្រុស១២នាក់ និងស្រី៦នាក់ ខណៈកំពុងឆ្លងដែនចូលទៅខាងប្រទេសកម្ពុជា។ ពេលនោះសមត្ថកិច្ចថៃបង្ហាញខ្លួនក្រុមជនសង្ស័យនិងចាប់នាំយកមកសួរចម្លើយនៅទីបញ្ជាការកងវរេទី៤។

សមត្ថកិច្ចបន្តថា ជនជាតិថៃទាំង១៨នាក់ខាងលើ ទទួលសារភាពថា ពួកគេចង់ឆ្លងទៅធ្វើការនៅកាស៊ីណូក្រុងប៉ោយប៉ែត ប្រទេសកម្ពុជាពិតមែន ។ ក្រោយពីសមត្ថកិច្ចសួរចម្លើយជនជាតិថៃ ទាំងអស់ឆ្លើយថាបាននាំគ្នាធ្វើដំណើរមកពីច្រើនខេត្តរបស់ប្រទេសថៃ ចង់ទៅធ្វើជាបុគ្គលិកកាស៊ីណូអនឡាញ នៅទីក្រុងប៉ោយប៉ែត ប្រទេសកម្ពុជា ដោយបានទាក់ទងតាម Facebook ដែលប្រកាសស្វែងរកការងារ ថែមទាំងឃើញថា កូវីដ-១៩ ផ្ដើមធូរ

ស្រាលហើយនៅប្រទេសកម្ពុជា។ ដោយយល់ថា អាចរកចំណូលបានយ៉ាងល្អនោះ ទើបពួកគេទៅរកការងារធ្វើ។ ក្រោយពីសួរនាំរួចទើបសមត្ថកិច្ចធ្វើកំណត់ហេតុចាប់ឃុំខ្លួននិងបញ្ជូនទៅឲ្យជំនាញស្រុកគោកឃ្សូង ចាត់ការតាមច្បាប់បន្ត រួមទាំងអនុវត្តតាមវិធានរបស់សុខាភិបាលដើម្បីធ្វើតេស្តរកមេរោគ covid-19ផងដែរ៕

## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១

### បាត់ដំបងបន្តរកឃើញអ្នកវិជ្ជមានកូវីដ-១៩ មកពីប្រទេសថៃ៩នាក់

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១៤ មិថុនា ២០២១ដោយ KC Virak

អាជ្ញាធរខេត្តបាត់ដំបង បន្តរកឃើញ និងបង្ហាញអត្តសញ្ញាណអ្នកវិជ្ជមានកូវីដ-១៩ ចំនួន ៩នាក់ សុទ្ធតែជាពលករទើបវិលត្រឡប់មកពីប្រទេសថៃ។ សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០២១នេះ ខេត្តបាត់ដំបង មានអ្នកឆ្លងជំងឺកូវីដ១៩ សរុបចំនួន ៥៣១ នាក់ និងបានជាសះស្បើយចំនួន ១៩៥ នាក់ ស្លាប់ចំនួន ២នាក់ និងកំពុងសម្រាកព្យាបាលក្នុងមន្ទីរពេទ្យចំនួន ៣៣៤ នាក់៕

### ជនសង្ស័យ២នាក់ ករណីនាំមនុស្សឆ្លងដែន ទៅប្រទេសថៃ ត្រូវបញ្ជូនទៅតុលាការ

https://cen-news.com/ Posted ByPen Srey NeatJune 14, 2021

ខេត្តបន្ទាយមានជ័យ ៖ ជនសង្ស័យចំនួន២នាក់ ដែលពាក់ព័ន្ធក្នុងករណីនាំមនុស្សឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ ត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៅថ្ងៃទី១៤ខែមិថុនាឆ្នាំ ២០២១ បញ្ជូនទៅសាលាដំបូងខេត្ត ដើម្បីមានវិធានការតាមនិតិវិធីច្បាប់ ។

លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនបានឲ្យដឹងថា ៖ នៅវេលាម៉ោង៥និង៣០នាទីល្ងាចថ្ងៃទី១២ខែមិថុនា ឆ្នាំ២០២១ កម្លាំងការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការឃាត់រថយន្ត០១គ្រឿង ម៉ាកសាំយ៉ុង ពណ៌លឿងពាក់ស្លាកលេខភ្នំពេញ ២W.២១១៧ បើកបរដោ យឈ្មោះ ម៉ាន គន្ធា ហៅសុជា ភេទប្រុសអាយុ៤២ឆ្នាំ ស្នាក់ នៅភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ដែលមានដឹកមនុស្សប្រុស ស្រី ចំនួន១៥នាក់ នៅលើផ្លូវជាតិលេ ខ៦ ចំណុចស្ពានទី១ ស្ថិតក្នុងភូមិកំពង់ស្វាយ សង្កាត់កំពង់ ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ក្រោយពីធ្វើការសួរនាំមនុស្សទាំង១៥នាក់និងអ្នកបើកបររួច ម កនិងដោយមានបទបញ្ជាពី លោកឧត្តមសេនីយ៍ទោសិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ព្រមទាំងមាន ការសម្របសម្រួលពីឯកឧត្តម កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យ កម្លាំងនគរបាលជំនាញបានធ្វើការឃាត់ខ្លួនឈ្មោះ ម៉ាន គន្ធា ហៅសុជា ភេទប្រុសអា យុ៤២ឆ្នាំ ស្នាក់នៅភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត អ្នកបើកបររថយន្តបញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ពីបទពាក់ព័ន្ធករណីនាំមនុស្សឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ។

លោកនាយការិយាល័យ បានបញ្ជាក់ទៀតថា៖ដោយឡែកឈ្មោះ សេង ហ៊ុយ ភេទប្រុស អាយុ៣១ឆ្នាំ រស់នៅភូមិភ្នំជញ្ជាំង ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ បើកបររថយន្តម៉ាក់HIGHLANDER ពណ៌សពាក់ស្លាក់លេខ ភ្នំ ពេញ 2AH-3897 ត្រូវបានកម្លាំងសម្ថកិច្ចចម្រុះនៅចំណុចភូមិតេជោភ្នំធំត្រ ដើរល្បាតប្រទះឃើញនិងធ្វើការឃាត់ខ្លួន ខាងជើងភូមិតេជោភ្នំធំត្រចម្ងាយប្រហែល៥០ម៉ែត្រ ក្នុងភូមិសាស្រ្តភូមិតាជោភ្នំធំត្រ ឃុំស្វាយចេក ស្រុកស្វាយចេក នៅវេលាម៉ោង៤និង៣០នាទីល្ងាចថ្ងៃទី១២ខែមិថុនា ឆ្នាំ២០២១ ដែលពាក់ព័ន្ធនាំមនុស្សឆ្លងដែនដោយខុសច្បាប់ ចំនួន១០នាក់ ។ នាយការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនលោកវរសេនីយ៍ ឯក ឡាយ គឹមលួន បានបញ្ជាក់ថា៖តាមចម្លើយសារភាពរបស់ជនពាក់ព័ន្ធទាំង២នាក់ ឈ្មោះម៉ាន គន្ធាហៅសុជា បានសារភាពបានដឹកពលករខ្មែរទាំង១៥នាក់មកពីខេត្តព្រៃវែងនិងខេត្តកំពង់ចាម បានតម្លៃម្នាក់

៣០.០០០រៀល យកមកសាងនៅខេត្តបន្ទាយមានជ័យ និងឈ្មោះសេង ហ៊ុយ បានសារភាពថាគេដឹកពលករទាំង ១០នាក់ ពីខេត្តបន្ទាយមានជ័យទៅចំណុចខាងជើងភូមិតេជោភ្នំធំត្រ ឃុំស្វាយចេកតម្លៃម្នាក់៥០.០០០រៀល ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ទាហានថៃឃាត់ខ្លួនពលករខ្មែរ១០នាក់ ឆ្លងដែនខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១៤ មិថុនា ២០២១ ដោយ KC Virak

ប្រទេសថៃ៖ ពលករខ្មែរចំនួន១០នាក់ ត្រូវបានទាហានថៃចាប់ខ្លួន នៅក្បែរខ្សែបន្ទាត់ព្រំដែន ខណៈពួកគេបានលបឆ្លងដែនទៅរកការងារធ្វើក្នុងខេត្តស្រះកែវ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង៦ល្ងាច ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ត្រង់ចំណុចណាង៉ាម ( ស្រែល្អ ) លើព្រំប្រទល់ស្រុកគោកខ្សូង និងស្រុកតាប្រាក់យ៉ា ក្នុងខេត្តស្រះកែវ។ ពលករខ្មែរចំនួន១០នាក់ ( ប្រុស៤នាក់ ) បានឆ្លងដែនចេញពីខេត្តបន្ទាយមានជ័យ ទៅរកការងារធ្វើផ្នែកកសិកម្ម ក្នុងខេត្តស្រះកែវ ប្រទេសថៃ ប៉ុន្តែត្រូវបានកម្លាំងទាហានឈុតខ្មៅថៃលេខ ១២៥ ល្បាតតាមព្រំដែនប្រទះឃើញ។ ដោយសារស្ថានការណ៍កូវីដ-១៩ កំពុងរីករាលដាលខ្លាំង មុននឹងនាំខ្លួនយកទៅសាកសួរ និងបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ ទាហានថៃបានធ្វើការត្រួតពិនិត្យកម្ដៅលើពលករខ្មែរទាំង១០នាក់ជាមុន ដើម្បីទប់ស្កាត់នូវជំងឺដ៏សាហាវនេះ៕ អត្ថបទ៖ សោ និយមរ័ត្ន

## ស្ត្រីពលករខ្មែរម្នាក់របួសបាក់ជើងដោយរថយន្តកៀរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញក្នុងចំណោមពលករជាង១០០នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey១៤ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ១០:៥២

បន្ទាយមានជ័យ ៖ ស្ត្រីជាពលករខ្មែរម្នាក់របួសធ្ងន់បាក់ជើងដោយរថយន្តកៀដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ ក្នុងចំណោមពលករជាង១០០នាក់ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១នេះ ។

ដោយយោងតាមរបាយការណ៍ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១នេះ នៅច្រករបៀងប៉ុស្តិ៍ចំប៉ក់ ឃុំបឹងបេង ស្រុកម៉ាឡៃ មានពលករខ្មែរចំនួន១៧នាក់ ស្រី៩នាក់ ក្នុងនោះមានស្ត្រីម្នាក់ឈ្មោះ ស្រី ម៉ន អាយុ៣០ឆ្នាំរស់នៅភូមិ .ឃុំកោះចិន ស្រុកពញាលឺ ខេត្តកណ្តាល របួសធ្ងន់បាក់កជើងស្តាំ ដោយរថយន្តកៀនៅប្រទេសថៃ ។

ច្រកអូរបីជាន់ស្រុកអូរជ្រៅ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ក្រុមការងារបានទទួលពលករខ្មែរត្រឡប់ពីប្រទេសថៃដែលទទួលនៅមណ្ឌលសំចតច្រកអូរបីជាន់ មានចំនួន៧៤នាក់ ស្រី៣៥នាក់ និងច្រកតំបន់ព្រំដែនបឹងត្រកួន មានចំនួន២១នាក់ ស្រី១០នាក់ និងកុមារ២នាក់ ។

ចំពោះពលករដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ ដែលត្រូវបានក្រុមការងារទទួលតាមច្រកក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ មានច្រកអូរបីជាន់ស្រុកអូរជ្រៅ ច្រកតំបន់ព្រំដែនបឹងត្រកួន ស្រុកថ្មពួក និងច្រករបៀងប៉ុស្តិ៍ចំប៉ក់ស្រុកម៉ាឡៃ រយៈពេល១ថ្ងៃ មានចំនួន១១២នាក់ ក្រោយពេលដែលក្រុមការងារពិនិត្យសុខភាព និងទទួលអាហារសម្រន់ ហើយបានធ្វើការណែនាំហើយត្រូវបានដឹកជញ្ជូនទៅដាក់នៅមណ្ឌលដើម្បីធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ៕

## កម្លាំងនគរបាល និងកម្លាំងយោធា សហការគ្នាទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមក ប្រទេសកម្ពុជាវិញពីយោធាថៃ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិគីឡូ៩

http://cambodiapolice.com/policekh/ 9:23 am 14 មិថុនា 2021

ខេត្តបាត់ដំបង ៖ នាថ្ងៃអាទិត្យ ៤កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាល ព្រំដែនចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនលេខ៨ ១៧ សហការជាមួយកម្លាំងយោធាធ្វើការទប់ស្កាត់ប្រជាពលរដ្ឋបំរុងលួចឆ្លងដែនចូលទឹកដីថៃ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូនចំនួន៤នាក់ ,ស្រី២នាក់ និងបានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញពីយោធាថៃ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិគីឡូ៩ ឃុំជ្រៃសីមាស្រុកសំពៅលូនចំនួន២នាក់ ,ស្រី១នាក់ ។ បន្ទាប់ពីសាកសួរ, កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងយើងបានប្រគល់បងប្អូនឱ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ៕

## ឃាត់ខ្លួនជនបរទេសមួយរូបពាក់ព័ន្ធ បទពេស្យាចារលើកុមារីរហូតដល់ទៅ៤នាក់

https://kohsantepheapdaily.com.kh/ Siem Reap១៤ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ១៦:១០

ខេត្តសៀមរាប ៖ តុលាការខេត្តសៀមរាប នៅរសៀលថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ម្សិលមិញនេះ បានសម្រេចឃុំខ្លួនជនបរទេសម្នាក់ ពីបទ ទិញពេស្យាចារលើកុមារ។

លោកវរសេនីយ៍ឯក ជា ហេង នាយការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត បានឱ្យដឹងថា ជនបរទេសនេះ ត្រូវបានចាប់ខ្លួនកាលពីល្ងាចថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១។ លោកបន្តថា ដំណើររឿង គឺកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ម្តាយក្មេងរងគ្រោះចំនួន៤នាក់ បានមកដាក់ពាក្យបណ្តឹងទៅលើជនបរទេសម្នាក់មិនស្គាល់ឈ្មោះ និងសញ្ញាតិ ប៉ុន្តែតែក្មេងៗស្គាល់មុខច្បាស់ ហើយហៅថា Teacher។ ក្រោយពីទទួលបានពាក្យបណ្តឹងរួច សមត្ថកិច្ចក៏បានធ្វើការសម្ភាសន៍ក្មេងស្រីរងគ្រោះទាំង៤នាក់ ដែលមានអាយុចាប់ពី ៖ ទី១-ក្មេងស្រីអាយុ១២ឆ្នាំ, ២- ក្មេងស្រីអាយុ១២ឆ្នាំ, ៣- ក្មេងស្រីអាយុ១៣ឆ្នាំ និងទី៤-ក្មេងស្រីមានអាយុ១០ឆ្នាំ។ លោកបានបញ្ជាក់ថា បើតាមក្មេងស្រីទាំង៤នាក់ ពួកគាត់បានបំភ្លឺថា ជនបរទេសរូបនោះបានហៅពួកខ្លួនទៅផ្ទះក្នុងភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ដោយទិញទូរស័ព្ទ ឱ្យម្នាក់១គ្រឿង។ បន្ទាប់មក ជនបរទេសរូបនេះបានឱ្យប្រាក់ពី១០ដុល្លារ រហូតឡើងដល់១០០ដុល្លារ និងបានឱ្យពួកខ្លួនលេងកន្លែងសម្ងាត់របស់គាត់ ហើយគាត់បានលេងកន្លែងសម្ងាត់របស់ពួកខ្លួនវិញ ក៏ដូចជាឱបថើប។ ហើយជនបរទេសរូបនេះបានធ្វើមកសកម្មភាពលើពួកខ្លួនជាច្រើនលើក ក្នុងពេលដែលហៅពួកខ្លួនទៅជួបម្តងៗ។

លោកនាយការិយាល័យបានឱ្យដឹងទៀតថា ក្រោយពីធ្វើការសម្ភាសន៍ទៅលើក្មេងស្រីទាំ៤នាក់រួច លោកក៏បានរាយការណ៍ទៅព្រះរាជអាជ្ញា ដើម្បីសុំដីកាបើកការស៊ើបអង្កេតជាបឋម។ លុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ លោកក៏បានកោះហៅជនបរទេសនោះមកសាកសួរ។ លោកបានបញ្ជាក់បន្ថែមទៀតថា ជនបរទេសរូបនោះមានឈ្មោះ Xavier Vincent G ភេទប្រុស អាយុ៥១ឆ្នាំ ជាជនជាតិបែលហ្សិច ។ ហើយជនបរទេសរូបនេះក៏បានឆ្លើយ

ថា រូបគាត់ស្គាល់ក្មេងរងគ្រោះទាំង៤នាក់នោះពិតប្រាកដមែន និងធ្លាប់បានទិញទូរស័ព្ទឱ្យ ព្រមទាំងឱ្យលុយក្មេងៗនោះចាយ ហើយក៏ធ្លាប់ទិញនំចំណីឱ្យញ៉ាំ និងធ្លាប់នាំក្មេងស្រីទាំង៤នាក់នោះដើរលេងទៅកាន់ភ្នំគូលែនផងដែរ ប៉ុន្តែគាត់មិនបានបំពានផ្លូវភេទទៅលើកុមារនោះទេ។ បើតាមលោក ជា ហេង បានបញ្ជាក់ថា ក្រោយពីសាកសួរ ពិនិត្យចម្លើយស៊ីសង្វាក់គ្នា ពេលវេលាកន្លែងកើតហេតុ និងការផ្តល់លុយកាត់ ព្រមទាំងសម្ភារៈផងនោះ លោកព្រះរាជអាជ្ញា មាស ច័ន្ទពិសិទ្ធ ក៏បានបញ្ជាឱ្យឃាត់ខ្លួន ហើយតុលាការក៏សម្រេចឃុំខ្លួនជនបរទេសរូបនេះ ដោយចោទប្រកាន់ពីបទ ទិញពេស្យាចារកុមារ។ បច្ចុប្បន្នជនសង្ស័យជាជនបរទេសរូបនេះ ត្រូវបានកម្លាំងជំនាញបញ្ជូនទៅដាក់ពន្ធនាគារបណ្តោះអាសន្នហើយ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣២នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី១២ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣២នាក់ ស្រី ១៤នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៨នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់៖ ចំនួន ១៨នាក់ ស្រី ៩នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង៖ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ៖ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣២នាក់ ស្រី ១៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## សមត្ថកិច្ចថៃឃាត់ពលករខ្មែរប្រុសស្រី១០នាក់លួចឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 14/06/2021

ក្រុងប៉ោយប៉ែត៖ កម្លាំងទាហានព្រំដែនរបស់សមត្ថកិច្ចថៃ បានស្កាត់ចាប់ឃុំខ្លួនពលករខ្មែរចំនួន១០នាក់ កាលពីវេលាម៉ោងប្រមាណ១៨និង១៥នាទីថ្ងៃទី១៣ មិថុនា ២០២១។

សេចក្តីរាយការណ៍ពីគេហទំព័រថៃបានឲ្យដឹងថា កម្លាំងទាហានស្រុកតា ព្រះយ៉ា សហការជាមួយទាហានកងកម្លាំងបូរផា កងរយទី១២៥ ស្រុកតា ព្រះយ៉ា និងអាជ្ញាធរដែនដី បានរួមគ្នាចាប់ពលករខ្មែរ ដែលលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ បានចំនួន១០នាក់ ក្នុងនោះមានប្រុស៤ និងស្រី៦នាក់។

ពលករដែលសមត្ថកិច្ចថៃចាប់យកទៅឃុំខ្លួនរួមមានឈ្មោះ៖

១-សេត ញៀន ភេទប្រុស អាយុ៣២ឆ្នាំ ២-រ៉ាន់ សឿន ភេទប្រុស អាយុ៣៧ឆ្នាំ ៣-យស មូហា ភេទប្រុស អាយុ៣១ឆ្នាំ ៤-គ្លឿន សេម ភេទប្រុស អាយុ៤៥ឆ្នាំ ៥-រើន ម៉ឺន ភេទស្រី អាយុ៤៤ឆ្នាំ ៦-លួន ឡេង ភេទស្រី អាយុ ៤០ឆ្នាំ ៧-ថៃ ឡេង ភេទស្រី អាយុ៤៣ឆ្នាំ ៨-ម៉េត ពីម ភេទស្រី អាយុ៣០ឆ្នាំ ៩-ណាត់ លឿន ស្រី អាយុ១៩ឆ្នាំ និង១០-អ៊ុត សន ភេទស្រី អាយុ១៨ឆ្នាំ។

អ្នកទាំងអស់មានសញ្ជាតិខ្មែរ ធ្វើដំណើរមកពីខេត្តបន្ទាយមានជ័យ។ យ៉ាងណាក៏ដោយ ក្រោយពីធ្វើការត្រួតពិនិត្យ សមត្ថកិច្ចថៃរកឃើញថា ពលករខ្មែរទាំងអស់បានលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ដោយចូលតាមច្រករបៀង តែមិនឃើញមានមេខ្យល់នាំផ្លូវទេ។ការចាប់ឃុំខ្លួនលើកនេះ សមត្ថកិច្ចថៃបានអនុវត្តតាមវិធានរបស់សុខាភិបាល និងធ្វើកំណត់ហេតុ រួចបញ្ជូនខ្លួនទៅឲ្យជំនាញស្រុកតា ព្រះយ៉ា ដើម្បីចាត់ការតាមច្បាប់បន្ត ឬបណ្តេញឲ្យចេញ តាមច្រកភូមិអូរបីជាន់ ក្នុងស្រុកអូរជ្រៅ នៃខេត្តបន្ទាយមានជ័យមកកម្ពុជាវិញ៕

## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១

### បុរស ២ នាក់ ត្រូវចោទក្រោមច្បាប់ជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ

https://www.postkhmer.com/ គឹម សារុំ | Publication date 15 June 2021 | 14:15 ICT

**បន្ទាយមានជ័យៈ** អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យនៅថ្ងៃទី ១៤ ខែមិថុនា បានសម្រេចចោទបុរស២នាក់ ជាមេខ្យល់ដែលបម្រុងនាំមនុស្សឆ្លងដែនទៅកាន់ប្រទេសថៃ ក្រោមច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជនសង្ស័យទាំង ២ នាក់ឈ្មោះ ម៉ាន គន្ធា ហៅ សុជា ភេទប្រុស អាយុ ៤២ ឆ្នាំ ស្នាក់នៅភូមិបាលិលេយ្យ ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត និងឈ្មោះ សេង ហ៊ុយ ភេទប្រុស អាយុ ៣១ ឆ្នាំ រស់នៅភូមិភ្នំជញ្ជាំង ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នគរបាលបានចាប់ខ្លួនពួកគេពីកន្លែងផ្សេងគ្នាកាលពីថ្ងៃទី ១២ ខែមិថុនា ដោយជនសង្ស័យទាំង ២ នាក់បម្រុងនាំមនុស្ស ២៥ នាក់ចេញទៅកាន់ប្រទេសថៃ តាមបណ្តោយព្រំដែនក្នុងខេត្តបន្ទាយមានជ័យ។

ព្រះរាជអាជ្ញារង លោក សំរិទ្ធ សុខុន និងជាអ្នកនាំពាក្យអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យឱ្យភ្នំពេញប៉ុស្តិ៍ដឹងនៅថ្ងៃទី ១៤ មិថុនាថា៖ «ជនទាំង ២ នាក់ត្រូវបានតំណាងអយ្យការចោទបទការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនតាមមាត្រា១១ នៃច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ»។ ពាក់ព័ន្ធបទចោទតាមមាត្រា ១១ នៃច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ ជនសង្ស័យប្រឈមនឹងការផ្តន្ទាទោសជាប់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ បើរកឃើញថា មានទោសតាមបទចោទ។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យប្រាប់នៅរសៀលថ្ងៃទី ១៤ មិថុនាថា ជនត្រូវចោទទាំង ២ នាក់ត្រូវបាននគរបាលឃាត់ខ្លួនក្នុង ២ គោលដៅផ្សេងគ្នា។ ជនឈ្មោះ សេង ហ៊ុយ ភេទប្រុសត្រូវបានសមត្ថកិច្ចចម្រុះឃាត់ខ្លួននៅវេលាម៉ោងជាង ៤ ទៀបភ្លឺ ឈានចូលថ្ងៃទី ១២ មិថុនាចំណុចភូមិគេដោភ្នំធំត្រឃុំ-ស្រុកស្វាយចេក ជាមួយរថយន្ត ១ គ្រឿងម៉ាក HIGHLANDER ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AH-3897 និងទប់ស្កាត់បានបុរសជាពលករចំនួន ១០ នាក់ដែលមេខ្យល់បម្រុងនាំឆ្លងដែន។ ពួកគេរស់នៅខេត្តព្រៃវែង។ ចំណែកបុរសជាមេខ្យល់ម្នាក់ទៀតត្រូវសមត្ថកិច្ចឃាត់ ពេលកំពុងបើករថយន្ត ១ គ្រឿងម៉ាកសាំយ៉ុងដឹកមនុស្សប្រុស ស្រី ចំនួន ១៥ នាក់ នៅលើកំណាត់ផ្លូវជាតិលេខ ៦ ត្រង់ចំណុចស្ពានទី ១ ស្ថិតក្នុងភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យកាលពីវេលាម៉ោងជាង ៥ ល្ងាចថ្ងៃទី ១២ ខែមិថុនា។

លោក គក់ សុភ័ក្តិ អធិការរងទទួលផែនការងារព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុកស្វាយចេកដែលប្រចាំការនៅប៉ុស្តិ៍របស់គណៈកម្មការទប់ស្កាត់ពលករ ដែលមានទីតាំងសាលាឃុំស្វាយចេកជិតព្រំដែនកម្ពុជា-ថៃ

បានប្រាប់នៅថ្ងៃទី ១៤ មិថុនាដែរថា ក្នុងភូមិសាស្រ្តឃុំស្វាយចេកនៅថ្ងៃទី ១១ មិថុនា សមត្ថកិច្ចទប់ស្កាត់ពលករបានចំនួន ៤៥ នាក់ក្នុងនោះមានស្រី ៣២ នាក់តែមេខ្យល់គេចខ្លួន។ ចំណែកថ្ងៃទី ១២ មិថុនាទប់ស្កាត់ពលករប្រុសបាន ១០ នាក់ និងឃាត់មេខ្យល់បានម្នាក់។ សរុបគឺសមត្ថកិច្ចចម្រុះធ្វើការទប់ស្កាត់ពលករប្រុសស្រីបានចំនួន ៥៥ នាក់ក្នុងនោះមានស្រី ២៣ នាក់។ លោកបញ្ជាក់ថា៖ «ក្រោយសមត្ថកិច្ចទប់ស្កាត់បានពលករហើយគឺត្រូវបញ្ជូនពួកគេទៅមណ្ឌលសំចតអូរបីជាន់ ព្រោះកន្លែងនោះជាកន្លែងបែងចែកពលករបើគាត់រស់នៅខេត្តណាគេឱ្យគាត់ទៅធ្វើចត្តាឡីស័កនៅខេត្តនោះវិញ»។

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៨នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី១៣ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៨នាក់ ស្រី ១៨នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៣នាក់ ស្រី ៦នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២១នាក់ ស្រី ១១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ២នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣២នាក់ ស្រី ១៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ។ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣២នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី១២ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និង

ប្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣២នាក់ ស្រី ១៤នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ប្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ប្រករបៀងអូរបីជាន់៖ ចំនួន ៨នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ប្រករបៀងម៉ាឡៃ៖ ចំនួន ៤នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ប្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៨នាក់ ស្រី ៩នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ប្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារា ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ប្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣២នាក់ ស្រី ១៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមប្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## កម្ពុជា ស្នើសិង្ហបុរី បង្កើតកិច្ចព្រមព្រៀងសម្រាប់បញ្ជូនពលករខ្មែរទៅធ្វើការនៅសិង្ហបុរីបន្ថែមទៀត

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១៥ មិថុនា ២០២១ដោយ Sorn Phanith

ប្រទេសកម្ពុជាបានស្នើដល់ភាគីសិង្ហបុរី ពិចារណាបង្កើតឱ្យមានកិច្ចព្រមព្រៀងបញ្ជូនពលករជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុញ្ញាតឱ្យមានការបញ្ជូនពលករខ្មែរទូទៅបន្ថែមទៅធ្វើការនៅសិង្ហបុរីបន្ថែមទៀត។ ការស្នើនេះបានធ្វើឡើងនៅព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ នៅទីស្ដីការក្រសួងការងារ នៅក្នុងជំនួបពិភាក្សាការងាររវាងលោក បណ្ឌិត អ៊ិត សំហេង រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោក ស្រី Teo Lay Cheng អគ្គរដ្ឋទូតប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលទើបតែងតាំងថ្មី។

លោកបណ្ឌិត អ៊ិត សំហេង បានមានប្រសាសន៍ថាបច្ចុប្បន្ននេះការបញ្ជូនពលការិនីខ្មែរ ទៅធ្វើការនៅប្រទេសសិង្ហបុរីនៅពុំទាន់មានកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នទទួលបន្ទុកណាមួយនៃប្រទេសសិង្ហបុរីនៅឡើយទេ ដែលនាំឱ្យមានការលំបាកក្នុងការគ្រប់គ្រងទិន្នន័យ ការការពារស្របច្បាប់ និងការស្វែងរកកិច្ចសហការនានាជាមួយភាគីសិង្ហបុរី។ លោក រដ្ឋមន្រ្តី បានស្នើដល់ភាគីសិង្ហបុរី ពិចារណាបង្កើតឱ្យមានកិច្ចព្រមព្រៀងបញ្ជូនពលករជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអនុញ្ញាតឱ្យមានការបញ្ជូនពលករទូទៅបន្ថែមក្រៅពីពលការិនីធ្វើការជាស្ត្រីជំនួយការមេផ្ទះ។ ជាមួយគ្នានេះដែរលោក រដ្ឋមន្រ្តី បានស្នើបន្តការចុះអនុស្សរណៈ នៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ(TVET) ដែលបានចុះហត្ថលេខារវាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយវិទ្យាស្ថានអប់រំបច្ចេកទេស (ITE) នៃប្រទេសសិង្ហបុរី និងដែលបានផុតកំណត់តាំងពីខែមករា ឆ្នាំ២០១៩ កន្លងទៅ ដែលជាគន្លឹះដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេស ពិសេសគឺកម្ពុជាត្រូវការធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ ហើយកន្លងមកសិង្ហបុរីក៏បានដើរតួយ៉ាងច្រើនក្នុងការជំរុញលើការងារនេះ។

ទាក់ទិននឹងសំណើទាំងនេះ លោក ស្រី ឯក អគ្គរដ្ឋទូត រីករាយ និងពេញចិត្តបន្តកិច្ចសហការភាពជាដៃគូជាមួយរដ្ឋាភិបាលកម្ពុជាឲ្យកាន់តែមានល្អប្រសើរបន្តទៀត។ លោកស្រី ឯក អគ្គរដ្ឋទូត បានបញ្ជាក់ថា តាមរយៈបេសកកម្មការទូតរបស់លោកជំទាវនៅកម្ពុជា លោកជំទាវនឹងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឲ្យកាន់តែស្អិតល្មួតបន្ថែមទៀត។

លោកបណ្ឌិត អ៊ិត សំហេង បានលើកឡើងពីវឌ្ឍនភាពនៃទំនាក់ទំនងការទូត និងវិស័យនានា ពិសេសគឺវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរវាងកម្ពុជា និងសិង្ហបុរី ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍប្រទេសកម្ពុជា។ លោក រដ្ឋមន្ត្រីបានលើកឡើងថា សិង្ហបុរីបានជួយបណ្តុះបណ្តាលជំនាញបច្ចេកទេសជាច្រើនដល់គ្រូបង្គោលនិងសិក្ខាកាមកម្ពុជាពិសេសសិង្ហបុរីបានបញ្ជូនគ្រូជំនាញៗមកបណ្តុះបណ្តាលដល់ប្រទេសកម្ពុជាផ្ទាល់។ លោក រដ្ឋមន្ត្រីបានបញ្ជាក់ទៀតថា លើសពីនេះ សិង្ហបុរីក៏បានជួយផ្នែកសុវត្ថិភាព និងសុខភាពរបស់កម្មករនៅកន្លែងធ្វើការងារ ដូចជាជួយរៀបចំបច្ចេកទេសសុវត្ថិភាពឡចំហាយនៅក្នុងរោងចក្រ ការបណ្តុះបណ្តាលអ្នកជំនាញត្រួតពិនិត្យឡចំហាយជាដើម ដោយបានចូលរួមកាត់បន្ថយបញ្ហាគ្រោះថ្នាក់ផ្សេងៗបានយ៉ាងច្រើននៅក្នុងរោងចក្រសហគ្រាស៕ **អត្ថបទ៖ សំអឿន**

## យោធភូមិភាគទី៥ ឃាត់ខ្លួនពលករចំនួន ៩នាក់លួចឆ្លងដែនខុសច្បាប់ ទៅប្រទេសថៃ

https://cen-news.com/ Posted ByPen Srey NeatJune 15, 2021

ខេត្តបន្ទាយមានជ័យ ៖ អនុវត្តតាមបទបញ្ជាមេបញ្ជាការយោធភូមិភាគទី៥ និងគណៈបញ្ជាការឯកភាពខេត្តបន្ទាយមានជ័យ ទប់ស្កាត់ការនាំពលករលួចឆ្លងដែនក្នុងភូមិសាស្រ្តខេត្ត ដោយមានការដឹកនាំបញ្ជាផ្ទាល់ពី លោក ឧត្តមសេនីយ៍ត្រី ជឹម ប៊ុនអាន មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដាក់បទបញ្ជាយ៉ាងតឹងរ៉ឹងការពារនៅតាមបន្ទាត់ព្រំដែន ក្នុងការរឹតបន្តឹងសន្តិសុខព្រំដែនទប់ស្កាត់ពលករលួចឆ្លងដែន ជាពិសេសបានចាត់តាំងកម្លាំងចុះស៊ើបអង្កេតស្វែងរកមុខសញ្ញាមេខ្យល់ ចាប់ខ្លួនបញ្ជូនឲ្យសមត្ថកិច្ចជំនាញចាត់ការតាមផ្លូវច្បាប់។ ជាក់ស្តែងនាយប់រំលងអាធ្រាត្រចូលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១នៅចំណុច ភូមិបឹងរាំង ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ មានពលករខ្មែរចំនួន ៩នាក់ ស្រី៣នាក់ ដែលប៉ុនប៉ងលួចឆ្លងដែន ចូលប្រទេសថៃ ត្រូវបានឃាត់ខ្លួនដោយកម្លាំង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដែលដឹកនាំដោយ វរសេនីយ៍ឯក ព្រហ្ម សុភា មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្ត ដែលសហការជាមួយផ្នែកសឹករងម៉ាឡៃ និង វរសេនាតូចនគរបាលព្រំដែនគោកលេខ៨១៥ កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាល ឃុំអូរស្រឡៅ។

សូមបញ្ជាក់ថា ក្រោយពីឃាត់ខ្លួនបាន លោកមេបញ្ជាការរង បានណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំបន្តចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនខុសច្បាប់ ដោយមិនគិតពីសុវត្ថិភាព និងខាតបង់ប្រាក់កាសជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣កុំ ៣ការពារ អោយបានទាំងអស់គ្នា និងបានប្រគល់ពួកគាត់ឲ្យទៅកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាល ឃុំអូរស្រឡៅ ដើម្បីសាកសួរនិងបញ្ជូនទៅធ្វើចត្តាឡីស័ក។ សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំង តំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការ សហការជាមួយកម្លាំងចម្រុះ ទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែន បញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

## បណ្តាញកុមារ និងយុវជនស្នើទៅក្រសួង និងស្ថាប័ន ៥ ឱ្យជួយដល់កុមារចំណាកស្រុក

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 15 June 2021 | 09:01 ICT

**ភ្នំពេញៈ** បណ្តាញកុមារ និងយុវជនបានចេញសេចក្តីថ្លែងការណ៍រួមមួយ ហើយបានដាក់ស្នើទៅក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន ៥ សូមឱ្យជួយរកដំណោះស្រាយដល់កុមារដែលធ្វើចំណាកស្រុកតាមឪពុកម្តាយរបស់ពួកគេដើម្បីឱ្យពួកគេទទួលបានការសិក្សាដូចកុមារផ្សេងទៀតដែរ។ បណ្តាញកុមារ និងយុវជនទាំងនេះរួមមានបណ្តាញ

កុមារអ្នកតស៊ូមតិ (CAN) ក្រុមតំណាងយុវវ័យ និងយុវជន (AYRG) និងសមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ(CCYM-CR)ដោយទទួលបានការគាំទ្រពីបណ្ដាអង្គការនានា ធ្វើការងារផ្នែកកុមារមួយចំនួនទៀត។

យុវតី ហួ បុប្ផា ប្រធានក្រុមគាំទ្រកុមារ និងយុវជននៃបណ្ដាញដែលដឹកនាំដោយកុមារ និងយុវជននេះបានថ្លែងប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ១៣ ខែមិថុនាថា សេចក្ដីថ្លែងការណ៍រួមនេះបានដាក់ទៅកាន់ក្រសួង និងស្ថាប័នពាក់ព័ន្ធចំនួន ៥ កាលពីថ្ងៃទី ១១ ខែមិថុនា ក្នុងនោះរួមមានក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ។ បុប្ផា បានឱ្យដឹងថា៖ «ពួកយើងរំពឹងថា នឹងទទួលបានការឆ្លើយតបជាវិជ្ជមាន ពីរាជរដ្ឋាភិបាលក៏ដូចជាបណ្ដាក្រសួងស្ថាប័នដែលពាក់ព័ន្ធ ដោយសារតែក្នុងសេចក្ដីថ្លែងការណ៍នេះកុមារ និងយុវជនបានលើកឡើងពីបញ្ហា និងផលលំបាករបស់ពួកគេនៅទីនេះ»។ តំណាងបណ្ដាញកុមារ និងយុវជនរូបនេះបញ្ជាក់ថា តាមរយៈសេចក្ដីថ្លែងការណ៍រួមនេះបានផ្ដោតសំខាន់លើការសិក្សា អប់រំរបស់កុមារ និងយុវជនដែលធ្វើចំណាកស្រុកតាមឪពុកម្ដាយ។ យុវតីរូបនេះបន្តថា៖ «បើសិនជាគ្មានការឆ្លើយតបពីបណ្ដាក្រសួង និងស្ថាប័នពាក់ព័ន្ធលើសេចក្ដីថ្លែងការណ៍រួមនេះ យើងនឹងធ្វើសេចក្ដីថ្លែងការណ៍រួម ១ ទៀត ដែលមានបញ្ចូលការថ្លែងការណ៍រួមពីកុមារដែលកំពុងធ្វើចំណាកស្រុកនៅប្រទេសថៃនាពេលខាងមុខបន្ថែមទៀត»។

សេចក្ដីថ្លែងការណ៍រួមបានឱ្យដឹងថា កាលពីថ្ងៃទី ២០ និង ២១ ខែមីនា ឆ្នាំ ២០២១ បណ្ដាញដែលដឹកនាំដោយកុមារ និងយុវជនរួមទាំងកុមារតំណាងអង្គការបន្ទាយស្រី ខេត្តសៀមរាប និងខេត្តបាត់ដំបងបានធ្វើការរួមគ្នាបង្កើតបានជាវេទិកាកុមារ និងយុវជនថ្នាក់ក្រោមជាតិនៅក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាបស្ដីពីការចំណាកស្រុករបស់កុមារតាមឪពុកម្ដាយ និងផលប៉ះពាល់ពីការធ្វើចំណាកស្រុកមកលើកុមារ។ វេទិកានេះបានពិភាក្សា ស្វែងយល់ពីស្ថានភាពជាក់ស្ដែង បញ្ហាប្រឈមតម្រូវការចាំបាច់ដំណោះស្រាយ និងអនុសាសន៍សម្រាប់ដោះស្រាយបញ្ហាដែលរងផលប៉ះពាល់ពីការធ្វើចំណាកស្រុក និងកុមារចំណាកស្រុក បាននិងកំពុងជួបប្រទះក្នុងស្ថានភាពដ៏លំបាកនៃអំឡុងពេលរីករាលដាលនៃជំងឺកូវីដ ១៩។ សេចក្ដីថ្លែងការណ៍បញ្ជាក់ថា៖ «ដោយផ្អែកលើការពិភាក្សាក្នុងវេទិកាយើងបានរកឃើញថា កុមារមួយចំនួនបានជួបប្រទះនូវបញ្ហាជាច្រើនទាក់ទងទៅនឹងការទទួលបានការអប់រំ បរិបទនៃការរស់នៅ និងការទទួលបានសេវាសាធារណៈជាដើម»។

កុមារ និងយុវជនបានបង្ហាញពីកង្វល់ថា បញ្ហាប្រឈមទាំងនោះបានជះឥទ្ធិទៅលើសិទ្ធិទទួលបានការអប់រំស្មើគ្នា និងសិទ្ធិទទួលបានការអភិវឌ្ឍចំណេះដឹង និងការអភិវឌ្ឍអាកប្បកិរិយារបស់កុមាររួមជាមួយការគោរពខ្លួនឯង សីលធម៌ ការយល់ដឹងពីសង្គម ការចូលរួមសកម្មភាពនានា និងការរស់នៅប្រចាំថ្ងៃ។ ក្រៅពីនេះកុមារទាំងអស់បានបង្ហាញនូវបំណងប្រាថ្នា ដើម្បីបានបញ្ចេញនូវសំឡេងរបស់ពួកគេទៅកាន់អ្នកពាក់ព័ន្ធ និងរាជរដ្ឋាភិបាលឱ្យមានការយកចិត្តទុកដាក់ និងពង្រឹងការអនុវត្តច្បាប់ ជាពិសេសគោលនយោបាយគាំពារសង្គមជួយដល់កុមារ និងយុវជនដែលរងផលប៉ះពាល់ពីការធ្វើចំណាកស្រុកក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ ១៩។ បណ្ដាញទាំងនេះបានស្នើសុំដល់ក្រសួងពាក់ព័ន្ធនានាសូមឱ្យកែលម្អប្រព័ន្ធអប់រំសម្រាប់កុមារ និងយុវជនដោយសម្រួលដល់ការចុះឈ្មោះការផ្ទេរពីតំបន់ ១ ទៅតំបន់ ១ ទៀត និងការបង្កើតឱ្យមានកម្មវិធីអប់រំក្រៅប្រព័ន្ធ ដូចជាការអប់រំភាសាខ្មែរ ថៃ និងការអប់រំចំណេះដឹងទូទៅនៅតាមសហគមន៍ដែលមានការចំណាកស្រុកជាពិសេសគឺនៅតំបន់ព្រំដែនកម្ពុជា-ថៃ។

ចំណែកក្រសួងអប់រំ គួរជានាយ៉ាងណា ឱ្យសាលារៀនទាំងអស់ផ្ដល់នូវព័ត៌មានបច្ចុប្បន្នភាពយ៉ាងសុក្រឹតអំពីនីតិវិធី និងលក្ខខណ្ឌសម្រាប់ចុះឈ្មោះសិស្ស (សំបុត្រកំណើត លិខិតបញ្ជាក់ពីការផ្ទេរ សាលារៀន និងឯកសារពាក់ព័ន្ធផ្សេងទៀត) ដល់គ្រួសារចំណាកស្រុក។ ក្រសួងអប់រំ គួរបន្តប្រើប្រាស់គោលវិធីដែលមានភាពបត់បែន និងបន្តជួយសម្រួលជាពិសេសដើម្បីឱ្យសាលារៀនអាចចុះឈ្មោះកុមារចំណាកស្រុកបាន។ បើតាមសេចក្ដីថ្លែងការណ៍។

លោក រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំថ្លែងនៅថ្ងៃទី ១៣ មិថុនាថា ក្រសួងអប់រំ ស្វាគមន៍ និងថ្លែងអំណរគុណចំពោះកិច្ចសហការវិជ្ជមានពីសំណាក់ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការចូលរួមលើកកម្ពស់គុណភាពអប់រំ សម្រាប់អ្នកសិក្សាមុន និងក្នុងបរិបទកូវីដ ១៩ ដែលត្រូវការការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធរួមទាំងសិស្ស-និស្សិត មាតាបិតា និងអាជ្ញាធរមូលដ្ឋាន។ លោកថ្លែងថា៖ «នៅចំពោះមុខនេះ គ្រប់ភាគីពាក់ព័ន្ធត្រូវបន្តអនុវត្តវិធានការ ៣ការពារ ៣កុំ និងដើរតួនាទីជាឆ្លុង ១ ក្នុងការចូលរួមបន្តជំរុញគុណភាពបង្រៀន និងរៀនពីចម្ងាយ និងអនឡាញ និងលើកកម្ពស់យន្តការលើកទឹកចិត្តអ្នកសិក្សាឱ្យបន្តការសិក្សាស្របនឹងគន្លងជីវិតថ្មីក្នុងវិស័យអប់រំ»។

លោកស្រី ញ៉េប សុភាព អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) បានស្វាគមន៍ចំពោះសេចក្តីថ្លែងការណ៍នេះ ហើយបាននិងកំពុងពិនិត្យ ដើម្បីឆ្លើយតប ឬបន្តគាំទ្រតាមរបៀបណាខ្លះ។ លោកស្រីថ្លែងថា៖ «រាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធមានគោលនយោបាយគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចគាំពារកុមារចំណាកស្រុក ទាំងការចំណាកស្រុកឆ្លងប្រទេស និងមិនឆ្លងប្រទេស។ សេចក្តីថ្លែងការណ៍ខ្លះវាជាចំណែកមួយដែលយើងតែងតែចូលរួម និងលើកទឹកចិត្តជានិច្ច។ យើងមិនអាចបដិសេធបានទេ បើវាសមស្រប ប៉ុន្តែសេចក្តីថ្លែងការណ៍ខ្លះដាក់មកបង្ហាញថាយើងអត់បានធ្វើអ្វីសោះ ដូច្នេះខ្ញុំសូមពិនិត្យមើលការងារនេះសិន»៕

## មេខ្យល់២នាក់ និងពលករ៩នាក់ ត្រូវឃាត់ខ្លួនក្បែរបន្ទាត់ព្រំដែន ខណៈដែលបម្រុង ឆ្លងដែនចូលទឹកដីថៃ

https://www.kampucheathmey.com/ ថ្ងៃពុធ ១៦ មិថុនា ២០២១ដោយ Sorn Phanith

មេខ្យល់ចំនួន០២នាក់ រួមទាំងពលករខ្មែរចំនួន០៩នាក់ ត្រូវកម្លាំងចម្រុះធ្វើការឃាត់ខ្លួន និងបញ្ជូនទៅកាន់អធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីចាត់ការតាមផ្លូវច្បាប់ ខណៈដែលពួកគេត្រៀមបម្រុងលួចឆ្លងដែនដោយខុសច្បាប់ចូលទៅក្នុងទឹកដីថៃ។ ដោយមានការថិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់ ដើម្បីចូលរួមទប់ស្កាត់បទល្មើសឆ្លងដែន និងការការពារ ទប់ស្កាត់ការឆ្លង រីករាលដាលនៃជំងឺកូវីដ-១៩ និងដោយមានការដាក់បទបញ្ជាផ្ទាល់ពី លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនៃស្នងការដ្ឋានខេត្តបាត់ដំបង នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង០៥ និង០៥នាទី ព្រឹក កម្លាំងចម្រុះដែលឈរជើងតាមបន្ទាត់ព្រំដែន ២៤ ម៉ោង លើ ២៤ ម៉ោង បានចុះទប់ស្កាត់ពលករខ្មែរបម្រុងលួចឆ្លង ដែនចូលទឹកដីថៃដោយខុសច្បាប់ចំនួន ០៩នាក់ក្នុងនោះ ស្រី០៣នាក់ និង ក្មេងស្រី០១នាក់ ។

សមត្ថកិច្ចនៅទីនោះបានឲ្យដឹងថា ក្នុងនោះ មុខសញ្ញានាំមនុស្សឆ្លងដែនខុសច្បាប់(មេខ្យល់)មាន ចំនួន ០២នាក់ ត្រូវបានឃាត់ខ្លួន គឺមានឈ្មោះ ១.ឈ្មោះ ធម ប៉េង ភេទប្រុស អាយុ៣០ ឆ្នាំ មានទីលំនៅក្នុងភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុក សំពៅលូន ២.ឈ្មោះ រួន ចាន់រ៉ា ភេទប្រុស អាយុ៣០ឆ្នាំ មានទីលំនៅក្នុងភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ សមត្ថកិច្ចបន្តថា ពលករខ្មែរទាំងនោះ ត្រូវបានកម្លាំង ទប់ស្កាត់បាននៅត្រង់ចំណុចភូមិសាស្ត្រ ភូមិអូរ ឃុំ សន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ក្រោយពីបានសាកសួរ អប់រំណែនាំរួចកម្លាំងចម្រុះបានបញ្ជូនពលករខ្មែរទាំង ៩ នាក់ ឲ្យទៅកម្លាំងអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដោយឡែកមេខ្យល់ គឺកម្លាំងកំពុងកសាងសំណុំរឿង ដើម្បីអនុវត្តតាមនីតិវិធីបន្ត៕ **អត្ថបទ៖ សោ និយមវ័ត្ន**

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៩នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃពុធ ទី១៦ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៩នាក់ ស្រី ១២នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៨នាក់ ស្រី ៣នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២០នាក់ ស្រី ៨នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ១នាក់ ស្រីចំនួន ១នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២៩នាក់ ស្រី ១២នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៩នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអង្គារ ទី១៥ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៩នាក់ ស្រី ២១នាក់ ក្នុងនោះកុមារា ៣នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១០នាក់ ស្រី ៥នាក់ កុមារា ១នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៨នាក់ ស្រី ១៥នាក់ កុមារា ២នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣៩នាក់ ស្រី ២១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករចំណាកស្រុកជាង ៨0.000 នាក់បានឆ្លងកាត់ព្រំដែនកម្ពុជាក្នុងរយៈពេល ៦ ខែនេះ

https://www.khmertimeskh.com/ Chhun Sunly / June 16, 2021

ចាប់តាំងពីមានការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នៅខេត្តសាមុតសាខន ប្រទេសថៃកាលពីថ្ងៃទី ៣ ខែធ្នូឆ្នាំមុនមកពលករចំណាកស្រុក ដែលបានវិលត្រឡប់មកកម្ពុជាវិញរហូតដល់ពាក់កណ្តាលខែមិថុនាឆ្នាំនេះមាន ចំនួនសរុប ៨០.៨៥៣ នាក់។ ខេត្តដែលប្រឈមនឹងចំនួនពលករចំណាកស្រុកដែលឆ្លងកាត់ព្រំដែនកម្ពុជា-ថៃច្រើនជាងគេរួមមានខេត្តបាត់ដំបង ឧត្តរមានជ័យ និងកោះកុង។

យោងតាមការិយាល័យរដ្ឋបាលខេត្តមួយចំនួនបានឲ្យដឹងថា ពួកគេជិតទទួលបានជោគជ័យក្នុងការគ្រប់គ្រងពលករចំណាកស្រុក ដែលវិលត្រលប់ទាំងអស់ហើយ ដោយពួកគេបានបញ្ជូនពលករទាំងនោះទៅមណ្ឌលនិងដាក់ឲ្យស្ថិតក្រោមការធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃជាដាច់ខាត និងអនុញ្ញាតឲ្យពួកគេត្រឡប់ទៅផ្ទះវិញក្រោយការធ្វើតេស្តទទួលបានលទ្ធផលអវិជ្ជមាន។ បើទោះបីមានការរឹតបន្តឹងផ្នែកសន្តិសុខនៅតាមច្រកព្រំដែនក៏ដោយ ក៏មានកម្មករចំនួន ២៤ នាក់បានចូលមកកម្ពុជាតាមរយៈខេត្តប៉ៃលិន បន្ទាយមានជ័យ និងឧត្តរមានជ័យ។ ដោយឡែកពលករចំនួន ១៤៨ នាក់ទៀតដែលបានចូលមកតាមរយៈប៉ុស្តិ៍ត្រួតពិនិត្យព្រំដែនមានចំនួន ៣២ នាក់វិជ្ជមានកូវីដ-១៩ និងមានជាប់ទាក់ទងនឹងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។ អ្នកទាំងអស់ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កនៅមណ្ឌលសុខភាព។

លោក សេក សំអុល នាយករងរដ្ឋបាល សាលាខេត្តកោះកុងបានប្រាប់កាសែតខ្មែរថាមស៍កាលពីម្សិលមិញថាពួកគេបានគ្រប់គ្រងពលករចំណាកស្រុកចំនួន ៧៤៦ នាក់ដោយក្នុងនោះមានចំនួន ២១៤ នាក់ បានវិលត្រឡប់មកពីប្រទេសថៃវិញក្នុងអំឡុងពេលនោះ។ លោកបានឲ្យដឹងថាក្នុងចំណោមពលករចំណាកស្រុកដែលបានវិលត្រឡប់វិញ មានតែម្នាក់ប៉ុណ្ណោះដែលវិជ្ជមានកូវីដ-១៩។ លោកបន្តថា៖ «បច្ចុប្បន្ន យើងមានពលករចំណាកស្រុកចំនួន ៥២ នាក់ក្នុងនោះមានស្ត្រី ២០ នាក់ដែលកំពុងស្ថិតនៅមណ្ឌលចត្តាឡីស័ក។ មកទល់ពេលនេះ យើងមិនទាន់រាយការណ៍នូវករណីស្លាប់ណាមួយនៅឡើយទេ»។

ទន្ទឹមនឹងនេះលោក ឌី រ៉ាដូ អភិបាលរងខេត្តឧត្តរមានជ័យ បាននិយាយថាពួកគេបានគ្រប់គ្រងលើពលករចំណាកស្រុកចំនួន ៧៨.១៣៤ នាក់ដោយក្នុងនោះមានស្ត្រីចំនួន ៣.៥៦១ នាក់។ លោកបន្តថា៖ «ក្នុងចំណោមនោះមានពលករចំនួន ១៣៣ នាក់វិជ្ជមានកូវីដ-១៩ និងមានអ្នកជំងឺចំនួន ៤៦ នាក់បានជាសះស្បើយ»។ លោកបន្ថែមថា ពួកគេនៅតែបន្តអនុវត្តយ៉ាងតឹងរឹងនូវការត្រួតពិនិត្យតាមព្រំដែន ដើម្បីធ្វើឲ្យប្រាកដថាអ្នកដែលបានចូលមកកម្ពុជាត្រូវបានត្រួតពិនិត្យ ធ្វើចត្តាឡីស័ក និងប្រកាន់ខ្ជាប់នូវវិធានការណ៍ការពារកូវីដ-១៩។

## ពលរដ្ឋខ្មែរ១០នាក់លួចឆ្លងដែនខុសច្បាប់ត្រូវទាហានថៃក្នុងខេត្តស្រះកែវឃាត់ខ្លួន

http://nokorwatnews.com/ 16/06/2021

ក្រុងប៉ោយប៉ែត៖ ពលករខ្មែរឆ្លងដែនខុងច្បាប់ចូលប្រទេសថៃអះអាងថា ជួលមេខ្យល់ម្នាក់៥០០បាតប្រាក់ថៃត្រូវសមត្ថកិច្ចឈុតខ្មៅ អង្គភាពលេខ១១៣របស់ថៃចាប់ឃុំខ្លួននៅបរិវេណព្រំដែនស្រុកខ្លង ហាត ខេត្តស្រះកែវ ។

សមត្ថកិច្ចតាមបន្ទាត់ព្រំដែនប្រាប់ថា:កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ មានទាហានឈុតខ្មៅលេខ១៣ បានល្បាតក្នុងភូមិសាស្ត្រទទួលខុសត្រូវ បានចាប់ឃុំខ្លួនពលករខ្មែរ ខណៈលួចឆ្លងដែនចូលប្រទេសដោយខុសច្បាប់ចំនួន១០នាក់ ក្នុងនោះប្រុស៥នាក់ ស្រី៤នាក់ និងក្មេងម្នាក់ កំពង់ដើរតាមច្រករបៀង ក្នុងឃុំខ្លងហាត ស្រុកខ្លងហាត ទើបសមត្ថកិច្ចចូលទៅចាប់ឃុំខ្លួន។សូមជំរាបថា ក្រោយពីសមត្ថកិច្ចថៃសួរនាំ ពួកគេបានឆ្លើយថា នាំគ្នាលួចធ្វើដំណើរមកពីខាងខេត្តបាត់ដំបង ចំណាយលុយឱ្យមេខ្យល់ជនជាតិខ្មែរ មិនស្គាល់ឈ្មោះ ក្នុងម្នាក់៥០០បាត ដើម្បីមកធ្វើការនៅប្រទេសថៃ។បន្ទាប់មកសមត្ថកិច្ចថៃបានអនុវត្តតាមវិធានសុខាភិបាល មុនហ្នឹងបញ្ជូនខ្លួនអ្នកទាំង១០ប្រគល់ទៅឲ្យសមត្ថកិច្ចជំនាញស្រុកខ្លងហាត ដើម្បីធ្វើកំណត់ហេតុចាប់ឃុំ និងបញ្ជូនប្រគល់ឲ្យខាងកម្ពុជាបន្ត៕

## ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១

### ពិធីចុះអនុស្សរណៈ យោគយល់គ្នា រវាងអគ្គលេខាធិការដ្ឋាន (គ.ជ.ប.ជ ) ជាមួយនិងអង្គការវីវើលអនលូស (We World Onlus) នៅប្រទេសកម្ពុជា

https://www.facebook.com/krongtepnews/ KRONG TEP NEWS ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១

(ភ្នំពេញ)៖ កាលពីរសៀលថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំនៅកម្មវិធីចុះអនុស្សរណៈ យោគយល់គ្នា រវាងគ.ជ.ប.ជ និងអង្គការវីវើលអនលូស (We World Onlus) ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ជាមួយនិងប្រធានអង្គការវីវើលអនលូស នៅប្រទេសកម្ពុជា ។ មានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន ប្រធាន និងអនុប្រធាន នៃក្រុមជំនួយកិច្ចការទាំង៦ របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ សហការីរបស់អង្គការវីវើលអនលូស និងមន្ត្រីក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន ។

អនុស្សរណៈយោគយល់នេះ មានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គជបជ និងអង្គការវីវើលអនលូស (We World Onlus) ក្នុងការរួមចំណែកធ្វើឱ្យប្រសើរឡើងនូវសិទ្ធិការងារ និងបរិយាកាសការងារប្រកបដោយសន្តិសុខ និងសុវត្ថិភាព សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលគ្មានជំនាញ និងមានជំនាញទាបនៅប្រទេសថៃ ជាពិសេសជាស្ត្រី ។ អង្គការវីវើល អនលូសមានបេសកកម្មការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សតាមរយៈគម្រោង សិទ្ធិការងារ៖ ការលើកកម្ពស់ និងការការពារសិទ្ធិការងាររបស់ពលករទេសន្តប្រវេសន៍កម្ពុជាដែលមានជំនាញទាប ក្នុងការបង្ការទប់ស្កាត់ពីការរំលោភបំពានដោយទម្រង់ណាមួយ នៃការកេងប្រវ័ញ្ចផ្សេងទៀតនៃអំពើជួញដូរមនុស្ស ឱស្របទៅនឹងយុទ្ធសាស្ត្រជាតិគ.ជ.ប.ជ ច្បាប់គោលនយោបាយ បទដ្ឋានគតិយុត្តិជាតិ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា និងប្រទេសថៃ ៕

### ពលករចំណាកស្រុក ៥២ នាក់ឆ្លងជំងឺកូវីដ-១៩នៅបន្ទាយមានជ័យ

https://www.khmertimeskh.com/ ខ្មែរថាមស៍ June 18, 2021

វេជ្ជបណ្ឌិតជួរមុខនៅខេត្តបន្ទាយមានជ័យ បានរកឃើញអ្នកវិជ្ជមានកូវីដ-១៩ ចំនួន៥២នាក់ ដោយប្រើឧបករណ៍តេស្តរហ័ស កាលពីម្សិលមិញ។ ចំណែក ២ នាក់ទៀតក៏ត្រូវបានរកឃើញនៅមណ្ឌលចត្តាឡីស័កនៅវិទ្យាល័យមង្គលបុរីស្រុកមង្គលបូរី។

លោក នង វុទ្ធី អនុប្រធានរដ្ឋបាលនៅសាលាខេត្តបន្ទាយមានជ័យ និងជាប្រធានមជ្ឈមណ្ឌលចត្តាឡីស័កបានប្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកនៅល្ងាចថ្ងៃទី ១៧ ខែមិថុនានេះថា ចាប់តាំងពីខែឧសភាមក មានករណីពល

កវខ្មែរវិលត្រឡប់មកពីប្រទេសថៃត្រូវបានរកឃើញវិជ្ជមានកូវីដ-១៩នៅក្នុងមណ្ឌលចត្តាឡីស័ក។ លោកបានបន្ថែមថា គ្រាន់តែមួយខែប៉ុណ្ណោះមនុស្សសរុប ១០០ នាក់ ត្រូវបានរកឃើញវិជ្ជមានកូវីដ-១៩។ ចាប់តាំងពីខែមិថុនា ករណីឆ្លងនៅតែត្រូវបានរកឃើញនៅខាងក្រៅសហគមន៍ស្ទើរតែរាល់ថ្ងៃ។ អ្វីដែលគួរឱ្យព្រួយបារម្ភជាងនេះទៅទៀតក្នុងរយៈពេលតែមួយថ្ងៃនៅថ្ងៃទី ១៧ មានពលករវិជ្ជមានកូវីដ-១៩ចំនួន៥២ នាក់។ រថយន្តសង្គ្រោះបន្ទាន់ជាច្រើនត្រូវបានប្រើដើម្បីដឹកពលករវិជ្ជមានកូវីដ-១៩ទាំងនោះ ។

យោងតាមរបាយការណ៍របស់លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅបានឱ្យដឹងថា ចាប់ពីដើមឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ១៧ ខែមិថុនាមានពលករខ្មែរចំនួន ៨៥.៥៤៥ នាក់ដែលបានវិលត្រឡប់មកពីប្រទេសថៃតាមច្រករបៀងអូរបាក់ ក្នុងនោះមានស្រី ៣៨៦៦ នាក់៕

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិស្ពានយោល

http://cambodiapolice.com/policekh/ 12:17 pm 17 មិថុនា 2021

ខេត្តបាត់ដំបង ៖ នាថ្ងៃព្រហស្បតិ៍ ៨កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់កម្លាំងប៉ុស្ដិ៍ព្រំដែនគីឡូ៩ ចំនួន០៤ នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ ភុន ហ៊ាង (នាយប៉ុស្ដិ៍ស្ដីទី) រួមជាមួយកម្លាំងផ្នែកសេនាធិការចំនួន០៣ នាក់ ដឹកនាំដោយលោក អនុសេនីយ៍ឯក សំ វុទ្ធី (នាយផ្នែក) សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកសំពៅលូន ចំនួន២នាក់ ដឹកនាំដោយលោកនាយចំណង់ ហ៊ី-វ៉ាន់ (មេបញ្ជាការរង ខ), កម្លាំងយោធាវរសេនាតូច ៥៣៣ ចំនួន២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ ចំរើន (មេបញ្ជាការរងគ) បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិស្ពានយោល ឃុំជ្រៃសីមា ស្រុកសំពៅលូនចំនួន៦នាក់ស្រី៣នាក់ ក្នុងនោះក្មេង១នាក់។ បន្ទាប់ពីសាកសួរ,កត់ឈ្មោះ និងអប់រំណែនាំរួចកម្លាំងយើងបានប្រគល់បងប្អូនឱយទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ៕

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិគីឡូ១៣

http://cambodiapolice.com/policekh/ 9:10 am 17 មិថុនា 2021

ខេត្តបាត់ដំបង ៖ នៅយប់ថ្ងៃពុធ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង២០ និង៣០នាទី តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានដឹកនាំកម្លាំង

នគរបាលប៉ុស្តិ៍ព្រំដែនកូនភ្នំ រួមជាមួយកម្លាំងផ្នែកស៊ើបការណ៍ ចំណុះវរសេនាតូចនគរបាលការពារព្រំដែនលេខ៨១៧ សហការជាមួយកម្លាំងយោធាកងអនុសេធំគាំទ្រ,វរសេនាតូច៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឈឹម សុភាព (មេបញ្ជាការ ខ) និងកម្លាំងយោធាកងអនុសេនុធំទី១, វរសេនាតូចលេខ២១ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ទ្បៃ លឿន (មេបញ្ជាការ ខ) បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ចំនួន ០៣នាក់។ បន្ទាប់ពីសាកសួរកត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងបានប្រគល់បងប្អូនឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ៕

## កម្ពុជារកឃើញវីរុសកូវីដ-១៩ បម្លែងថ្មី ប្រភេទ B.1.617.2 ចំនួន ៧ករណី លើពលករធ្វើដំណើរមកពីថៃ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ១៩ មិថុនា ២០២១

ក្រសួងសុខាភិបាល នៅថ្ងៃទី ១៩ ខែមិថុនានេះ បានឱ្យដឹងថា កម្ពុជារកឃើញវីរុសកូវីដ-១៩ បម្លែងថ្មី ប្រភេទ B.1.617.2 ចំនួន ៧ករណីលើអ្នកដំណើរវិលត្រឡប់មកពីប្រទេសថៃតាមច្រកព្រំដែនកម្ពុជា-ថៃ។ ក្រសួងសុខាភិបាលបញ្ជាក់ថា ករណីទី១ កើតនៅលើស្ត្រីជនជាតិខ្មែរអាយុ ២៦ ឆ្នាំ មានទីលំនៅភូមិក្របៅ ឃុំភ្នំលៀប ស្រុកព្រះនេត ព្រះ ខេត្តបន្ទាយមានជ័យ។ ក្រសួងឱ្យដឹងទៀតថា នៅខេត្តឧត្តមានជ័យកើតនៅលើខ្លួនបុរស ២ នាក់ ខេត្តសៀមរាប ចំនួន ២ ករណី ខេត្តកំពង់ចាម១ករណី និងខេត្តកំពត ១ករណី។ ក្រសួងសុខាភិបាល អំពាវនាវឱ្យប្រជាពលរដ្ឋបង្កើនការប្រុងប្រយ័ត្ន បន្តអនុវត្តវិធានការ ៣ ការពារ និង ៣ កុំ។

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៦នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី១៩ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៦នាក់ ស្រី ២៦នាក់ ក្នុងនោះកុមារា ៤ នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៦នាក់ ស្រី ៧នាក់ កុមារា ២នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៩នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣១នាក់ ស្រី ១៥នាក់ កុមារា ១នាក់ កុមារី ២នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារា ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥៦នាក់ ស្រី ២៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករចំនួន១៦នាក់ បម្រុងឆ្លងដែនខុសច្បាប់ទៅថៃ ត្រូវបានឃាត់ខ្លួន ដោយកម្លាំងវរសេនាតូចថ្មើរជើងលេខ៥១១

https://cen-news.com/ Posted ByPen Srey Neat June 20, 2021

បន្ទាយមានជ័យ ៖ ពលករចំនួន ១៦នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងវរសេនាតូចលេខ ៥១១ កងពលតូចថ្មើរជើងលេខ៥១ ឃាត់ខ្លួនបាននៅវេលាម៉ោង ១និង២៥នាទីយប់ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០២១នេះ ខណៈពេលដែលពួកគេ បម្រុងលួចឆ្លងដែនទៅប្រទេសថៃ ចំនួន ១៦នាក់ ក្នុងនោះស្រី ចំនួន ១០នាក់ ត្រង់ចំណុចភូមិសាស្ត្រ ភូមិសង្កែ ឃុំបឹងបេង ស្រុក ម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ដោយមានបទបញ្ជាពីលោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ៥១ និងដឹកនាំកម្លាំងផ្ទាល់ដោយលោកវរសេនីយ៍ត្រី លឹម វណ្ណារិទ្ធ មេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ៥១១ បានដឹកនាំកម្លាំងល្បាត ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។ ខណៈកងកម្លាំងចម្រុះល្បាត ក៏បានជួប ពលករបម្រុងលួចឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំង វរសេនាតូចថ្មើរជើងលេខ៥១១ កងពលតូចថ្មើរជើងលេខ៥១ ឃាត់ខ្លួនបានតែម្តង ។

សូមបញ្ជាក់ថា ក្រោយពីឃាត់ខ្លួនបាន លោកមេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ៥១១ ក៏បានណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំបន្តចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣កុំ ៣ការពារ អោយបានទាំងអស់គ្នា។ បច្ចុប្បន្នពលករទាំង១៦នាក់ ត្រូវបានបញ្ជូនទៅអធិការដ្ឋាននគរបាល ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងបន្តស្រាវជ្រាវរកមេខ្យល់ និងអ្នកពាក់ព័ន្ធចាត់វិធានការតាមផ្លូវច្បាប់៕ ដោយ៖បញ្ញាស័ក្តិ

## ពលករខ្មែរ ៦ នាក់ជួបគ្រោះថ្នាក់ចរាចរណ៍ត្រូវរថយន្តបុកស្លាប់ ៣ នាក់នៅប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ២០ មិថុនា ២០២១ ដោយ deth leng

ពលករខ្មែរចំនួន ៣ នាក់ បានស្លាប់បាត់បង់ជីវិត និង៣នាក់ផ្សេងទៀត រងរបួស ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ ត្រូវរថយន្តបុករ៉ះ ក្នុងចំណោមពលករជាច្រើននាក់។ ហេតុការណ៍ដ៏រន្ធត់នេះបានកើតឡើងកាលពីវេលាម៉ោង ៥ និង ៣០ នាទី ល្ងាចថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ ត្រង់ចំណុចកណ្តាលស្ពាន ឆ្លងព្រែកព្រះអង្គចៅ ក្នុងខេត្តសមុទ្រប្រាកាន ប្រទេសថៃ។

ប្រភពពីបណ្តាញព័ត៌មានក្នុងស្រុកបានបញ្ជាក់ថា នៅមុនពេលកើតហេតុគឺមានរថយន្តមួយគ្រឿងម៉ាកនីសាន់ ព៌ណក្រហម ពាក់ស្លាកលេខ បាងកក៩០៦៤ បានបើកបរឡើងស្ពានយ៉ាងលឿន លុះនៅពេលពើបប្រទះជាមួយនឹងស្លាកសញ្ញាការដ្ឋាន រថយន្តនេះក៏បានបួងចង្កូតទៅម្ខាង បណ្តាលអោយបុករ៉ះទៅលើកម្មករស្រីៗដែលកំពុងគូសគំនូសលឿងនៅលើផ្លូវ ធ្វើអោយស្លាប់៣នាក់ និងរបួសធ្ងន់៣នាក់ ដែលពួកគេទាំងអស់គឺជាពលករខ្មែរ។ ភ្លាមៗនោះដែរសព និងអ្នករបួស ត្រូវបានតម្រួតថៃបញ្ចូលទៅរក្សាទុក និងបញ្ជូនទៅព្យាបាលនៅឯមន្ទីរពេទ្យ ឡាតក្រាក់បាំង និងមន្ទីរពេទ្យ ជុឡាវ៉ាត់៨៕ អត្ថបទ៖សោ និយមរ័ត្ន

## សមត្ថកិច្ចថៃបន្តចាប់ពលករខ្មែរបញ្ជូនមកកម្ពុជាវិញ

http://nokorwatnews.com/ 18/06/2021

ក្រុងប៉ោយប៉ែត៖ កងកម្លាំងការពារព្រំដែនរបស់ថៃ បន្តចាប់ឃុំខ្លួនពលករខ្មែរបន្ថែម១១នាក់ទៀតដែលលួចឆ្លងដែនខុសច្បាប់ចូលមកស្រុកតា ព្រះយ៉ា ខេត្តស្រះកែវ។ សមត្ថកិច្ចថៃឈរជើងតាមព្រំដែនរាយការណ៍ថា កាលពីវេលាម៉ោង១២និង១៧នាទី ថ្ងៃទី១៧ មិថុនា ២០២១ សមត្ថកិច្ចថៃប្រចាំស្រុកតា ព្រះយ៉ា នៃកងកម្លាំងបូរផា សហការជាមួយនគរបាលការពារព្រំដែនទី១២ បានចាប់ឃុំខ្លួនពលករខ្មែរ ដែលលួចឆ្លងដែនចូលថៃដោយខុសច្បាប់បានចំនួន១១នាក់បន្ថែមទៀត ក្នុងនោះមានប្រុស៤ នាក់។

សមត្ថកិច្ចខាងលើបញ្ជាក់ថា កាលពីរំលងអធ្រាត្រ ឈានចូលថ្ងៃទី១៧ មិថុនា ២០២១ សមត្ថកិច្ចថៃស្រុកតា ព្រះយ៉ា ក៏បានចាប់ឃុំខ្លួនពលករខ្មែរ ដែលលួចឆ្លងដែនដោយខុសច្បាប់ចូលក្នុងប្រទេសបានចំនួន១២នាក់ផងដែរ។ ពលករខ្មែរខាងលើ បានលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ដែលមិនមានមេខ្យល់នាំផ្លូវ និងមានគោលបំណងទៅធ្វើការនៅក្នុងខេត្តមួយចំនួន របស់ប្រទេសថៃ។ បន្ទាប់មកសមត្ថកិច្ចធ្វើកំណត់ហេតុនិងអនុវត្តតាមវិធានរបស់សុខាភិបាលដោយបញ្ជូនបន្តទៅឲ្យជំនាញ ដើម្បីចាត់ការតាមច្បាប់ និងបញ្ជូនមកប្រទេសកម្ពុជាវិញតាមច្រកអូរបីជាន់ក្នុងស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ៕

## ពលករខ្មែរចាញ់បោកមេខ្យល់លួចឆ្លងដែនខុសច្បាប់ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួន បញ្ជូនមកកម្ពុជាវិញ

http://nokorwatnews.com/ 18/06/2021

ខេត្តបន្ទាយមានជ័យ៖ សមត្ថកិច្ចទាហានឈុតចំពោះកិច្ចតាព្រះយ៉ា កងកម្លាំងបូរផា សហការជាមួយកម្លាំងនគបាលល្បាតព្រំដែនកាលពីវេលាម៉ោង១២៖១២នាទី យប់រំលងអធ្រាត្រ ឈានចូលថ្ងៃទី១៧ មិថុនា ឆ្នាំ ២០២១ នេះ។ សមត្ថកិច្ចតាមបន្ទាត់ព្រំដែនប្រាប់ថា ពលករខ្មែរ១២នាក់ ដែលលួចឆ្លងដែនចូលប្រទេសថៃខុសច្បាប់ នៅបរិវេណក្នុងតំបន់ទទួលខុសត្រូវ ក្នុងនោះមានប្រុស៦នាក់ និងស្រី៦នាក់ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួន។

សមត្ថកិច្ចបញ្ជាក់ថា បានប្រទះឃើញក្រុមពលករខាងលើ កំពុងដើរឆ្លងថ្នល់សំដៅមកទិសខាងលិចនៅបរិវេណភូមិទ័ពសៀម ឃុំតាព្រះយ៉ា ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ ដោយប្រើច្រករបៀង និងមានមេខ្យល់ជនជាតិខ្មែរម្នាក់មិនស្គាល់ឈ្មោះ ជាអ្នកនាំផ្លូវ ដោយចំណាយលុយឲ្យមេខ្យល់ក្នុងម្នាក់៦.០០០បាត ដើម្បីទៅធ្វើការនៅតាមបណ្តាខេត្តរបស់ថៃ។យ៉ាងណាក៏ដោយ ក្រោយចាប់ឃុំខ្លួនពលករខ្មែរទាំងអស់ សមត្ថកិច្ចបានអនុវត្តតាមវិធានរបស់សុខាភិបាល បន្ទាប់មកបញ្ជូនទៅឲ្យជំនាញធ្វើកំណត់ហេតុចាប់ឃុំខ្លួន ដើម្បីចាត់ការតាមច្បាប់ និងបញ្ជូនចេញពីប្រទេស របស់ខ្លួនតាមច្រកអូរបីជាន់ ក្នុងស្រុកអូជ្រៅខេត្តបន្ទាយមានជ័យ ៕

## ថៃឃាត់ខ្លួនពលករខ្មែរឆ្លងដែនខុសច្បាប់១២នាក់

https://www.rasmeinews.com/ 17 June, 2021

**ដោយ: ភ្នំស្វាយ/ព្រំដែនកម្ពុជា-ថៃ:** *នៅថ្ងៃទី១៧ ខែមិថុនាឆ្នាំ២០២១ វេលាម៉ោង ២ រំលងអាធ្រាត្រពលករខ្មែរខុសច្បាប់មានចំនួនសរុប ១២ នាក់ ត្រូវសមត្ថកិច្ច និងកងកម្លាំងថៃឃាត់ខ្លួន នៅចំណុច ភូមិថាសសៀម អនុតាតាវង ស្រុកតាផៃ ខេត្តស្រះកែ រប្រទេសថៃ ។*

ប្រភពព័ត៌មានពីកងកម្លាំងថៃបានឱ្យដឹងថា មានមេខ្យល់ខ្មែរ ដែលមិនស្គាល់ឈ្មោះ បាននាំពលករដើរពីកម្ពុជាទៅថៃ ដោយចំណាយបង់ថវិកាក្នុងម្នាក់ៗ ហើយបូកចូលគ្នាសរុប ៦.០០០ បាត ដើម្បីបានទៅធ្វើការនៅប្រទេសថៃ ។ ប្រភពដដែលបានបន្តថា ៖ គោលដៅទី ១. ទៅធ្វើការនៅទីក្រុងបាងកក មានមនុស្ស ៤ នាក់ ដែល

ចង់ទៅធ្វើការសំណង់៣នាក់ និងដេរ១នាក់ ។ ២. ទៅខេត្តប៉ាធូមថានី ២ នាក់ គឺចង់ទៅធ្វើការក្នុងវិស័យសំណង់ ។ ៣.ទៅខេត្តសាមុតប្រាកាន៥នាក់ ចង់ទៅធ្វើការសំណង់។ ៤.ទៅខេត្តរ៉ាក់យ៉ង មាន១នាក់ ចង់ធ្វើការផ្នែកសំណង់។ ក្រោយឃាត់ខ្លួន និងធ្វើកំណត់ហេតុកងកម្លាំងសមត្ថកិច្ច និងគ្រូពេទ្យជួរមុខថៃបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការបង្ការប្រឆាំងនឹងកូវីដ១៩ ដោយបញ្ជូនទៅធ្វើចត្តាឡីស័ក និងរៀបចំធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ ៕

# ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ សហការឃាត់ខ្លួនពលរដ្ឋខ្មែរ ១៦នាក់ធ្វើការអប់រំ បម្រុងឆ្លងដែនទៅប្រទេសថៃ

http://cambodiapolice.com/policekh/ 8:56 pm 20 មិថុនា 2021

បាត់ដំបង ៖ ប្រជាពលរដ្ឋខ្មែរចំនួន១៦នាក់ (ស្រីចំនួន១០នាក់) ជឿតាមមេខ្យល់បម្រុងឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ត្រូវបានកម្លាំងសមត្ថកិច្ចចម្រុះឃាត់ខ្លួនធ្វើការអប់រំ ត្រង់ចំណុចភូមិសាស្រ្តភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ នៅវេលាមព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ ។

លោក សឹង្ហ ទុំ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១១បានឲ្យដឹងថា កម្លាំងវរសេនាតូចថ្មើរជើងលេខ ៥១១ ដឹកនាំកម្លាំងផ្ទាល់ដោយ លឹម វណ្ណារិទ្ធ បាន ល្បាត២៤ម៉ោងលើ២៤ម៉ោងប្តូរវេនគ្នា សហការជាមួយកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលទៅក្នុងសហគមន៍ ។ លោកបន្តថា ខណៈកងកម្លាំងចម្រុះល្បាត ក៏បានជួបប្រជាពលរដ្ឋខ្មែរបម្រុងលួចឆ្លងដែនចេញទៅប្រទេសថៃ ចំនួន១៦នាក់ (ស្រី១០នាក់) ហើយបានធ្វើការឃាត់ពួកគាត់ ។ ក្រោយពីឃាត់ខ្លួន កម្លាំងបាន ណែនាំពួកគាត់កុំបន្តចាញ់បោកមេខ្យល់ដែលតែងតែបញ្ចុះបញ្ចូល នាំឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣កុំ ៣ការពារ ឲ្យបានទាំងអស់គ្នា។ ក្រោយពីអប់រំរួច បានបញ្ជូនពួកគាត់ទៅអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងបន្តស្រាវជ្រាវរកមេខ្យល់ចាត់វិធានការតាមផ្លូវច្បាប់ ៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ចុះល្បាតការពារសន្តិសុខ សណ្តាប់ធ្នាប់តាមខ្សែបន្ទាត់ព្រំដែន

http://cambodiapolice.com/policekh/ 8:59 am 20 មិថុនា 2021

ខេត្តបាត់ដំបង ៖ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារុជ ស្នងការរង ទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ នៅថ្ងៃសៅរ៍ ១០កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនគីឡូ១៣ ដឹកនាំដោយលោក អនុសេនីយ៍ទោ ម៉ឹង ម៉េត នាយប៉ុស្តិ៍ស្តីទី ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធា បានចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្រ្តប៉ុស្តិ៍គ្រប់គ្រង ចំណុចភូមិឈើទាល ឃុំសិ រីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ដល់ចំណុចភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុក សំពៅលូន ខេត្តបាត់ដំបង ៕

## វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧សហការទទួលពលករខ្មែរត្រឡប់មកពីប្រទេសថៃចំនួន២នាក់ បញ្ជូនទៅធ្វើចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 2:33 pm 20 មិថុនា 2021

ខេត្តបាត់ដំបង៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក៏ដូចជាយោបល់លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ ។

ជាក់ស្តែង នៅថ្ងៃអាទិត្យ ១១កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង សហការជាមួយកម្លាំងយោធាទៅទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចរមណីយដ្ឋានទឹកធ្លាក់ភ្នំ(៥៣)នៃភូមិសាស្ត្រភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ចំនួន១នាក់(ស្រី)។ បន្ទាប់ពីធ្វើការសាកសួរ កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងយើងបានប្រគល់រូបគាត់ឱ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កវិទ្យាល័យពេជ្រចិន្តា ស្រុកភ្នំព្រឹក និងត្រង់ចំណុចនៃភូមិសាស្ត្រភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ចំនួន ១នាក់ (ស្រី) ។ បន្ទាប់ពីធ្វើការសាកសួរ និងអប់រំណែនាំរួច សមត្ថកិច្ចបានប្រគល់ជូន ក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៤នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអាទិត្យ ទី២០ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៤នាក់ ស្រី ១៩នាក់ ក្នុងនោះកុមារា ៤នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៥នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤នាក់ ស្រី ១នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣៨នាក់ ស្រី ១៥នាក់ កុមារា ៣នាក់ កុមារី ២នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៦នាក់ ស្រីចំនួន ២នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥៤នាក់ ស្រី ១៩នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែន នីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករខ្មែរ៩នាក់ ត្រូវទាហានឈុតខ្មៅថៃឃាត់ខ្លួនក្បែរបន្ទាត់ព្រំដែន

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២១ មិថុនា ២០២១ដោយ KC Virak

ខេត្តបាត់ដំបង៖ ពលករខ្មែរប្រុសស្រីចំនួន០៩នាក់ ត្រូវបានកម្លាំងយោធាឈុតខ្មៅ នៃវរការពារព្រំដែនថៃលេខ១២ ឃាត់ខ្លួន ខណៈពលករទាំងនោះលួចឆ្លងដែនដោយខុសច្បាប់ចូលទៅក្នុងទឹកដីថៃ។ ដោយសារប្រទេសថៃ មានការទប់ស្កាត់បទល្មើសឆ្លងដែន និងការការពារ ទប់ស្កាត់ការឆ្លង រីករាលដាលនៃជំងឺកូវីដ-១៩ ផងនោះ នៅរសៀលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ កម្លាំងយោធាថៃដែលឈរជើងតាមបន្ទាត់ព្រំដែនបានចុះទប់ស្កាត់ពលករខ្មែរដែលលួចឆ្លងដែនចូលទឹកដីថៃដោយខុសច្បាប់ ត្រង់ចំណុច ឃុំខ្លងហាត ស្រុកខ្លងហាត ខេត្តស្រះកែវ មានចំនួន៩នាក់ ក្នុងនោះមាន ស្រី០៣នាក់ និងប្រុស០៦នាក់។

តាមការសារភាពរបស់ពលករទាំងនោះបាននិយាយថា ពួកគេបានធ្វើដំណើរតាមច្រករបៀង ដោយត្រៀមបង់លុយទៅឱ្យមនុស្សម្នាក់ដើម្បីនាំផ្លូវ ដោយក្នុងម្នាក់ៗបង់អស់ ៧,០០០បាត ក្នុងគោលបំណងឱ្យជូនទៅរកការងារធ្វើ ឱ្យដល់ទីកន្លែង ដូចជារោងចក្រធ្វើសារម៉ាវកំប៉ុង ការងារសំណង់នៅខេត្តប៉ាធុមថានី រោងចក្រកែច្នៃមាន់នៅខេត្តឈុនបុរី និងនៅខេត្តរ៉ាក់យ៉ង ក្នុងប្រទេសថៃ។ បច្ចុប្បន្ន ពលករខ្មែរទាំង០៩នាក់ត្រូវបានបញ្ជូនទៅកាន់អង្គភាពដើម្បីអនុវត្តតាមនីតិវិធីមុននឹងបញ្ជូនឱ្យត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ៕ អត្ថបទ៖ សោ និយមវ័ត្ន

## មេខ្យល់និងអ្នកពាក់ព័ន្ធ៦នាក់បាននាំមនុស្សឆ្លងដែនត្រូវកងកម្លាំងការពារព្រំដែនឃាត់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២១ មិថុនា ២០២១ដោយ Sorn Phanith

នគរបាលការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបញ្ជូនមេខ្យល់៣នាក់ ក្នុងនោះមានអ្នកពាក់ព័ន្ធ៣នាក់ នាំមនុស្សឆ្លងដែនមិនស្របច្បាប់ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១នេះ។

លោកវរសេនីយ៍ទោ បោន ស៊ីហា អធិការស្ដីទី បានឲ្យដឹងថាមេខ្យល់៦នាក់ និងពលករខ្មែរសរុបចំនួន១២នាក់ ត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៩១១ ធ្វើការឃាត់ខ្លួននៅចំណុចអូរព្រំដែន នៅវេលាម៉ោង៣និង៤៥នាទីរសៀលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ ដោយក្នុងនោះមាន វត្ថុតាងទូរសព្ទដៃ៦គ្រឿង កង់បីឥណ្ឌា ១គ្រឿងនិងម៉ូតូ០២គ្រឿង។ លោកវរសេនីយ៍ទោ បោន ស៊ីហា អធិការស្ដីទីបានបញ្ជាក់ឲ្យដឹងទៀតថាមេខ្យល់ទាំង៦នាក់ ១. ឈ្មោះ សុខា រ៉ាវុធ ភេទប្រុស អាយុ២០ឆ្នាំ ស្នាក់នៅភូមិបាលិលេយ្យ សង្កាត់និងក្រុងប៉ោយប៉ែត, ២. ឈ្មោះ ខេមរា សូរ៉ាវីត ហៅម៉ៅ ភេទប្រុស អាយុ៣២ឆ្នាំ ស្នាក់នៅភូមិក្បាលស្ពាន២ សង្កាត់និងក្រុងប៉ោយប៉ែត, ៣. ឈ្មោះ លី វ៉ន ភេទប្រុស អាយុ១៧ឆ្នាំ ស្នាក់នៅភូមិព្រៃព្រិច សង្កាត់និងក្រុងប៉ោយប៉ែតទាំង៣នាក់នេះជាមេខ្យល់។ ៤. ឈ្មោះ ដឹង ហៅ ណាន ភេទប្រុស អាយុ១៧ឆ្នាំ ស្នាក់នៅភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្ដាលក្រុងប៉ោយប៉ែត, ៥. ឈ្មោះ ប៉ែន ធៃណាម ភេទប្រុស អាយុ១៨ឆ្នាំ ស្នាក់នៅភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្ដាលក្រុងប៉ោយប៉ែត, ៦. ឈ្មោះ ឃួម សឿម ភេទប្រុសអាយុ ៣៥ឆ្នាំ នៅភូមិសាមគ្គីមានជ័យ សង្កាត់និងក្រុងប៉ោយប៉ែត ៣នាក់នេះជាអ្នកពាក់ព័ន្ធដឹកជញ្ជូនពលករដើម្បីឆ្លងដែន។

លោកស្រីវរសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារ នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា មេខ្យល់ចំនួន៣នាក់ និងអ្នកពាក់ព័ន្ធចំនួន៣នាក់ ត្រូវបានកម្លាំងនគរបាលជំនាញ

ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធីច្បាប់នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១នេះហើយដែរ ចំណែកប្រជាពលរដ្ឋទាំង៦នាក់ បញ្ជូនទៅធ្វើចត្តាឡីស័ក នៅវិទ្យាល័យនិមិត្ត ក្នុងសង្កាត់និមិត្ត ក្រុងប៉ោយប៉ែត៕ **អត្ថបទ៖ វ៉ាន់ ណាង**

## មេខ្យល់ម្នាក់ នាំចេញពលករដោយខុសច្បាប់ ទៅប្រទេសថៃ ត្រូវប៉េអឹមបញ្ជូនទៅតុលាការ

https://cen-news.com/ Posted ByPen Srey NeatJune 21, 2021

បន្ទាយមានជ័យ ៖ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ សហការជាមួយកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ បានចុះល្បាតតាមបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដើម្បីទប់ស្កាត់ការនាំចេញពលករដោយខុសច្បាប់ ទៅប្រទេសថៃ រហូតដល់ចំណុចភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ វេលាម៉ោង១៩ និង៤០នាទី បានប្រទះឃើញប្រជាពលរដ្ឋជាច្រើននាក់បម្រុងឆ្លងដែន ឃើញដូច្នេះកម្លាំងយើងបាននាំគ្នាបម្រុងហៅមកសួរនាំ ស្រាប់តែប្រជាពលរដ្ឋទាំងអស់នោះនាំគ្នារត់គេចខ្លួន ពេលនោះកម្លាំងយើងឃាត់បានពលករម្នាក់ ហើយនាំមកមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ ដើម្បីសួរនាំអំពីរឿងហេតុ។

លោកវរសេនីយ៍ត្រី តាំង សុខហេង មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថស្រុកបានឱ្យដឹងថា តាមការស្តាប់ចម្លើយ របស់ពលករទើបកំណត់មុខសញ្ញាមេខ្យល់បាន ហើយកម្លាំងចម្រុះរបស់យើង បន្តធ្វើការស្រាវជ្រាវរហូតដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ ទើបឃាត់ខ្លួនបានមេខ្យល់ម្នាក់ឈ្មោះ គង់ ពៅ ហៅ ឃ្លោក ភេទប្រុស អាយុ ៤៦ឆ្នាំ បច្ចុប្បន្ន រស់នៅភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ហើយបញ្ជូនមកបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថស្រុក ដើម្បីសាកសួរចម្លើយ។ លោកវរសេនីយ៍ត្រី តាំង សុខហេង បានឱ្យដឹងទៀតថា ក្រោយពីសាកសួរចម្លើយរួចមក បានឆ្លើយសារភាពថា ខ្លួនពិតជាបាននាំពលករបម្រុងឆ្លងដែន ទៅប្រទេសថៃពិតប្រាកដមែនកាលពីថ្ងៃទី១៣ ខែមិថុនា កន្លងមកនេះ តែត្រូវបានកម្លាំងចម្រុះ ធ្វើសកម្មភាពបង្ក្រាបទាន់ពេលវេលា។ ដោយផ្អែកលើការស្តាប់ចម្លើយរបស់ពលករ និងស្តាប់ចម្លើយសារភាពរបស់មេខ្យល់ ទើបកម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ កសាងសំណុំរឿងបញ្ជូន មកបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តចាត់ការបន្ត ចំណែកពលករត្រូវបានបញ្ជូន ទៅមណ្ឌលធ្វើចត្តាឡីស័កស្រុកម៉ាឡៃតាំងពីថ្ងៃទី១៣ ខែមិថុនា ម្ល៉េះ។

លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត ទទួលការងារយុត្តិធម៌បានឱ្យដឹងថា ការឃាត់ខ្លួនជនសង្ស័យខាងលើ ដោយទទួលបានការអនុញ្ញាត ពីលោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្តផងដែរ បច្ចុប្បន្នជនសង្ស័យខាងលើ ត្រូវបានកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស បញ្ជូនទៅសាលាដំបូងខេត្តចាត់ការតាមនីតិវិធីហើយ ៕រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

# ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១

## រដ្ឋបាលខេត្តកំពង់ឆ្នាំង បើកកិច្ចប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារប្រចាំឆមាសទី១ និងលើកទិសដៅការងារអនុវត្តបន្តឆ្នាំ២០២១ របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://gdlf-kh.com/ Sam Sophearum កំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង៖ ថ្ងៃចន្ទ ១២កើត ខែ បឋមាសាឍ ឆ្នាំ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០២១ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង បើកកិច្ចប្រជុំបូកសរុបលទ្ធផលសកម្មភាពការងារប្រចាំឆមាសទី១ និងទិសដៅការងារអនុវត្តបន្តឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ ប៊ិន សុភី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើ

ជួញដូរមនុស្ស គ.ខ.ប.ជ ខេត្តកំពង់ឆ្នាំង នៅសាលប្រជុំ "ខ ៣" សាលាខេត្តកំពង់ឆ្នាំង។ ដោយមានការចូលរួមពី នាយករងរដ្ឋបាលសាលាខេត្ត នាយកទីចាត់ការរដ្ឋបាលសាលាខេត្ត សមាជិក សមាជិការលេខាធិការដ្ឋាន គ.ខ.ប .ជ មន្ទីរ អង្គភាពពាក់ព័ន្ធ លោកស្រី អភិបាលរងក្រុង ស្រុក។

បន្ទាប់ពីស្តាប់របាយការណ៍របស់អង្គប្រជុំរួចមក លោកជំទាវ ប៊ិន សុភី ប្រធានអង្គប្រជុំមានប្រសាសន៍ថា ដើម្បីទទួលបានភាពជោគជ័យ និងប្រសិទ្ធភាពក្នុងការអនុវត្តការងារសម្រេចនូវភារកិច្ច និងផែនការថ្មីៗ ដែលគណៈកម្មាធិការបានប្រគល់ជូន សមាជិក សមាជិកា ទាំងអស់ត្រូវមានការសហការគ្នាឱ្យខ្លាំងជាងនេះបន្តទៀត ជាពិសេស សហការជាមួយមន្ត្រីជំនាញ អាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ សង្កាត់ ដែលជាអ្នករស់នៅជិតប្រជាពលរដ្ឋជាប្រចាំងាយស្រួលដោះស្រាយពេលជួបបញ្ហាផ្សេងៗ ក្នុងនោះត្រូវរាយការណ៍ និងរៀបចំរបាយការណ៍ឱ្យបានរៀងរាល់ខែ ដើម្បីក្រុមការងារលេខាធិការដ្ឋានបូកសរុបជូនគណៈកម្មាធិការ។ លោកជំទាវ បានមានប្រសាសន៍បញ្ជាក់បន្ថែម ដល់ក្រុមការងារធ្វើយ៉ាងណា ឱ្យប្រជាពលរដ្ឋយល់កាន់តែច្បាស់ពីផលប៉ះពាល់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន បណ្តុះការស្រលាញ់ការងារដាំដំណាំ កសិកម្មនៅមូលដ្ឋាន វិញ។ ចូលរួមទប់ស្កាត់ មិនចូលរួមក្នុងចលនាបាស់បោរខុសច្បាប់ និងរាយការណ៍ជាបន្ទាន់ចំពោះ មេខ្យល់អូសទាញ តាមគ្រប់រូបភាព ព្រមទាំងចូលរួមថែរក្សាការពារសន្តិភាព ថែរក្សាកូនចៅ ជៀសវាងការរំលោភបំពានផ្លូវភេទ លើស្ត្រីកុមារ និងការពារខ្លួនពីជំងឺផ្សេងៗ ជាពិសេសជំងឺកូវីដ-១៩ ដែលកំពុងរីករាលដាលទូទាំងសកលលោក ត្រូវតែប្រុងប្រយ័ត្ន និងអនុវត្តតាមវិធានការ របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានជាប្រចាំ ៕

## អាជ្ញាធរខេត្តឧត្តរមានជ័យ រកឃើញអ្នកជំងឺកូវីដ១៩ ចំនួន១១នាក់ ជាពលករមកពីប្រទេសថៃ

http://freshnewsasia.com/ 2021-06-22 09:15pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១នេះ បានប្រកាសពីការរកឃើញអ្នកជំងឺកូវីដ១៩ ចំនួន១១នាក់ថ្មីបន្ថែម ដែលជាពលករមកពីប្រទេសថៃ និងករណីជាសះស្បើយចំនួន ០៣នាក់។ នេះបើតាមសេចក្តីប្រកាសព័ត៌មាន ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាន។ បច្ចុប្បន្ន អ្នកជំងឺកូវីដ១៩ ចំនួន៨នាក់ ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមណ្ឌលព្យាបាលផ្ទះសំណាក់ឧត្តមរដ្ឋា ០២នាក់ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្ត និងចំនួន ០១នាក់ទៀត ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរ ពេទ្យបង្អែកស្រុកអន្លង់វែង។ ដោយឡែកអ្នកពាក់ព័ន្ធដែលមានហានិភ័យខ្ពស់ផ្សេងទៀត ត្រូវបានបញ្ជូនទៅតាមដានសុខភាព និងធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យតេជោ សែនសំពេង។ ក្រុមការងារបន្តស្រាវជ្រាវរកអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីចាត់ចែងតាមនីតិវិធី។

សូមជម្រាបជូនថា មកទល់ពេលនេះខេត្តឧត្តរមានជ័យ មានអ្នកជំងឺកូវីដ១៩ ចំនួន ២០០នាក់ ករណីជានាំចូលពីបរទេសចំនួន ១៦៥នាក់ និងករណីពាក់ព័ន្ធព្រឹត្តិការណ៍ «សហគមន៍ ២០ កុម្ភៈ» ចំនួន ៣៥នាក់ បានព្យាបាលជាសះស្បើយចំនួន ៩០នាក់ ករណីស្លាប់ចំនួន ០២នាក់ និងកំពុងសម្រាកព្យាបាលចំនួន ១០៨នាក់ (នៅមន្ទីរពេទ្យបង្អែកខេត្តចំនួន ២០នាក់ នៅមណ្ឌលព្យាបាលផ្ទះសំណាក់ឧត្តមរដ្ឋចំនួន ៧០នាក់ និងនៅមន្ទីរពេទ្យបង្អែកស្រុកអន្លង់វែងចំនួន ១៨នាក់)៕

## ពលករខ្មែរ១០នាក់លួចឆ្លងដែនខុសច្បាប់ ត្រូវបានឃាត់ខ្លួន

https://www.rasmeinews.com/ 23 June, 2021

**ដោយៈគ្រញូង/បាត់ដំបង៖** នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ នៅចំណុចភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង សមត្ថកិច្ចនគរបាលវរៈការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាសឹករងស្រុកសំពៅលូនរួម និងមន្ត្រីយោធាទំនាក់ទំនងព្រំដែន បានធ្វើការស្ទាក់ចាប់ពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន១០នាក់។ ការឃាត់ខ្លួនពលករទាំង១០នាក់នេះ ខណៈពេលពួកគាត់ កំពុងលួចឆ្លងដែនតាមច្រករបៀងមួយកន្លែងនៅទីតាំងខាងលើ។ ក្រោយពីការឃាត់រួច សមត្ថកិច្ចបាននាំពលករខ្មែរទាំងនោះ យកទៅប៉ុស្តិ៍នគរបាលវរៈសេនាតូចការពារព្រំដែនគីឡូ១៣ ដើម្បីធ្វើការសាកសួរ និងបន្តស្រាវជ្រាវរកមេខ្យល់ រួចបញ្ជូនទៅឱ្យក្រុមគ្រូពេទ្យជំនាញដើម្បីធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៩នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអង្គារ ទី២២ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៩នាក់ ស្រី ១៤នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៨នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៥នាក់ ស្រី ៩នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ៣នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៣នាក់ ស្រីចំនួន ១នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៩នាក់ ស្រី ១៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ២០ថ្ងៃ រកឃើញកូវីដ-១៩លើពលករមកពីថៃតាមច្រកខេត្តឧត្តរមានជ័យ ១៧៩នាក់ បីនាក់ប្រភេទថ្មី

https://news.btv.com.kh/ 06/22/2021 03:06 PM

ឧត្តរមានជ័យ ៖ រយៈពេល២០ថ្ងៃ ក្នុងខែមិថុនានេះ មានការរកឃើញអ្នកវិជ្ជមានកូវីដ-១៩ ចំនួន១៧៩នាក់ លើពលករខ្មែរឆ្លងដែនមកពីថៃ តាមច្រកខេត្តឧត្តរមានជ័យ ក្នុងនោះអ្នកឆ្លងមេរោគបំប្លែងថ្មីប្រភេទB-1-617-2 ( Daalta ) ដែលជាប្រភេទមកពីឥណ្ឌានោះ មានចំនួនបីនាក់។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាល ខេត្តឧត្តរមានជ័យ បានឱ្យដឹងថា ពលករឆ្លងដែនមកពីថៃ តាមច្រកខេត្តឧត្តរមានជ័យ ក្នុងខែមិថុនានេះ មានចំនួនកើនឡើងដល់៤០៩០នាក់។ លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា ការរកឃើញមេរោគបំប្លែងខ្លួនថ្មី មានប្រភពមកពីឥណ្ឌាលើពល ករមកពីថៃ គឺជាក្តីបារម្ភមួយថ្មីដែលទាមទារឱ្យអាជ្ញាធរមានសមត្ថកិច្ច ដែលកំពុងឈរជើងនៅតាមច្រក ព្រំដែនទាំងអស់ បង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងវំហូរចូលនៃពលករ ដោយត្រូវពិនិត្យសុខភាព ពួកគេឱ្យបានហ្មត់ចត់។ លោក បានស្នើដល់អាជ្ញាធរខេត្តឧត្តរមានជ័យ ត្រូវផ្តល់ព័ត៌មានឱ្យបានឆាប់រហ័ស ក្នុងករណីមាន ការពាក់ព័ន្ធនឹងអ្នកមានវិជ្ជមានកូវីដ-១៩ ក្នុងមូលដ្ឋានរបស់ខ្លួន៕ អត្ថបទ៖ ឃិន សារិទ្ធ

## ពលករខ្មែរ២២នាក់ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួន ខណៈពួកគេចាញ់បោកមេខ្យល់យកទៅបោះបង់ចោល

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២២ មិថុនា ២០២១ដោយ KC Virak

ពលករខ្មែរប្រុសស្រីចំនួន២២នាក់ ត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួនក្រោយពីពួកគេបានចូលទៅរកការងារធ្វើតាមមេខ្យល់ ដោយម្នាក់ៗចំណាយលុយឱ្យមេខ្យល់អស់រាប់ពាន់បាត ហើយមេខ្យល់នាំយកទៅបោះបង់ចោលក្នុងប្រទេសថៃ ទើបសមត្ថកិច្ចថៃឃាត់ខ្លួនតែម្តង។

បើយោងតាមសេចក្តីរាយការណ៍ពីប្រភពនៅប្រទេសថៃបានឱ្យដឹងថា សមត្ថកិច្ចនៃខេត្តស្រះកែវបានឃាត់ខ្លួនពលករខ្មែរទាំង២២នាក់នោះនៅវេលាម៉ោង០៤:៣០នាទីទៀបភ្លឺ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១នេះ ដោយសមត្ថកិច្ចថៃព្រំដែនតាប្រាយ៉ា ខេត្តស្រះកែវ។ សមត្ថកិច្ចថៃប្រាប់ដល់ប្រភពបន្តថា ពលករខ្មែរទាំង២២នាក់នោះមានស្រី១១នាក់ និងប្រុសចំនួន១១នាក់ ដែលពលករទាំងនេះត្រូវបានមេខ្យល់នាំឆ្លងដែនខុសច្បាប់តាមច្រករបៀង ដើម្បីចូលមកប្រទេសថៃ តែត្រូវសមត្ថកិច្ចថៃចាប់បាននៅចំណុចភូមិលូកឆាង ឃុំតាប្រាយ៉ា ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ។

បើយោងតាមការសារភាពរបស់ពលករខ្មែរទាំង២២នាក់ បានប្រាប់សមត្ថកិច្ចថៃថា ពួកគេធ្វើដំណើរទៅធ្វើការនៅកន្លែងមួយចំនួនផ្សេងៗគ្នានៅទីក្រុងបាងកក ប្រទេសថៃ ដោយត្រូវចំណាយលុយឱ្យមេខ្យល់នាំផ្លូវក្នុងម្នាក់ចំនួន៦,០០០ ទៅ៨,០០០បាត ដោយមេខ្យល់សន្យាថានឹងជូនពួកគាត់ដល់កន្លែងធ្វើការរៀងៗខ្លួនតែម្តង។ក្រោយសមត្ថកិច្ចថៃសួរនាំរួចពលរដ្ឋខ្មែរជាពលករទាំង២២នាក់នោះត្រូវបានសមត្ថកិច្ចថៃបញ្ជូនឱ្យមកកម្ពុជាវិញ តាមច្រករបៀងក្នុងស្រុកគោកខ្លូង អូរបីជាន់ដើម្បីឱ្យសមត្ថកិច្ចកម្ពុជាទទួលយកចាត់ការបន្តតាមផ្លូវច្បាប់៕ សៅ សារិទ្ធ

## ចាប់មិនចេះអស់! នៅតែមានការលួចឆ្លងដែនពីថៃមកកម្ពុជា និងពីកម្ពុជាទៅថៃ ទោះបីព្រំដែនត្រូវបានយាមកាមតឹងរ៉ឹងក៏ដោយ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១

(បន្ទាយមានជ័យ)៖ ក្នុងដំណាក់កាលកូវីដ១៩នេះ បើទោះបីព្រំដែនកម្ពុជា-ថៃ មានការយាមកាមតឹងរឹងយ៉ាងណាក៏ដោយ ក៏នៅមានជនជាតិថៃមានបំណងមកធ្វើការនៅកម្ពុជា ខាងពលរដ្ឋកម្ពុជា មានបំណងចង់ធ្វើការនៅថៃ។ ជាក់ស្តែង ទាហានស្រុកតាប្រាយ៉ា បានចាប់ឃុំខ្លួនក្រុមជនជាតិថៃ ដែលមានបំណងលួចឆ្លងដែនចូលមកធ្វើការនៅកាស៊ីណូប៉ោយប៉ែតចំនួន ៩នាក់ និងចាប់ពលករខ្មែរលួចឆ្លងដែនចូលប្រទេសថៃ ៦នាក់ ផងដែរ។ នេះបើតាមការចុះផ្សាយរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៅថ្ងៃទី២២ ខែមិថុនានេះ។

អគ្គស្នងការដ្ឋាននគរបាលជាតិ បានឲ្យដឹងថា សមត្ថកិច្ចតាមបន្ទាត់ព្រំដែន កាលពីវេលាម៉ោង១១ និង១២នាទីយប់ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ បានចាប់ឃុំខ្លួនជនជាតិថៃ ៩នាក់ ក្នុងនោះប្រុស៣នាក់ និងស្រី៦នាក់

កំពុងលួចឆ្លងដែនទៅខាងប្រទេសកម្ពុជា។ បន្ទាប់ពីសមត្ថកិច្ចសួរនាំពួកគេឲ្យដឹងថា ជនជាតិថៃទាំងនេះ បានទទួលការណែនាំពីមិត្តភ័ក្តដែលធ្វើការនៅក្រុមហ៊ុនកាស៊ីណូនៅប៉ោយប៉ែតឲ្យមកធ្វើការនៅទីនោះ ដោយទទួលបានប្រាក់ខែក្នុង១ខែ ចំនួន២១.០០០បាត និងធ្វើការមានកំណត់៦ខែ ហើយការធ្វើដំណើរក្រុមហ៊ុនជាអ្នកចំណាយលុយអ្នកទាំងអស់ ពួកគេបានធ្វើការទំនាក់ទំនងគ្នាតាមផេក ហើយថានឹងមានរថយន្តមកទទួលនៅអារញ្ញ និងដឹកទៅស្នាក់នៅបរិវេណព្រៃម្នាងវត្ត ណងយ៉ាកែវ នៅម៉ោង០៧ នឹង២៤នាទីយប់ រហូតដល់ម៉ោង២២នឹង៣០នាទីយប់ ទើបផ្តើមចេញដំណើរពីបរិវេណវត្តខាងលើ រហូតដល់ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។

បន្ទាប់ពីចាប់ខ្លួនជនជាតិថៃរួចមក នូវវេលាម៉ោង១រំលងអាធ្រាត ឈានចូលព្រឹកថ្ងៃទី២១ ខែមិថុនា សមត្ថកិច្ចស្រុកតាប្រាយ៉ា ខេត្តស្រះកែវ បានចាប់ឃាត់ខ្លួនពលករខ្មែរចំនួន៦នាក់ ដែលលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ក្នុងនោះប្រុស៥នាក់ និងស្រីម្នាក់ នៅបរិវេណចំការដំឡូង ក្រោយភូមិទព័សៀម ឃុំតាប្រាយ៉ា ស្រុកតាប្រាយ៉ា ដោយមានមេខ្យល់ជនជាតិខ្មែរមិនស្គាល់ឈ្មោះជាអ្នកនាំផ្លូវ ដើរមកពីប្រទេសកម្ពុជា ដោយចំណាយលុយក្នុងម្នាក់៦.០០០បាត និងចង់ទៅធ្វើការនៅខេត្តនន់ថះបុរី ខាងផ្នែកសំណង់។

សមត្ថកិច្ចខាងលើបញ្ជាក់ថា ចំពោះជនជាតិថៃទាំង៩នាក់ ដែលត្រូវចាប់ខ្លួនបានបញ្ជូនទៅសមត្ថកិច្ចជំនាញស្រុកគោកឃ្សូង ដើម្បីចាត់ការតាមច្បាប់។ ដោយឡែកពលរដ្ឋខ្មែរ ៦នាក់ទៀត ក្រោយធ្វើកំណត់ហេតុឃាត់ខ្លួនហើយ សមត្ថកិច្ចនឹងធ្វើការបញ្ជូនមកកម្ពុជាវិញ៕

## ពលករខ្មែរជាច្រើននាក់ឆ្លងជំងឺកូវីដ១៩ នៅប្រទេសថៃ ដង្ហោយហៅរដ្ឋាភិបាលជួយពួកគាត់ជាបន្ទាន់

https://www.rfa.org/khmer/news/ ដោយ មួង ណារ៉េត2021-06-21

ពលករខ្មែរធ្វើការនៅប្រទេសថៃទាំងនោះព្រួយបារម្ភខ្លាចគ្រោះថ្នាក់ដល់អាយុជីវិតក្នុងគ្រាអាសន្ននេះ ព្រោះពួកគាត់មានសុខភាពទ្រុឌទ្រោមបណ្តើរហើយ ដោយពុំមានថ្នាំព្យាបាលនិងគ្មានអាហារហូបចុកគ្រប់គ្រាន់នោះទេ។

ពលករមានស្រុកកំណើតនៅខេត្តឧត្តរមានជ័យម្នាក់លោក រាប សារិន ប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី២១ ខែមិថុនាថា លោកឆ្លងជំងឺកូវីដ១៩រយៈពេលមួយសប្តាហ៍មកហើយ ប៉ុន្តែពុំមានអាជ្ញាធរណាមកសួរសុខទុក្ខ ឬ បញ្ជូនគាត់ទៅព្យាបាលជំងឺនៅឡើយទេ។ ពលករធ្វើការសំណង់នៅទីក្រុងបាងកករូបនេះកំពុងធ្លាក់ខ្លួនឈឺ ដោយមិនអាចធ្វើការងារអ្វីបានឡើយ។ ពលករវ័យ ៣៧ ឆ្នាំរូបនេះបន្តថា បច្ចុប្បន្នលោកស្នាក់នៅក្នុងតង់កៅស៊ូនៅកន្លែងធ្វើការងារយ៉ាងវេទនា និងគ្មានអាហារហូបចុកគ្រប់គ្រាន់នោះទេ៖ «ភ័យណាស់បងខ្ញុំបែកប្រពន្ធបែកកូនហើយ វាឈឺក ហើយធ្វើឱ្យដេកវាមិនលក់ ហើយវាឈឺក្បាលដូចគេថា ពីមុនកូវីដ ដល់ពេលកើតខ្លួនឯងបានដឹង។ អស់កម្លាំងពីខ្លួនលើងវាអត់ឱ្យឃ្លានបណ្តោយ គេឱ្យថ្នាំប៉ារ៉ាលេប។ ខ្ញុំសូមអោយរដ្ឋាភិបាលជួយអន្តរាគមន៍ឱ្យគេយកខ្ញុំទៅពេទ្យផង កុំឱ្យទុកចោលអីចឹង។ ខ្ញុំអត់មានលុយកាក់ទេ»។

ដូចគ្នានេះដែរ ពលការិនីខ្មែរធ្វើការសំណង់នៅក្រុងបាងកកម្នាក់ទៀតលោកស្រី រាប ស្រីពៅ ថ្លែងថា លោកស្រីនិងកូនរបស់គាត់អាយុ ៥ ខែ បានឆ្លងជំងឺកូវីដ១៩ រយៈពេល ៤ ថ្ងៃមកហើយ ដោយពុំមានថ្នាំលេបព្យាបាលជំងឺនៅឡើយទេ។ ស្ត្រីកូនខ្ចីរូបនេះប្រាប់ថា ដោយសារគ្មានអាហារហូបគ្រប់គ្រាន់ធ្វើឱ្យលោកស្រីគ្មានទឹកដោះបំបៅកូននោះទេ។ លោកស្រីបន្តថា ចាប់តាំងពីឆ្លងជំងឺកាចសាហាវនេះមក ថៅកែជនជាតិថៃបានបង្ខាំងលោកស្រី និងពលករដែលឆ្លងជំងឺកូវីដ១៩ជាច្រើននាក់ទៀតឱ្យនៅមួយកន្លែង ប៉ុន្តែមិនបានផ្តល់ស្បៀងអាហារជូនដល់ពួកគាត់ហូបចុកគ្រប់គ្រាន់ឡើយ។ ស្ត្រីវ័យ ២២ ឆ្នាំរូបនេះព្រួយបារម្ភខ្លាចសុខភាពទ្រុឌទ្រោម បណ្តាលឱ្យគ្រោះថ្នាក់ដំទាំងម្តាយនិងកូន៖ «គេអោយតែថ្នាំប៉ារ៉ាសេតាមលពេទ្យក៏មិនមកមើល ពេទ្យមកមើលបានត្រឹមតែថតរូបហើយទៅវិញ អត់មានសួរនាំអីគ្នាបន្តិច អត់មានយករបស់អីមកត្រួតគ្នាថា គ្នាយ៉ាងម៉េចហើយ បានត្រឹមតែមកថតរូបហើយទៅវិញ

។ គេអត់យកចិត្តទុកដាក់នឹងប្រជាជនខ្មែរយើងទេ ប្រជាពលរដ្ឋគេ គេយកទៅម្តងមួយៗ តែប្រជាពលរដ្ឋយើងអត់សោះ គឺសំខាន់ឱ្យគេយកកូនខ្មែរទៅមុខ ខ្ញុំប្រាប់គេហើយថា កូនខ្ញុំដកដង្ហើមលំបាក តែគេអត់យកទៅ។ យើងហូបតែត្រីខ ពងទារាល់ថ្ងៃយើងអត់មានកម្លាំងទេ ព្រោះវាធ្វើទុក្ខខាងប្រព័ន្ធដកដង្ហើម។ ណាមួយយើងនៅអីចឹងថវិកាក៏អត់គ្រប់គ្រាន់ដែរព្រោះយើងត្រូវចាយវាយរាល់ថ្ងៃទិញរបស់របររាល់ថ្ងៃ»។

នៅកន្លែងធ្វើការរបស់ពលករខ្មែរមួយក្រុមនេះ មានពលករខ្មែរប្រហែល ៥០ នាក់បានឆ្លងជំងឺកូវីដ១៩។ ក្នុងនោះមានកុមារអាយុ ៩ ឆ្នាំម្នាក់ និងទារកអាយុក្រោម ៩ខែ ២នាក់បានឆ្លងជំងឺកាចសាហាវនេះ ហើយមានពលករខ្លះបានឈឺធ្ងន់ធ្ងរ។

កាលពីថ្ងៃទី២០ ខែមិថុនា ក្រុមពលករទាំងនេះបានប្រមូលផ្តុំគ្នាថតវីដេអូបង្ហោះតាមបណ្តាញសង្គមហ្វេសប៊ុករបស់ខ្លួន អំពាវនាវដល់រដ្ឋាភិបាលខ្មែរនិងថៃឱ្យជួយសង្គ្រោះអាយុជីវិតរបស់ពួកគាត់ជាបន្ទាន់។ ប៉ុន្តែរហូតមកដល់ពេលនេះ ពុំមានអាជ្ញាធរណាចុះទៅជួយដល់ពួកគាត់នៅឡើយទេ៖ «សុំឱ្យរដ្ឋាភិបាលជួយកូនចៅផងនៅប្រទេសថៃ កើតជំងឺកូវីដគេមិនយកទៅពេទ្យទេ នៅផ្លូវវិផាវឌីច្រកទី២០ គេឃុំមិនឱ្យចេញទៅណាទេ គេយកតែកូនថៃទៅ គេឱ្យហូបតែត្រីខ ពងមាន់ និងមីកញ្ចប់។ គេយកមកទុកចោលជាង១អាទិត្យហើយ សូមឱ្យសម្តេច ហ៊ុន សែន ជួយកូនចៅផង នៅប្រទេសថៃ គេយកតែកូនថៃទៅព្យាបាលទេ ខ្មែរយើងគេមិនយកទៅពេទ្យទេគេថា ចាំណេះថ្ងៃណោះជាង១អាទិត្យហើយ»។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ និងអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយជុំវិញពីក្តីកង្វល់របស់ពលករខ្មែរនេះបានទេនៅថ្ងៃទី២១ ខែមិថុនា ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។ ប៉ុន្តែមន្ត្រីស្ថានទូតខ្មែរនៅទីក្រុងបាងកកបានទូរស័ព្ទប្រាប់ក្រុមពលករទាំងនោះថា ស្ថានទូតខ្មែរបានស្នើទៅអាជ្ញាធរថៃ ដើម្បីឱ្យជួយដោះស្រាយបញ្ហានេះហើយ។បន្ថែមពីនេះអាជ្ញាធរថៃបានតម្រូវឱ្យពួកគាត់ស្នាក់នៅព្យាបាលជំងឺកូវីដ១៩នៅកន្លែងធ្វើការងារដដែល។

ទោះជាយ៉ាងណាមន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកពលករលោក ឌី ថេហូយ៉ា យល់ថា រដ្ឋាភិបាលខ្មែរគួរតែអន្តរាគមន៍ជួយដល់ក្រុមពលករទាំងនោះជាបន្ទាន់ ដើម្បីការពារកុំឱ្យពួកគាត់ជួបគ្រោះថ្នាក់ធំនៅពេលខាងមុខ។ លោកបញ្ជាក់ទៀតថា បញ្ហានេះប្រសិនបើអាជ្ញាធរប្រទេសទាំង២មិនឆាប់ដោះស្រាយទេនោះ អាចនឹងធ្វើឱ្យពលករខ្លះធ្លាក់ខ្លួនឈឺធ្ងន់ ហើយមិនអាចជួយសង្គ្រោះបានទាន់ពេលវេលានោះទេ ជាពិសេសកុមារតូចៗដែលមានកម្លាំងទន់ខ្សោយ៖ «ត្រូវមើលដែរថៅកែណាដែលគិតព្យាយាមលាក់បាំងអំពីជំងឺកូវីដហ្នឹង រដ្ឋាភិបាលថៃគួរតែចាត់វិធានការធ្ងន់ធ្ងរ ព្រោះកាលណា លាក់បាំងព័ត៌មានវាបណ្តោយឱ្យពួកគាត់កាន់តែប្រឈមខ្លាំង។ ទី២ វាអត់មានជាវិធានការទប់ស្កាត់ វាជាការបណ្តែតបណ្តោយឱ្យមានការឆ្លងបន្ថែមទៀត។ ទី៣ហ្នឹងគឺថា ស្ថានទូតខ្មែរនៅប្រទេសថៃហ្នឹង ត្រូវតែតាមដានព័ត៌មានហ្នឹងឱ្យបានច្បាស់ ហើយឆ្លើយតបឱ្យត្រូវពេលវេលា»។

កន្លងមកមានពលករខ្មែរធ្វើការនៅប្រទេសថៃជាច្រើននាក់ ដែលបានឆ្លងជំងឺកូវីដ១៩ពួកគាត់បានបង្ហោះសារនៅក្នុងបណ្តាលសង្គមហ្វេសប៊ុក បង្ហាញពីទុក្ខលំបាករបស់ខ្លួន ដូចជា គ្មានស្បៀងអាហារហូបចុក និងគ្មានគ្រូពេទ្យព្យាបាលជំងឺជាដើម។ មន្ត្រីសង្គមស៊ីវិលលោក ឌី ថេហូយ៉ា លើកទឹកចិត្តដល់ពលករឱ្យចេះសម្តែងមតិបង្ហាញពីទុក្ខកង្វល់របស់ខ្លួនតាមបណ្តាញសង្គមបន្តទៀត ដើម្បីឱ្យអាជ្ញាធរពាក់ព័ន្ធនិងសាធារណជនបានដឹង និងជួយដល់ពួកគាត់បានទាន់ពេលវេលា។ របាយការណ៍អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការស្របច្បាប់និងមិនស្របច្បាប់មានជាង ១លាន ៨សែន នាក់ (១,៨០០,០០០) ធ្វើការនៅប្រទេសថៃ៕

# ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១

## តុលាការចោទមេខ្យល់ ៣ នាក់ និងបក្ខពួករឿងនាំពលករឆ្លងដែនខុសច្បាប់

https://www.postkhmer.com/ គឹម សារុំ | Publication date 23 June 2021 | 10:29 ICT

**បន្ទាយមានជ័យៈ** អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យកាលពីម្សិលមិញបានចោទប្រកាន់បុរសមេខ្យល់ ៣ នាក់ និងបុរសបក្ខពួក ៣ នាក់ទៀត បន្ទាប់ពីសមត្ថកិច្ចចាប់ខ្លួនករណីនាំបុរសជាពលករ ៦ នាក់បម្រុងឆ្លងដែនទៅថៃកាលពីថ្ងៃ ២០ មិថុនា នៅចំណុចអូរព្រំដែនក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

លោក ព្រះរាជអាជ្ញារង សំរិទ្ធ សុខុន និងជាអ្នកនាំពាក្យអយ្យការអមសាលាដំបូងខេត្តនេះប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យបានចោទមេខ្យល់ និងបក្ខពួកចំនួន ៦ នាក់ ដែលមេខ្យល់ទាំងនោះឈ្មោះ សុខា វ៉ារុធ អាយុ ២០ ឆ្នាំ រស់នៅភូមិបាលិលេយ្យ សង្កាត់-ក្រុងប៉ោយប៉ែត, ទី២-ឈ្មោះ ខេមរា ស្វ៉ារិត ហៅ ម៉ៅ អាយុ ៣២ ឆ្នាំ រស់នៅភូមិក្បាលស្ពាន ២ សង្កាត់-ក្រុងប៉ោយប៉ែត និងឈ្មោះ លី រ៉ែន អាយុ ១៧ ឆ្នាំ រស់នៅភូមិព្រៃព្រិច សង្កាត់-ក្រុងប៉ោយប៉ែត ខេត្ត បន្ទាយមានជ័យ។

ចំណែកបុរសបក្ខពួក ឈ្មោះ ជឹង ហៅ ណាន អាយុ ១៧ ឆ្នាំ,ឈ្មោះ ប៉ែន ឆៃណាម អាយុ ១៨ ឆ្នាំ និងឈ្មោះ យួម សឿម អាយុ ៣៥ ឆ្នាំ។ ពួកគេត្រូវបានចោទតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជនទាំង ៣ នាក់នេះជាអ្នកសម្រួលមធ្យោបាយដឹកពលករ និងមេខ្យល់។ លោកថា៖ «ខាងអយ្យការបានចោទជនទាំង ៦ នាក់ និងបានបញ្ជូនពួកគេទៅចៅក្រមស៊ើបសួរ ដើម្បីបន្តនីតិវិធីតាមផ្លូវច្បាប់ទៀត»។

យោងតាមមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ បើតុលាការរកឃើញថា ពួកគេពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែននោះនឹងប្រឈមជាប់ពន្ធនាគារពី ២ ទៅ ៥ ឆ្នាំ និងពិន័យប្រាក់ចូលថវិការដ្ឋពី ៤ លានទៅ ១០ លានរៀល។

លោកស្រី ឌី សុជាតិ ស្នងការរងផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបន្ទាយមានជ័យឱ្យដឹងពីម្សិលមិញថា ជនទាំង ៦ នាក់ត្រូវបាននគរបាលក្រុងប៉ោយប៉ែតស្ទាក់ឃាត់បាននៅចំណុចអូរព្រំដែនក្នុងក្រុងប៉ោយប៉ែតពីម៉ោងជិត ៥ ល្ងាចថ្ងៃ ២០ មិថុនា។ ក្នុងនោះសមត្ថកិច្ចដកហូតបានវត្ថុតាងទូរស័ព្ទដៃ ៦ គ្រឿង ម៉ូតូកង់៣តណ្ឌា១គ្រឿង និងម៉ូតូ ២គ្រឿងទៀត។ លោកស្រីបានបញ្ជាក់ថា៖«ករណីនេះយើងក៏ទប់ស្កាត់បុរសពេញវ័យជាពលករបាន៦នាក់ផងដែរ ហើយយើងបានដឹកពួកគេទៅធ្វើចត្តាឡីស័កនៅក្រុងប៉ោយប៉ែតទាំងអស់។ ពួកគាត់សុទ្ធតែអ្នកក្រុងប៉ោយប៉ែតទេ។ ប៉ុន្តែបើពលកររស់នៅខេត្តផ្សេងយើងបញ្ជូនទៅខេត្តរបស់គាត់រស់នៅ»។ លោកស្រីឱ្យដឹងដែរថា ទន្ទឹមនឹងការឃាត់ខ្លួនមេខ្យល់ខាងលើនេះកាលពីម៉ោងជាង ១ រំលងអធ្រាត្រឈានចូលថ្ងៃទី ២០ មិថុនា កងពលតូចថ្មើរជើងលេខ ៥១ សហការជាមួយកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៥ និងវរសេនាតូចថ្មើរជើងលេខ ៥១១ បានទប់ស្កាត់ពលករបាន ១៦ នាក់ក្នុងនោះមានស្រី ១០ នាក់។ ការឃាត់ខ្លួននេះធ្វើឡើងនៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ខណៈពួកគេបម្រុងលួចឆ្លងដែនទៅប្រទេសថៃ។

ករណីដោយឡែកមួយទៀតកាលពីថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០២១ សមត្ថកិច្ចនគរបាលខេត្តបន្ទាយមានជ័យដែលយាមតាមបន្ទាត់ព្រំដែន បានឃាត់ខ្លួនជនជាតិថៃ ៥ នាក់ (ស្រីម្នាក់) បញ្ជូនឱ្យផ្នែកអន្តោប្រវេសន៍ ពាក់ព័ន្ធនឹងករណីលួចឆ្លងដែនចូលមកកម្ពុជាខុសច្បាប់ ដើម្បីរកការងារធ្វើ។ នេះបើតាមលោក អេង លីហួរ ស្នងការរងផែនការងារជនអន្តោប្រវេសន៍ខេត្តនេះប្រាប់នៅរសៀលថ្ងៃទី ២២ ខែមិថុនា។ យ៉ាងណាក្តី លោក អេង លីហួរ បានអះអាងថា សមត្ថកិច្ចរបស់លោកបានប្រគល់ពួកគេឱ្យទៅភាគីថៃវិញហើយ។ លោកបានបញ្ជាក់ថា៖ «ពួកគេទាំង ៥ នាក់នោះ តម្រូវឱ្យធ្វើចត្តាឡីស័កប៉ុន្មានថ្ងៃដែរ តែយើងមិនបានឃាត់ខ្លួនបញ្ជូនទៅតុលាការអីទេ»៕

## ពលករខ្មែរ នៅតែបន្តត្រឡប់ពីប្រទេសថៃ ១ថ្ងៃ ជាង ១០០នាក់ តាមច្រកអូរបីជាន់ ក្រោយពិនិត្យសុខភាពហើយ ត្រូវបានដឹកជញ្ជូនទៅធ្វើចត្តាឡីស័ក នៅស្រុកកំណើត

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៣ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ២២:៥៧

បន្ទាយមានជ័យ៖ ពលករខ្មែរ នៅតែបន្តត្រឡប់ពីប្រទេសថៃ ចូលកម្ពុជាវិញ ១ថ្ងៃ ជាង ១០០នាក់ តាមច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ អ្នកមកពីថៃទាំងនោះ ក្រោយពិនិត្យសុខភាពរួចហើយ ត្រូវបានដឹកជញ្ជូនទៅកាន់ស្រុកកំណើត ដើម្បីធ្វើចត្តាឡីស័ក នៅទីនោះ។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ បានប្រាប់ថា នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ មានពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ មានចំនួន ១០៦នាក់ ស្រី ៤៤នាក់ តាមច្រកអូរជាន់ ស្រុកអូរជ្រៅ ដែលក្រុមការងារមណ្ឌលសំចត ច្រកអូរបីជាន់ទទួល ដើម្បីពិនិត្យសុខភាព ហើយមានអាហារសម្រន់ជូន និងណែនាំពួកគាត់ មិនត្រូវធ្វើចំណាកស្រុក ដោយខុសច្បាប់ តាមរយៈមេខ្យល់នោះទេ។ លោកបានបញ្ជាក់ថា ពលករដែលត្រឡប់ពីប្រទេសថៃ ដែលចូលតាមច្រកអូរបីជាន់នេះ មានប្រជាពលរដ្ឋ នៅខេត្តបន្ទាយមានជ័យ ចំនួន ៥៦នាក់ ស្រី ២៥នាក់ ខេត្តបាត់ដំបង ចំនួន ២១នាក់ ស្រី ៨នាក់ ខេត្តកំពត មានចំនួន ២នាក់ ខេត្តព្រៃវែង មានចំនួន ២នាក់ ស្រីម្នាក់ ខេត្តពោធិ៍សាត់ ចំនួន ៣នាក់ ស្រី ២នាក់ ខេត្តសៀមរាប មានចំនួន ១៨នាក់ ស្រី ៤នាក់ ខេត្តស្វាយរៀង មានចំនួន ៣នាក់ ស្រី ២នាក់ និងខេត្តត្បូងឃ្មុំ មានចំនួនម្នាក់។

លោក លី សុវណ្ណារិទ្ធ បានបញ្ជាក់ថា ចំពោះពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាវិញ តាមច្រកអូរបីជាន់ ក្រោយពេលក្រុមការងារមណ្ឌលសំចត ទទួល និងក្រោយពេលពិនិត្យសុខភាពហើយ ត្រូវបានដឹកតាមរថយន្តក្រសួងការពារជាតិ ទៅដាក់នៅមណ្ឌលចត្តាឡីស័ក ក្នុងខេត្តបន្ទាយមានជ័យ ហើយដឹកបន្តទៅតាមបណ្ដាខេត្តស្រុកកំណើត ដើម្បីដាក់តាមមណ្ឌលធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ៕ ប៊ុន ធឿន

## កម្លាំងនគរបាល នឹងកម្លាំងយោធា ទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ពីភាគីយោធាថៃ កងអនុសេនាធំលេខ១១១៣ ត្រង់ចំណុចភូមិសាស្រ្តភូមិទឹកផុស

http://cambodiapolice.com/policekh/ 9:29 am 23 មិថុនា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ នៅថ្ងៃអង្គារ ១៣កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្នុងភូមិសាស្រ្តប៉ុស្តិ៍គ្រប់គ្រង ក្នុងស្រុកសំពៅលូន ខេត្តបាត់ដំបង ព្រមទាំងបានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ ពីភាគីយោធាថៃកងអនុសេនាធំលេខ១១១៣ ត្រង់ចំណុចភូមិសាស្រ្តភូមិទឹកផុស ឃុំអង្គរបាន ស្រុកសំពៅលូនចំនួន២នាក់, ស្រី១នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ កត់ឈ្មោះ និងធ្វើការអប់រំណែនាំរួចកម្លាំងយើងបានប្រគល់ពួកគាត់ឱយទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២តាមរថយន្តយោធា ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៧នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃពុធ ទី២៣ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៧នាក់ ស្រី ២៣នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៤នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៦នាក់ ស្រី ៣នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣៣នាក់ ស្រី ១៥នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ៤នាក់ ស្រីចំនួន ២នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥៧នាក់ ស្រី ២៣នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## មេខ្យល់ចំនួន ២នាក់ និងពលករ ចំនួន ១១នាក់ បម្រុងឆ្លងដែនខុសច្បាប់ ត្រូវបានឃាត់ខ្លួន ដោយកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ

https://cen-news.com/ Posted ByPen Srey Neat June 24, 2021

បន្ទាយមានជ័យ ៖ មេខ្យល់ចំនួន ២នាក់ ដែលសកម្មក្នុងការនាំពលករឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យឃាត់ខ្លួនបានយប់ថ្ងៃទី២៣ ឈានចូលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១នេះ ខណៈពេលដែលពួកគេកំពុងដឹកនាំពលករឆ្លងដែនទៅប្រទេសថៃ ចំនួន ១១នាក់ ក្នុងនោះស្រី ២នាក់ ត្រង់ភូមិសាស្ត្រ អូរព្រំដែន ភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ក្រោមការបញ្ជាផ្ទាល់របស់លោក ឧត្តមសេនីយ៍ត្រី ជឹម ប៊ុនអាន មេបញ្ជាការ បានចាត់តាំងលោក វរសេនីយ៍ឯក រិទ្ធ រ៉ម មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដឹកនាំកម្លាំងល្បាតជាប់ជាប្រចាំ ដោយអនុវត្តតាមបទបញ្ជា លោកបានដឹកនាំកម្លាំងល្បាត២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងកងរាជអាវុធហត្ថស្រុក និងកម្លាំងផ្នែកសឹករងម៉ាឡៃ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។ ជាក់ស្តែងនៅយប់ ថ្ងៃទី២៣ ឈានចូល ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ខណៈលោកកំពុងដឹកនាំកម្លាំងដើរល្បាតក៏ជួបមេខ្យល់ ២នាក់ បម្រុងនាំពលករឆ្លងដែនចេញទៅប្រទេសថៃ កម្លាំងតំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ ក៏ឃាត់ខ្លួនបានតែម្តង ។

សូមបញ្ជាក់ថា មេខ្យល់ ១- ឈ្មោះ នឿន សីហា ភេទប្រុស អាយុ ៣៩ ឆ្នាំរស់នៅភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ២- ឈ្មោះ យន សុផាត ភេទប្រុស អាយុ៣៩ឆ្នាំ រស់នៅភូមិអូល្វា ឃុំជ្រៃសីមា

ស្រុកសំពៅលូន ខេត្តបាត់ដំបង មេខ្យល់ ទាំងពីក្រោយពីបានសាកសួររួចក៏ប្រគល់ឲ្យកម្លាំងអាវុធហត្ថស្រុកចាត់ការតាមនីតិវិធីច្បាប់ ចំណែកឯពលករទាំង ១១នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កស្រុកម៉ាឡៃ ។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំង តំបន់ប្រតិបត្តិការសឹករង ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការ សហការជាមួយកម្លាំងចម្រុះ ទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់ ៕រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ជនជាតិថៃប្រុសស្រី៥នាក់ចំណាយប្រាក់៩ពាន់បាតក្នុងម្នាក់ចេញពីកម្ពុជាទៅស្រុកកំណើតវិញត្រូវសមត្ថកិច្ចថៃឃាត់ខ្លួន

http://nokorwatnews.com/ 23/06/2021

ក្រុងប៉ោយប៉ែតៈ នៅតែមានបន្តលួចឆ្លងដែនខុសច្បាប់ទាំងពលរដ្ឋខ្មែរ និងពលរដ្ឋថៃត្រូវកម្លាំងសមត្ថកិច្ចទាំងខាងកម្ពុជាទាំងកម្លាំងសមត្ថកិច្ចថៃចាប់បានជាបន្តបន្ទាប់ក្នុងដំណាក់កាលទប់ស្កាត់ការរីករាលដាល covid-19 ជាក់ស្តែងកម្លាំងទាហានការពារព្រំដែនរបស់ថៃក្នុងស្រុកតា ព្រះយ៉ាខេត្តស្រះកែវ កាលពីថ្ងៃទី២២ មិថុនា ២០២១ នេះក្រោយទទួលបានសេចក្តីរាយការណ៍ថា មានជនជាតិថៃ លួចឆ្លងដែនចេញពីប្រទេកម្ពុជា ដោយខុសច្បាប់សមត្ថកិច្ចក៏បានចុះទៅត្រួតពិនិត្យ និងឃ្លាំមើល រហូតជួបប្រទះក្រុមជនជាតិជាតិថៃគួរឲ្យសង្ស័យ ទើបសមត្ថកិច្ចចូលទៅត្រួតពិនិត្យ និងចាប់ខ្លួនជនជាតិថៃចំនួន៥នាក់ ក្នុងនោះមានប្រុស២ និងស្រី៣នាក់ ខណៈកំពុងដើរឆ្លងចេញពីទឹកដីកម្ពុជា ចូលមកប្រទេសថៃ ទើបសមត្ថកិច្ចឃាត់ខ្លួនយកមកសួរនាំ។ សមត្ថកិច្ចតាមបន្ទាត់ព្រំដែនបង្ហើបថាៈ ជនជាតិថៃទាំង៥នាក់ខាងលើ បានសារភាពថា ពួកគេបានទៅធ្វើការនៅកាស៊ីណូនៅទីក្រុងភ្នំពេញមកធ្វើការមានរយៈពេល៤ខែហើយ និងបានសុំឈប់ពីការងារក្នុងក្រុមហ៊ុនអនឡាញដែលមានឈ្មោះ"NAS"ដោយសារមានបញ្ហាមួយចំនួន ជាហេតុធ្វើឲ្យពួកគេសម្រេចចិត្តលាឈប់ ទើបឲ្យខាងក្រុមហ៊ុនជួយទាក់ទងមេខ្យល់ជនជាតិខ្មែរ ដោយចំណាយលុយក្នុងម្នាក់ចំនួន៩.០០០បាត ដើម្បីធ្វើដំណើរវិលត្រឡប់ទៅប្រទេសខ្លួនវិញ(ថៃ) ដោយវិធីលួចឆ្លងចូលប្រទេសដោយខុសច្បាប់ តាមច្រករបៀង រហូតត្រូវសមត្ថកិច្ចចាប់បានតែម្តង៕

## ទប់ស្កាត់ប្រជាពលរដ្ឋ បម្រុងលួចឆ្លងដែនចូលទឹកដីថៃ និងទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ចំនួន ១៦នាក់

https://cen-news.com/ Posted ByPen Srey Neat June 24, 2021

ខេត្តបាត់ដំបង ៖កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ទប់ស្កាត់ប្រជាពលរដ្ឋ បម្រុងលួចឆ្លងដែនចូលទឹកដីថៃ និងទទួលប្រជាពលរដ្ឋត្រឡប់ ចូលប្រទេសកម្ពុជាវិញ ក្នុងភូមិសាស្ត្រស្រុកសំពៅលូន។ នៅថ្ងៃពុធ ទី២៣ ខែមិថុនា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរង ទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រងក្នុងស្រុកសំពៅលូន ខេត្តបាត់ដំបង ព្រមទាំងបានធ្វើសកម្មភាព ទប់ស្កាត់ប្រជាពលរដ្ឋបម្រុងលួចឆ្លង

ដែនចូលទឹកដីថៃ និងទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ សរុបចំនួន ១៦នាក់ (ស្រី៤នាក់) ក្នុងនោះក្មេង ៥នាក់ រួមមាន៖

ប្រជាពលរដ្ឋបំរុងលួចឆ្លងដែនចូលទឹកដីថៃចំនួន ០២នាក់ប្រុស ត្រង់ចំណុចនៃភូមិសាស្រ្តភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ។ ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃចំនួន ០៦នាក់ ស្រី ០២នាក់ ក្នុងនោះក្មេង ០២នាក់ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ។ ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃចំនួន ០៣នាក់ ក្នុងនោះក្មេង ០២នាក់ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ។ ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចំនួន ០៥នាក់ ស្រី ០២នាក់ ក្នុងនោះក្មេង ០១នាក់ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ។ បន្ទាប់ពីធ្វើការសាកសួរ កត់ឈ្មោះ និងធ្វើការអប់រំណែនាំរួច កម្លាំងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ តាមវថយន្តយោធា ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

### ពលករប្រុសស្រីចំនួន ១៦នាក់ឆ្លងដែនចូលប្រទេសថៃខុសច្បាប់ត្រូវបានកម្លាំងជំនាញបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័ក

http://nokorwatnews.com/ 24/06/2021

ខេត្តបាត់ដំបង៖ កងកម្លាំងនគរបាលការិយាល័យជំនាញរបស់ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងបានឲ្យដឹងថា÷ កម្លាំងចម្រុះការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ខណៈចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលកររចេញ ចូលខុសច្បាប់នៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២១នេះបានឃាត់ខ្លួនពលករប្រុសស្រីសរុបចំនួន ១៦នាក់ ពេលដែលពួកគេកំពុងព្យាយាមលួចឆ្លងដែនចូលក្នុងប្រទេសថៃទាំងប្រថុយប្រថានតាមការអូសទាញរបស់មេខ្យល់។

ពលករទាំងអស់ខាងលើរួមមានចំនួន ២នាក់ ត្រូវសមត្ថកិច្ចឃាត់ខ្លួនបាននៅត្រង់ចំណុចភូមិសាស្រ្តភូមិអូរ ឃុំសន្តិភាព និងពលករខ្មែរសរុបចំនួន ១៤នាក់ផ្សេងទៀតត្រូវសមត្ថកិច្ចថៃឃាត់ខ្លួនបានចំណុចឈមគ្នាក្នុងភូមិសាស្រ្តភូមិគីឡូ ៩ ឃុំជ្រៃសីមា និងត្រង់ចំណុចភូមិសាស្រ្តភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន រួចប្រគល់ឲ្យកម្លាំងការពារតំបន់ព្រំដែនកម្ពុជាដើម្បីអនុវត្តច្បាប់។ ការឃាត់ខ្លួននេះកម្លាំងសមត្ថកិច្ចបានសាកសួរ រួចណែនាំអប់រំ និងចុងក្រោយប្រគល់ពួកគាត់ទៅឲ្យក្រុមគ្រូពេទ្យដើម្បីនាំយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ តាមគោលការណ៍របស់ក្រសួងសុខាភិបាល ពិសេសរាជរដ្ឋាភិបាលដែលបានកំណត់៕

### កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលករខ្មែរ២នាក់ ត្រឡប់មកពីប្រទេសថៃ បញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 7:12 pm 24 មិថុនា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលកររចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ។

ជាក់ស្តែង នៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រស្រុកសំពៅលូន ខេត្តបាត់ដំបង ព្រមទាំងបានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ចំនួន២នាក់(ស្រី) ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ។ បន្ទាប់ពីធ្វើការសាកសួរ កត់ឈ្មោះ និងធ្វើការអប់រំណែនាំរួច កម្លាំងបានប្រគល់ពួកគាត់ទៅឲ្យក្រុមគ្រូពេទ្យ ដើម្បីបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ ៕

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ទប់ស្កាត់ប្រជាពលរដ្ឋបំរុងលួចឆ្លងដែនចូលទឹកដីថៃ និងទទួលប្រជាពលរដ្ឋត្រឡប់ចូលប្រទេសកម្ពុជាវិញ ក្នុងភូមិសាស្ត្រស្រុកសំពៅលូន

http://cambodiapolice.com/policekh/ 9:04 am 24 មិថុនា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃពុធ ១៤កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រងក្នុងស្រុកសំពៅលូន ខេត្តបាត់ដំបង ព្រមទាំងបានធ្វើសកម្មភាពទប់ស្កាត់ប្រជាពលរដ្ឋបំរុងលួចឆ្លងដែនចូលទឹកដីថៃ និងទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ សរុបចំនួន ១៦នាក់ (ស្រី៤នាក់) ក្នុងនោះក្មេង ០៥នាក់ មានដូចខាងក្រោម ៖

-ប្រជាពលរដ្ឋបំរុងលួចឆ្លងដែនចូលទឹកដីថៃចំនួន ០២នាក់ប្រុស ត្រង់ចំណុចនៃភូមិសាស្ត្រភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ។

-ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃចំនួន ០៦នាក់ ស្រី ០២នាក់ ក្នុងនោះក្មេង ០២នាក់ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ។

-ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃចំនួន ០៣នាក់ ក្នុងនោះក្មេង ០២នាក់ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ។

-ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចំនួន ០៥នាក់ ស្រី ០២នាក់ ក្នុងនោះក្មេង ០១នាក់ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ។

បន្ទាប់ពីធ្វើការសាកសួរ កត់ឈ្មោះ និងធ្វើការអប់រំណែនាំរួច កម្លាំងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ តាមរថយន្តយោធា ៕

# ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៧០នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃព្រហស្បតិ៍ ទី២៤ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៧០នាក់ ស្រី ២៦នាក់ ក្នុងនោះ កុមារ ១នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២០នាក់ ស្រី ៦នាក់ កុមារ ១នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤នាក់ ស្រី ១នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់៖ ចំនួន ៤៤នាក់ ស្រី ១៩នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង៖ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ៖ ចំនួន ២នាក់ ស្រីចំនួន ១នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៧៦នាក់ ស្រី ២៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១

# មេខ្យល់ជនជាតិថៃ៣នាក់ និងពលករខ្មែរ២១នាក់ លួចឆ្លងដែនខុសច្បាប់ ត្រូវទាហានថៃ និងនគរបាលខ្មែរ ឃាត់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២៥ មិថុនា ២០២១ដោយ Kang Tola

បន្ទាយមានជ័យ ៖ កម្លាំងទាហានថៃ បានធ្វើការសហការជាមួយកម្លាំងនគរបាលកម្ពុជាល្បាតតាមព្រំដែនទី១២ ក្នុងនោះកម្លាំងទាហានថៃ សហការជាមួយកម្លាំងនគរបាលកម្ពុជា បានធ្វើការឃាត់ខ្លួនមេខ្យល់ជនជាតិថៃ ៣នាក់ និងពលករខ្មែរចំនួន២១នាក់ បានជាបន្តបន្ទាប់នៅក្នុងទឹកដីភូមិកែវផេចផ្លយ និងភូមិណងផៃ កាលពីវេលាម៉ោង៥ នាទីទៀបភ្លឺ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១នេះ។

តាមសេចក្ដីរាយការណ៍ពីកម្លាំងជួរមុខបានប្រាប់ថា ពលករខ្មែរដែលលួចឆ្លងដែនខុសច្បាប់ចូលទឹកដីថៃនោះ មានប្រុស១២នាក់ និងស្រី៩នាក់ ចេញពីប្រទេសកម្ពុជាចូលទៅទឹកដីថៃ ព្រមទាំងមានមេខ្យល់ជនជាតិថៃ១នាក់ និងអ្នកមើលផ្លូវជនជាតិថៃ២នាក់ ដែលមេខ្យល់ទាំង៣នាក់នេះ ជាអ្នករស់នៅក្នុងស្រុកតាព្រះយ៉ា នាំទៅប្រទេសថៃ។ ដោយឡែកពលករខ្មែរទាំងអស់ចង់ទៅស៊ីឈ្នួលនៅក្នុងប្រទេសថៃ។ កម្លាំងទាហានថៃបានធ្វើការសហការជាមួយកម្លាំងនគរបាលកម្ពុជា ក្រោយពីការចាប់ឃុំខ្លួនពលករ២១នាក់ សមត្ថកិច្ចបាននាំខ្លួនអ្នកទាំងអស់ទៅសួរនាំ និងធ្វើកំណត់ហេតុចាប់ខ្លួន អនុវត្តតាមវិធានការរបស់ផ្នែកសុខាភិបាល។ ក្រោយពីសាកសួរ និងធ្វើកំណត់ហេតុរួចរាល់ ពលករទាំងអស់ត្រូវបញ្ជូនមកកម្ពុជាវិញតាមច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមាន

ជ័យ ដើម្បីធ្វើចត្តាឡីស័កខេត្តបន្ទាយមានជ័យ១៤ថ្ងៃ ចំណែកមេខ្យល់៣នាក់ប្រគល់ទៅឲ្យកម្លាំងទាហានថៃយកទៅប្រទេសវិញធ្វើតាមនីតិវិធីច្បាប់៕ *ដោយ ៖ វ៉ាន់ ណាង*

## មេខ្យល់២នាក់ទៀតហើយ ត្រូវបានកម្លាំងអាវុធហត្ថខេត្ត បញ្ជូនទៅតុលាការនៅរសៀលថ្ងៃសុក្រនេះ

https://cen-news.com/ Posted ByPen Srey Neat June 25, 2021

បន្ទាយមានជ័យ ៖ បើយោងតាមលោកវរសេនីយ៍ត្រី តាំង សុខហេង មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ បានប្រាប់ឱ្យដឹងថា នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ កម្លាំងរបស់លោកបានសហការ ជាមួយកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដឹកនាំដោយលោកវរសេនីយ៍ឯក រិទ្ធ រ៉ម មេបញ្ជាការរង ទទួលទិសស្រុកម៉ាឡៃ បានធ្វើការចុះល្បាត តាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រស្រុក ដើម្បីទប់ស្កាត់ការនាំពលរដ្ឋ ចេញចូលទៅប្រទេសថៃដោយខុសច្បាប់ ហើយប្រទះឃើញប្រជាពលរដ្ឋចំនួន១១នាក់ ក្នុងនោះមានមេខ្យល់ចំនួន០២នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃ នៅចំណុចច្រករបៀងមួយកន្លែង ស្ថិតក្នុងភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ហើយបានធ្វើការឃាត់ខ្លួន និងដកហូតបានម៉ូតូចំនួន០៣គ្រឿងផងដែរ បន្ទាប់មកក៏បានបញ្ជូនមកមូលដ្ឋានកងរាជអាវុធហត្ថស្រុកដើម្បីសួរនាំ។

លោកវរសេនីយ៍ត្រី តាំង សុខហេង បានឱ្យដឹងទៀតថា ក្រោយពីកម្លាំងជំនាញសួរនាំរួចទើបដឹងថា ក្នុងចំនួន១១នាក់មានមេខ្យល់ចំនួន០២នាក់ ១.ឈ្មោះ នឿន សីហា ភេទប្រុស អាយុ៣៩ឆ្នាំ បច្ចុប្បន្ន រស់នៅភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ២.ឈ្មោះ ឃន សុផាត ភេទប្រុស អាយុ៣៩ឆ្នាំ បច្ចុប្បន្ន រស់នៅភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ហើយមេខ្យល់ទាំង០២នាក់នេះ បានឆ្លើយសារភាពថា ពួកគេមានគ្នាចំនួន០៣នាក់ ហើយម្នាក់ទៀតឈ្មោះ ឡឹក ភេទប្រុស អាយុប្រហែល៥០ឆ្នាំ ពេលសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ ឡឹក បានរត់គេចខ្លួនបាត់ ហើយពួកគេពិតជាបាននាំពលករទាំង០៩នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃពិតប្រាកដមែន។ ចំណែកពលករទាំង០៩នាក់ ក្រោយពីសមត្ថកិច្ចសួរនាំរួច ត្រូវបានបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័កស្រុកម៉ាឡៃ ចំពោះជនសង្ស័យទាំង០២នាក់ ត្រូវបានកម្លាំងជំនាញមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ កសាងសំណុំរឿង បញ្ជូនមកបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តចាត់ការបន្ត។

លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត ទទួលការងារយុត្តិធម៌ បានបញ្ជាក់ផងដែរថា ការឃាត់ខ្លួនជនសង្ស័យខាងលើនេះ ធ្វើឡើងដោយទទួលបានការអនុញ្ញាត ពីលោកឧត្តមសេនីយ៍ត្រី បោន បិន មេបញ្ជាការកងរាជអាវុធហត្ថខេត្ត និងមានការសម្របសម្រួលពីសំណាក់ ឯកឧត្តម កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តផងដែរ បច្ចុប្បន្ន ជនសង្ស័យ និងវត្ថុតាង ត្រូវបានកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស បញ្ជូនទៅសាលាដំបូងខេត្តចាត់ការតាមច្បាប់ហើយ៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

## នគរបាលប៉ុស្តិ៍ព្រំដែន កម្លាំងយោធា ចេញល្បាតទប់ស្កាត់ប្រជាពលរដ្ឋ ចំនួន៨នាក់ បម្រុងលួចឆ្លងដែនខុសច្បាប់ ទៅថៃ

https://cen-news.com/ Posted ByPen Srey Neat June 26, 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃសៅរ៍ ទី២៦ ខែមិថុនា ឆ្នាំ២០២១ កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង បានធ្វើសកម្មភាពទប់ស្កាត់ ប្រជាពលរដ្ឋបម្រុងលួចឆ្លងដែនខុសច្បាប់ ចូលក្នុងទឹកដីប្រទេសថៃ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ចំនួន៨នាក់ (ស្រី៤នាក់)។

ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជាថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូច នគរបាលការពារព្រំដែនគោក លេខ៨ ១៧ បានបញ្ជាឲ្យកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជាថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង ក៏ប្រទះឃើញប្រជាពលរដ្ឋទាំង៨នាក់នោះ បម្រុងលួចឆ្លងដែនខុសច្បាប់ ចូលក្នុងទឹកដីប្រទេសថៃ។ បន្ទាប់ពីធ្វើការសាកសួរ កត់ឈ្មោះធ្វើកិច្ចសន្យាអប់រំណែនាំរួច កម្លាំងយើងបានប្រគល់បងប្អូន ឱ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅពិនិត្យសុខភាព និងយកសំណាកនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣ មុននឹងបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## មេខ្យល់និងពលករត្រូវចាប់បានបន្តបន្ទាប់ទាំងយប់

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៦ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ១២:៥៧

ខេត្តបន្ទាយមានជ័យ ៖ ខ្មែរ-ថៃ៥នាក់ត្រូវបានកម្លាំងប៉ុស្តិ៍បឹងសាគូនៃនគរបាលការពារព្រំដែនគោកលេខ ៩១១ ធ្វើការទប់ស្កាត់មិនឲ្យលួចឆ្លងដែនខុសច្បាប់ជាបន្តបន្ទាប់២លើកក្នុងយប់តែមួយ ព្រមទាំងឃាត់ខ្លួនជនសង្ស័យ(មេខ្យល់)៤នាក់ កាលពីថ្ងៃទី២៥ មិថុនា ២០២១ ជិតបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រភូមិព្រៃព្រិច និងភូមិទួលប្រាសាទសង្កាត់ និងក្រុងប៉ោយប៉ែត ។

ប្រភពបានឲ្យដឹងថា ករណីទប់ស្កាត់និងឃាត់ខ្លួនជនសង្ស័យនេះលើកទី១ កើតឡើងម៉ោង២០ និង២០នាទីយប់ មានមនុស្ស៩នាក់ ស្រី៣នាក់ កុមារម្នាក់។ ក្នុងចំណោមមនុស្ស៩នាក់ខាងលើ ៤នាក់ជាអាជីវករនិងកម្មករ ។ ក្នុងនោះ ជនសង្ស័យ(មេខ្យល់)ចំនួន៣នាក់ និងអ្នកម៉ូតូឌុបដឹកជញ្ជូន២នាក់ ។ សមត្ថកិច្ចប្រាប់ថា ជនសង្ស័យក្នុងករណីទី១ មានម្នាក់ត្រូវខាងលោកទាក់ទងទៅសមត្ថកិច្ចថៃសហការណ៍ឃាត់ខ្លួនបញ្ជូនឲ្យក្រោយពីគេមកចាំទទួលអាជីវករ និងកម្មករខាងលើដែប្រុងលួចឆ្លងដែនចេញពីកម្ពុជាទៅផ្សាររុងក្លឿស្រុកអារញ្ញខេត្តស្រះកែវ ប្រទេសថៃ។ ដោយឡែក ករណីទី២បានកើតឡើងនៅម៉ោងជិត១២អធ្រាត្រយប់ថ្ងៃដដែលកម្លាំងប៉ុស្តិ៍បឹងសាគូបានធ្វើការទប់ស្កាត់និងឃាត់ខ្លួនមនុស្ស៦នាក់ ក្នុងនោះម្នាក់ជាជនជាតិថៃឈ្មោះស៊ុង ស័ក ភេទប្រុស អាយុ៦៣ឆ្នាំ ប្រុងលួចឆ្លងដែន និងមេខ្យល់ម្នាក់ ព្រមទាំងម៉ូតូ៣គ្រឿងនិងមនុស្សអមដំណើរ៤នាក់ផ្សេងទៀត។

លោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្តិ៍បឹងសាគូ នៃនគរបាលការពារព្រំដែនគោកលេខ៩១១ប្រាប់ឲ្យដឹងថា ករណីខាងលើកម្លាំងរបស់លោកបានទប់ស្កាត់ និងឃាត់ខ្លួនមនុស្សចំនួន១៥នាក់ ដោយ៥នាក់ ប្រុងលួចឆ្លងដែន ខ្មែរ៤នាក់ ថៃ១នាក់,ជនសង្ស័យ(មេខ្យល់)ចំនួន៤នាក់ និងម៉ូតូសរុប៥គ្រឿង មនុស្ស៦នាក់ ជាប់ពាក់ព័ន្ធដឹកជញ្ជូននិងអមដំណើរ។ លោកបញ្ជាក់ថា ករណីទប់ស្កាត់និងឃាត់ខ្លួនជនសង្ស័យខាងលើ គឺធ្វើឡើងតាមបទបញ្ជាដ៏មុឺងម៉ាត់ពីលោកឧត្តមសេនីយ៍ទោសិទ្ធ ឡោះស្នងការនគរបាលខេត្ត ក៏ដូចជាការណែនាំចង្អុលបង្ហាញផ្ទាល់ពីលោកវរសេនីយ៍ឯកសូ ចាន់ណារី មេបញ្ជាការវរៈរបស់លោកក្នុងកាទប់ស្កាត់រាល់បទល្មើសក្នុងភូមិសាស្ត្រទទួលខុសត្រូវតែម្តង។ លោកនាយប៉ុស្តិ៍ប្រាប់ថាទាំងពលករ,ជនសង្ស័យ,ម៉ូតូនិងអ្នកពាក់ព័ន្ធក្រោយឃាត់និងទប់ស្កាត់ បានបញ្ជូនទៅទីបញ្ជាការវរៈដើម្បីសាកសួរនិងចាត់ការបន្តតាមនិតិវិធីច្បាប់៕

## ខេត្តឧត្តរមានជ័យ ប្រកាសរកឃើញអ្នកឆ្លងជំងឺកូវីដ ១៨នាក់ និងជាពលករ មកពីប្រទេសថៃ ១៣នាក់

http://m.freshnewsasia.com/ 2021-06-25 08:26pm

(ឧត្តរមានជ័យ)៖ រដ្ឋបាលខេត្តឧត្តរមានជ័យ នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១នេះ បានចេញសេចក្តីប្រកាសព័ត៌មានពីការរកឃើញអ្នកជំងឺកូវីដ១៩ ចំនួន១៨នាក់ទៀត ជាពលករមកពីប្រទេសថៃ ចំនួន១៣នាក់។ តាមសេចក្តីប្រកាសព័ត៌មាន ដែលបណ្តាញព័ត៌មាន Fresh News ទទួលបានមុននេះបន្តិច។ សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី២៥ ខែមិថុនាឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យ រកឃើញជំងឺកូវីដចំនួន ៣០៥នាក់ ក្នុងនោះករណីនាំចូលពីបរទេសចំនួន ២៦៤នាក់ ឆ្លងក្នុងសហគមន៍ចំនួន ៤១នាក់ និងព្យាបាលជាសះស្បើយចំនួន ៩១នាក់ កំពុងសម្រាកព្យាបាលចំនួន ២១២នាក់ និងស្លាប់ ២នាក់៕

## អនុវត្តគោលការណ៍ថ្មី គ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស តម្រូវឲ្យធ្វើតេស្តរហ័ស លើគ្រប់ពលករ ដែលបានឆ្លងដែនចូលមកកម្ពុជា និងការធ្វើចត្តាឡីស័កនៅនឹងកន្លែង

https://cen-news.com/ Posted ByPen Srey NeatJune 27, 2021

ខេត្តឧត្តរមានជ័យ ៖ អាជ្ញាធរចុះពិនិត្យលើស្ថានភាពជាក់ស្តែង នៃការគ្រប់គ្រងពលករ ដែលធ្វើចំណាកស្រុកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ និងតម្រូវការចាំបាច់បន្ថែម សំដៅធ្វើយ៉ាងទប់ស្កាត់ឲ្យខាងតែបាននូវការចម្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍។

ឯកឧត្តម ប៉ែន កុសល្យ អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ អញ្ជើញជួបពិភាក្សាការងារ ជាមួយឯកឧត្តម ហ៊ុន ម៉ានិត អគ្គនាយកស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ និងជាប្រធានអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក នៅបរិវេណច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់នារសៀលថ្ងៃសៅរ៍ ទី២៦ ខែមិថុនា ឆ្នាំ២០២១។ កិច្ចប្រជុំនេះប្រព្រឹត្តិទៅ ក្នុងគោលបំណងពិនិត្យលើស្ថានភាពជាក់ស្តែង នៃការគ្រប់គ្រងពលករដែលធ្វើចំណាកស្រុក ពីប្រទេសថៃចូលមកប្រទេសកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ និងតម្រូវការចាំបាច់បន្ថែម សំដៅធ្វើយ៉ាងទប់ស្កាត់ឲ្យខាងតែបាននូវការចម្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍។

ក្រោយពីបានស្តាប់របាយការណ៍របស់ ឯកឧត្តមអភិបាលខេត្តរួច ឯកឧត្តម ហ៊ុន ម៉ានិត ក៏បានកោតសរសើរ ចំពោះការខិតខំប្រឹងប្រែងរបស់រដ្ឋបាលខេត្ត ក្នុងការរៀបចំគ្រប់គ្រងពលករ និងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍។ បន្ទាប់មកឯកឧត្តមក៏បានលើកជាអនុសាសន៍មួយចំនួនជូនរដ្ឋបាលខេត្ត ដើម្បីយកមករៀបចំជាគោលការណ៍អនុវត្តចំពោះមុខ ក្នុងនោះផ្តោតសំខាន់លើ វិធានការត្រៀមទទួលពលករខ្មែរ ដែលបានចូលមកកាន់តែច្រើនឡើង ជាពិសេសក្នុងការអនុវត្តគោលការណ៍ថ្មី ដែលតម្រូវឲ្យធ្វើតេស្តរហ័សលើគ្រប់ពលករដែលបានឆ្លងដែនចូលមក និងការធ្វើចត្តាឡីស័កនៅនឹងកន្លែង ដោយក្នុងនោះឯកឧត្តម ហ៊ុន ម៉ានិត ក៏បានស្នើឲ្យរដ្ឋបាលខេត្ត រៀបចំផែនការសកម្មភាព និងរៀបចំទីតាំងមណ្ឌលចត្តាឡីស័ក ក៏ដូចជាលើកសំណើពាក់ព័ន្ធនឹងតម្រូវការសម្ភារ បរិក្ខារបច្ចេកទេសដាក់ជូនគណៈកម្មការ និងអនុគណៈកម្មការថ្នាក់ជាតិដើម្បីជាយន្តការគាំទ្រដល់រដ្ឋបាលខេត្ត៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

# សង្គមស៊ីវិលបារម្ភពីការនាំពលករកម្ពុជាខុសច្បាប់ទៅក្រៅប្រទេសអំឡុងវិបត្តិកូវីដ-១៩

https://vodkhmer.news/ កញ្ញា ហ៊ន ថូរ៉ាន ២៤ មិថុនា ២០២១ ម៉ោង ១១:១០

សង្គមស៊ីវិលលើកឡើងថា ការនាំពលករកម្ពុជាខុសច្បាប់ទៅក្រៅប្រទេសក្នុងអំឡុងវិបត្តិកូវីដ-១៩ តាមរយៈមេខ្យល់ បានធ្វើឱ្យមានការកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់ប្រជាជនស្លូតត្រង់ ដែលជាសកម្មភាពមួយគួរឱ្យព្រួយបារម្ភនិងសោកស្ដាយបំផុត។

មន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) លោក ឌី ថេហូយ៉ា បានលើកឡើងក្នុងកម្មវិធី «សិទ្ធិមនុស្ស៣៦៥» របស់វីអូឌី នៅព្រឹកថ្ងៃពុធថា ចាប់តាំងពីខែមីនា ឆ្នាំ២០២០ ដែលមានការផ្ទុះនូវជំងឺកូវីដ-១៩ រហូតមកដល់ពេលបច្ចុប្បន្ន ការនាំពលករកម្ពុជាខុសច្បាប់ទៅក្រៅប្រទេស ជាពិសេសទៅប្រទេសថៃ តាមរយៈមេខ្យល់ បាននាំឱ្យមានការកេងប្រវ័ញ្ចកម្លាំងពលកម្មពលរដ្ឋជាបន្តបន្ទាប់។ លោកបន្តថា៖ «**ការដែលនាំរត់ពន្ធឬមួយជួញដូរមនុស្ស ដើម្បីយកកម្លាំងពលកម្មពលរដ្ឋខ្មែរយើង ដែលជាជនស្លូតត្រង់ទៅតាមបណ្ដាខេត្ត ជាពិសេសគឺតាមទីជនបទ ទៅប្រទេសថៃ ជាសកម្មភាពមួយដែលយើងគួរឱ្យសោកស្ដាយ ហើយយើងមិនគិតថាក្នុងកាលៈទេសៈដែលលំបាកបែបនេះហើយ ប្រឈមមុខពីបញ្ហាកូវីដបែបនេះ ពួកគាត់ត្រូវបានចាញ់បោកគេបន្ថែមទៀតក្នុងការបញ្ជូនទៅប្រទេសថៃទេ**»។ លោកបន្តទៀតថា តាមការសិក្សាស្រាវជ្រាវរបស់អង្គការសង់ត្រាល់ថ្មីៗនេះ សង្កេតឃើញថា មូលហេតុនៃការចំណាកស្រុកទៅកាន់ប្រទេសជិតខាងដែលមានប្រមាណ៨០ភាគរយ គឺបណ្ដាលមកពីពលរដ្ឋទាំងនោះមិនមានប្រាក់ចំណូលសម្រាប់ទ្រទ្រង់ជីវភាពរស់នៅ។

លោកបញ្ជាក់ថា៖ «**នៅក្នុងការសិក្សាស្រាវជ្រាវហ្នឹង យើងក៏បានសួរថាមូលហេតុអ្វីបានជាគាត់មិនមានប្រាក់ចំណូល គាត់ក៏បានថា ទីមួយ គឺគាត់អត់មានការងារធ្វើនៅក្នុងស្រុក។ ទីពីរ គឺគាត់មានដីស្រែដីចម្ការតិច មិនអាចផ្គត់ផ្គង់ជីវភាពបាន ឬមួយអ្នកដែលមានដីអាចធ្វើស្រែធ្វើចម្ការបានហើយ ប៉ុន្តែគេថាទិន្នផលនោះគឺមិនសូវមានទីផ្សារទេ។ ហេតុផលទីបី គឺគាត់បានបញ្ជាក់ដែរថា ពួកគាត់បានខ្ចីលុយធនាគារ ហើយជាទូទៅគឺគាត់មិនស្គាល់លុយធនាគារនោះទេ គឺគាត់ស្គាល់តែខ្ចីលុយអង្គការ តែយើងសួរទៅថា អង្គការហ្នឹងវាយ៉ាងម៉េច! សួរបញ្ជាក់ទៅថាគឺវាមានអ្នកឱ្យខ្ចីបុលតាមភូមិផង វាមានមីក្រូហិរញ្ញវត្ថុផង វាមានធនាគារផងអីជាដើម**»។

អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ក្នុងកម្មវិធីនោះដែរថា ស្ថានភាពការជួញដូរមនុស្សក្នុងដំណាក់កាលវិបត្តិកូវីដ-១៩នេះ មិនមែនមានតែកម្ពុជាទេ ហើយប្រទេសជិតខាងក៏បានបិទព្រំដែនតាំងពីខែមីនា ឆ្នាំ២០២០មកម្ល៉េះ។ ចំណែកឯការហូរចូលត្រលប់មកវិញនៃពលកររបស់ខ្មែរ មកដល់ពេលបច្ចុប្បន្ននេះ លោកស្រីថា មានប្រមាណ២០ម៉ឺននាក់ ហើយក៏មានអ្នកនាំចេញទៅវិញខ្លះផងដែរ តាមការអូសទាញឬការបញ្ចុះបញ្ចូលរបស់មេខ្យល់។ លោកស្រីយល់ថា បញ្ហានេះត្រូវមានវិធានការដោះស្រាយ បើមិនដូច្នេះទេ ភាពរងគ្រោះរបស់ពលរដ្ឋនៅតែកើនឡើងបន្ថែមទៀត។ លោកស្រីមានប្រសាសន៍ថា៖ «**ការជួញដូរមនុស្សក្នុងដំណាក់កាលនេះ គឺការនាំពលករឆ្លងដែនខុសច្បាប់ បោកបញ្ឆោតទៅរកការងារឬអាជីវកម្មដែលគាត់ប្រមូលលុយកាក់ហើយគ្មានការទទួលខុសត្រូវ។ អ៊ីចឹងបើសិនជាមិនចង់ឱ្យមានការឆ្លងដែនខុសច្បាប់ ទោះបីមានការទប់ស្កាត់ ខាងនេះមានអាជ្ញាធរ មានការទប់ស្កាត់តាមប្រទេសគោលដៅ ប៉ុន្តែគាត់នៅតែចេញទៅបាន មកពីមានប្រឡោះ បានន័យថា មានអ្នកត្រូវការពួកគាត់ ហើយគាត់ទទួលឱ្យធ្វើការទាំងប្រថុយប្រថានទៅ ហើយបើគេចាប់បានគឺចាប់ទៅ បើគេចាប់មិនបាន គាត់សម្ងំធ្វើការនៅទីនោះទៅ ដោយខុសច្បាប់**»។

ទំព័រហ្វេសប៊ុករបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា បានស្រង់ប្រសាសន៍របស់លោកស្រី Kristin Parco ប្រធានបេសកកម្មអង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំកម្ពុជា មកចុះផ្សាយកាលពីថ្ងៃទី២២ ខែមិថុនា ថាវិបត្តិ

កូវីដ-១៩បានបង្កឱ្យមានភាពងាយរងគ្រោះថ្មីៗជាច្រើន និងមានភាពធ្ងន់ធ្ងរជាងមុន ហើយថែមទាំងបានបង្កើតហានិភ័យចំពោះអំពើកេងប្រវ័ញ្ចបុគ្គលនិងសហគមន៍នៅក្នុងបណ្តាញជួញដូរមនុស្ស។

ចំណែកអនុប្រធានផ្នែកស្ត្រីនិងកុមារ នៃសមាគមការពារសិទ្ធិមនុស្សអាដហុក លោកស្រី មាស សាអ៊ីម បានបង្ហាញក្តីព្រួយបារម្ភចំពោះការចំណាកស្រុករបស់ពលរដ្ឋកម្ពុជាទៅកាន់ប្រទេសផ្សេងៗ ជាពិសេសទៅកាន់ប្រទេសជិតខាង ដែលអាចជះឥទ្ធិពលអាក្រក់ក្នុងការអភិវឌ្ឍរបស់ប្រទេសជាតិ ព្រោះអាចខ្វះនូវធនធានមនុស្ស។ លោកស្រីបន្តថា៖ **«យើងសង្កេតឃើញថា អ្នកដែលបានចំណាកស្រុកភាគច្រើន អាចរាប់ថាជាយុវវ័យដែលគាត់មានកម្លាំងពេញលេញ ជាធនធានដែលគួរអភិវឌ្ឍប្រទេសជាតិ ប៉ុន្តែពួកគាត់បែរជាមិនបាននៅអភិវឌ្ឍប្រទេសជាតិ បែរជាត្រូវបានគេជួញដូរឬក៏កេងប្រវ័ញ្ចនៅខាងក្រៅប្រទេសមួយចំនួន។ អ៊ីចឹងអាហ្នឹងវាជាការខាតបង់ផ្នែកសេដ្ឋកិច្ចធនធានមនុស្សដ៏សំខាន់នៅក្នុងការអភិវឌ្ឍប្រទេសជាតិ»**។ លោកស្រីបន្ថែមថា៖ **«ការត្រលប់មកវិញ[របស់]គាត់ជាបន្ទុកសម្រាប់ជាតិ គឺគាត់អាចខ្លះមានពិការភាព ខ្លះទៀតមានបញ្ហាវិបល្លាសស្មារតី ហើយខ្លះទៀតពេលត្រលប់មកវិញ គាត់មានអាយុជ្រេ[ច្រើន]ទៅហើយ ដែលគាត់ពិបាកនៅក្នុងការកសាងសមត្ថភាព ក៏ដូចជាការបំពេញការងារដែលអាចជួយទ្រទ្រង់ទៅដល់ជីវភាពគ្រួសារ ក៏ដូចជាសង្គមបាន»**។ ក្តីបារម្ភទាំងនេះ លោកស្រី មាស សាអ៊ីម ស្នើឱ្យអាជ្ញាធរចាត់វិធានការ ដោយចាប់មេខ្យល់យកមកផ្តន្ទាទោសនិងអនុវត្តច្បាប់ឱ្យបានពេញលេញ ពង្រីកការស៊ើបអង្កេតឱ្យបានតឹងរ៉ឹង ដោយមិនត្រូវចាប់តែមេខ្យល់តូចតាចនោះទេ ពោលគឺត្រូវចាប់ទាំងអស់ ទាំងអ្នកពាក់ព័ន្ធដែលរៀបចំឯកសារក្លែងក្លាយសម្រាប់ការឆ្លងដែនផងដែរ។

លោក ជុំ សុខ វ័យ៣៨ឆ្នាំ រស់នៅក្នុងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ដែលធ្លាប់ចាញ់បោកមេខ្យល់ទៅប្រទេសថៃ បានរៀបរាប់ថា មេខ្យល់បាននាំរូបលោកនិងពលករខ្មែរ៩នាក់ទៀតទៅខេត្តឈុនបុរី ប្រទេសថៃ ហើយលោកនិងអ្នកទាំង៩នាក់នោះត្រូវបានតម្រួតថៃឃាត់ខ្លួន និងដាក់ពន្ធនាគារនៅខេត្តសុរិន្ទ អស់រយៈពេល៦ឆ្នាំ ពោលគឺចាប់តាំងពីឆ្នាំ២០១៦ រហូតដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ ទើបពួកលោកត្រូវបានគេដោះលែងវិញ ដោយសារព្រះមហាក្សត្រថៃបានព្រះរាជទានលើកលែងទោស ក្រោយអនុវត្តទោសបាន៤ឆ្នាំ។ លោកថា៖ **«ខ្ញុំស្គាល់គេ [មេខ្យល់] តាមរយៈបងប្អូន ហើយគេនាំខ្ញុំទៅឱ្យ ខ្ញុំបានបង់លុយប្រមាណជាង៣០ម៉ឺនរៀល [២៥០០បាត-លុយថៃ] សម្រាប់ការធ្វើឯកសារ។ គេនាំខ្ញុំទៅថៃតាមច្រកអូរស្មាច់ គេ [តម្រួតថៃ] បានចាប់និងឃុំខ្លួនសួរចម្លើយ ហើយចោទប្រកាន់ពីបទក្លែងបន្លំឯកសារនិងត្រាខុសច្បាប់គេ ហើយមេខ្យល់ទាំង៤នាក់ដែលនាំទៅគឺបានរត់គេចបាត់ស្រមោលអស់»**។

បើតាមមន្ត្រីជាន់ខ្ពស់នៃអង្គការសង់ត្រាល់ លោក ហូយ៉ា អំឡុងពេលមានវិបត្តិជំងឺកូវីដ-១៩ មានពលករជាង ២ ០០០នាក់ត្រូវបានចាប់ខ្លួនក្នុងពេលពួកគាត់កំពុងធ្វើដំណើរដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ក្នុងនោះ ពួកគាត់ម្នាក់ៗត្រូវបង់ប្រាក់ចំនួន៣ ០០០បាត ឬស្មើជាង១០០ដុល្លារទៅឱ្យមេខ្យល់៕

## ត្រៀមទទួលពលករខ្មែរ ដែលបានចូលមកកាន់តែច្រើនឡើង នៅច្រកទ្វារអូរបីជាន់ បន្ទាប់ពីមានការរាលដាលជំងឺកូវីដ១៩ នៅប្រទេសថៃ

https://cen-news.com/ Posted ByPen Srey NeatJune 27, 2021

ខេត្តបន្ទាយមានជ័យ ៖ ឯកឧត្តមហ៊ុន ម៉ានិត រៀបចំគោលការណ៍អនុវត្ត វិធានការត្រៀមទទួលពលករខ្មែរដែលបានចូលមកកាន់តែច្រើនឡើងបន្ទាប់ពីមានការរាលដាលជំងឺកូវីដ១៩នៅប្រទេសថៃ ។ នៅថ្ងៃអាទិត្យទី២៧ ខែមិថុនា ឆ្នាំ២០២១ ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ ជួបពិភាក្សាការងារជាមួយ ឯកឧត្តម ហ៊ុន ម៉ានិត អគ្គនាយកស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ និងជាប្រធានអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក នៅបរិវេណច្រកទ្វារអូរបីជាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

ឯកឧត្តម ហ៊ុន ម៉ានិត និងប្រតិភូអនុគណៈកម្មការ បានអញ្ជើញពិនិត្យមើលទីតាំងនៃការគ្រប់គ្រង ការពិនិត្យយកសំណាកបងប្អូនពលករ ដែលក្រុមការងារចម្រុះខេត្ត បាននឹងកំពុងបំពេញបេសកកម្មការងារ ដើម្បីប្រយុទ្ធទប់ស្កាត់នឹងជំងឺកូវីដ១៩ ។ បានបន្តកិច្ចប្រជុំពិភាក្សាការងារ ជាមួយអាជ្ញាធរខេត្ត កងកម្លាំងប្រដាប់អាវុធជាគណៈកម្មការខេត្តប្រយុទ្ធនឹងជំងឺកូវីដ១៩ ក្នុងគោលបំណងពិនិត្យលើស្ថានភាពជាក់ស្តែង នៃការគ្រប់គ្រងពលករដែលធ្វើចំណាកស្រុកពីប្រទេសថៃចូលមកប្រទេសកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ និងតម្រូវការចាំបាច់បន្ថែម សំដៅធ្វើយ៉ាងទប់ស្កាត់ឲ្យខាងតែបាននូវការចម្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍។ ឯកឧត្តម ហ៊ុន ម៉ានិត បានលើកជាអនុសាសន៍មួយចំនួនជូនរដ្ឋបាលខេត្ត ដើម្បីយកមករៀបចំជាគោលការណ៍អនុវត្តចំពោះមុខ ក្នុងនោះផ្តោតសំខាន់លើវិធានការត្រៀមទទួលពលករខ្មែរដែលបានចូលមកកាន់តែច្រើនឡើង ជាពិសេសក្នុងការអនុវត្តគោលការណ៍ថ្មីដែលតម្រូវឲ្យធ្វើតេស្តរហ័សលើគ្រប់ពលករដែលបានឆ្លងដែនចូលមក និងការធ្វើចត្តាឡីស័កនៅនឹងកន្លែង។ ឯកឧត្តម ហ៊ុន ម៉ានិត ក៏បានស្នើឲ្យរដ្ឋបាលខេត្ត រៀបចំផែនការសកម្មភាព និងរៀបចំទីតាំងមណ្ឌលចត្តាឡីស័ក ក៏ដូចជាលើកសំណើពាក់ព័ន្ធនឹងតម្រូវការសម្ភារ បរិក្ខារបច្ចេកទេសដាក់ជូនគណៈកម្មការ និងអនុគណៈកម្មការថ្នាក់ជាតិដើម្បីជាយន្តការគាំទ្រដល់រដ្ឋបាលខេត្ត៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១

### កម្លាំងចម្រុះឃាត់ពលករ៤គោលដៅផ្សេងគ្នា សរុបចំនួន៣២នាក់ បម្រុងឆ្លងដែនទៅថៃខុសច្បាប់

http://cambodiapolice.com/policekh/ 11:21 am 27 មិថុនា 2021

បន្ទាយមានជ័យ ៖ កម្លាំងចម្រុះរួមមាន នគរបាលព្រំដែនគោកលេខ៩១១ បានសហការជាមួយកងពលតូចថ្មើរជើងលេខ៥១ កងរាជអាវុធហត្ថ និងកងការពារព្រំដែនគោកលេខ៥០៣ ឃាត់ខ្លួនពលករ និងអ្នកនាំផ្លូវសរុបចំនួន៣២នាក់ (ស្រីចំនួន១០នាក់) ក្នុងនោះមានជនជាតិថៃម្នាក់ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ នៅវេលាម៉ោង២៣និង៣៤នាទី ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ស្ថិតនៅក្នុងភូមិសាស្ត្រ ក្រុងប៉ោយប៉ែត និងស្រុកអូរជ្រៅ។

សមត្ថកិច្ចការពារព្រំដែនប្រាប់ថា ដើម្បីពង្រឹងការល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា កម្លាំងចម្រុះសហការជាមួយគ្នា ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ ចូលទៅក្នុងសហគមន៍ និងតំបន់ផ្សេងទៀត។ សមត្ថកិច្ចបន្តថា នៅពេលកងកម្លាំងចម្រុះល្បាតក្នុងភូមិសាស្ត្រទទួលខុសត្រូវបានជួបពលករបម្រុងលួចឆ្លងដែន ត្រូវបានធ្វើការឃាត់ខ្លួនដើម្បីសួរនាំនិងធ្វើការអប់រំណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំឲ្យបន្តចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូល នាំពួកគាត់ឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុខភាព សុវត្ថិភាព និងខាតបង់ប្រាក់របស់បងប្អូននោះឡើយ ជាពិសេសបច្ចុប្បន្ននេះទាំងភាគីកម្ពុជានិងថៃ កំពុងតែប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ មិនឲ្យមានការឆ្លងដែននោះឡើយ ។ ដូច្នេះដើម្បីទប់ស្កាត់ជម្ងឺកាចសាហាវនេះកុំឲ្យរីករាលដាលឆ្លងចូលក្នុងសហគមន៍ គឺមានតែយើង ទប់ស្កាត់ទាំងអស់គ្នា ចូលរួមអនុវត្តវិធានការ «៣កុំ ៣ការពារ» ដើម្បីគ្រួសារ និងសង្គមជាតិ ។

ចំពោះពលករទាំង២៧នាក់ ត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័កនិងមនុស្សចំនួន៥នាក់សង្ស័យជាអ្នកនាំនិងអ្នកពាក់ព័ន្ធប្រគល់ឲ្យសមត្ថកិច្ចមូលដ្ឋានដើម្បីសួរនាំស្រាវជ្រាវបន្តផ្លូវរកមេខ្យល់ចាត់ការតាមផ្លូវច្បាប់ផងដែរ៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលករខ្មែរ២ នាក់ ត្រឡប់មកពីប្រទេសថៃ បញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 7:12 pm 24 មិថុនា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ។

ជាក់ស្តែង នៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រស្រុកសំពៅលូន ខេត្តបាត់ដំបង ព្រមទាំងបានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ចំនួន២នាក់(ស្រី) ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ។ បន្ទាប់ពីធ្វើការសាកសួរ កត់ឈ្មោះ និងធ្វើការអប់រំណែនាំរួច កម្លាំងបានប្រគល់ពួកគាត់ទៅឲ្យក្រុមគ្រូពេទ្យ ដើម្បីបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ ៕

## មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ អំពាវនាវប្រជាពលរដ្ឋ កុំឱ្យបន្តចាញ់បោកមេខ្យល់លួចឆ្លងដែនខុសច្បាប់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២១

AKP បន្ទាយមានជ័យ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១៖ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ លោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋកុំឱ្យបន្តចាញ់បោកមេខ្យល់ ដែលតែងតែបញ្ឆោះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ចូលទៅប្រទេសថៃដោយមិនគិតពីសុខសុវត្ថិភាពអាយុជីវិតនិងខាត បង់ប្រាក់ជាបន្តបន្ទាប់ នោះ។ ការអំពាវនាវយ៉ាងដូច្នេះក្នុងឱកាសលោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ បានធ្វើការអប់រំណែនាំដល់ពលរដ្ឋចំនួន៣២នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ចូលទៅប្រទេសថៃ ត្រូវបានកម្លាំងកងពលតូចថ្មើរជើងលេខ៥១សហការជាមួយកងរាជអាវុធហត្ថ,កងការពារព្រំដែនគោកលេខ៥០៣ និង នគរបាលព្រំដែនគោកលេខ៩១១ ឃាត់ខ្លួនបាននៅវេលាម៉ោង ១១:៤៥នាទីយប់ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១នេះ នៅចំនួន៤គោលដៅផ្សេងគ្នា ស្ថិតនៅក្នុងភូមិសាស្ត្រ ក្រុងប៉ោយប៉ែត និងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

លោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ បានបញ្ជាក់ទៀតថា ដោយអនុវត្តតាមបទបញ្ជារបស់មេ បញ្ជាការកងទ័ពជើងគោក, យោធភូមិភាគទី៥នោះ កងពលតូចថ្មើរជើងលេខ៥១បានបង្កើនពង្រឹងការចុះល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នាសហការជាមួយកម្លាំងចម្រុះដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់និងការឆ្លងរាលដាលនៃជំងឺកូវីដ១៩ មិនឱ្យចូលទៅក្នុងសហគមន៍ និងតំបន់ផ្សេងទៀត។ លោកឱ្យដឹងទៀតថា ខណៈដែលកងកម្លាំងចម្រុះកំពុងល្បាតក៏បានជួបពលករដែល បម្រុងលួចឆ្លងដែនត្រូវបានកងកម្លាំង កងពលតូចថ្មើរជើងលេខ៥១ឃាត់ខ្លួនបានតែម្តង ក្រោយពីឃាត់ខ្លួនហើយក៏បានធ្វើការណែនាំអប់រំដល់បងប្អូនប្រជាពលរដ្ឋកុំឱ្យបន្តចាញ់បោកពួកមេខ្យល់ដែលតែងតែបញ្ឆោះបញ្ចូលនាំពលករឆ្លងដែន ដោយខុសច្បាប់តាមច្រករបៀង ដោយមិនគិតពីសុខសុវត្ថិភាព អាយុជីវិតនិងខាតបង់ប្រាក់ ជាច្រើនទៀតផងនោះ។

ជាមួយនោះលោកក៏បានក្រើនរម្លឹកដល់បងប្អូនប្រជាពលរដ្ឋសូមឱ្យបន្តចូលរួមអនុវត្តវិធានការ ៣កុំ ៣ការពារ ឱ្យបានខ្ជាប់ខ្ជួនទាំងអស់គ្នា ដើម្បី ជៀសផុតពីការឆ្លងជំងឺកូវីដ១៩នោះ។ លោកបានប្រាប់ឱ្យដឹងទៀតថា បច្ចុប្បន្នពលរដ្ឋទាំង៣២នាក់នេះត្រូវបានបញ្ជូនទៅ កាន់មណ្ឌលចត្តាឡីស័ក និងមនុស្សចំនួន៤នាក់សង្ស័យជាអ្នកនាំផ្លូវបន្តស្រាវជ្រាវរកមេខ្យល់ និងអ្នកពាក់ព័ន្ធចាត់វិធានការតាមផ្លូវច្បាប់៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៨នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសុក្រ ទី២៥ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៨នាក់ ស្រី ៨នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣៣នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១២នាក់ ស្រី ៥នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៨នាក់ ស្រី ៨នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៧០នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃព្រហស្បតិ៍ ទី២៤ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៧០នាក់ ស្រី ២៦នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២០នាក់ ស្រី ៦នាក់ កុមារា ១នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤នាក់ ស្រី ១នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៤៤នាក់ ស្រី ១៩នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារ ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ២នាក់ ស្រីចំនួន ១នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៧៦នាក់ ស្រី ២៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## រយៈពេលចុងក្រោយនេះ រកឃើញវិជ្ជមានកូវីដ-១៩រាល់ថ្ងៃ លើពលករមកពីថៃតាមច្រកខេត្តឧត្តរមានជ័យ

https://news.btv.com.kh/ 06/25/2021 01:06 PM

ភិបាលខេត្តឧត្តរមានជ័យបានឱ្យដឹងថា រយៈពេលចុងក្រោយនេះរកឃើញវិជ្ជមានកូវីដ-១៩ រាល់ថ្ងៃលើពលករមកពីថៃ តាមច្រកខេត្តនេះ។ មន្ត្រីជំនាញបានធ្វើការអំពាវនាវដល់អាជ្ញាធរពាក់ព័ន្ធបង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងរំហូរចូលនៃពលករមកពីថៃ។

វេជ្ជបណ្ឌិត ឃ្លោក ហួត ទីប្រឹក្សាក្រសួងសុខាភិបាល និងជាប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យបានបញ្ជាក់ថា ពលករខ្មែរមកពីថៃ ត្រូវបានរកឃើញវិជ្ជមានកូវីដ-១៩ រាល់ថ្ងៃ ដែលគិតត្រឹមថ្ងៃទី២៤ ខែមិថុនានេះគឺមានការកើនឡើងចំនួន៦០នាក់ហើយ នៅថ្ងៃទី២៤ មិថុនា ឆ្នាំ២០២១នេះ។ វេជ្ជបណ្ឌិត ឃ្លោក ហួត បានឲ្យដឹងទៀតថា ក្នុងចំណោមពលករដែលឆ្លងដែនមក មន្ត្រីជំនាញធ្វើ ចត្តាឡីស័កជួរមុខ តែងតែពិនិត្យរកឃើញនូវអ្នកវិជ្ជមានជំងឺកូវីដ-១៩ ជារាងរាល់ថ្ងៃ គ្រាន់តែតិច និងច្រើន ប៉ុណ្ណោះ តាមរយៈការធ្វើតេស្តរហ័ស។ ពលករ ដែលមានវិជ្ជមានកូវីដ-១៩ ត្រូវបានដាក់ឱ្យព្យាបាលនៅតាមមន្ទីរពេទ្យខេត្តនេះដោយយក ចិត្តទុកដាក់។ ប៉ុន្តែអ្វី ដែលជាកត្តាគួរឲ្យមានការបារម្ភខ្លាំងនោះ ភាគច្រើនគឺអ្នកជំងឺកូវីដ-១៩ ដែលពាក់ ព័ន្ធទៅនឹងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ គឺអ្នកជំងឺងាយនឹងមានការប្រឈមនឹងគ្រោះថ្នាក់ខ្លាំង ពិសេសគឺអ្នកជំងឺ ដែលមានអាយុច្រើន ដោយសារតែពួកគេមកទទួលការព្យាបាល ខណៈស្ថានភាពជំងឺ មានសភាពធ្ងន់ធ្ងរហើយ និងពេលខ្លះ អាចប្រឈមនឹងការស្លាប់បាត់បង់ជីវិតផងដែរ។

បច្ចុប្បន្ននេះ ក្នុងខេត្តឧត្តរមានជ័យ មានអ្នកជំងឺកូវីដ-១៩ ចំនួន២៨៧នាក់ ក្នុងនោះករណីនាំចូល ពីថៃចំនួន២៥១នាក់ ករណីឆ្លងសហគមន៍២០កុម្ភៈ ចំនួន៣៦នាក់ ជាសះស្បើយ១១៤នាក់ និងស្លាប់ពីរ នាក់ ៕ អត្ថបទ៖ ឃិន សារិទ្ធ

## មិនខ្វល់នៅថៃ៖ ពលករខ្មែររាប់រយនាក់បានសម្រុកត្រឡប់មកកម្ពុជាវិញ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 28/06/2021 - 09:22

ពលករខ្មែរ ដែលធ្វើការនៅប្រទេសថៃរាប់រយនាក់ត្រូវបានរាយការណ៍ថា បានសម្រុកចូលមកប្រទេសកម្ពុជាវិញដោយសារបារម្ភពីការឆ្លងកូវីដ-១៩ ខ្វះការយកចិត្តទុកដាក់គាំពារសង្គមពីថៃ និងភាពស្រពិចស្រពិលនៃសុវត្ថិភាពការងារជាដើម។ ការសម្រុកវិលត្រលប់មកប្រទេសកំណើតវិញរបស់ពលករខ្មែរនៅពេលនេះ គឺដោយសារប្រទេសថៃដែលកំពុងប្រឈមនឹងរលកថ្មីនៃជំងឺកូវីដ-១៩ បានដាក់វិធានការរឹតបន្តឹងបន្ថែមដោយបិទខ្ទប់ទីក្រុងបាងកក និងទីក្រុងជុំវិញរយៈពេល១ខែ ចាប់ពីថ្ងៃចន្ទនេះតទៅ។ លោក លឹង សុផុន មន្ត្រីសិទ្ធិការងារទទួលបន្ទុកផ្នែកពលករចំ

ណាកស្រុករបស់អង្គការសង់ត្រាល់ ប្រចាំប្រទេសថៃ បានប្រាប់វិទ្យុបារាំងអន្តរជាតិ RFI នៅថ្ងៃទី២៨ ខែមិថុនានេះ ថា កាលពីថ្ងៃអាទិត្យម្សិលមិញ មានពលករខ្មែរដល់ទៅ ២០០នាក់ បានចូលមកប្រទេសកម្ពុជាវិញ តាមច្រកអូស្មាច់ ព្រំប្រទល់ខេត្តសុរិន្ទ នៃប្រទេសថៃ និងខេត្តឧត្តរមានជ័យ នៃប្រទេសកម្ពុជា។

## ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

## ឧត្តមសេនីយ៍ឯក ជីវ ផល្លី ជំរុញការិយាល័យជំនាញ បន្តស្រាវជ្រាវកន្លែងសង្ស័យ មានជួញដូរពលរដ្ឋវៀតណាម មកធ្វើការនៅកន្លែងកាស៊ីណូ កន្លែងល្បែងកម្សាន្ត និងនៅតាមកន្លែងល្បែងអនឡាញ

https://cen-news.com/ Posted ByPen Srey NeatJune 29, 2021

ភ្នំពេញ ៖ ក្រុមការងារប្រតិកម្មរហ័ស អគ្គស្នងការដ្ឋាននគរបាលជាតិ សូមជម្រាបជូនសាធារណជន ពាក់ព័ន្ធការចុះផ្សាយរបស់វិទ្យុបរទេសនិយាយភាសាខ្មែរ ដែលមានខ្លឹមសារថា ស្ថានទូតវៀតណាម បានផ្តល់ព័ត៌មានថា មានជនជាតិវៀតណាម ត្រូវក្រុមជួញដូរមនុស្សបោកប្រាស់ ឲ្យមកធ្វើការនៅកន្លែងកាស៊ីណូ កន្លែងល្បែងកម្សាន្ត និងនៅតាមកន្លែងល្បែងអនឡាញផ្សេងៗ នៅក្នុងប្រទេសកម្ពុជា។

យោងតាមរបាយការណ៍បឋម ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រុមការងារប្រតិកម្មរហ័សអគ្គស្នងការដ្ឋាននគរបាលជាតិ សូមជម្រាបជូនសាធារណជន អ្នកសារព័ត៌មាន ពិសេសបណ្តាញទំនាក់ទំនងសង្គមមេត្តាជ្រាបថា៖ កាលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ មានវិទ្យុបរទេសនិយាយភាសាខ្មែរបានចេញផ្សាយព័ត៌មាន និងបានបង្ហោះតាមបណ្តាញសង្គមដោយមានខ្លឹមសារថា ស្ថានទូតវៀតណាមបានផ្តល់ព័ត៌មានថា មានជនជាតិវៀតណាមត្រូវក្រុមជួញដូរមនុស្សបោកប្រាស់ ឲ្យមកធ្វើការនៅកន្លែងកាស៊ីណូ កន្លែងល្បែងកម្សាន្ត និងនៅតាមកន្លែងល្បែងអនឡាញ ផ្សេងៗនៅក្នុងប្រទេសកម្ពុជា។

សកម្មភាពជួញដូរធ្វើឡើងតាមរយៈមេខ្យល់ជនជាតិចិន និងកម្ពុជា និងសន្យាថា ជនជាតិវៀតណាមទាំងនោះ ទទួលបានការងារសាមញ្ញ ប្រាក់ខែពី ៨០០ដុល្លា ទៅ១,០០០ដុល្លាក្នុង១ខែ ផ្តល់អាហារហូបចុក កន្លែងស្នាក់នៅ នៅក្នុងសណ្ឋាគារ និងកាស៊ីណូ ភាគច្រើន នៅក្រុងព្រះសីហនុ។ ពួកគេត្រូវបានកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយបង្ខំឲ្យធ្វើការ១ថ្ងៃពី ១៥ ទៅ ១៦ ម៉ោង បើសិនមិនដូច្នេះទេ ពួកគេនឹងវាយធ្វើបាប ។ ពួកគេភាគច្រើនបានរងនូវទារុណកម្ម វាយដំពេលពួកគេព្យាយាមរត់ និងបដិសេធមិនធ្វើការតាមការកំណត់ ។ ចំពោះអ្នកដែលមានបំណងចង់វិលត្រឡប់ទៅប្រទេសវៀតណាម ថៅកែបង្ខំឲ្យចុះហត្ថលេខាលើលិខិតជំពាក់បំណុលច្រើនពាន់ដុល្លារអាមេរិក ឬត្រូវនាំទៅលក់កម្លាំងពលកម្មនៅក្រុមហ៊ុនផ្សេងទៀត។

បន្ទាប់ពីបានទទួលព័ត៌មាននេះ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឧត្តមសេនីយឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានណែនាំ និងជំរុញឲ្យការិយាល័យជំនាញ ស្នងការដ្ឋាននគរបាលខេត្តពាក់ព័ន្ធ ពិសេសខេត្តព្រះសីហនុ ធ្វើការស្រាវជ្រាវស៊ើបអង្កេត បញ្ជាក់ព័ត៌មានរកការពិត ដើម្បីមានចំណាត់ការតាមនីតិវិធី។

ដោយឡែកនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ នាយកដ្ឋានបានទំនាក់ទំនងទៅ លោក ហ៊ាង ទឹមហ៊ីវ អនុព័ន្ធនគរបាលអមស្ថានទូតវៀតណាមប្រចាំកម្ពុជា ដោយលោកឆ្លើយតបថា លោកមិនទាន់ទទួលបានព័ត៌មាននេះទេ លោកនឹងពិភាក្សាជាមួយស្ថានទូត និងឆ្លើយមកនាយកដ្ឋានវិញ ដើម្បីបន្តកិច្ចសហប្រតិបត្តិការ។

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ តាមរបាយការណ៍របស់ការិយាល័យជំនាញ នៃស្នងការដ្ឋានខេត្តព្រះសីហនុ បានបញ្ជាក់ថា កន្លងមកក្នុងការព្រឹត្តិការណ៍២០កុម្ភៈមកដល់បច្ចុប្បន្ន ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយការិយាល័យគ្រប់គ្រងជនបរទេស នៃផែនការងារអន្តោប្រវេសន៍ បានឃាត់

ខ្លួនជនជាតិវៀតណាម បានចំនួន២៣នាក់ (ស្រី១៥នាក់) ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ការលួចឆ្លងដែនចូលប្រទេសកម្ពុជា ដោយខុសច្បាប់ និងករណីព្យាយាមរត់គេចពីខេត្តព្រះសីហនុ ដោយបំពានបំរាមបិទខ្ទប់ របស់គណៈបញ្ជាការឯកភាពខេត្ត នៃការទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ-១៩ ហើយពុំមានការពាក់ព័ន្ធ បទល្មើសជួញដូរមនុស្ស ឬការកេងប្រវ័ញ្ចពលកម្ម លើជនជាតិវៀតណាម ដូចការចុះផ្សាយកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ នោះឡើយ ។

ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានថ្លែងថា ជាទិសដៅអនុវត្តបន្ត នាយកដ្ឋានបានណែនាំ និងជំរុញការិយាល័យជំនាញ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ពិសេសខេត្តព្រះសីហនុ បន្តស្រាវជ្រាវកន្លែងសង្ស័យថា មានជួញដូរពលរដ្ឋវៀតណាម ក្នុងករណីរកឃើញស្នើសុំគោលការណ៍ថ្នាក់ដឹកនាំចាត់ការតាមច្បាប់៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## នគរបាលបញ្ជូនជនសង្ស័យចំនួន១០នាក់ទៅតុលាការ ពីបទ នាំមនុស្សចេញមិនស្របច្បាប់ ឆ្លងដែនទៅប្រទេសថៃ

https://cen-news.com/ Posted ByPen Srey NeatJune 29, 2021

បន្ទាយមានជ័យ ៖ កម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១នេះ បានបញ្ជូនខ្លួនជនសង្ស័យ ចំនួន១០នាក់ ពីបទនាំមនុស្សចេញមិនស្របច្បាប់ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីអនុវត្តតាមនីតិវិធី ។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា ជនសង្ស័យទាំង១០នាក់នេះ គឺពាក់ព័ន្ធករណីនាំមនុស្សឆ្លងដែនទៅប្រទេសថៃ មិនស្របច្បាប់ ត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនលេខ៩១១ បានធ្វើការឃាត់ខ្លួនចំនួន០២ករណី ដោយឡែកពីគ្នា ជាបន្តបន្ទាប់ នៅក្នុងភូមិសាស្ត្រ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ រួចបានធ្វើការប្រគល់ឲ្យនគរបាលអធិការដ្ឋានក្រុងប៉ោយប៉ែត រៀបចំសំណុំរឿងបញ្ជូនមកការិយាល័យជំនាញប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការបន្ត ។ លោកស្រីឧត្តមសេនីយ៍ស្នងការរង បានបញ្ជាក់ថា ក្នុងកិច្ចប្រតិបត្តិការនេះ កម្លាំងសមត្ថកិច្ចដកហូតវត្ថុតាងម៉ូតូ ចំនួន០៥គ្រឿង ដែលជាមធ្យោបាយសម្រាប់បម្រើឲ្យបទល្មើស ដឹកជញ្ជូនពលករដើម្បីឆ្លងដែន។

បើយោងតាមចម្លើយបំភ្លឺរបស់ពលករចំនួន ៥នាក់ (ជនជាតិថៃ០១នាក់) និងចម្លើយសារភាពរបស់ជនសង្ស័យទាំង១០នាក់ឲ្យដឹងថា ពួកគេពិតជាបានប្រព្រឹត្តអំពើនាំមនុស្សចេញដោយមិនស្របច្បាប់ពិតប្រាកដមែន។ បច្ចុប្បន្នជនសង្ស័យនិងវត្ថុតាងម៉ូតូ កម្លាំងនគរបាលការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។ ចំពោះពលករចំនួន០៥នាក់ ត្រូវបានធ្វើកិច្ចសន្យាអប់រំរួចឲ្យពួកគេវិលទៅលំនៅឋានវិញ ។ ចំណែកជនជាតិថៃ០១នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក នៅវិទ្យាល័យនិមិត្ត ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

# ពលករខ្មែរសម្រុកមកពីថៃ បន្ទាប់ពីថៃបិទទីតាំងស្នាក់នៅ ពេលផ្ទុះការឆ្លងកូវីដជាថ្មី

https://m.postkhmer.com/ ឡុង គីមម៉ារីតា 29 June 2021 | 08:55 ICT

**បន្ទាយមានជ័យៈ** ពលករកម្ពុជាដែលធ្វើការក្នុងវិស័យសំណង់នៅប្រទេសថៃ បានសម្រុកវិលត្រឡប់ចូលមកប្រទេសវិញតាមច្រកព្រំដែនមួយចំនួន នៅពេលដែលរដ្ឋាភិបាលថៃសម្រេចបិទរាល់ទីតាំងស្នាក់នៅតាមការដ្ឋានសំណង់ទាំងអស់ នៅក្នុងទីក្រុងបាងកក និងខេត្តចំនួន ៤ ផ្សេងទៀតរយៈពេល ៣០ ថ្ងៃ ខណៈប្រទេសនេះបានផ្ទុះការឆ្លងរាលដាលជំងឺកូវីដ ១៩ ជាថ្មី។

នាយករដ្ឋមន្ត្រីថៃ បានចេញសេចក្តីប្រកាសកាលពីថ្ងៃទី ២៧ ខែមិថុនា បិទទីតាំងស្នាក់នៅតាមការដ្ឋានសំណង់ក្នុងទីក្រុងបាងកក និងខេត្តចំនួន ៤ ផ្សេងទៀតចាប់ពីថ្ងៃចន្ទ ទី ២៨ ខែមិថុនាតទៅ ដើម្បីទប់ស្កាត់រលកទី ៣ នៃការរីករាលដាលជំងឺកូវីដ ១៩។ ការសម្រេចនេះ រដ្ឋាភិបាលថៃបានអនុលោមតាមវិធានការតឹងរ៉ឹង ដោយហាមមិនឱ្យមានសកម្មភាពរបស់កម្មកររយៈពេល ៣០ ថ្ងៃ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ យ៉ាងខ្លីកាលពីថ្ងៃទី ២៨ មិថុនាថា ក្រសួងការបរទេស ស្ថានទូតកម្ពុជា និងក្រសួងការងារកំពុងសហការគ្នា ធ្វើការជាមួយភាគីថៃ ដើម្បីដោះស្រាយបញ្ហាដែលកម្មករខ្មែរ សម្រុកវិលត្រឡប់មកកម្ពុជាវិញនេះ។ ប៉ុន្តែលោកមិនបញ្ជាក់ទេថាតើនឹងមានការដោះស្រាយយ៉ាងដូចម្តេចរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលថៃនោះទេ។

ចំពោះពលករខ្មែរនៅប្រទេសថៃវិញ លោក លឹង សុផុន ក្រុមការងារនៃអង្គការសង់ត្រាល់ប្រចាំប្រទេសថៃបានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ២៨ មិថុនាថា ដោយសារតែរដ្ឋាភិបាលថៃបានប្រកាសបិទការដ្ឋានសំណង់យ៉ាងដូច្នេះ ទើបធ្វើឱ្យពលករខ្មែរ ដែលស្ថិតក្នុងវិស័យសំណង់មានក្តីបារម្ភ ហើយក៏មានពលករជាច្រើនសម្រេចចិត្តវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ។ លោកឱ្យដឹងថា តាមព័ត៌មានទទួលបានពីមន្ត្រីប្រចាំការនៅតាមច្រកព្រំដែនថៃ-កម្ពុជាដោយគ្រាន់តែក្នុងរយៈពេល ១ ថ្ងៃកាលពីថ្ងៃទី ២៧ មិថុនា មានកម្មកររាប់រយនាក់ បានសម្រុកចេញពីប្រទេសថៃតាមច្រកអូរស្មាច់ ច្រកអូរបីជាន់ ច្រកព្រំដែនបឹងត្រកួន និងច្រករបៀងតូចៗផ្សេងទៀតនៃខេត្តសុរិន្ទរបស់ថៃ។ លោកបញ្ជាក់ថា៖ «ដោយសារមានការប្រកាស ដូច្នេះពួកគាត់មានក្តីបារម្ភ ព្រោះរយៈពេលបិទនេះ គឺ១ខែឯណោះហើយពួកគាត់បានឃើញមិត្តភក្តិរបស់ពួកគាត់ នៅកន្លែងធ្វើការសំណង់នោះមានការឆ្លង ហើយក៏មានការធ្វើចត្តាឡីស័ក។ អ្នកមិនទាន់ឆ្លង ពួកគាត់ក៏ព្រួយបារម្ភ ហើយសម្រុកទៅច្រើន ដូចថ្ងៃទី ២៨ មិថុនានេះ ក៏មានទៅច្រើនដែរ»។

បើតាមលោក លឹម សុផុន ការដែលពលករក្នុងវិស័យនេះ សម្រុកវិលចូលប្រទេស បន្ទាប់ពីពួកគេហាក់មិនមានការទុកចិត្តនឹងវិធានការដែលរដ្ឋាភិបាលថៃបានផ្តល់ឱ្យពួកគេក្នុងអំឡុងពេលឆ្លងជំងឺកូវីដ ១៩ ខណៈក្នុង ១ ថ្ងៃៗ ថៃ មានចំនួនអ្នកឆ្លងជំងឺនេះច្រើនទៅៗជាង ៥ ០០០ នាក់ ហើយចំនួនអ្នកស្លាប់ក្នុង ១ ថ្ងៃៗមានដល់ ៥០ នាក់។ លោករៀបរាប់ថា៖ «ពួកគាត់ក៏បារម្ភដែរ ព្រោះនៅពេលឆ្លងក៏មិនដឹងថា ទៅព្យាបាលជំងឺនេះនៅកន្លែងណាទេ ហើយតាមតំបន់មួយចំនួននៅប្រទេសថៃ គឺមន្ទីរពេទ្យពេញទៅដោយអ្នកជំងឺ គ្មានកន្លែងព្យាបាលទេ។ នៅពេលពលករខ្មែរយើងខ្លះឈឺ គឺគាត់មិនត្រូវបានគេយកចិត្តទុកដាក់នោះទេ គេយកគាត់ទៅដាក់កន្លែងមួយឆ្ងាយៗពីមន្ទីរពេទ្យ ហើយគាត់ខ្វះខាតនូវស្បៀងអាហារផង។អ៊ីចឹងហើយបានធ្វើឱ្យពលករផ្សេងគាត់ខ្លាចហើយវិលមកខ្មែរវិញ»។

លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យលោក សិទ្ធ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យលោក ប៉ែន កុសល្យ អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ មិនអាចសុំការអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ នៅថ្ងៃទី ២៨ ខែមិថុនា ដោយពួកលោកខ្លះមិនលើកទូរស័ព្ទ និងខ្លះទៀតបដិសេធធ្វើអត្ថាធិប្បាយ។

ប៉ុន្តែបើតាមលោក សឿម ប៊ុនរិទ្ធិ អ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបងបានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ២៨ មិថុនាថា ចំពោះស្ថានភាពនៅតាមច្រកព្រំដែនចំនួន ៤ នៅខេត្តបាត់ដំបងវិញ គឺស្ថិតក្នុងសភាពស្ងប់ស្ងាត់ដដែល ដោយមិនមានពលករខ្មែរត្រឡប់មកច្រើន ដូចច្រកព្រំដែននៅជាប់ខេត្តសុរិន្ទរបស់ថៃនោះទេ។ បើទោះជាស្ថានភាព បែបនេះក្តី ក៏អាជ្ញាធរខេត្តបានត្រៀមមណ្ឌលចត្តាឡីស័កនៅតាមសាលារៀនជាច្រើនកន្លែងបន្ថែមទៀត ដោយក្នុង នោះក៏បានត្រៀមរួចជាស្រេចនូវកន្លែងព្យាបាលជំងឺកូវីដ១៩ សម្រាប់ក្រុមគ្រូពេទ្យផងដែរ បន្ទាប់ពីទទួលបាន ព័ត៌មានពីប្រទេសថៃ ដែលបានបិទការដ្ឋានសំណង់មួយចំនួនដល់ទៅ ៣០ ថ្ងៃនេះ។ លោកបញ្ជាក់ថា៖ «ពលករ ដែលខាងថៃផ្សព្វផ្សាយថា សម្រុកមកនេះមិនទាន់មកដល់ព្រំដែនយើងទេ។ ចាំមើល យើងរង់ចាំមើល ២ ទៅ ៣ ថ្ងៃទៀតមើល។ យើងបានប្រជុំហើយជាមួយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិហើយ ពាក់ព័ន្ធគោលការណ៍មួយចំនួន។ ក្នុងនោះ យើងក៏ត្រៀមរៀបចំទីតាំងសម្រាប់មន្ត្រីសុខាភិបាលយើង ត្រៀមធ្វើតេស្តរហ័ស នៅតាមច្រកព្រំដែនទាំង ៤ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបងយើង»។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីផ្នែកសិទ្ធិពលករចំណាកស្រុកនៃអង្គការ សង់ត្រាល់ លើកឡើងថា ដើម្បី បញ្ចៀសកុំឱ្យពលករខ្មែរសម្រុកចូលប្រទេសក្នុងស្ថានភាពលំបាកនេះ រដ្ឋាភិបាលត្រូវតែធានាគោលនយោបាយ គាំពារពួកគាត់ឱ្យអាចរស់បាននៅតាមការដ្ឋានសំណង់ដែលពួកគាត់កំពុងធ្វើការ ដោយមានការហូបចុកគ្រប់គ្រាន់ និងធានាការចំណាយផ្សេងៗ ដូចជាថ្លៃទឹក ថ្លៃភ្លើង និងថ្លៃកន្លែងស្នាក់នៅ។ លោកបន្ថែមថា៖ «ក្នុងពេលនេះ ពលករគួរតែទទួលបានការគាំពារមួយចំនួនទៀត ពាក់ព័ន្ធនឹងកូវីដ ១៩ ហ្នឹងហើយពួកគាត់ គួរតែទទួលបានប្រាក់ ឈ្នួល ឬចំណែកណាមួយក្នុងអំឡុងពេលដែលបិទការដ្ឋានមិនឱ្យមានការសាងសង់។ ព្រោះបើសិនជាគ្មានគោល នយោបាយគាំពារទាំងនេះទេ គឺពួកគាត់មិនមានជម្រើសអ្វីក្រៅពីត្រឡប់មកខ្មែរទេ ហើយបើគាត់មក គឺបន្ទុករបស់រ ដ្ឋាភិបាលកម្ពុជានោះក៏កាន់តែធ្ងន់ដែរ»៕

## ពលករខ្មែរត្រឡប់ពីប្រទេសថៃចូលតាមច្រកអូរបីជាន់រយៈពេល២ថ្ងៃមាន១៤៣នាក់ និងរកឃើញវិជ្ជមានកូវីដ១៥នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៩ ខែ មិថុនា ឆ្នាំ ២០២១ ម៉ោង ១០:២៨

បន្ទាយមានជ័យ ៖ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលតាមច្រកអូរបីជាន់រយៈពេល២ថ្ងៃ មានចំនួន ១៤៣នាក់ រកឃើញអ្នកវិជ្ជមានកូវីដ១៩ មានចំនួន១៥នាក់ នៅថ្ងៃទី២៧ ដល់២៨ ខែមិថុនា ឆ្នាំ២០២១ ស្ថិតឃុំ អូរបីជាន់ ស្រុកអូរជ្រៅ ។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅបានប្រាប់ថា នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១នេះ មានពល ករខ្មែរត្រឡប់ពីប្រទេសថៃចូលតាមច្រកអូរបីជាន់ស្រុកអូរជ្រៅ ដែលត្រូវបានក្រុមការងារមណ្ឌលសំចតទទួលមាន ចំនួន៧៥នាក់ ស្រី៣៣នាក់ ហើយត្រូវបានក្រុមការងារយកសំណាក់ធ្វើតេស្តរកឃើញវិជ្ជមានកូវីដ១៩ មានចំនួន៣ នាក់ ស្រី២នាក់ ប្រុស១នាក់ មានប្រជាពលរដ្ឋស្រុកពួក ខេត្តសៀមរាបចំនួន២នាក់ និងស្រុកមង្គលបូរីខេត្តបន្ទាយ មានជ័យចំនួន១នាក់ ។ លោកបានបញ្ជាក់ថា ៖ បើប្រៀបធៀប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១ក្រុមការងារ មណ្ឌលសំចតច្រកអូរបីជាន់ស្រុកអូរជ្រៅទទួលពលករខ្មែរត្រឡប់ពីប្រទេសថៃ មានចំនួន៦៨នាក់ ស្រី២៣នាក់ ហើយក្រុមការងារយកសំណាក់ធ្វើតេស្តលទ្ធផលវិជ្ជមានកូវីដ១៩ មានចំនួន១២នាក់ ស្រី៥នាក់ប្រុស៧នាក់ មាន ប្រជាពលរដ្ឋ នៅស្រុកចិត្តបុរីខេត្តក្រចេះ មានចំនួន២នាក់ស្រី១នាក់ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ មាន ចំនួន១នាក់ ស្រុកបវេល ខេត្តបាត់ដំបងចំនួន២នាក់ ស្រុកបាកាន ខេត្តពោធិ៍សាត់ មានចំនួន២នាក់ ស្រី១នាក់ ស្រុកមេសាង ខេត្តព្រៃវែង មានចំនួន១នាក់ ស្រុកបន្ទាយអំពិល ខេត្តឧត្តមានជ័យ មានចំនួន២នាក់ ស្រី១នាក់ ។

លោក លី សុវណ្ណារិទ្ធ បានបញ្ជាក់ថា ៖ ចំពោះពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាតាមច្រកអូរបីជាន់ស្រុកអូរជ្រៅ ក្រោយក្រុមការងារទទួលដាក់មណ្ឌលសំចតនៅច្រកអូរជាន់ស្រុកអូរជ្រៅ ហើយបានធ្វើការពិនិត្យសុខភាព និងយកសំណាកធ្វើតេស្ត ហើយបានជូនអាហារសម្រន់ហើយអ្នកអវិជ្ជមានកូវីដ១៩ត្រូវបានដឹកជញ្ជូនតាមរថយន្តក្រសួងការពារជាតិដាក់មណ្ឌល ដើម្បីធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ចំណែកអ្នករកឃើញវិជ្ជមានកូវីដ១៩ ត្រូវបានដឹកទៅដាក់មណ្ឌលព្យាបាលជំងឺឆ្លងកូវីដ១៩ ។

## របាយការណ៍៖ កង្វះខាតការងារនិងបំណុលកើនឡើងក្នុងពេលវិបត្តិជំងឺកូវីដ១៩ នាំឲ្យពលករចំណាកស្រុករស់នៅទាំងត្រដរ

https://khmer.voanews.com/ 28 មិថុនា 2021 ហ៊ុល រស្មី

ភ្នំពេញ៖ ក្រោមសម្ពាធនៃការឆ្លងរាតត្បាតជំងឺកូវីដ១៩ អ្នកស្រី ផន ទូច អាយុ៤០ឆ្នាំ មិនអាចវិលត្រឡប់ទៅធ្វើការងារសំណង់នៅទីក្រុងបាងកកប្រទេសថៃ ដូចមុនឡើយ។ អ្នកស្រីបានចាកចេញពីប្រទេសថៃអស់រយៈពេលពីរឆ្នាំមកហើយ និងកំពុងរស់នៅក្នុងស្ថានភាពលំបាកលំបិនខាងលុយកាក់ក្រោមហេតុផលថាគ្មានការងារធ្វើនៅស្រុកសំពៅលូនខេត្តបាត់ដំបងជាទីដែលអ្នកស្រីសព្វថ្ងៃពឹងអាស្រ័យលើការលក់ដូរនំបញ្ចុកតាមផ្សារ។ អ្នកស្រីប្រាប់វីអូអេពីខេត្តបាត់ដំបងកាលពីថ្ងៃអាទិត្យថា ជីវភាពប្រចាំថ្ងៃកាន់តែលំបាកខ្លាំងឡើងបានជំរុញចិត្តឲ្យអ្នកស្រីចង់វិលត្រឡប់ទៅប្រទេសថៃ ដើម្បីអាចរកចំណូលបានប្រមាណ២៣០បាត ឬប្រមាណ៣ម៉ឺនរៀលក្នុងមួយថ្ងៃពីការងារជាកម្មករសំណង់។ អ្នកស្រីថ្លែងថា៖ «ចង់ត្រឡប់ទៅវិញណាស់ប៉ុន្តែទៅវាអត់រួចពេលនៅនេះចឹង មិនដឹងធ្វើអីរកវាអត់ទាន់ហូប»។ អ្នកស្រីថាការលក់ដូរមិនសូវចំណេញដោយសារតែពលរដ្ឋនៅផ្អើលម្តងម្កាលចំពោះការឆ្លងជំងឺកូវីដ១៩នោះធ្វើឲ្យការប្រាក់នៃបំណុលរបស់អ្នកស្រីកើនឡើងផងដែរ។ ក្នុងរយៈពេល៦ទៅ៧ខែចុងក្រោយនេះប្រាក់ជំពាក់អ្នកស្រីដែលដើមឡើយមានត្រឹមតែ១លានរៀលនោះបានកើនដល់២លានរៀលរួចទៅហើយ។ អ្នកស្រីបន្ថែមថា៖ «ចងការគេចងការខែគេមួយខែគេយកមួយលានដប់ម៉ឺន»។

កង្វះការងារធ្វើ និងបំណុលកើនឡើងបានរួមរឹតជីវិតរបស់ក្រុមពលករចំណាកស្រុកជាច្រើនពាន់នាក់ដែលបានវិលត្រឡប់ពីប្រទេសក្បែរខាងមកប្រទេសកំណើតវិញក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ១៩។ នេះជាការរកឃើញរបស់ក្រុមអ្នកឃ្លាំមើលសិទ្ធិពលករ និងរបាយការណ៍របស់អង្គការសហប្រជាជាតិមួយ ស្តីពីការវិលត្រឡប់របស់ពលករចំណាកស្រុក ដែលចេញផ្សាយកាលពីពេលថ្មីៗនេះ។ ការិយាល័យអង្គការសហប្រជាជាតិ (អ.ស.ប.) ប្រចាំកម្ពុជា បានពិនិត្យលើស្ថានភាពរបស់ពលករចំណាកស្រុកដែលប្រឈមនឹងភាពងាយរងគ្រោះនិងការបាត់បង់ការងារនៅពេលប្រទេស ដែលទទួលពលករ ទាំងនោះអនុវត្តវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩។ របាយការណ៍ដែលចេញផ្សាយកាលពីថ្ងៃទី២២ ខែមិថុនា ពណ៌នាថានៅក្នុងតំបន់មេគង្គច្រករបៀងជាច្រើនដែលមានភាពសកម្មសម្រាប់ការធ្វើចំណាកស្រុកត្រូវបានបិទភ្លាមៗក្នុងអំឡុងពេលយូរ ខណៈប្រទេសជាច្រើនបានអនុវត្តវិធានការតឹងរឹងសម្រាប់ការធ្វើដំណើរឆ្លងតាមព្រំដែន។ របាយការណ៍បន្តថាការបាត់បង់ការងារការរឹតបន្តឹងជាច្រើនខាងសេដ្ឋកិច្ចនិងការបិទខ្ទប់នៅប្រទេសដែលទទួលយកពលករចំណាកស្រុកនោះបានបង្ខំឲ្យពលករចំណាកស្រុកជាច្រើននាក់វិលត្រឡប់មកប្រទេសកំណើតខ្លួនវិញ។ គិតត្រឹមពេលចេញរបាយការណ៍មានពលករកម្ពុជាជាង២០ម៉ឺននាក់ដែលក្នុងនោះមាន៤៣%ជាស្ត្រីបានវិលត្រឡប់ពីប្រទេសជិតខាងមកប្រទេសកម្ពុជាវិញចាប់តាំងពីការចាប់ផ្តើមនៃការឆ្លងរាតត្បាតជំងឺកូវីដ១៩កាលពីដើមឆ្នាំ២០២០។

របាយការណ៍ឲ្យដឹងក្នុងន័យដើមថា៖ «ជិត៣០%នៃក្រុមគ្រួសារពលករចំណាកស្រុកដែលបាន វិលត្រឡប់គ្មានប្រាក់ចំណូលទាល់តែសោះហើយច្រើនជាង៥០% នៃពលករចំណាកស្រុកដែលបានវិលត្រឡប់ជាប់បំណុល។ ពលករចំណាកស្រុកជាស្ត្រីដែលបានវិលត្រឡប់គឺទំនងច្រើនជាងបុរស និងគ្មានលុយកាក់ហើយប្រឈមផលវិបាក

ច្រើនក្នុងការរកការងារធ្វើ។ពាក់ព័ន្ធនឹងការទទួលបានសេវាគាំទ្រខាងសង្គម និងសុខាភិបាលវិញនោះគឺមានតែពលករដែលវិលត្រឡប់មកវិញ២៥%តែប៉ុណ្ណោះដែលមានប័ណ្ណក្រីក្រហើយជាង៤០% មានបញ្ហាក្នុងការទទួលបានការថែទាំសុខាភិបាលដោយសារតែកង្វះលុយកាក់ឬក៏ការនៅឆ្ងាយពីអ្នកផ្ដល់សេវាថែទាំសុខភាព»។

នាយកប្រតិបត្តិនៃអង្គការសង់ត្រាល់លោក មឿន តុលា ប្រាប់វីអូអេនៅថ្ងៃចន្ទនេះថា ស្ថានភាពបំណុលរបស់ពលករចំណាកស្រុកដែលវិលត្រឡប់មកពីប្រទេសថៃក្នុងគ្រាមានការឆ្លងរាតត្បាតជំងឺកូវីដ១៩ មិនថមថយទេ ហើយពលករតែងតែប៉ុនប៉ងឆ្លងទៅរកការងារធ្វើនៅប្រទេសថៃវិញ។ លោកបញ្ជាក់ថា៖ «អីចឹងជាភស្តុតាងមកដល់ឥឡូវហ្នឹងក៏នៅតែមានពលរដ្ឋខ្មែរយើងឆ្លងដែន ដោយប្រថុយប្រថានទៅប្រទេសថៃរៀងរាល់ថ្ងៃដែរ ហើយថៃចាប់ចាប់រៀងរាល់ថ្ងៃគឺហេតុផល ដោយសារអត់ទទួលបាននូវសេវាសាធារណៈគ្រប់គ្រាន់ទទួលមានមុខរបរសមប្រកបដើម្បីប្រកបរបរនៅក្នុងស្រុកក៏ដូចជាមិនទទួលបានប្រយោជន៍អីផ្សេងៗមិនមានការងារធ្វើគ្រប់គ្រាន់»។លោកបន្ថែមថា ទោះបីពលករទាំងនោះបានដឹងថាការចាកចេញទៅប្រទេសថៃទាំងខុសច្បាប់អាចប្រឈមនឹងការចាប់ខ្លួនរបស់អាជ្ញាធរថៃក៏ដោយ ក៏ពួកគាត់នៅតែប្រឹងជម្នះទៅ ដើម្បីដោះស្រាយបញ្ហាជីវភាព។ លោកថ្លែងថា៖ «បើតាមពួកយើងសម្ភាសអីហ្នឹងមិនមែនគាត់មិនដឹងថាឆ្លងដែនទៅគេដោយខុសច្បាប់មានហានិភ័យខ្ពស់តាំងពីតម្រួតថៃចាប់ឬក៏គេអាចទាហានថៃបាញ់ឬមួយក៏ឆ្លងកូវីដ១៩ទេហើយទៅដល់ប្រទេសថៃហ្នឹងក៏អត់ទាន់មានការងារគ្រប់គ្រាន់ដែរ ប៉ុន្តែគាត់ប្រថុយទៅក្រែងអាចទៅធ្វើការនៅតាមហាងអីបានបន្តិចបន្តួចបានគ្រាន់ចាយ»។

លោក មឿន តុលា យល់ស្របនឹងការវាយតម្លៃរបស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងស្ថានភាពជីវភាពរបស់ពលករចំណាកស្រុកដែលវិលត្រឡប់មកពីប្រទេសជិតខាង ជាពិសេសគឺប្រទេសថៃ។ លោក មឿន តុលា ថ្លែងថា៖ «កន្លងមកហ្នឹងពួកខ្ញុំក៏បានសម្ភាស ពលករខ្មែរយើងដែលត្រឡប់មកប្រទេសកម្ពុជាវិញដែរហើយតាមចម្លើយរបស់ពួកគាត់ហ្នឹងគឺប្រហាក់ប្រហែលគ្នាជាមួយនឹងអ្វីដែលការលើកឡើងរបស់អង្គការសហប្រជាជាតិហ្នឹង។ មានអ្នកដែលទទួលបាន ID Poor មិនអត់ទេប៉ុន្តែគ្រាន់ថាភាគច្រើនរបស់ពួកគាត់ហ្នឹងអត់បានទទួលនូវID Poor ហ្នឹងទេហើយអ្នកដែលត្រឡប់មកវិញបើសិនជាបុរសគាត់អាចទៅទៅធ្វើការសំណង់ឲ្យគេប៉ុន្តែ មិនមែនជាការជាប់លាប់ទេ...ប៉ុន្តែបើស្ត្រីវិញយើងឃើញថាគាត់ពេលដែលមកក្នុងស្រុកហ្នឹងគាត់មានឱកាសដូចបុរសទេ»។

បើតាមសេចក្តីព្រាងនៃរបាយការណ៍របស់អង្គការសង់ត្រាល់ កាលពីខែសីហា ឆ្នាំ២០២០ ស្តីពីដំណើរស្វែងរកការពិតអំពីតម្រូវការមូលដ្ឋានរបស់ពលករចំណាកស្រុកកម្ពុជាក្នុងពេលមានជំងឺឆ្លងរាតត្បាតកូវីដ១៩ ពលករចំណាកស្រុកជាច្រើននាក់ឲ្យដឹងថាពួកគេបានធ្លាក់ចូលក្នុងចំណងបំណុល ដោយលើកហេតុផលថាពួកគេគ្មានលុយកាក់ដើម្បីរស់ បញ្ជូនកូនទៅរៀននិងគ្មានលុយទិញដីសម្រាប់ដាំដំណាំ និងសង់ផ្ទះ។ របាយការណ៍ឲ្យដឹងបន្ថែមថាពលករបានចំណាកស្រុកតាមរយៈមេខ្យល់ក្នុងស្រុក ដែលយកកម្រៃទាបបើធៀបនឹងទៅតាមការចំណាកស្រុកតាមវិស័យឯកជន។ ពលករចំណាកស្រុកក៏មានបញ្ហានឹងការគ្រប់គ្រងចំណូលរបស់ពួកគេដែលការណ៍នេះបានធ្វើឲ្យពួកគេកាន់តែក្រទៅនិងលំបាកវេទនាទៅ។ អ្នកខ្លះត្រូវចាប់ខ្លួនដោយអាជ្ញាធរថៃ ហើយជាប់ពន្ធនាគារ។ ចំណែកអ្នកខ្លះទៀតត្រូវបានគេបោកនិងកេងប្រវ័ញ្ច។ របាយការណ៍បញ្ជាក់ថា៖«ពួកគេភាគច្រើនបានប្រាប់ថាពួកគេចង់ចំណាកស្រុកទៅប្រទេសថៃម្តងទៀត ដើម្បីរកការងារដោយសារតែពួកគេគ្មានដីសម្រាប់ធ្វើកសិកម្មនិងគ្មានការងារដើម្បីចិញ្ចឹមជីវិតនៅប្រទេសកម្ពុជា»។

អ្នកស្រី ប៉ុល សៅនី ស្ត្រីមេម៉ាយមានកូនពីរនាក់ដែលកំពុងរស់នៅក្នុងស្រុកថ្មពួកខេត្តបន្ទាយមានជ័យនិយាយថាអ្នកស្រីមិនវិលត្រឡប់ទៅប្រទេសថៃវិញទេ ទោះបីអ្នកស្រីធ្លាប់ធ្វើជាកម្មករសំណង់នៅទីនោះ១០ឆ្នាំមកហើយ ដោយបារម្ភអំពីការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ អ្នកស្រីថ្លែងថា៖ «មិនហ៊ានទៅទេខ្លាច! ព្រោះអីឯណោះតាមមើលព័ត៌មាន វាបែកច្រើន»។ អ្នកស្រីបន្ថែមថាបច្ចុប្បន្ននេះ អ្នកស្រីមិនមានផ្ទះសម្បែងផ្ទាល់ខ្លួនទេដោយបាន

រស់នៅក្នុងផ្ទះអ្នកជិតខាង និងបានពឹងផ្អែកលើចំណូលដែលបានពីការសម្អាតដីជំឡូងមីទៅតាមរដូវកាលនៃការដាំដុះ។

អង្គការសហប្រជាជាតិបានលើកទឹកចិត្តឲ្យអាជ្ញាធរកម្ពុជាផ្ដល់ការការពារ និងបើកផ្លូវឲ្យអ្នកចំណាកស្រុកដែលត្រឡប់មកវិញមានលទ្ធភាពយកឈ្នះលើផលប៉ះពាល់រយៈពេលវែងនៃជំងឺកូវីដ១៩។ អង្គការសហប្រជាជាតិបានទទូចដល់អាជ្ញាធរជានាថា ប័ណ្ណក្រីក្រត្រូវបានផ្ដល់ជូនអ្នកចំណាកស្រុកដែលត្រឡប់មកវិញរូបណាដែលមានលក្ខណៈសម្បត្តិអាចទទួលបាន និងជំនួយបន្ថែមទៀតត្រូវបានផ្ដល់ ដើម្បីមានលទ្ធភាពទទួលបានការងារ ឬក៏ឱកាសបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីជំរុញឲ្យពួកគេអាចសម្របខ្លួនបាននៅក្នុងសហគមន៍។

លោក ឈួរ សុបញ្ញា ប្រធាននាយកដ្ឋានសុខុមាលភាពសង្គមនៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងសង្គមកិច្ចអតីត យុទ្ធជន និងយុវនីតិសម្បទាប្រាប់វីអូអេនៅថ្ងៃចន្ទនេះថាលោកមិនទាន់ឃើញរបាយការណ៍របស់អង្គការសហប្រជាជាតិទេទាក់ទិនស្ថានភាពរបស់ពលករចំណាកស្រុកក្នុងការទទួលបានប័ណ្ណក្រីក្រ។ ក៏ប៉ុន្តែលោកថាក្រសួងបានចាត់ចែងឲ្យមានច្រកសម្រាប់ពលករទាំងនោះស្នើសុំប័ណ្ណនេះពីអាជ្ញាធរមានសមត្ថកិច្ច។ លោកថ្លែងថា៖ «អីចឹងចំពោះទិដ្ឋភាពនេះយើងខ្ញុំជម្រាបជូនទៅថាការផ្ដល់ប័ណ្ណសមធម៌ទាំងប្រភេទក្រីក្រ១ក្រីក្រ២នេះ គឺយើងមិនមែនបានន័យថារក្សារបត់ពីលើកមុនទេបានន័យថាយើងប្តូររបត់ដើម្បីស្របទៅតាមស្ថានភាពនៃកូវីដនេះហើយ។ ចំពោះរបាយការណ៍នេះយើងខ្ញុំមិនហ៊ានសន្និដ្ឋានថា ម៉េចទេក៏ប៉ុន្តែយើងនៅមិនទាន់បានទទួលនូវរបាយការណ៍នោះទេបាទ»។ បើតាមលោក ឈួរ សុបញ្ញា រដ្ឋាភិបាលតាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺកូវីដ១៩នោះបានផ្ដល់សាច់ប្រាក់ជាង៣៥១លានដុល្លារដល់ពលរដ្ឋជាង៧០ម៉ឺនគ្រួសារស្មើនឹងជាង២,៧លាននាក់គិតត្រឹមខែមិថុនានេះ។ ដោយឡែកនៅក្នុងវិធានការបិទខ្ទប់ភូមិសាស្រ្តមួយចំនួនក្នុងប្រទេសរដ្ឋាភិបាលបានផ្ដល់ប្រាក់ជាង៤លានដុល្លារដល់ពលរដ្ឋចំនួនជាង៦ម៉ឺនគ្រួសារ។

វីអូអេមិនទាន់អាចទាក់ទងសុំការអធិប្បាយពីលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានទេ។ យ៉ាងណាក៏ដោយលោក មឿន តុលា នាយកប្រតិបត្តិនៃអង្គការសង់ត្រាល់បង្ហាញក្ដីបារម្ភចំពោះបញ្ហាបំណុលរបស់ពលករដែលបានវិលត្រឡប់មកស្រុកកំណើតវិញ។ លោកជឿថាអំពើហិង្សាមួយចំនួនរវាងអ្នកខ្ចីនិងម្ចាស់បំណុលអាចកើតឡើង ប្រសិនបើរដ្ឋាភិបាលមិនមានវិធានការដោះស្រាយការលើកពេលសងបំណុលឲ្យទាន់ពេលវេលានោះ៕

## ស្ថានភាពរស់នៅរបស់ពលករខ្មែរជួបការលំបាកក្រោយពេលអាជ្ញាធរថៃបិទខ្ទប់រយៈពេល ១ខែ ដើម្បីទប់ស្កាត់ជំងឺកូវីដ១៩

https://www.rfa.org/ ដោយ ហេង រស្មី 2021-06-28

ពលករខ្មែរជាច្រើននាក់ធ្វើការនៅប្រទេសថៃ កំពុងជួបការលំបាកអំពីជីវភាពរស់នៅប្រចាំថ្ងៃ ក្រោយពេលអាជ្ញាធរថៃបានបិទខ្ទប់មិនឱ្យពួកគាត់ចាកចេញពីកន្លែងធ្វើការ។ អាជ្ញាធរថៃបានបិទខ្ទប់ការដ្ឋានសំណង់នៅទីក្រុងបាងកក និងខេត្តចំនួន ៥ជាប់ទីក្រុងបាងកករយៈពេល ១ខែ ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិលយល់ថា ពលករខ្មែរ ដែលធ្វើការក្រៅប្រព័ន្ធអាចនឹងរងផលប៉ះពាល់ខ្លាំងពីការបិទខ្ទប់នេះ។ ពលករខ្មែរមួយចំនួន ព្រួយបារម្ភពីសុវត្ថិភាពនិងជីវភាពរស់នៅប្រចាំថ្ងៃ ដោយសារពួកគេមិនបានធ្វើការងាររកប្រាក់ចំណូលអំឡុងពេលការបិទខ្ទប់នេះ។

ពលករធ្វើការសំណង់នៅទីក្រុងបាងកក លោក ធន សុខឿន ប្រាប់អាស៊ីសេរីនៅថ្ងៃទី២៨ មិថុនាថា អាជ្ញាធរថៃបានដាក់កម្លាំងប៉ូលិស និងទាហានជាច្រើននាក់បិទខ្ទប់មិនឱ្យពួកលោកចេញពីកន្លែងធ្វើការនោះឡើយ។ ពលករវ័យ ៤០ឆ្នាំរូបនេះ បន្ថែមថា វិធានការរបស់អាជ្ញាធរថៃនេះ បានប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ពលករខ្មែរ ជាពិសេស អ្នកដែលទើបចូលធ្វើការ បណ្ដាលឱ្យគ្មានប្រាក់ទិញស្បៀងអាហារហូបចុកនៅក្នុងគ្រាអាសន្ន

នេះ៖ «គេចាប់ផ្ដើមបិទបីថ្ងៃហ្នឹងតែម្ដង ពីល្ងាចមិញឃើញគេយកទាហាន និងប៉ូលិសមកដាក់តែគេអត់ទាន់ខ្ទប់ទេ។ តែថ្ងៃនេះសូម្បីតែចេញទៅទិញអាហារនៅផ្សារក៏គេមិនឱ្យទៅដែរ។ ការងារក៏មិនឱ្យធ្វើហើយមិនឱ្យចេញទៅណាទៀតផង គេឱ្យយើងនៅតែក្នុងការដ្ឋានសំណង់។ អីចឹងបានថា វាជាបញ្ហាមួយដែលធ្ងន់ធ្ងរចំពោះពលករខ្មែរ»។

ដូចគ្នានេះដែរ ពលការិនីមានស្រុកកំណើតនៅខេត្តព្រះវិហារ លោកស្រី សែន រស្មី ថ្លែងទាំងអួលដើមកថា លោកស្រីគ្មានប្រាក់ទិញស្បៀងអាហារហូបចុកនោះទេ ពីព្រោះមួយរយៈនេះ ពួកគាត់ ធ្វើការងារមិនបានទៀងទាត់នោះទេ។ ស្ត្រីវ័យ ៣៨ឆ្នាំនេះរូបនេះ បន្ថែមទៀតថា ប្ដីរបស់គាត់បានឆ្លងជំងឺកូវីដ១៩ ហើយត្រូវបានអាជ្ញាធរថៃបញ្ជូនទៅព្យាបាលជំងឺជិត ១០ថ្ងៃមកហើយ មិនទាន់បានធូរស្រាលនៅឡើយ។ ដូច្នេះលោកស្រីព្រួយបារម្ភខ្លាចអាជ្ញាធរថៃបិទខ្ទប់យូរធ្វើឱ្យគ្មានប្រាក់ចំណូលចិញ្ចឹមជីវិតនិងប្រាក់ផ្ញើទៅឱ្យឪពុកម្ដាយនៅស្រុកកំណើតដោះស្រាយជីវភាព៖ «ខ្ញុំតឹងទ្រូងសឹងតែសម្លាប់ខ្លួនចោល ប្ដីក៏កើតកូវីដ ខ្ញុំក៏មិនដឹងធ្វើការអី បើគេបិទយ៉ាងនេះ។ ខ្ញុំមកនេះដើម្បីរកលុយបង់ការប្រាក់ធនាគារបើគេ បើខ្ញុំអត់មានលុយបង់ធនាគារមានពីណាគេជួយខ្ញុំ ពិបាកចិត្តគេបិទអីចឹង ខ្ញុំបានជួយម៉ែខ្ញុំ គាត់មានអីហូបនៅផ្ទះ។ ខ្ញុំពិបាកចិត្តណាស់ខ្ញុំទើបមកអីចេះគ្មានលុយគ្មានកាក់ទេ»។

ចំណែកពលការិនីធ្វើការសំណង់នៅកណ្ដាលទីក្រុងបាងកកម្នាក់ទៀត លោកស្រី កុយ មិនា វិញ លោកស្រីថ្លែងថា លោកស្រីមិនបានទិញស្បៀងអាហារត្រៀមទុកហូបចុកអំឡុងពេលបិទខ្ទប់ដូចពលករជាច្រើនទៀតដែរ។ លើសពីនេះគ្រួសាររបស់លោកស្រីបានរស់នៅបែកគ្នា ដោយប្ដី និងប្អូនរបស់គាត់ ២នាក់ បានឆ្លងជំងឺកូវីដ១៩ ហើយត្រូវបានអាជ្ញាធរបញ្ជូនទៅព្យាបាលជំងឺនៅមន្ទីរពេទ្យមិនទាន់ត្រឡប់មកវិញនៅឡើយ៖ «ប្អូនព្រួយបារម្ភត្រង់ថា គិតប្អូន ព្រោះប្អូននៅឆ្ងាយ ព្រោះយើងមកអត់មានឪពុកម្ដាយមកជុំបងប្អូនដល់ពេលឃ្លាតពីប្អូនទៅខ្ញុំដេកមិនលក់ទេ ខ្ញុំពិបាកចិត្តណាស់។ពិបាកចិត្តដែលបែកប្អូនទៅដេកពេទ្យឆ្ងាយ ហើយបារម្ភប្អូនថ្នាំក៏គេមិនឱ្យលេប ហើយគេមិនបានមើលយើងជិតដល់ទេ គេយកយើងទៅដាក់ចោល គេឱ្យតែបាយហូបប៉ុណ្ណោះឯង»។

អាជ្ញាធរថៃបានបិទខ្ទប់ការដ្ឋានសំណង់ទាំងអស់នៅទីក្រុងបាងកក និងខេត្តចំនួន៥ទៀតជាប់រាជធានីរបស់ថៃរយៈពេល១ខែ ដោយចាប់ពីថ្ងៃទី២៨ មិថុនា រហូតដល់ថ្ងៃទី២៧កក្កដាដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩។ រដ្ឋមន្ត្រីក្រសួងការងាររបស់ថៃ លោក សុឆាត ឈុមក្លិន (Sochat Chumklin) ថ្លែងនៅក្នុងសន្និសីទសារព័ត៌មាននៅថ្ងៃទី២៨មិថុនាថាអំឡុងពេលបិទខ្ទប់នេះ រដ្ឋាភិបាលថៃនឹងផ្ដល់សាច់ប្រាក់ជូនដល់ពលករបរទេសដែលបានធ្វើការងារក្នុងប្រព័ន្ធម្នាក់ចំនួន៥០ភាគរយនៃប្រាក់ឈ្នួលក្នុងមួយខែ។

ជាមួយគ្នានេះមន្ត្រីស្ថានទូតខ្មែរទទួលបន្ទុកផ្នែកពលករប្រចាំនៅប្រទេសថៃ លោក គឹម ចំរើន បានបង្ហោះសារនៅក្នុងហ្វេសប៊ុករបស់លោកនៅព្រឹកថ្ងៃទី២៨ មិថុនាថា ការបិទខ្ទប់នេះដោយសារអាជ្ញាធរបានរកឃើញថាការរាតត្បាតជំងឺកូវីដ១៩ ភាគច្រើននៅក្នុងការដ្ឋានសំណង់។ លោកបញ្ជាក់ថា វិធានការនេះ អាជ្ញាធរថៃបានដាក់ពង្រាយកម្លាំងសមត្ថកិច្ចហាមឃាត់ដាច់ខាតមិនឱ្យពលករណាម្នាក់ចេញពីកន្លែងធ្វើការនោះទេ។បន្ថែមពីនេះលោកថា អាជ្ញាធរថៃក៏បានដាក់ប៉ុស្តិ៍ត្រួតពិនិត្យតឹងតែងនៅខេត្តជាប់ទីក្រុងបាងកក ដើម្បីត្រួតពិនិត្យសុខភាពអ្នកធ្វើដំណើរផងដែរ។លោកអំពាវនាវឱ្យពលករទាំងអស់ឱ្យមានការប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តតាមការណែនាំរបស់អាជ្ញាធរថៃឱ្យបានខ្ជាប់ខ្ជួន ដើម្បីឱ្យរួចផុតពីការឆ្លងជំងឺកាចសាហាវនេះ។

ទោះជាយ៉ាងណាអង្គការសង់ត្រាល់(Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហ្វយ៉ា មានប្រសាសន៍ថា ពលករខ្មែរដែលធ្វើការក្រៅប្រព័ន្ធនឹងរងផលប៉ះពាល់ខ្លាំងពីការបិទខ្ទប់នេះ ពីព្រោះពួកគេភាគច្រើនធ្វើការងារដោយខុសច្បាប់។ មន្ត្រីសង្គមស៊ីវិលរូបនេះ បញ្ជាក់ថា ថៅកែជនជាតិថៃ អាចឆ្លៀតឱកាសនេះបញ្ឈប់ ឬបណ្ដេញពលករចេញពីការងារដោយមិនផ្ដល់ប្រាក់ឈ្នួលជូនឱ្យពួកគាត់នោះឡើយ៖ «វាពិតណាស់ដែលគាត់ត្រូវប្រឈមនឹងការមិនអើពើមិនទទួលខុសត្រូវពីថៅកែអីជាដើមអីចឹង ហើយការព្រួយបារម្ភគាត់ហ្នឹងមិនខុសទេព្រោះដោយសារតែជាបទពិសោធន៍ពួកគាត់ហ្នឹងគឺរងគ្រោះអីចឹង។ ទីមួយគឺពាក់ព័ន្ធការរស់នៅ ការហូបចុកប្រចាំថ្ងៃ មួយ

ទៀតគឺពាក់ព័ន្ធនឹងសុវត្ថិភាពតាមស្តាប់មើលទោនៅតាមការងារសំណង់នេះ ដូចជាមិនសូវយកចិត្តទុកដាក់ក្នុងការមើលថែឬធ្វើតេស្តឱ្យបានត្រឹមត្រូវដើម្បីឱ្យគាត់មានអារម្មណ៍ស្ងប់ ឬទុកចិត្តថាកើតឬមិនកើតទេ ។អីចឹងហើយបានជាបង្កើតឱ្យមានការព្រួយបារម្ភខ្លាំងជាងការងារនៅក្នុងប្រព័ន្ធ»។ លោក ឌី ថេហ្វយ៉ា បន្តថា ដើម្បីដោះស្រាយបញ្ហានេះរដ្ឋាភិបាលខ្មែរនិងថៃគួរតែចុះតាមដាននៅតាមការដ្ឋានសំណង់ និងផ្តល់ស្បៀងអាហារជូនដល់ពួកគាត់ហូបចុកនៅតំបន់បិទខ្ទប់នោះ។ បន្ថែមពីនេះរដ្ឋាភិបាលប្រទេសទាំងពីរក៏គួរតែសម្រួលឱ្យពួកគេបានវិលត្រឡប់ទៅកម្ពុជាវិញ ប្រសិនបើពួកគេមិនអាចរស់នៅប្រទេសថៃបន្តទៀតបាន។ របាយការណ៍របស់អង្គការសង់ត្រាល់ឱ្យដឹងថាបច្ចុប្បន្នមានពលករខ្មែរធ្វើការងារស្របច្បាប់និងមិនស្របច្បាប់មាន ១.៨០០.០០០នាក់ ធ្វើការនៅប្រទេសថៃ៕